# សេចក្តីកំណត់
# ចំពោះមាត្រានីមួយៗនៃ
# ក្រមរដ្ឋប្បវេណី

## ភាគ ៣ ៖ គន្ថីទី ៥

រៀបចំដោយ

គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី

និង

ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី

ក្រសួងយុត្តិធម៌

ភ្នំពេញ ២០១០

សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី
ត្រូវបានបោះពុម្ព នៅរាជធានីភ្នំពេញ
ដោយការិយាល័យកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌
នៅក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា
នៅឆ្នាំ ២០១០ ។

កម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌
គឺជាកម្មវិធីសហប្រតិបត្តិការបច្ចេកទេស
រវាងក្រសួងយុត្តិធម៌ និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

សិទ្ធិនិពន្ធ © ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី ឆ្នាំ២០១០
ISBN: 9789995083373

| | អ្នកនិពន្ធ |
|---|---|
| ជំពូកទី ១ និង ជំពូកទី ៤ | លោកសាស្ត្រាចារ្យ **Kamata Kaoru** |
| ជំពូកទី ២ ទៅ ជំពូកទី ៣ | លោកសាស្ត្រាចារ្យ **Urakawa Michitaro** |
| ជំពូកទី ៥ ទៅ ជំពូកទី ៦ | លោកសាស្ត្រាចារ្យ **Matsumoto Tsuneo** |
| ជំពូកទី ៧ | លោកសាស្ត្រាចារ្យ **Nomura Toyohiro** |
| ជំពូកទី ៨ | លោកសាស្ត្រាចារ្យ **Yamamoto Yutaka** |
| ជំពូកទី ៩ និង ជំពូកទី ១៣ | លោកសាស្ត្រាចារ្យ **Minami Toshifumi** |
| ជំពូកទី ១០ | លោកសាស្ត្រាចារ្យ **Nomi Yoshihisa** |
| ជំពូកទី ១១ ទៅ ជំពូកទី ១២ និង ជំពូកទី ១៤ និង ជំពូកទី ១៥ | លោកសាស្ត្រាចារ្យ **Niimi Ikufumi** |
| ជំពូកទី ១៦ | លោកសាស្ត្រាចារ្យ **Morishima Akio** |

កំណត់សម្គាល់

នៅក្នុងសេចក្តីកំណត់នៃមាត្រានីមួយៗមានសេចក្តីកំណត់ខ្លះដែលមានការបង្ហាញអំពីការបកស្រាយអ្នកដែលបានរៀបចំសេចក្តីព្រាងដើមនៃមាត្រានោះ ។ សូមចាត់ទុកការបកស្រាយនោះជាទស្សនៈមួយក្នុងចំណោមការបកស្រាយជាច្រើនដែលអាចមាន ដើម្បីយកទៅចាត់ចែងកិច្ចការជាក់ស្តែងនៅប្រទេសកម្ពុជា ។

# មាតិកា


**គន្ថីទី ៥ កិច្ចសន្យាសំខាន់ៗ និង អំពើអនីត្យានុកូល ---------- ១**

**ជំពូកទី ១ ការលក់ទិញ ---------- ១**

ផ្នែកទី ១ លក្ខណៈនៃការលក់ និង ការបង្កើតកិច្ចសន្យាលក់ទិញ ---------- ១

ផ្នែកទី ២ ភាគីនៃកិច្ចសន្យាលក់ទិញ និង កម្មវត្ថុនៃកិច្ចសន្យាលក់ទិញ ---------- ៧

ផ្នែកទី៣ អានុភាពនៃកិច្ចសន្យាលក់ទិញ ---------- ១០

កថាភាគទី ១ ករណីយកិច្ចរបស់អ្នកលក់ ---------- ១១

កថាភាគទី ២ ករណីយកិច្ចរបស់អ្នកទិញ ---------- ២៩

ផ្នែកទី ៤ ការរំលាយកិច្ចសន្យាលក់ទិញដោយអនុវត្តសិទ្ធិលោះ ---------- ៣២

**ជំពូកទី ២ ការដូរ ---------- ៣៤**

**ជំពូកទី ៣ ប្រទានកម្ម ---------- ៣៥**

**ជំពូកទី ៤ ការខ្ចីបរិភោគ ---------- ៤១**

ផ្នែកទី ១ និយមន័យ និង ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ ---------- ៤១

ផ្នែកទី ២ ការខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ ---------- ៤៤

ផ្នែកទី ៣ ករណីយកិច្ចឱ្យខ្ចីរបស់អ្នកឱ្យខ្ចី ---------- ៤៩

ផ្នែកទី ៤ ករណីយកិច្ចសងរបស់អ្នកខ្ចី ---------- ៥៣

**ជំពូកទី ៥ ភតិសន្យា ---------- ៥៦**

ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ ---------- ៥៦

ផ្នែកទី ២ អានុភាពនៃភតិសន្យា ---------- ៦០

ផ្នែកទី ៣ ការបញ្ចប់ភតិសន្យា ---------- ៦៩

ផ្នែកទី ៤ កិច្ចសន្យាប្រវាស់ ---------- ៧៥

**ជំពូកទី ៦ ការខ្ចីប្រើ ---------- ៧៦**

**ជំពូកទី ៧ អាណត្តិ ---------- ៨២**

**ជំពូកទី ៨ កិច្ចសន្យាម៉ៅការ ---------- ៩៥**

**ជំពូកទី ៩ កិច្ចសន្យាការងារ ---------- ១០៦**

**ជំពូកទី ១០ បញ្ញើ ---------------------------------------------------------- ១១០**
ផ្នែកទី ១ បទប្បញ្ញត្តិទូទៅស្តីពីបញ្ញើ------------------------------------------ ១១០
ផ្នែកទី ២ បញ្ញើដោយរួមបញ្ចូលគ្នា------------------------------------------------១៣០
ផ្នែកទី ៣ បញ្ញើបរិភោគ ----------------------------------------------------១៣១
ផ្នែកទី ៤ វិសុណ្ឌាប័ន ----------------------------------------------------- ១៣៣
**ជំពូកទី ១១ កិច្ចសន្យាក្រុមហ៊ុន -----------------------------------------------១៣៧**
**ជំពូកទី ១២ កិច្ចសន្យាធនលាភសាមយិកមួយជីវិត ----------------------------------- ១៥៣**
**ជំពូកទី ១៣ ការសះជា--------------------------------------------------- ១៥៨**
**ជំពូកទី ១៤ ការគ្រប់គ្រងដោយឈើឆ្កាល ------------------------------------------១៦៣**
**ជំពូកទី ១៥ សេចក្តីចម្រើនដោយឥតហេតុ -----------------------------------------១៧១**
**ជំពូកទី ១៦ អំពើអនីត្យានុកូល --------------------------------------------- ១៧៩**

**សមាសភាពនៃគណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណីកម្ពុជា :**

| | |
|---|---|
| ឯកឧត្ដម **អង្គ វង្ស វឌ្ឍានា** | រដ្ឋមន្ដ្រី, ក្រសួងយុត្ដិធម៌ (ប្រធាន) |
| ឯកឧត្ដម **ស៊ុយ នូ** | រដ្ឋលេខាធិការ, ក្រសួងយុត្ដិធម៌ (អាណត្ដិទី ១) |
| ឯកឧត្ដម **អ៊ី ដន** | រដ្ឋលេខាធិការ, ក្រសួងយុត្ដិធម៌ (អាណត្ដិទី ២) |
| ឯកឧត្ដម **ហ៊ី សោភា** | រដ្ឋលេខាធិការ, ក្រសួងយុត្ដិធម៌ |
| លោកជំទាវ **ចាន់ សុខាវី** | រដ្ឋលេខាធិការ, ក្រសួងយុត្ដិធម៌ |
| ឯកឧត្ដម **យូ ប៊ុនឡេង** | ប្រធានសាលាឧទ្ធរណ៍ |
| ឯកឧត្ដម **គង់ ស្រ៊ឹម** | អនុប្រធានតុលាការកំពូល |
| ឯកឧត្ដម **ប៊ុន ហ៊ុន** | អនុរដ្ឋលេខាធិការ, ក្រសួងយុត្ដិធម៌ |
| ឯកឧត្ដម **កើត រិទ្ធ** | អនុរដ្ឋលេខាធិការ, ក្រសួងយុត្ដិធម៌ |
| ឯកឧត្ដម **ជួន តេជ** | អគ្គាធិការរង, ក្រសួងយុត្ដិធម៌ |
| ឯកឧត្ដម **ប៉ែន ពេជ្រសាលី** | អគ្គនាយកអគ្គនាយកដ្ឋានបច្ចេកទេស, ក្រសួងយុត្ដិធម៌ |
| ឯកឧត្ដម **ឆួន សំភី** | អគ្គនាយកអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្ដិធម៌, ក្រសួងយុត្ដិធម៌ |
| លោក **ម៉ុង មុន្នីចរិយា** | ប្រធានសាលាដំបូងខេត្ដព្រះសីហនុ |
| លោក **យូរ ឧត្ដរា** | ចៅក្រមតុលាការកំពូល |
| លោក **ស៊ីរិទ្ធ សុផល** | ចៅក្រមសាលាឧទ្ធរណ៍ |
| លោក **សាលី ឆារ៉ា** | ចៅក្រមសាលាឧទ្ធរណ៍ |
| លោកស្រី **ខៀវ សុខា** | អគ្គនាយករងអគ្គនាយកដ្ឋានបច្ចេកទេស, ក្រសួងយុត្ដិធម៌ |
| លោក **ស៊ឹង បញ្ញាវុឌ្ឍ** | ចៅក្រមតុលាការកំពូល |
| លោក **ហ៊ឹង ធីឫទ្ធិ** | ចៅក្រមសាលាដំបូងខេត្ដស្ទឹងត្រែង |
| លោក **ទូច ថាវរិទ្ធិ** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណី, ក្រសួងយុត្ដិធម៌ |
| លោក **និស្ស ឫទ្ធី** | ចៅក្រមក្រសួងយុត្ដិធម៌ |

**សមាសភាពនៃក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី :**

| | |
|---|---|
| លោក **Morishima Akio** | សាស្ដ្រាចារ្យកិត្ដិយស, សកលវិទ្យាល័យ Nagoya (ប្រធាន) |
| លោក **Kamata Kaoru** | សាស្ដ្រាចារ្យ, សកលវិទ្យាល័យ Waseda |
| លោក **Matsumoto Tsuneo** | សាស្ដ្រាចារ្យ, សកលវិទ្យាល័យ Hitotsubashi |
| លោក **Minami Toshifumi** | ចៅក្រម, សាលាឧទ្ធរណ៍នៃតំបន់ Tokyo |

| | |
|---|---|
| លោក **Motoyama Atsushi** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Ritsumeikan |
| លោក **Niimi Ikufumi** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Meiji |
| លោក **Nomi Yoshihisa** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Tokyo |
| លោក **Nomura Toyohiro** | ព្រឹទ្ធបុរស និង សាស្ត្រាចារ្យ, សកលវិទ្យាល័យ Gakushuin |
| លោក **Sato Keita** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Chuo |
| លោក **Tanamura Masayuki** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Waseda |
| លោក **Urakawa Michitaro** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Waseda |
| លោក **Yamamoto Yutaka** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Kyoto |
| លោក **Hatanaka Hisaya** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Fukuoka |

**ជំនាញការ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន** (JICA) **ប្រចាំក្រសួងយុត្តិធម៌ :**

| | |
|---|---|
| លោក **Sakano Issei** | ទីប្រឹក្សា នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Yamada Yoichi** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Imaizumi Manabu** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោកស្រី **Homma Yoshiko** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Kai Mineo** | អតីតអ្នកសម្របសម្រួល នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Kamiki Atsushi** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| កញ្ញា **Manabe Kana** | អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| កញ្ញា **Terauchi Kozue** | អ្នកសម្របសម្រួល នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Kiyohara Hiroshi** | ទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |

**អ្នកបកប្រែ :**

| | |
|---|---|
| លោក **សរ សិនិរា** | អតីតជំនួយការជាន់ខ្ពស់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **ស សុវាន** | អតីតជំនួយការ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **ជិន មុនី** | អតីតជំនួយការ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **កែវ ទ៉ាន្នី** | ជំនួយការ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |
| លោក **Sakano Issei** | ទីប្រឹក្សា នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌ |

# គន្ថីទី ៥ កិច្ចសន្យាសំខាន់ៗ និង អំពើអនីត្យានុកូល

## ជំពូកទី ១ ការលក់ទិញ

### ផ្នែកទី ១ លក្ខណៈនៃការលក់ និង ការបង្កើតកិច្ចសន្យាលក់ទិញ

**មាត្រា ៥១៥**.- និយមន័យនៃការលក់ទិញ

ការលក់ទិញសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថា អ្នកលក់មានករណីយកិច្ចត្រូវផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិ ឱ្យទៅភាគីម្ខាងទៀតហៅថា អ្នកទិញ ហើយអ្នកទិញមានករណីយកិច្ចត្រូវចេញថ្លៃជាប្រាក់ឱ្យអ្នកលក់ ។

(កំណត់)

គោលបំណងនៃកិច្ចសន្យាលក់ទិញគឺមិនមែនអនុប្បទាន "វត្ថុ" ទេ គឺអនុប្បទាន "សិទ្ធិលើទ្រព្យសម្បត្តិ" ដូចជាកម្មសិទ្ធិ ឬ សិទ្ធិប្រត្យក្សផ្សេងៗ ដែលជាមូលដ្ឋាននៃការគ្រប់គ្រងវត្ថុ និង សិទ្ធិលើបំណុល លើសពីនេះ ក៏មានភាគហ៊ុន កម្មសិទ្ធិបញ្ញា ជាអាទិ៍ ។ ហេតុនេះហើយ អ្នកលក់មិនត្រឹមតែត្រូវប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញឱ្យអ្នកទិញប៉ុណ្ណោះទេ តែថែមទាំងត្រូវមានករណីយកិច្ចធ្វើឱ្យអ្នកទិញបានធ្វើលទ្ធកម្មនូវសិទ្ធិដែលជាកម្មវត្ថុទៀតផង ។ ផ្ទុយទៅវិញ អ្នកទិញមានករណីយកិច្ចបង់ "ថ្លៃទិញជាប្រាក់" ។ ក្នុងករណីដែលតម្លៃថ្នូរមិនមែនជាប្រាក់ទេ គេហៅថា "ការដូរ" ។

ម្យ៉ាងទៀត កិច្ចសន្យាលក់ទិញ គឺជាកិច្ចសន្យាដែលបង្កើតនូវ "ករណីយកិច្ច" ផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិ ហេតុនេះហើយ ឧទាហរណ៍ថា ទោះបីជាលក់ទិញវត្ថុដែលកំពុងផលិត ហើយដែលមិនទាន់មានរូបរាងនៅឡើយ ឬ លក់ទិញនូវវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកផ្សេង ជាអាទិ៍ ដែលមិនអាចផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិភ្លាមៗក៏ដោយ ក៏កិច្ចសន្យានោះមានសុពលភាពដែរ ។ ចំពោះករណីដែលកម្មវត្ថុនៃការលក់ទិញជាសិទ្ធិរបស់អ្នកដទៃ គឺមានចែងជាពិសេសចាប់ពីមាត្រា ៥៣១ (ករណីយកិច្ចត្រូវផ្ទេរសិទ្ធិ និង ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់) ទៅ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០១៧ និង មាត្រា ១០២១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ៥១៦**.- ការបង្កើតកិច្ចសន្យាលក់ទិញ

កិច្ចសន្យាលក់ទិញអាចត្រូវបានបង្កើតឡើង ដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងតែប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ ។ ប៉ុន្តែ ភាគីអាចកំណត់ការធ្វើលិខិតយថាភូត ឬ លិខិតឯកជន ជាល័ក្ខខ័ណ្ឌសម្រាប់ការ

បង្កើតកិច្ចសន្យាបាន ។

(កំណត់)

ចំពោះការបង្កើតកិច្ចសន្យាលក់ទិញ ជាគោលការណ៍ គឺអាចបង្កើតឡើងឱ្យតែមានការព្រមព្រៀង (convention, agreement) រវាងភាគី ដោយមិនចាំបាច់ធ្វើលិខិតជាលាយល័ក្ខណ៍អក្សរ ឬ មិនចាំបាច់មានទម្រង់ ដូចជាការប្រគល់វត្ថុទេ (គោលការណ៍នៃការបង្កើតដោយការព្រមព្រៀង) ។ ក្នុងករណីដែលចាំបាច់មានទម្រង់ ដូចជាលិខិតកិច្ចសន្យាលក់ទិញជាលាយល័ក្ខណ៍អក្សរ សេចក្តីបញ្ជាក់ ការចុះបញ្ជី ជាដើម ក្នុងការបង្កើតកិច្ចសន្យាលក់ទិញ ឬ ដើម្បីបញ្ជាក់កិច្ចសន្យាលក់ទិញ ច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត នឹងកំណត់អំពីទម្រង់នេះ ។ ទោះបីជាគ្មានបញ្ញត្តិនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀតក៏ដោយ ក៏ភាគីមានសេរីភាពក្នុងការយកទម្រង់ណាមួយ មកធ្វើជាល័ក្ខខ័ណ្ឌដើម្បីបង្កើតកិច្ចសន្យាបានដែរ ។ នៅក្នុងវាក្យខណ្ឌទី ២ នៃមាត្រានេះ ចែងតែអំពី "ការធ្វើលិខិត" ប៉ុណ្ណោះ ប៉ុន្តែ ក្រៅពីការធ្វើលិខិតជាលាយល័ក្ខណ៍អក្សរ ភាគីក៏អាចយកទម្រង់ផ្សេងទៀត ដូចជាការប្រគល់ប្រាក់កក់ ជាដើម មកធ្វើជាល័ក្ខខ័ណ្ឌបានដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០២២ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ៤ នៃក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច

**មាត្រា ៥១៧**.- ការសន្យាលក់ទិញជាមុនដោយឯកតោភាគី

១-ក្នុងករណីដែលភាគីតែម្ខាងសន្យាជាមុនក្នុងការលក់ ឬ ទិញ ការលក់ទិញនេះនឹងមានអានុភាពចាប់តាំងពីពេលដែលភាគីម្ខាងទៀតបង្ហាញឆន្ទៈបំពេញការទិញ ឬ លក់ចំពោះអ្នកសន្យានោះ ។

២-ប្រសិនបើអំឡុងពេលសម្រាប់ការបង្ហាញឆន្ទៈដែលបានចែងក្នុងកថាខណ្ឌទី ១ នេះមិនត្រូវបានកំណត់ទេ អ្នកសន្យាជាមុនអាចកំណត់នូវអំឡុងពេលសមរម្យមួយ ហើយអាចដាស់តឿនឱ្យភាគីម្ខាងទៀតបង្ហាញឆន្ទៈថា ព្រម ឬ មិនព្រមបំពេញការទិញ ឬ លក់នៅក្នុងអំឡុងពេលនោះ ។ ក្នុងករណីដែលភាគីម្ខាងទៀតមិនបានបង្ហាញឆន្ទៈនៅក្នុងអំឡុងពេលកំណត់ទេ ការសន្យាជាមុននោះ ត្រូវបាត់បង់អានុភាព ។

(កំណត់)

"ការសន្យាជាមុន" គឺជាកិច្ចសន្យាដែលភាគីម្ខាងផ្តល់សិទ្ធិដល់ភាគីម្ខាងទៀតបង្កើតកិច្ចសន្យាលក់ទិញ ។ ឧទាហរណ៍ ក្រុមហ៊ុនអាកាសចរណ៍ A បន្ទាប់ពីការចរចារជាមួយក្រុមហ៊ុនផលិតយន្តហោះ B ជាច្រើនដង ក៏បានសម្រេចនូវការព្រម

ព្រៀងស្តីពីល័ក្ខខ័ណ្ឌនៃកិច្ចសន្យាមួយ ប៉ុន្តែ ដើម្បីសម្រេចការទិញយន្តហោះ ខ្លួនចាំបាច់ត្រូវពិនិត្យមើលចំនួនអ្នកជិះក្នុងអំឡុងពេល ២ ទៅ ៣ ឆ្នាំទៀត ជាអាទិ៍ ។ ក្នុងករណីនេះ ប្រសិនបើក្រុមហ៊ុនអាកាសចរណ៍ A គិតឃើញថា ខ្លួនចង់បានជាដាច់ខាតនូវយន្តហោះនោះ នៅពេលដែលខ្លួនសម្រេចទិញ រីឯក្រុមហ៊ុន B វិញ គិតឃើញដែរថា ប្រសិនបើក្រុមហ៊ុន A សម្រេចថាទិញ ខ្លួនចង់ឱ្យគេទិញយន្តហោះរបស់ក្រុមហ៊ុនខ្លួន នោះក្រុមហ៊ុន B អាចផ្តល់សិទ្ធិដល់ក្រុមហ៊ុន A ក្នុងការបង្កើតកិច្ចសន្យា ដោយគ្រាន់តែបង្ហាញឆន្ទៈឯកតោភាគី នៅពេលដែលក្រុមហ៊ុន A ចង់បាន (សិទ្ធិបញ្ចប់ការសន្យាជាមុន និង សម្រេចបង្កើតកិច្ចសន្យាលក់ទិញ, សិទ្ធិធ្វើជម្រើស) ។ ក្នុងករណីនេះ មានពេលខ្លះ ក្រុមហ៊ុន B អាចទទួលនូវតម្លៃថ្នូរនៃលទ្ធកម្មសិទ្ធិបញ្ចប់ការសន្យាជាមុន និង សម្រេចបង្កើតកិច្ចសន្យាលក់ទិញនេះ ពីក្រុមហ៊ុន A ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៥៦ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៥៨៩ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៥១៨.- ប្រាក់កក់

បើអ្នកទិញបានបង់ប្រាក់កក់ទៅឱ្យអ្នកលក់ អ្នកទិញអាចរំលាយកិច្ចសន្យាលក់ទិញដោយបោះបង់ចោលប្រាក់កក់នោះបាន រីឯអ្នកលក់អាចរំលាយកិច្ចសន្យាលក់ទិញដោយសងប្រាក់ស្មើនឹងពីរដងនៃប្រាក់កក់នេះមកវិញបានដែរ ។ ប៉ុន្តែ ភាគីមិនអាចរំលាយកិច្ចសន្យាបានឡើយ ក្រោយពេលភាគីម្ខាងទៀតបានចាប់ផ្តើមអនុវត្តកិច្ចសន្យាហើយ ។

(កំណត់)

ប្រាក់កក់មានតួនាទីដូចជា (១) បញ្ជាក់នូវការបង្កើតកិច្ចសន្យា (ប្រាក់កក់បញ្ជាក់កិច្ចសន្យា) (២) ថវបនីយនូវសិទ្ធិរំលាយកិច្ចសន្យា (ប្រាក់កក់សម្រាប់រំលាយកិច្ចសន្យា) (៣) រឹបអូសយកប្រាក់កក់ក្នុងករណីដែលមិនអនុវត្តកាតព្វកិច្ច (យកប្រាក់កក់មកធ្វើជាប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា) (ប្រាក់កក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា) ជាអាទិ៍ ។ មាត្រានេះមានអត្ថន័យបកស្រាយថា ជាគោលការណ៍ ប្រាក់កក់គឺជាប្រាក់កក់សម្រាប់រំលាយកិច្ចសន្យា មិនមែនជាប្រាក់កក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យាទេ បើគ្មានការព្រមព្រៀងពិសេសរវាងភាគី ។ ប៉ុន្តែ ទោះបីជាមានការព្រមព្រៀងជាប្រាក់កក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យាក៏ដោយ ក៏អាចមានករណីដែលត្រូវបកស្រាយព្រមជាមួយគ្នាថា ជាប្រាក់កក់សម្រាប់រំលាយកិច្ចសន្យាដែរ ។

ក្នុងករណីដែលមានការបង់ និង ទទួលប្រាក់នៅពេលធ្វើកិច្ចសន្យា មានបញ្ហាមួយក្នុងការបកស្រាយថា តើប្រាក់នោះជាប្រាក់កក់ ឬ ជាប្រាក់មួយភាគនៃថ្លៃលក់ ។ ការបកស្រាយនេះត្រូវធ្វើឡើងទៅតាមទំនៀមទម្លាប់នៃកិច្ចការជំនួញ ។

ការ "ចាប់ផ្តើមអនុវត្ត" គឺមិនមែនត្រឹមតែជាករណីដែលអនុវត្តកាតព្វកិច្ចមួយភាគប៉ុណ្ណោះទេ គឺរាប់បញ្ចូលករណីដែលធ្វើសកម្មភាពចាំបាច់ដើម្បីផ្តល់ការអនុវត្ត ដែលអាចដឹងច្បាស់ បើមើលពីខាងក្រៅថែមទៀត ។

ម្យ៉ាងទៀត ក្នុងករណីដែលអ្នកលក់ ឬ អ្នកទិញតែម្ខាងបានចាប់ផ្ដើមអនុវត្ត មានបញ្ហាត្រង់ចំណុចថា តើភាគីដែលបានចាប់ផ្ដើមអនុវត្តអាចរំលាយកិច្ចសន្យាបាន ឬ មិនបាន ។ មាត្រានេះមានគោលបំណងកុំឱ្យនាំឱ្យមានការខូចប្រយោជន៍របស់ភាគីដែលបានចាប់ផ្ដើមអនុវត្ត ហេតុដូច្នេះ អាចបកស្រាយថា ការរំលាយដោយភាគីដែលបានចាប់ផ្ដើមអនុវត្ត អាចត្រូវបានទទួលស្គាល់ លើកលែងតែមានកាលៈទេសៈពិសេស ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៥៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៥៩០ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៥១៩**.- ការលក់ដោយមានការភ្លក់សាក

១-ការលក់របស់ណាដែលមានទំនៀមទំលាប់តម្រូវឱ្យមានការភ្លក់សាកមុននឹងទិញ ត្រូវមានអានុភាពនៅពេលអ្នកទិញបានយល់ព្រម ក្រោយពេលបានភ្លក់សាករួចហើយ ។

២-ក្នុងករណីដែលមិនបានកំណត់អំឡុងពេលសម្រាប់អ្នកទិញដើម្បីយល់ព្រម អ្នកលក់អាចដាស់តឿនឱ្យអ្នកទិញឆ្លើយច្បាស់អំពីការយល់ព្រម ឬ មិនយល់ព្រម ដោយកំណត់អំឡុងពេលសមរម្យបាន ។ ក្នុងករណីដែលអ្នកទិញមិនបានឆ្លើយច្បាស់ ក្នុងអំឡុងពេលនោះ ត្រូវចាត់ទុកថា អ្នកទិញបដិសេធក្នុងការធ្វើកិច្ចសន្យា ។

(កំណត់)

ចំពោះការលក់ទិញវត្ថុដែលមានទំនៀមទម្លាប់ដែលអ្នកទិញភ្លក់សាកមុននឹងទិញនោះ ទោះបីជាគ្មានការសន្យាជាក់លាក់នូវការភ្លក់សាកនេះក៏ដោយ ក៏កិច្ចសន្យានេះមិនត្រូវបង្កើតឡើងភ្លាមដោយត្រឹមតែមានការព្រមព្រៀងអំពីវត្ថុដែលជាកម្មវត្ថុ និង ថ្លៃលក់ប៉ុណ្ណោះទេ គឺកិច្ចសន្យានេះនឹងត្រូវបានបង្កើតនៅពេលដែលអ្នកទិញបានភ្លក់សាក ហើយយល់ព្រមទិញ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៥៨៧ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៥២០**.- ការលក់ដោយមានការប្រើសាក

១-ចំពោះការលក់ទិញដោយមានការប្រើសាក កិច្ចសន្យាលក់ទិញនោះមានអានុភាពនៅពេលដែលអ្នកទិញបានយល់ព្រមក្នុងអំឡុងពេលប្រើសាក ឬ អំឡុងពេលប្រើសាកនោះកន្លងហួស ដោយអ្នកទិញមិនបានបង្ហាញឆន្ទៈទេ ។ ក្នុងករណីដែលអ្នកទិញបដិសេធមិនទទួលវត្ថុដែលជាកម្មវត្ថុ កិច្ចសន្យាលក់ទិញនោះ ត្រូវចាត់ទុកថា មិនត្រូវបានបង្កើតឡើយ ។

២-ក្នុងករណីដែលមិនបានកំណត់អំឡុងពេលប្រើសាកនៅក្នុងកិច្ចសន្យា អ្នកលក់អាចដាស់តឿនឱ្យអ្នកទិញឆ្លើយច្បាស់អំពីការយល់ព្រម ឬ មិនយល់ព្រម ដោយកំណត់អំឡុងពេលសមរម្យបាន ។ ក្នុងករណីដែលអ្នកទិញមិនបានឆ្លើយច្បាស់ ក្នុងអំឡុងពេលនោះ ហើយបន្តប្រើសាកវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យានោះ ត្រូវចាត់ទុកថា អ្នកទិញបានយល់ព្រម ។

(កំណត់)

ឧទាហរណ៍ ដូចជាករណីលក់ទិញនាវាចាស់ ក្នុងករណីដែលបានធ្វើកិច្ចសន្យាទិញនេះដោយមានល័ក្ខខ័ណ្ឌឱ្យអ្នកទិញប្រើសាកសិន ហើយបើបានដឹងថា មានលទ្ធផលល្អតាមការសង្ឃឹមរបស់អ្នកទិញនោះ ទើបសម្រេចទិញវត្ថុនោះ ។ កិច្ចសន្យានេះមិនត្រូវបានបង្កើតឡើងដោយគ្រាន់តែបានព្រមព្រៀងគ្នាអំពីវត្ថុដែលជាកម្មវត្ថុ និង ថ្លៃលក់ទិញនោះទេ គឺបង្កើតឡើងនៅពេលដែលអ្នកទិញបានប្រើសាក ហើយយល់ព្រមទិញ ។ ការចាត់ចែងក្នុងករណីដែលអ្នកទិញមិនបានបង្ហាញឆន្ទៈអ្វីសោះ ក្រោយពីការប្រើសាក មានភាពខុសគ្នានឹងមាត្រា ៥១៩ (ការលក់ដោយមានការភ្លក់សាក) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៥៨៨ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១០៤៩ និង មាត្រា ១០៧០ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ៥២១**.- ថ្លៃលក់ទិញ

១-ភាគីនៃកិច្ចសន្យាត្រូវកំណត់ចំនួនប្រាក់នៃថ្លៃលក់ទិញ ឬ វិធីកំណត់ចំនួនប្រាក់នោះ នៅក្នុងកិច្ចសន្យា ។

២-ចំនួនប្រាក់នៃថ្លៃលក់ទិញអាចត្រូវបានកំណត់ ដោយយោលទៅតាមតម្លៃនៃទំនិញណាមួយនៅទីផ្សារក្នុងពេលបច្ចុប្បន្ន ឬ អនាគត ឬ ដោយផ្អែកលើការវាយតម្លៃដែលធ្វើដោយតតិយជនដែលត្រូវបានជ្រើសរើស តាមរបៀបកំណត់ដោយគូភាគី ។ ក្នុងករណីដែលការវាយតម្លៃរបស់តតិយជនត្រូវបានធ្វើឡើងដោយភាន់ច្រឡំ ឬ ករណីដែលការវាយតម្លៃនោះ ច្បាស់ជាផ្ទុយនឹងសមភាព ភាគីនៃកិច្ចសន្យាដែលទទួលការខូចខាតផលប្រយោជន៍របស់ខ្លួន ដោយសារការវាយតម្លៃនោះ អាចតវ៉ាចំពោះការវាយតម្លៃនោះបាន ។

៣-ភាគីនៃកិច្ចសន្យាអាចកំណត់ចំនួនថ្លៃលក់ទិញដោយបង្ហាញចំនួនថ្លៃដើមពិតប្រាកដ ឬ ដោយឱ្យអ្នកទិញបង់ធនលាភ ដែលមិនកំណត់ពេល ឬ ធនលាភមួយជីវិតបាន ។

ប៉ុន្តែ ក្នុងករណីដែលតតិយជនវាយតម្លៃ ដោយយោលទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ថ្លៃលក់ទិញត្រូវបានកំណត់ដោយបង្ហាញចំនួនថ្លៃដើមពិតប្រាកដ លើកលែងតែករណីដែលគូភាគីប្រគល់សិទ្ធិទៅតតិយជនដោយដាក់លាក់ ។

(កំណត់)

ចំពោះកិច្ចសន្យាលក់ទិញ ចំនួនថ្លៃលក់ទិញជាកត្តាមួយសំខាន់ណាស់ ។ ដូច្នេះ កិច្ចសន្យាលក់ទិញមិនត្រូវកើតឡើង បើមិនកំណត់នូវចំនួនទឹកប្រាក់នៃថ្លៃលក់ទិញ ឬ អាចកំណត់នាពេលអនាគត ។ ម្យ៉ាងទៀត ថ្លៃលក់ទិញអាចកំណត់បាន ដោយយករបៀបបង់តាមបណ្តាក់តាមពេលវេលាដែលកំណត់ ដោយមិនចាំបាច់កំណត់ថ្លៃសរុបក៏បានដែរ ឧទាហរណ៍ ត្រូវបង់មួយឆ្នាំ ០០ រៀល រហូតដល់អ្នកលក់ទទួលមរណភាព ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៥៩១ និង មាត្រា ១៥៩២ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១០២១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ៥២២.-** សោហ៊ុយក្នុងការលក់ទិញ

ចំពោះសោហ៊ុយធ្វើលិខិត ឬ សោហ៊ុយផ្សេងៗដែលត្រូវចំណាយក្នុងការធ្វើកិច្ចសន្យាលក់ទិញ ភាគីទាំងសងខាងត្រូវចេញស្មើគ្នា លើកលែងតែករណីដែលមានការកំណត់ផ្សេងដោយគូភាគី ។

(កំណត់)

កិច្ចសន្យាលក់ទិញត្រូវធ្វើឡើងសម្រាប់ផលប្រយោជន៍របស់ភាគីសងខាង ហេតុនេះហើយភាគីសងខាងត្រូវទទួលបន្ទុកនូវសោហ៊ុយស្មើគ្នា ។ ប៉ុន្តែ ភាគីមានសេរីភាពធ្វើការព្រមព្រៀងផ្សេងពីនេះ ។ ម្យ៉ាងទៀត សោហ៊ុយសម្រាប់នីតិវិធីចាំបាច់ដើម្បីឱ្យអ្នកទិញធ្វើលទ្ធកម្មនូវសិទ្ធិដោយពិតប្រាកដ (ការចុះបញ្ជីដែលជាល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង ការចុះបញ្ជីដែលជាល័ក្ខខ័ណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្សក្រៅពីករណីនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង ការជូនដំណឹងដែលជាល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុល ជាអាទិ៍) គឺជាសោហ៊ុយសម្រាប់អនុវត្តកាតព្វកិច្ច មិនមែនជាសោហ៊ុយសម្រាប់បង្កើតកិច្ចសន្យាទេ ហេតុនេះហើយ ប្រសិនបើគ្មានការព្រមព្រៀងរវាងភាគីទេ ជាគោលការណ៍ សោហ៊ុយនេះគឺជាបន្ទុករបស់កូនបំណុល (អ្នកលក់) តាមបញ្ញត្តិនៃមាត្រា ៤៤៦ (សោហ៊ុយនៃការសង) (ប៉ុន្តែ មាត្រា ១៥៩៣ នៃក្រមរដ្ឋប្បវេណីបារាំងចែងថា សោហ៊ុយសម្រាប់ធ្វើលិខិតបញ្ជាក់ និង សោហ៊ុយផ្សេងទៀតពាក់ព័ន្ធនឹងការលក់ទិញ គឺជាបន្ទុករបស់អ្នកទិញ) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៥៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៥២៣**.- ការអនុវត្តដូចគ្នាចំពោះកិច្ចសន្យាទូទៅដែលយកតម្លៃថ្នូរ

បញ្ញត្តិនៃជំពូកទី ១ (ការលក់ទិញ) នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះកិច្ចសន្យាដែលយកតម្លៃថ្នូរ ក្រៅពីកិច្ចសន្យាលក់ទិញ ។

(កំណត់)

កិច្ចសន្យាលក់ទិញ ជាប្រភេទចម្បងមួយក្នុងចំណោមកិច្ចសន្យាដែលយកតម្លៃថ្នូរ (កិច្ចសន្យាមូលា : កិច្ចសន្យាដែលភាគីសងខាងចេញចំណាយដែលមានអត្ថន័យជាតម្លៃថ្នូរ) ហេតុដូច្នេះ បញ្ញត្តិស្ដីពីកិច្ចសន្យាលក់ទិញ មានលក្ខណៈជាបញ្ញត្តិទូទៅស្ដីពីកិច្ចសន្យាដែលយកតម្លៃថ្នូរដែរ ហើយត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះកិច្ចសន្យាដែលយកតម្លៃថ្នូរផ្សេងទៀត លុះត្រាតែមិនផ្ទុយនឹងលក្ខណៈនៃកិច្ចសន្យានោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៥៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ២ ភាគីនៃកិច្ចសន្យាលក់ទិញ និង កម្មវត្ថុនៃកិច្ចសន្យាលក់ទិញ

**មាត្រា ៥២៤**.- ភាគីនៃកិច្ចសន្យាលក់ទិញ

រូបវន្តបុគ្គល ឬ នីតិបុគ្គលទាំងឡាយអាចលក់ ឬ ទិញបាន លើកលែងតែក្នុងករណីដែលច្បាប់ហាមឃាត់ ។

(កំណត់)

ជនទាំងអស់ ទោះជាជនជាតិបរទេសក៏ដោយ ជាអនីតិជនក៏ដោយ អាចបង្កើតកិច្ចសន្យាលក់ទិញក្នុងនាមជាអ្នកលក់ ឬ អ្នកទិញបាន លើកលែងតែករណីដែលហាមនៅក្នុងមាត្រា ៥២៥ (បុគ្គលដែលមិនអាចក្លាយជាអ្នកទិញបាន (មួយ)) និង មាត្រា ៥២៦ (បុគ្គលដែលមិនអាចក្លាយជាអ្នកទិញបាន (ពីរ)) ព្រមទាំងហាមដោយច្បាប់ផ្សេងទៀត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៥៩៤ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១០២៣ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ៥២៥**.- បុគ្គលដែលមិនអាចក្លាយជាអ្នកទិញបាន (មួយ)

១-អ្នកគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់ តាមផ្លូវតុលាការ ឬ តាមកិច្ចសន្យា មិន

អាចក្លាយជាអ្នកទិញ ឬ ជាអ្នកទិញដោយការលក់ដោយបង្ខំ នូវទ្រព្យសម្បត្តិដែលខ្លួនបាន ទទួលភារកិច្ចលក់ ដោយផ្ទាល់ខ្លួន ឬ តាមរយៈអន្តរការី បានឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះ មន្ត្រីរាជការដែលទទួលបន្ទុកចាត់ការ ការលក់ដោយបង្ខំ ឬ ទទួលបន្ទុកគ្រប់គ្រងការលក់ ដោយបង្ខំ ។

៣-ចំពោះការលក់ទិញដែលផ្ទុយនឹងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ មានតែ កម្មសិទ្ធិករនៃវត្ថុមុនពេលលក់ ឬ សន្តតិជនឬប្រតិសិទ្ធិរបស់កម្មសិទ្ធិករនោះទេ ទើបអាច លុបចោលកិច្ចសន្យានេះបាន ។

(កំណត់)

ឧទាហរណ៍ ប្រសិនបើអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលអវត្តមាន ទិញអចលនវត្ថុរបស់បុគ្គលអវត្តមាននោះ ដោយកំណត់នូវល័ក្ខខ័ណ្ឌធ្វើឱ្យខ្លួនមានប្រៀបជាង ដោយប្រើឈ្មោះខ្លួនឯង ឬ ប្រើអន្តរការី (តុក្កតាចំបើង) (កិច្ចសន្យាដែលជនណាម្នាក់ធ្វើឡើងក្នុងនាមអ្នកតំណាងបុគ្គលណាម្នាក់ និង សាមីខ្លួននោះ ហៅថា "កិច្ចសន្យាដោយខ្លួនឯង") កិច្ចសន្យាបែបនេះធ្វើឱ្យខូចប្រយោជន៍បុគ្គលអវត្តមានយ៉ាងខ្លាំង ។ ហេតុនេះហើយបានជាមាត្រានេះចែងហាមមិនឱ្យធ្វើសកម្មភាពដែលមានប្រយោជន៍ផ្ទុយគ្នាបែបនេះ ហើយអ្នកដែលខូចប្រយោជន៍ដោយសារសកម្មភាពនេះ (ក្នុងឧទាហរណ៍នេះ គឺបុគ្គលអវត្តមាន ព្រមទាំងសន្តតិជន និង ប្រតិសិទ្ធិដោយឡែករបស់បុគ្គលនោះ) អាចលុបចោលនូវកិច្ចសន្យានេះបាន ។ ចំពោះករណីលក់ដោយបង្ខំក៏ដូចគ្នាដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៥៩៦ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១០២៣ និង មាត្រា ១៥៩៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ៥២៦**.- បុគ្គលដែលមិនអាចក្លាយជាអ្នកទិញបាន (ពីរ)

១-ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី ឬ មន្ត្រីតុលាការផ្សេងទៀត មិនអាចក្លាយ ជាអ្នកទិញ ឬ ជាអ្នកទិញដោយការលក់ដោយបង្ខំ ដោយផ្ទាល់ខ្លួន ឬ តាមរយៈអន្តរការី នូវវត្ថុ ឬ សិទ្ធិ ដែលជាកម្មវត្ថុនៃវិវាទដែលកំពុងចាត់ការនៅតុលាការដែលខ្លួនបំពេញ ភារកិច្ចបានទេ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះ ករណីដែលមេធាវី ឬ សារការី ក្លាយជាអ្នកទិញ ឬ ជាអ្នកទិញដោយការលក់ដោយបង្ខំ

នូវវត្ថុ ឬ សិទ្ធិដែលទាក់ទងនឹងរឿងក្ដីដែលខ្លួនទទួលបន្ទុក ។

៣-ចំពោះការលក់ទិញដែលផ្ទុយនឹងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ មានតែអ្នកលក់ ភាគីម្ខាងទៀតដែលមានវិវាទអំពីសិទ្ធិ ឬ សន្តតិជនឬប្រតិសិទ្ធិរបស់អ្នកលក់ឬភាគីម្ខាងទៀតទេ ទើបអាចលុបចោលកិច្ចសន្យានេះបាន ។

(កំណត់)

ឧទាហរណ៍ ប្រសិនបើចៅក្រមបានរកចំណុចខ្សោយរបស់ភាគីនៃបណ្ដឹង ហើយធ្វើកិច្ចសន្យាទិញនូវវត្ថុ ដែលទាក់ទងនឹងរឿងក្ដីដែលត្រូវបានចាត់ការដោយតុលាការដែលខ្លួនធ្វើការ អំពើនោះអាចធ្វើឱ្យខូចប្រយោជន៍របស់ភាគីនៃបណ្ដឹងនោះ ហេតុនេះហើយបានជាមាត្រានេះហាមអំពើនេះ ព្រមទាំងផ្ដល់សិទ្ធិលុបចោលឱ្យអ្នកដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ។ ក្នុងករណីដែលមានការខូចផលប្រយោជន៍ដល់ភាគីនៃបណ្ដឹងដោយសារអំពើនេះ ភាគីនៃបណ្ដឹងនោះក៏អាចទាមទារឱ្យសងសំណងការខូចខាតដោយយកអំពើអនីត្យានុកូលមកធ្វើជាមូលហេតុបានផងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៥៩៧ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១០២៣ និង មាត្រា ១៥៩៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ៥២៧**.- វត្ថុដែលអាចលក់បាន

វត្ថុ ឬ សិទ្ធិទាំងឡាយណា ទោះបីជាកើតមានឡើងនាពេលអនាគតក៏ដោយ ក៏អាចយកទៅធ្វើជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញបានដែរ លើកលែងតែវត្ថុ ឬ សិទ្ធិនោះមានលក្ខណៈមិនអាចធ្វើអនុប្បទាន ឬ ច្បាប់ហាមឃាត់មិនឱ្យធ្វើអនុប្បទាន ។

(កំណត់)

កិច្ចសន្យាលក់ទិញគ្រាន់តែបង្កើតនូវកាតព្វកិច្ចផ្ទេរសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញតែប៉ុណ្ណោះ (សូមមើលមាត្រា ៥៣០ (ករណីយកិច្ចទូទៅរបស់អ្នកលក់)) ដូច្នេះ ការលក់ទិញនូវវត្ថុនាពេលអនាគត និង ការលក់ទិញវត្ថុរបស់អ្នកដទៃក៏មានសុពលភាពដែរ ។ ចំពោះការលក់ទិញនូវវត្ថុរបស់អ្នកដទៃ ប្រសិនបើមិនចាត់ទុកថា មានសុពលភាពទេ អ្នកទិញមិនអាចទាមទារឱ្យអ្នកលក់ធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ ហើយប្រគល់វត្ថុនោះឱ្យទៅអ្នកទិញបានទេ ហើយអ្នកទិញក៏មិនអាចទាមទារឱ្យអ្នកលក់ទទួលខុសត្រូវក្នុងការមិនអាចផ្ទេរកម្មសិទ្ធិពីអ្នកលក់ទៅអ្នកទិញដែរ ។ ហេតុដូច្នេះ មានបញ្ហា (សូមមើលពីមាត្រា ៥៣១ (ករណីយកិច្ចត្រូវផ្ទេរសិទ្ធិ និង ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់) ដល់មាត្រា ៥៣៣ (ការទទួលខុសត្រូវក្នុងការធានាចំពោះករណីដែលសិទ្ធិមួយភាគ ជាសិទ្ធិរបស់អ្នកដទៃ) ។

ចំពោះករណីនៃ "អលទ្ធភាពទាំងស្រុងតាំងពីដំបូង" ដូចជាករណីដែលវត្ថុដែលជាកម្មវត្ថុជាក់លាក់នៃកិច្ចសន្យាលក់ទិញបានបាត់បង់ទាំងស្រុងរួចហើយ នៅពេលធ្វើកិច្ចសន្យាលក់ទិញ ហើយមិនអាចអនុវត្តកាតព្វកិច្ចនោះ ជាអាទិ៍

សូមមើលមាត្រា ៣៩៥ (អលទ្ធភាពតាំងពីដំបូង) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៥៩៨ និង មាត្រា ១៥៨៩ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១០១៨ មាត្រា និង ១០១៩ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ៣៥ នៃក្រឹត្យ-ច្បាប់ លខេ ៣៨ ក្រ.ច

## ផ្នែកទី៣ អានុភាពនៃកិច្ចសន្យាលក់ទិញ

**មាត្រា ៥២៨**.- ការផ្ទេរកម្មសិទ្ធិ

១-ចំពោះការផ្ទេរកម្មសិទ្ធិលើកម្មវត្ថុក្នុងកិច្ចសន្យាលក់ទិញ ត្រូវអនុវត្តទៅតាមគោលការណ៍ទូទៅដែលបានកំណត់ចាប់ពីមាត្រា ១៣៣ (ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស ដោយការព្រមព្រៀង) ដល់មាត្រា ១៣៥ (ល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង) នៃក្រមនេះ ។[១]

២-បើកម្មវត្ថុនៃកិច្ចសន្យាលក់ទិញជាសិទ្ធិលើទ្រព្យសម្បត្តិក្រៅពីកម្មសិទ្ធិ ការផ្ទេរសិទ្ធិទាំងនោះ ត្រូវអនុវត្តទៅតាមគោលការណ៍ទូទៅដែលទាក់ទងនឹងការផ្ទេរសិទ្ធិនីមួយៗនោះ ។

(កំណត់)

ឧទាហរណ៍ ក្នុងកិច្ចសន្យាលក់ទិញចលនវត្ថុ ក្នុងករណីដែលមានការសន្យាថា "កម្មសិទ្ធិត្រូវផ្ទេរជាថ្នូរនឹងការបង់ថ្លៃលក់" កម្មសិទ្ធិនឹងត្រូវផ្ទេរ នៅពេលបង់ថ្លៃលក់ តាមអានុភាពនៃកិច្ចសន្យាលក់ទិញ (ដោយមិនចាំបាច់ធ្វើសកម្មភាពពិសេសទេ) (មាត្រា ១៣៣) ។ ប្រសិនបើគ្មានការសន្យាពិសេសអំពីពេលវេលាដែលត្រូវផ្ទេរកម្មសិទ្ធិក្នុងកិច្ចសន្យាទេ ជាគោលការណ៍ កម្មសិទ្ធិត្រូវផ្ទេរនៅពេលដែលកិច្ចសន្យានោះមានអានុភាព ។ ប៉ុន្តែ ក្នុងករណីនៃការលក់ទិញចលនវត្ថុ ប្រសិនជាមិនបានប្រគល់ចលនវត្ថុទេ ការផ្ទេរកម្មសិទ្ធិនេះ មិនអាចតតាំងចំពោះតតិយជនបានឡើយ (កថាខណ្ឌទី ១ នៃមាត្រា ១៣៤) ។ ក្នុងករណីលក់ទិញសិទ្ធិលើបំណុល សិទ្ធិលើបំណុលត្រូវផ្ទេរទៅអនុប្បទានិកដោយស្វ័យប្រវត្តិ តាមអានុភាពនៃកិច្ចសន្យាលក់ទិញ (មាត្រា ៥០២) ប៉ុន្តែ ប្រសិនបើអនុប្បទាយីមិនបានជូនដំណឹងទៅកូនបំណុល ឬ កូនបំណុលមិនបានយល់ព្រម តាមបញ្ញត្តិនៃមាត្រា ៥០៣ ទេ អនុប្បទានសិទ្ធិលើបំណុលនោះមិនអាចតតាំងចំពោះកូនបំណុល ឬ តតិយជនផ្សេងបានទេ ។ ម្យ៉ាងទៀត ក្នុងករណីនៃការលក់ទិញអចលនវត្ថុ ប្រសិនបើមិនបានចុះបញ្ជីទេ ការផ្ទេរកម្មសិទ្ធិមិនត្រូវបង្កើតអានុភាពឡើយ (មាត្រា ១៣៥) ។

[១] កថាខណ្ឌទី ១ នៃមាត្រា ៥២៨ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

## កថាភាគទី ១ ករណីយកិច្ចរបស់អ្នកលក់

**មាត្រា ៥២៩**.- ករណីយកិច្ចត្រូវពន្យល់របស់អ្នកលក់

អ្នកលក់មានករណីយកិច្ចត្រូវពន្យល់ឱ្យបានច្បាស់លាស់ នូវខ្លឹមសារនៃករណីយ-កិច្ចដែលអ្នកលក់ទទួលបន្ទុក ទំនាក់ទំនងគតិយុត្តដែលទាក់ទងនឹងវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញ ហើយជាពិសេសក្នុងករណីលក់អចលនវត្ថុ ត្រូវពន្យល់ដល់អ្នកទិញឱ្យបានច្បាស់លាស់នូវខ្លឹមសារនៃសិទ្ធិ ការទទួលបន្ទុក និង ព្រំដែននៃអចលនវត្ថុ ជាអាទិ៍ ។

(កំណត់)

ដើម្បីជៀសវាងកុំឱ្យវិវាទកើតឡើងនាអនាគត គូភាគីគួរតែបង្កើតកិច្ចសន្យាលក់ទិញ ដោយយល់អំពីខ្លឹមសារចម្បងនៃកិច្ចសន្យានោះដោយត្រឹមត្រូវ ។ ក្នុងកិច្ចសន្យាលក់ទិញ ករណីយកិច្ចរបស់អ្នកទិញមានភាពច្បាស់លាស់ ដោយសារករណីយកិច្ចចម្បងនោះមានតែករណីយកិច្ចបង់ថ្លៃលក់ទិញប៉ុណ្ណោះ ។ ផ្ទុយទៅវិញ ករណីយកិច្ច និង ការទទួលខុសត្រូវរបស់អ្នកលក់អាចមានខ្លឹមសារផ្សេងៗ ហើយជាទូទៅ អ្នកលក់មានព័ត៌មានអំពីវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ ។ ហេតុដូច្នេះ មាត្រានេះតម្រូវឱ្យអ្នកលក់មានករណីយកិច្ចពន្យល់ ។ ប្រសិនបើអ្នកលក់បំពានករណីយកិច្ចពន្យល់នេះ អ្នកលក់នោះត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលបានកើតឡើងដោយសារការបំពាននោះ ។ លើសពីនេះទៀត ប្រសិនបើអ្នកលក់ពន្យល់ហេតុមិនពិត ឬ លាក់ហេតុពិត ដោយចេតនា ចំពោះចំណុចដែលមានឥទ្ធិពលលើការសម្រេចរបស់អ្នកទិញក្នុងការធ្វើ ឬ មិនធ្វើកិច្ចសន្យា ហើយជាលទ្ធផល នាំឱ្យអ្នកទិញភាន់ច្រឡំ និង ធ្វើកិច្ចសន្យាដោយផ្អែកលើការភាន់ច្រឡំនេះ អាចមានករណីដែលកិច្ចសន្យានោះត្រូវបានលុបចោលដោយយកការឆបោក ឬ ការភាន់ច្រឡំមកធ្វើជាមូលហេតុ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៦០២ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៥៣០**.- ករណីយកិច្ចទូទៅរបស់អ្នកលក់

អ្នកលក់មានករណីយកិច្ច ត្រូវផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលខ្លួនបានលក់ ត្រូវប្រគល់វត្ថុដែលបានលក់ ត្រូវថែរក្សាទុកនូវវត្ថុដែលបានលក់រហូតដល់ពេលប្រគល់ ព្រមទាំងត្រូវប្រគល់លិខិតផ្សេងៗដែលចាំបាច់ដើម្បីបញ្ជាក់នូវសិទ្ធិ ចំពោះអ្នកទិញ តាមកិច្ចសន្យា និង បញ្ញត្តិនៃក្រមនេះ ។

(កំណត់)

មាត្រានេះរៀបរាប់ករណីយកិច្ចទូទៅរបស់អ្នកលក់ ។ ចំពោះខ្លឹមសារលម្អិតនៃករណីយកិច្ចនីមួយៗនេះ មានបញ្ញត្តិចាប់ពីមាត្រា ៥៣១ ទៅ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៦០៣ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៥៣១**.- ករណីយកិច្ចត្រូវផ្ទេរសិទ្ធិ និង ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់

១-អ្នកលក់មានករណីយកិច្ចត្រូវផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការលក់ទិញទៅឱ្យអ្នកទិញ។

២-ប្រសិនបើកម្មវត្ថុនៃការលក់ទិញជាសិទ្ធិរបស់អ្នកដទៃ អ្នកលក់មានករណីយកិច្ចត្រូវទទួលសិទ្ធិនោះ ហើយត្រូវផ្ទេរសិទ្ធិនោះទៅឱ្យអ្នកទិញ ។

៣-ប្រសិនបើអ្នកលក់មិនអាចផ្ទេរសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញទៅឱ្យអ្នកទិញបានទេ អ្នកទិញអាចរំលាយកិច្ចសន្យាបាន ។ ក្នុងករណីនេះ ប្រសិនបើអ្នកទិញមិនបានដឹង នៅពេលធ្វើកិច្ចសន្យាថា សិទ្ធិនោះមិនមែនជាសិទ្ធិរបស់អ្នកលក់ទេ អ្នកទិញអាចទាមទារសំណងនៃការខូចខាតបាន ។

(កំណត់)

តាមមាត្រា ១៥៩៩ នៃក្រមរដ្ឋប្បវេណីបារាំង មាត្រា ១០១៩ នៃក្រមរដ្ឋប្បវេណីកម្ពុជាចាស់ ចែងថា ការលក់វត្ថុអ្នកដទៃ ត្រូវចាត់ទុកជាមោឃៈ ប៉ុន្តែ ក្រមថ្មីនេះចាត់ទុកថា ការលក់វត្ថុអ្នកដទៃមានសុពលភាព ដោយមានមូលហេតុដូចបានពន្យល់នៅក្នុងសេចក្តីកំណត់នៃមាត្រា ៥៣២ ។ ដោយយកចំណុចនេះមកធ្វើជាបុរេល័ក្ខខ័ណ្ឌ មាត្រានេះចែងថា អ្នកលក់មានករណីយកិច្ចត្រូវធ្វើលទ្ធកម្មនូវសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញនោះ ហើយផ្ទេរទៅឱ្យអ្នកទិញ ហើយចែងផងដែរអំពីការទទួលខុសត្រូវក្នុងករណីដែលករណីកិច្ចនេះមិនត្រូវបានអនុវត្ត (ការទទួលខុសត្រូវក្នុងការធានា) ។

ប្រសិនបើអ្នកលក់មិនអាចអនុវត្តករណីយកិច្ចផ្ទេរសិទ្ធិបានទេ ទោះបីជាអ្នកទិញបានដឹង នៅពេលធ្វើកិច្ចសន្យាថា អ្នកលក់មិនមែនជាកម្មសិទ្ធិករលើវត្ថុដែលជាកម្មសិទ្ធិក៏ដោយ ក៏អ្នកទិញនោះអាចទាមទារឱ្យរំលាយកិច្ចសន្យានេះបានដែរ (វាក្យខណ្ឌទី ១ កថាខណ្ឌទី ៣) ។ លើសពីនេះទៀត ក្នុងករណីដែលអ្នកទិញមានភាពសុចរិត (ពេលធ្វើកិច្ចសន្យាមិនបានដឹងថា អ្នកលក់គ្មានសិទ្ធិនោះ) ក្រៅពីសិទ្ធិរំលាយ អ្នកទិញទទួលសិទ្ធិទាមទារនូវសំណងនៃការខូចខាតផងដែរ (វាក្យខណ្ឌទី ២ កថាខណ្ឌទី ៣ នៃមាត្រានេះ) ។ ប៉ុន្តែ ប្រសិនបើករណីយកិច្ចផ្ទេរសិទ្ធមិនអាចអនុវត្តបាន ដោយសារ

អ្នកទិញមានហេតុដែលនាំឱ្យទទួលខុសត្រូវ នោះអ្នកលក់មិនត្រូវទទួលខុសត្រូវដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រានេះទេ ។

សិទ្ធិទាមទារនូវសំណងនៃការខូចខាតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រានេះ ត្រូវកើតឡើង ទោះបីជាអ្នកលក់មានហេតុដែលនាំឱ្យទទួលខុសត្រូវក៏ដោយ គ្មានក៏ដោយ ហេតុដូច្នេះ ជាគោលការណ៍ ទំហំនៃការខូចខាតដែលត្រូវសងសំណងនោះ មានត្រឹមតែការខូចខាតដែលអ្នកទិញបានទទួលដោយសារតែខ្លួនបានជឿជាក់ថា នឹងធ្វើលទ្ធកម្មនូវកម្មសិទ្ធិនោះដោយប្រសិទ្ធភាពតែប៉ុណ្ណោះ (ផលប្រយោជន៍ពីជំនឿ) ។ ប៉ុន្តែ ប្រសិនបើអ្នកលក់មានហេតុដែលនាំឱ្យទទួលខុសត្រូវ ដូចជាករណីដែលអ្នកលក់អាចធ្វើលទ្ធកម្មសិទ្ធិ ហើយផ្ទេរសិទ្ធិនោះទៅអ្នកលក់ ប៉ុន្តែ មិនបានធ្វើដូច្នេះដោយចេតនា ជាអាទិ៍ អ្នកទិញអាចទាមទារនូវការទទួលខុសត្រូវក្នុងការមិនអនុវត្តកាតព្វកិច្ច តាមបញ្ញត្តិចាប់ពីមាត្រា ៣៩៨ (ល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត) ទៅ ។ ក្នុងករណីនេះ អ្នកទិញអាចទាមទារនូវសំណងនៃផលប្រយោជន៍ពីការអនុវត្តបាន ។

ម្យ៉ាងទៀត មាត្រានេះ មិនមានបញ្ញត្តិពិសេសដែលកម្រិតនូវអំឡុងពេលដែលអាចអនុវត្តសិទ្ធិទេ ហេតុនេះហើយ អ្នកទិញអាចអនុវត្តសិទ្ធិរំលាយ នៅក្នុងអំឡុងពេលដែលកិច្ចសន្យាលក់ទិញមានអត្ថិភាព ហើយអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារនូវសំណងនៃការខូចខាតនេះ គឺ ៥ ឆ្នាំ ដែលជាអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៦០ និង មាត្រា ៥៦១ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៤៣ ដល់ មាត្រា ៤៩ នៃក្រឹត-ច្បាប់ លេខ ៣៨ ក្រ.ច, មាត្រា ១០១៩ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ១៥៩៩ និង មាត្រា ១៦២៦ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៤៣៤ ដល់ មាត្រា ៤៤៣ នៃក្រមរដ្ឋប្បវេណីអល្លឺម៉ង់

**មាត្រា ៥៣២.-** សិទ្ធិរំលាយកិច្ចសន្យារបស់អ្នកលក់សិទ្ធិអ្នកដទៃ

១-ប្រសិនបើអ្នកលក់មិនបានដឹងថា សិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញមិនមែនជារបស់ខ្លួន នៅពេលធ្វើកិច្ចសន្យាទេ ហើយមិនអាចទទួលយកសិទ្ធិនោះដើម្បីផ្ទេរទៅឱ្យអ្នកទិញបានទេ អ្នកលក់អាចរំលាយកិច្ចសន្យានោះបាន តែត្រូវសងការខូចខាត ។

២-ក្នុងករណីនៃកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើនៅពេលធ្វើកិច្ចសន្យា អ្នកទិញបានដឹងថា សិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញមិនមែនជាសិទ្ធិរបស់អ្នកលក់ទេ អ្នកលក់អាចរំលាយកិច្ចសន្យានោះបាន ដោយមិនចាំបាច់សងការខូចខាត ។

(កំណត់)

ឧទាហរណ៍ អ្នកលក់បានយល់ច្រឡំថា វត្ថុដែលជាកម្មវត្ថុនៃការលក់ជាកម្មសិទ្ធិរបស់ខ្លួន ប៉ុន្តែ តាមការពិត វត្ថុនោះ

ជារបស់អ្នកដទៃ ។ ក្នុងករណីនេះ ដូចដែលបានកំណត់នៅក្នុងមាត្រាមុននេះ អ្នកលក់មានករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនោះ ហើយផ្ទេរកម្មសិទ្ធិនោះទៅឱ្យអ្នកទិញ ។ ប៉ុន្តែ ប្រសិនបើមិនអាចធ្វើបានទេ អ្នកលក់អាចរំលាយកិច្ចសន្យាដើម្បីឱ្យរួចផុតពីករណីយកិច្ចផ្ទេរសិទ្ធិនោះបាន ដោយមានល័ក្ខខ័ណ្ឌសងនូវសំណងនៃការខូចខាតដែលខ្លួនត្រូវសង តាមបញ្ញត្តិនៃមាត្រា ៥៣១ មុននេះ ។ ប៉ុន្តែ ប្រសិនបើអ្នកទិញដឹងនៅពេលធ្វើកិច្ចសន្យាថា វត្ថុនោះជាកម្មសិទ្ធិរបស់តតិយជន (ទុច្ចរិត) អ្នកទិញមិនទទួលការខូចខាតដែលមកពីហេតុដែលវត្ថុនោះជាកម្មសិទ្ធិរបស់តតិយជនទេ ហេតុដូច្នេះ អ្នកលក់អាចរំលាយនូវកិច្ចសន្យាបាន ដោយមិនចាំបាច់សងនូវសំណងនៃការខូចខាត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៦២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៥៣៣.-** ការទទួលខុសត្រូវក្នុងការធានាចំពោះករណីដែលសិទ្ធិមួយភាគជាសិទ្ធិរបស់អ្នកដទៃ

១-ក្នុងករណីសិទ្ធិមួយភាគក្នុងចំណោមសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញ គឺជាសិទ្ធិរបស់អ្នកដទៃហើយបើអ្នកលក់មិនអាចទទួលសិទ្ធិនៃភាគនោះដើម្បីផ្ទេរទៅឱ្យអ្នកទិញបានទេ អ្នកទិញអាចទាមទារឱ្យបន្ថយនូវតម្លៃ តាមសមាមាត្រនៃភាគនោះបាន ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើ នៅពេលធ្វើកិច្ចសន្យា អ្នកទិញមិនបានដឹងថា ភាគខ្លះនោះមិនមែនជារបស់អ្នកលក់ទេ ហើយបើទទួលស្គាល់ថា អ្នកទិញនឹងមិនទិញតែភាគដែលសល់តែប៉ុណ្ណោះទេ អ្នកទិញនោះអាចរំលាយកិច្ចសន្យាបាន ។

៣-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ បើនៅពេលធ្វើកិច្ចសន្យា អ្នកទិញមិនបានដឹងថា សិទ្ធិមួយភាគនោះ មិនមែនជារបស់អ្នកលក់ទេ អ្នកទិញក៏អាចទាមទារសំណងនៃការខូចខាតបានដែរ ។

៤-សិទ្ធិដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះ ត្រូវអនុវត្តក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលអ្នកទិញបានដឹងការពិត ក្នុងករណីដែល នៅពេលធ្វើកិច្ចសន្យា អ្នកទិញមិនបានដឹងថា សិទ្ធិមួយភាគក្នុងចំណោមសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញ មិនមែនជារបស់អ្នកលក់ទេ ឬ គិតចាប់ពីពេលធ្វើកិច្ចសន្យាក្នុងករណីដែលអ្នកទិញបានដឹងថា សិទ្ធិមួយភាគក្នុងចំណោមសិទ្ធិដែលជាកម្មវត្ថុនៃការ

លក់ទិញមិនមែនជារបស់អ្នកលក់ នៅពេលធ្វើកិច្ចសន្យា ។

(កំណត់)

ក្នុងករណីសិទ្ធិមួយភាគក្នុងចំណោមសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញ គឺជាសិទ្ធិរបស់អ្នកដទៃ ហើយបើអ្នកលក់មិនអាចទទួលសិទ្ធិនៃភាគនោះដើម្បីផ្ទេរទៅឱ្យអ្នកទិញបានទេ ករណីនេះគឺជាការមិនអនុវត្តកាតព្វកិច្ចមួយភាគរបស់អ្នកលក់ ហេតុដូច្នេះ បញ្ញត្តិនៃមាត្រា ៥៣១ ត្រូវយកមកអនុវត្តចំពោះភាគដែលមិនត្រូវបានអនុវត្តនោះ ។ ប៉ុន្តែ ករណីនេះមិនមែនជាការមិនអនុវត្តកាតព្វកិច្ចទាំងស្រុងទេ ហេតុដូច្នេះ ការទទួលស្គាល់ឱ្យរំលាយកិច្ចសន្យាទាំងមូលដោយស្វ័យប្រវត្តិ មិនមានភាពសមរម្យទេ ។ អាស្រ័យហេតុនេះ មាត្រានេះចែងថា ជាគោលការណ៍ អ្នកទិញអាចទាមទារឱ្យបន្ថយនូវថ្លៃលក់ទិញ រហូតដល់តម្លៃនៃភាគដែលត្រូវបានផ្ទេរទៅអ្នកទិញនោះដោយមានសុពលភាព ហើយទទួលស្គាល់ករណីលើកលែងដែលអ្នកទិញអាចរំលាយកិច្ចសន្យាទាំងមូល តែក្នុងករណីដែលគោលបំណងក្នុងការធ្វើកិច្ចសន្យាលក់ទិញមិនអាចសម្រេចបាន ដោយភាគដែលត្រូវបានផ្ទេរទៅអ្នកទិញ ហើយអ្នកទិញមានភាពសុចរិតប៉ុណ្ណោះ ។ ម្យ៉ាងទៀត អ្នកទិញសុចរិតក៏អាចទាមទារសំណងនៃការខូចខាតផងដែរ ប៉ុន្តែ ក្នុងករណីដែលអ្នកទិញទាមទារទាំងការបន្ថយថ្លៃលក់ទិញ និងសំណងការខូចខាត អ្នកទិញមិនអាចទាមទារសំណងនៃការខូចខាត ចំពោះផលប្រយោជន៍ដែលអ្នកទិញអាចទទួលបានប្រសិនបើខ្លួនធ្វើលទ្ធកម្មសិទ្ធិទាំងមូល (ផលប្រយោជន៍ពីការអនុវត) បានទេ អាចទាមទារគ្រាន់តែសំណងនៃការខូចខាតចំពោះផលប្រយោជន៍ពីជំនឿប៉ុណ្ណោះ ដោយសារអ្នកទិញនោះមិនបានបង់ថ្លៃលក់ទិញជាថ្នូរនឹងសិទ្ធិទាំងមូល ។

កថាខណ្ឌទី ៤ កំណត់អំឡុងពេលសម្រាប់ប្រើសិទ្ធិទាមទារឱ្យបន្ថយថ្លៃលក់ទិញ សិទ្ធិរំលាយ និង សិទ្ធិទាមទារសំណងការខូចខាត ខ្លីជាងករណីធម្មតានៃការទទួលខុសត្រូវក្នុងការមិនអនុវត្តកាតព្វកិច្ច ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៦៤ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ៥៦២ និង មាត្រា ៥៦៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៦៣៦ និង មាត្រា ១៦៣៧ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៥៣៤.-** ការទទួលខុសត្រូវក្នុងការធានាក្នុងករណីដែលមានសិទ្ធិប្រត្យក្សជាផលុបភោគ ជាអាទិ៍

១-ក្នុងករណីដែលកម្មវត្ថុនៃការលក់ទិញភ្ជាប់ជាមួយសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យនៅ សេវភាព សិទ្ធិជួល សិទ្ធិឃាត់ទុក ឬ សិទ្ធិលើការបញ្ចាំសម្រាប់តតិយជន ហើយបើអ្នកទិញមិនអាចប្រើប្រាស់ ឬ ទទួល ផលពីកម្មវត្ថុទាំងមូល ឬ មួយផ្នែក ដោយសារអត្ថិភាពនៃសិទ្ធិនោះ អ្នកទិញដែលមិនបានដឹងអំពីអត្ថិភាពនៃសិទ្ធិនោះ

នៅពេលធ្វើកិច្ចសន្យា អាចទាមទារសំណងនៃការខូចខាតពីអ្នកលក់បាន ។[២]

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើគោលបំណងនៃកិច្ចសន្យាមិនអាចសម្រេចបាន ដោយសារអត្ថិភាពនៃសិទ្ធិនោះ អ្នកទិញដែលមិនបានដឹងអំពីអត្ថិភាពនៃសិទ្ធិនោះនៅពេលធ្វើកិច្ចសន្យា ក៏អាចរំលាយកិច្ចសន្យាបានដែរ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលសេវភាពដែលត្រូវមានសម្រាប់អចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ បែរជាគ្មានទៅវិញ ។

៤-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ទី ២ ឬ ទី ៣ ខាងលើនេះ ការរំលាយកិច្ចសន្យា ឬ ការទាមទារសំណងនៃការខូចខាត ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលអ្នកទិញបានដឹងការពិត ។

(កំណត់)

ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញភ្ជាប់ជាមួយសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យនៅ សេវភាព សិទ្ធិជួល សិទ្ធិឃាត់ទុក ឬ សិទ្ធិលើការបញ្ចាំ សម្រាប់តតិយជន ហើយបើអ្នកទិញមិនអាចប្រើប្រាស់ ឬ ទទួលផលពីកម្មវត្ថុទាំងមូល ឬ មួយផ្នែក ដោយសារអត្ថិភាពនៃសិទ្ធិនោះ មានទំនាក់ទំនងស្រដៀងគ្នានឹងករណីដែលសិទ្ធិមួយភាគ (តាមបរិមាណ) ជាសិទ្ធិរបស់អ្នកដទៃ ហេតុដូច្នេះ អ្នកលក់ត្រូវទទួលខុសត្រូវក្នុងការធានា ប្រហាក់ប្រហែលគ្នានឹងករណីដែលបានកំណត់នៅក្នុងមាត្រា ៥៣៣ ។

ក្នុងករណីដែលសេវភាពដែលត្រូវមានសម្រាប់អចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ បែរជាគ្មានទៅវិញ ក៏ដូចគ្នានឹងករណីដែលមានបន្ទុកនៃសិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល ត្រង់ចំណុចថា ការប្រើប្រាស់ និង អាស្រ័យផលដែលអ្នកទិញសង្ឃឹមចំពោះវត្ថុដែលជាកម្មវត្ថុ ត្រូវបានរារាំង ហេតុដូច្នេះ ត្រូវអនុលោមទៅតាមបញ្ញត្តិដូចគ្នា ។

កថាខណ្ឌទី ៤ ចែងអំពីអំឡុងពេលខ្លីសម្រាប់ប្រើសិទ្ធិ ដូចករណីដែលបានកំណត់នៅក្នុងមាត្រា ៥៣៣ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៦៦ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៦៣៦ និង មាត្រា ១៦៣៨ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៥៣៥.-** ការទទួលខុសត្រូវក្នុងការធានា ក្នុងករណីដែលមានសិទ្ធិប្រាតិភោគប្រត្យក្ស

---

[២] កថាខណ្ឌទី ១ នៃមាត្រា ៥៣៤ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

១-ក្នុងករណីដែលមានឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំដែលកំណត់ថា ម្ចាស់បំណុល មិនប្រើប្រាស់ និង អាស្រ័យផល ឬ មានហ៊ីប៉ូតែកដែលបានដាក់លើអចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ នៅពេលដែលអ្នកទិញបានបាត់បង់កម្មសិទ្ធិលើអចលនវត្ថុនោះដោយសារសិទ្ធិប្រាតិភោគប្រត្យក្សនោះត្រូវបានអនុវត្ត អ្នកទិញអាចរំលាយកិច្ចសន្យាបាន ។

២-ក្នុងករណីដែលអ្នកទិញបានធ្វើការចំណាយដើម្បីរក្សាកម្មសិទ្ធិ អ្នកទិញអាចទាមទារឱ្យអ្នកលក់សងថ្លៃចំណាយនោះមកវិញបាន ។

៣-ក្នុងករណីណាមួយដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ ប្រសិនបើអ្នកទិញបានទទួលការខូចខាត អ្នកទិញអាចទាមទារសំណងនៃការខូចខាតនោះបាន ។

៤-ប្រសិនបើអ្នកទិញ បានទិញអចលនវត្ថុដែលភ្ជាប់សិទ្ធិប្រាតិភោគប្រត្យក្សដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងតម្លៃដែលបានដកចេញនូវចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគប្រត្យក្សនោះរួចហើយ អ្នកទិញនោះពុំមានសិទ្ធិដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះឡើយ ។

(កំណត់)

អត្ថិភាពនៃសិទ្ធិប្រាតិភោគដែលម្ចាស់សិទ្ធិប្រាតិភោគមិនកាន់កាប់វត្ថុដែលជាកម្មវត្ថុ មិនរារាំងការប្រើប្រាស់ និង អាស្រ័យផលពីវត្ថុដែលជាកម្មវត្ថុនោះ ប៉ុន្តែ ប្រសិនបើសិទ្ធិប្រាតិភោគនោះត្រូវបានអនុវត្ត អ្នកទិញត្រូវបាត់បង់កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនោះ ។ ប្រសិនបើអ្នកទិញបានទិញអចលនវត្ថុក្នុងតម្លៃដែលដកចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគនោះពីតម្លៃនៃអចលនវត្ថុ អ្នកទិញនោះមិនទទួលការខូចខាតអ្វីទេ ប៉ុន្តែ ប្រសិនបើអ្នកទិញនោះបានទិញអចលនវត្ថុនោះ ដោយយកការរំលត់សិទ្ធិប្រាតិភោគនោះ ដោយការសងចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយអ្នកលក់ ជាអាទិ៍ មកធ្វើជាបុរេល័ក្ខខ័ណ្ឌ អ្នកទិញនោះនឹងទទួលការខូចខាតដែលខ្លួនមិនអាចព្យាករបាន ដោយសារការបាត់បង់កម្មសិទ្ធិដោយកាអនុវត្តសិទ្ធិប្រាតិភោគ ។ ដើម្បីសម្របសម្រួលផលប្រយោជន៍រវាងអ្នកលក់ និង អ្នកទិញនៅក្នុងករណីនេះ មាត្រានេះចែងអំពីវិធីសង្គ្រោះដូចជាការរំលាយកិច្ចសន្យា ការសងថ្លៃចំណាយមកវិញ និង ការទាមទារសំណងការខូចខាត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៦៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៥៣៦**.- ការទទួលខុសត្រូវក្នុងការធានាក្នុងការលក់ដោយបង្ខំ

១-អ្នកដែលបានទិញតាមរយៈការលក់ដោយបង្ខំ អាចរំលាយកិច្ចសន្យាចំពោះកូនបំណុល ឬ ទាមទារឱ្យបន្ថយតម្លៃបាន ដោយអនុលោមទៅតាមបញ្ញត្តិពីមាត្រា ៥៣១ (ករណីយកិច្ចត្រូវផ្ទេរសិទ្ធិ និង ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់) ដល់មាត្រា ៥៣៥ (ការទទួលខុសត្រូវក្នុងការធានា ក្នុងករណីដែលមានសិទ្ធិប្រាតិភោគប្រត្យក្ស) នៃក្រមនេះ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើកូនបំណុលស្ថិតក្នុងភាពអសាធនីយ អ្នកទិញអាចទាមទារឱ្យម្ចាស់បំណុលដែលបានទទួលចំណែកនៃថ្លៃលក់ សងប្រាក់ដែលបានមកពីការលក់នោះទាំងអស់ ឬ មួយភាគវិញបាន ។

៣-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ ប្រសិនបើកូនបំណុលបានដឹងអំពីអត្ថិភាពនៃហេតុ ដែលក្លាយជាមូលហេតុនៃការទទួលខុសត្រូវក្នុងការធានា ហើយមិនបានជូនដំណឹងទៅស្ថាប័នដែលអនុវត្តការលក់ដោយបង្ខំទេ ឬ ម្ចាស់បំណុលបានដឹងហើយ តែនៅតែទាមទារឱ្យលក់ដោយបង្ខំ អ្នកទិញអាចទាមទារនូវសំណងនៃការខូចខាតពីអ្នកទាំងនោះបាន ។

(កំណត់)

ក្នុងករណីនៃការលក់ដោយបង្ខំ វត្ថុដែលជាកម្មវត្ថុត្រូវបានលក់ដោយផ្ទុយនឹងឆន្ទៈរបស់កូនបំណុល ហេតុដូច្នេះ ត្រូវគិតពិចារណាអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការតម្រូវឱ្យកូនបំណុល (កម្មសិទ្ធិករនៃវត្ថុដែលជាកម្មវត្ថុ ជាអាទិ៍) ទទួលខុសត្រូវ ដូចគ្នានឹងការទទួលខុសត្រូវរបស់អ្នកលក់នៅក្នុងករណីនៃការលក់ទិញធម្មតា ។ ប៉ុន្តែ ចំពោះអ្នកទិញវិញ គ្មានមូលហេតុអ្វីក្នុងការទទួលការចាត់ចែងផ្សេងពីអ្នកទិញនៅក្នុងការលក់ទិញដោយស្ម័គ្រចិត្ត ដោយសារគ្មានភាពខុសគ្នាត្រង់ចំណុចថា មិនបានធ្វើលទ្ធកម្មនូវសិទ្ធិដែលខ្លួនសង្ឃឹមថា អាចទទួលបាន ។ ម្យ៉ាងទៀត ប្រសិនបើវត្ថុ ឬ សិទ្ធិដែលមានវិការៈ ត្រូវបានលក់ក្នុងតម្លៃនៃវត្ថុដែលគ្មានវិការៈ ហើយប្រាក់ដែលបានមកពីការលក់ ត្រូវបានចែកចំណែកឱ្យទៅម្ចាស់បំណុល កូនបំណុលនឹងទទួលផលប្រយោជន៍ហួសហេតុ (ការរលត់កាតព្វកិច្ច) ហេតុដូច្នេះ ការតម្រូវឱ្យកូនបំណុលទទួលខុសត្រូវក្នុងការធានា ដូចអ្នកលក់នៅក្នុងករណីនៃការលក់ទិញដោយស្ម័គ្រចិត្ត មានសមភាពផងដែរ ។ ក្នុងករណីនេះ ផលប្រយោជន៍ដែលបានមកពីហេតុដែលវត្ថុ ឬ សិទ្ធិនោះត្រូវបានលក់ក្នុងតម្លៃថ្លៃហួសហេតុ ត្រូវបានទទួលដោយប្រយោល ដោយម្ចាស់បំណុលដែលបានទទួលការចែកចំណែក ហេតុដូច្នេះ មាត្រានេះចែងថា ប្រសិនបើកូនបំណុលស្ថិតនៅក្នុងស្ថានភាពអសាធនីយ អ្នកទិញអាចទាមទារឱ្យម្ចាស់បំណុលដែលបានទទួលចំណែកនៃថ្លៃលក់ សងផលប្រយោជន៍នោះ ។

ម្យ៉ាងទៀត មាត្រានេះតម្រូវឱ្យម្ចាស់បំណុលដែលបានដាក់ពាក្យសុំឱ្យលក់ដោយបង្ខំ ដោយដឹងអំពីអត្ថិភាពនៃវិការៈ ទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាតផងដែរ ។

ម្យ៉ាងទៀត មាត្រានេះចែងថា បញ្ញត្តិស្ដីពីការទទួលខុសត្រូវក្នុងការធានា ក្នុងករណីដែលមានវិការៈនៃសិទ្ធិ ចំពោះវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ (ការទទួលខុសត្រូវក្នុងការធានាក្នុងករណីដកហូតសិទ្ធិ garantie d'éviction) (មាត្រា ៥៣១ ដល់មាត្រា ៥៣៥) ត្រូវយកមកអនុវត្តចំពោះករណីនៃការលក់ដោយបង្ខំ ប៉ុន្តែ បញ្ញត្តិនៃមាត្រានេះ មិនមានន័យថា បញ្ញត្តិនៃមាត្រា ៥៤០ អំពីការទទួលខុសត្រូវក្នុងការធានាវិការៈនៃវត្ថុ មិនត្រូវយកមកអនុវត្តនោះឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៦៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៥៣៧.-** ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់សិទ្ធិលើបំណុល

១-អ្នកលក់សិទ្ធិលើបំណុលត្រូវទទួលខុសត្រូវចំពោះអត្ថិភាពនៃសិទ្ធិលើបំណុលនោះ ។

២-ក្នុងករណីដែលអ្នកលក់សិទ្ធិលើបំណុលបានធានាសាធនភាពរបស់កូនបំណុលនោះត្រូវសន្មតថា បានធានាសាធនភាពរបស់កូនបំណុលដែលមាននៅពេលធ្វើកិច្ចសន្យានោះ ។

៣-ក្នុងករណីដែលអ្នកលក់សិទ្ធិលើបំណុលដែលមិនទាន់ដល់ពេលកំណត់ត្រូវសង បានធានាសាធនភាពអនាគតរបស់កូនបំណុល នោះត្រូវសន្មតថា បានធានាសាធនភាពរបស់កូនបំណុលនៅពេលកំណត់ត្រូវសង ។

(កំណត់)

អ្នកលក់សិទ្ធិលើបំណុល ត្រូវទទួលខុសត្រូវចំពោះអត្ថិភាពនៃសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញ ប៉ុន្តែ ជាគោលការណ៍មិនត្រូវទទួលខុសត្រូវអំពីហេតុដែលកូនបំណុលធ្វើ ឬ មិនធ្វើការសងជាក់ស្តែងចំពោះសិទ្ធិលើបំណុលនោះ ។ ក្នុងករណីដែលអ្នកលក់បានធានាសាធនភាពរបស់កូនបំណុលនៅក្នុងកិច្ចសន្យាលក់ទិញ ជាធម្មតា គេអាចគិតថា អ្នកលក់គ្រាន់តែធានាសាធនភាពរបស់កូនបំណុលនៅពេលធ្វើកិច្ចសន្យាប៉ុណ្ណោះ ហើយអ្នកលក់នោះគ្មានឆន្ទៈទទួលខុសត្រូវចំពោះការផ្លាស់ប្តូរសាធនភាពនៅពេលក្រោយ ហេតុដូច្នេះ បញ្ញត្តិសន្មតដូច្នោះ ត្រូវបានរៀបចំឡើង ។ ប៉ុន្តែ ក្នុងករណីដែលអ្នកលក់សិទ្ធិលើបំណុលដែលមិនទាន់ដល់ពេលកំណត់ត្រូវសង បានធានាសាធនភាពអនាគតរបស់កូនបំណុល នោះត្រូវសន្មតថាអ្នកលក់មានឆន្ទៈធានាសាធនភាពរបស់កូនបំណុលនៅពេលកំណត់ត្រូវសង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៦៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៥៣៨**.- ការព្រមព្រៀងគ្នាក្នុងការអនុគ្រោះ ឬ កម្រិតនូវការទទួលខុសត្រូវក្នុងការធានា

ទោះបីជាមានការព្រមព្រៀងគ្នាក្នុងការអនុគ្រោះ ឬ កម្រិតនូវការទទួលខុសត្រូវក្នុងការធានាដែលអ្នកលក់ត្រូវមាន តាមបញ្ញត្តិពីមាត្រា ៥៣១ (ករណីយកិច្ចត្រូវផ្ទេរសិទ្ធិ និង ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់) ដល់មាត្រា ៥៣៧ (ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់សិទ្ធិលើបំណុល) នៃក្រមនេះ ក៏ដោយ ក៏អ្នកលក់មិនអាចរួចផុតពីការទទួលខុសត្រូវបានដែរ ចំពោះហេតុការណ៍ដែលអ្នកលក់បានដឹងតែមិនបានផ្តល់ដំណឹង ឬ សិទ្ធិដែលខ្លួនបានបង្កើតសម្រាប់តតិយជន ឬ បានធ្វើអនុប្បទានទៅតតិយជន ។

(កំណត់)

បញ្ញត្តិចាប់ពីមាត្រា ៥៣១ ដល់ មាត្រា ៥៣៧ ដែលបានចែងអំពីការទទួលខុសត្រូវក្នុងការធានា គឺជាបញ្ញត្តិដែលមិនត្រូវអនុវត្តដាច់ខាតទេ ហើយការសន្យាពិសេសដែលបន្ថយ ឬ អនុគ្រោះការទទួលខុសត្រូវនេះ មានសុពលភាព ។ ប៉ុន្តែ ក្នុងករណីដែលអ្នកលក់ដឹងអំពីអត្ថិភាពនៃវិការៈ តែមិនបានផ្តល់ដំណឹង ឬ ក្នុងករណីដែលអ្នកលក់បង្កើតវិការៈដោយផ្ទាល់ខ្លួន ការរួចផុតពីការទទួលខុសត្រូវដោយយកការព្រមព្រៀងអំពីបន្ថយ ឬ អនុគ្រោះការទទួលខុសត្រូវក្នុងការធានាមកធ្វើជាមូលហេតុ មិនត្រូវបានអនុញ្ញាតឡើយ ដោយសារផ្ទុយនឹងគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៧២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៦២៧ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៥៣៩**.- ករណីយកិច្ចផ្តល់វត្ថុដែលគ្មានវិការៈ

១-អ្នកលក់ត្រូវមានករណីយកិច្ចប្រគល់វត្ថុដែលគ្មានវិការៈឱ្យទៅអ្នកទិញ ។

២-លើកលែងតែគូភាគីបានកំណត់ផ្សេង វត្ថុដែលបានប្រគល់ឱ្យទៅអ្នកទិញមានលក្ខណៈណាមួយដូចខាងក្រោមនេះ ត្រូវបានចាត់ទុកថា មានវិការៈ :

ក-វត្ថុនោះមានភាពមិនស្របនឹងចំនួន គុណភាព និង លក្ខណៈដែលបានកំណត់ក្នុងកិច្ចសន្យា ។

ខ-វត្ថុនោះមានភាពផ្សេងពីគំរូដែលអ្នកលក់បានបង្ហាញឱ្យអ្នកទិញមើលចំពោះចំនួន គុណភាព និង លក្ខណៈ ។

គ-វត្ថុនោះមិនស្របនឹងវិធីប្រើដែលអ្នកលក់ត្រូវបានបង្ហាញ ដោយជាក់លាក់ ឬដោយតុណ្ហីភាព នៅពេលធ្វើកិច្ចសន្យា ។[៣]

ឃ-វត្ថុនោះមិនស្របនឹងវិធីប្រើធម្មតានៃវត្ថុប្រភេទដូចគ្នា ។

ង-វត្ថុនោះមិនត្រូវបានខ្ចប់តាមវិធីធម្មតានៃការខ្ចប់វត្ថុប្រភេទដូចគ្នា ឬ តាមវិធីសមរម្យដើម្បីការពារវត្ថុនោះ ។

(កំណត់)

ដោយយោងទៅតាមមាត្រា ៣៥ នៃអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទិញទំនិញជាអន្តរជាតិ (United Nations Convention on Contracts for the International Sale of Goods, CISG) ទោះបីជាវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញនោះជាវត្ថុកំណត់ជាក់លាក់ដែលមិនអាចមានរបស់ជំនួសក៏ដោយ វត្ថុដែលមិនបានកំណត់ជាក់លាក់ក៏ដោយ ក៏អ្នកលក់មានករណីយកិច្ចប្រគល់នូវវត្ថុដែលគ្មានវិការៈទៅឱ្យអ្នកទិញដែរ ។ ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុមានវិការៈ ទោះបីជាអ្នកលក់មានហេតុដែលនាំឱ្យមានការទទួលខុសត្រូវក៏ដោយ គ្មានក៏ដោយ ក៏អ្នកទិញអាចទាមទារឱ្យអ្នកលក់អនុវត្តពេញលេញ ឱ្យរំលាយកិច្ចសន្យា និង/ឬ ឱ្យបន្ថយនូវតម្លៃទិញ តាមបញ្ញត្តិចាប់ពីមាត្រាខាងក្រោមទៅបានដែរ ។ ក្នុងករណីដែលអ្នកលក់មានហេតុដែលនាំឱ្យមានការទទួលខុសត្រូវ អ្នកលក់នោះត្រូវទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត ដោយសារការមិនអនុវត្តកាតព្វកិច្ចផងដែរ ដោយយោងតាមមាត្រា ៣៩៨ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៥ នៃ អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទិញទំនិញជាអន្តរជាតិ (United Nations Convention on Contracts for the International Sale of Goods, CISG), មាត្រា ៥៧០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៥៤០**.- ការទទួលខុសត្រូវក្នុងការធានាវិការៈ

១-នៅពេលដែលហានិភ័យត្រូវផ្ទេរទៅអ្នកទិញ បើវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញមានវិការៈ ទោះបីជាវិការៈនេះត្រូវបានដឹងច្បាស់នៅក្រោយពេលដែលហានិភ័យត្រូវបានផ្ទេរក៏ដោយ ក៏អ្នកលក់ត្រូវទទួលខុសត្រូវក្នុងការប្រគល់វត្ថុជំនួស ការជួសជុលវិការៈ ការរំលាយកិច្ចសន្យា ឬ ការបន្ថយនូវតម្លៃ ស្របតាមកិច្ចសន្យា និង បញ្ញត្តិនៃក្រមនេះដែរ ។

២-ទោះបីជាវិការៈកើតឡើងនៅក្រោយពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ប្រសិនបើវិការៈនោះបានកើតឡើងដោយសារអ្នកលក់ធ្វើខុសនឹងករណីយកិច្ច

---

[៣] ចំណុច គ កថាខណ្ឌទី ២ នៃមាត្រា ៥៣៩ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

របស់ខ្លួន ក៏អ្នកលក់ត្រូវទទួលខុសត្រូវក្នុងការធានាវិការៈ ដូចបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះដែរ ។

៣-ក្នុងករណីដែលអ្នកលក់ធានាថា វត្ថុដែលជាកម្មវត្ថុនៃការលក់នោះត្រូវស្រប នឹងគោលបំណងធម្មតា ឬ គោលបំណងពិសេស ក្នុងអំឡុងពេលដែលបានកំណត់ក្រោយពីការប្រគល់ ឬ ធានាថា វត្ថុដែលជាកម្មវត្ថុនោះត្រូវរក្សាទុកនូវគុណភាពពិសេស ឬ លក្ខណៈពិសេសផងដែល ក្នុងអំឡុងពេលដែលបានកំណត់ក្រោយពីការប្រគល់ ហើយបើមានការបំពានលើការធានានោះ អ្នកលក់ត្រូវទទួលខុសត្រូវក្នុងការធានាវិការៈដូចគ្នាដែរ ។

៤-ក្នុងករណីដែលអ្នកទិញបានដឹង ឬ មិនបានដឹងដោយសារកំហុសធ្ងន់ធ្ងររបស់ខ្លួនអំពីវិការៈនៃវត្ថុដែលជាកម្មវត្ថុនោះ នៅពេលធ្វើកិច្ចសន្យាលក់ទិញ អ្នកលក់មិនត្រូវទទួលខុសត្រូវក្នុងការធានាវិការៈនោះទេ ។

(កំណត់)

ការវិនិច្ឆ័យថា មាន ឬ គ្មានវិការៈ ត្រូវធ្វើតាមមាត្រា ៣៦ និង កថាខណ្ឌទី ៣ នៃមាត្រា ៣៥ នៃអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទិញទំនិញជាអន្តរជាតិ (CISG) ដោយយកពេលផ្ទេរហានិភ័យ (ពេលប្រគល់វត្ថុដែលជាកម្មវត្ថុ) មកធ្វើជាមូលដ្ឋាន គឺមិនមែនយកពេលធ្វើកិច្ចសន្យា មកធ្វើជាមូលដ្ឋានទេ (ដោយមិនបែងចែកថា ជាអលទ្ធភាពតាំងពីដំបូង ឬ ជាអលទ្ធភាពក្រោយពេលធ្វើកិច្ចសន្យាទេ) ។ ហេតុដូច្នេះ បញ្ញត្តិនៃមាត្រានេះ ត្រូវយកមកអនុវត្តមិនមែនតែចំពោះវិការៈដែលមានអត្ថិភាពនៅពេលធ្វើកិច្ចសន្យាប៉ុណ្ណោះទេ ព្រមទាំងចំពោះវិការៈដែលកើតឡើងក្នុងអំឡុងពេលក្រោយពេលធ្វើកិច្ចសន្យា រហូតដល់ប្រគល់វត្ថុដែលជាកម្មវត្ថុផងដែរ ។ ម្យ៉ាងទៀត ការវិនិច្ឆ័យថា អ្នកទិញមានភាពសុចរិត ឬ ទុច្ចរិតវិញ (វិការៈជា "វិការៈកំបាំង" ឬ មិនមែន) ត្រូវធ្វើដោយយកពេលដែលធ្វើកិច្ចសន្យាមកធ្វើជាមូលដ្ឋាន ។

ចំពោះកថាខណ្ឌទី ១ មានឧទាហរណ៍ដូចជា អ្នកលក់បានប្រគល់មាន់ដែលមានផ្ទុកជម្ងឺឆ្លង តែមិនទាន់កើតជម្ងឺនៅឡើយទៅឱ្យអ្នកទិញ ហើយក្រោយពីបានប្រគល់ មាន់នោះកើតជម្ងឺឆ្លង ហើយបានឆ្លងទៅមាន់ផ្សេងទៀត ជាអាទិ៍ ។ មានន័យថា វិការៈដែលមានអត្ថិភាពនៅមុនពេលប្រគល់ បានចេញជាក់លាក់ ក្រោយពេលប្រគល់ ។

ប្រសិនបើអ្នកទិញបានដឹងជាមុនថា វត្ថុដែលជាកម្មវត្ថុទិញនោះមានវិការៈ ខ្លួនច្បាស់ជាបានទិញក្នុងតម្លៃថោកជាងធម្មតា ហេតុដូច្នេះ អ្នកទិញនោះមិនអាចទាមទារឱ្យអ្នកលក់ទទួលខុសត្រូវក្នុងការធានានូវវិការៈនោះបានទេ ។ ការបញ្ជាក់អំពីភាពទុច្ចរិតរបស់អ្នកទិញ ជាការពិបាកណាស់ ហេតុដូច្នេះ ក្នុងករណីដែលអ្នកទិញមិនបានដឹងអំពីវិការៈនោះដោយកំហុសធ្ងន់ធ្ងរ ក៏មិនអាចទាមទារឱ្យអ្នកលក់ទទួលខុសត្រូវក្នុងការធានាវិការៈនេះដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣៦ និង កថាខណ្ឌទី ៣ នៃមាត្រា ៣៥ នៃ អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទិញទំនិញជាអន្តរជាតិ (United Nations Convention on Contracts for the International Sale of Goods, CISG), មាត្រា ៥៧០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៥៤១**.- សិទ្ធិជួសជុលរបស់អ្នកលក់

១-ក្នុងករណីដែលអ្នកលក់ប្រគល់វត្ថុដែលមានវិការៈមុនពេលកំណត់ត្រូវប្រគល់ អ្នកលក់នោះអាចជួសជុលវិការៈរហូតដល់ពេលកំណត់នោះបាន លុះត្រាតែមិនបណ្តាលឱ្យខូចខាតផលប្រយោជន៍ហួសហេតុដល់អ្នកទិញ ។ ប៉ុន្តែ អ្នកទិញមិនត្រូវបានរារាំងក្នុងការអនុវត្តសិទ្ធិទាមទារសំណងនៃការខូចខាតឡើយ ។

២-ទោះបីជាក្រោយពេលកំណត់ត្រូវប្រគល់ក៏ដោយ អ្នកលក់អាចជួសជុលវិការៈទាំងអស់ដោយចេញចំណាយដោយខ្លួនឯងបាន លុះត្រាតែមិនបណ្តាលឱ្យមានការខូចខាតផលប្រយោជន៍ហួសហេតុដល់អ្នកទិញ ។ ប៉ុន្តែ អ្នកទិញមិនត្រូវបានរារាំងក្នុងការអនុវត្តសិទ្ធិរំលាយ និង សិទ្ធិទាមទារសំណងនៃការខូចខាតឡើយ ។

**មាត្រា ៥៤២**.- សិទ្ធិទាមទារឱ្យអនុវត្តពេញលេញរបស់អ្នកទិញ

១-អ្នកទិញអាចទាមទារឱ្យអ្នកលក់អនុវត្តករណីយកិច្ចបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកទិញទាមទារការសង្គ្រោះដែលមិនសមស្របនឹងការទាមទារឱ្យអនុវត្តករណីយកិច្ចនោះ ។

២-ក្នុងករណីដែលកម្មវត្ថុនៃការលក់ទិញមានវិការៈ អ្នកទិញអាចទាមទារឱ្យអ្នកលក់ប្រគល់វត្ថុជំនួសដែលគ្មានវិការៈបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការរៀបចំវត្ថុដែលមានប្រភេទដូចគ្នា ដោយអ្នកលក់នឹងបង្កើតបន្ទុកមិនសមរម្យហួសហេតុ ដោយគិតពិចារណានូវកាលៈទេសៈជុំវិញទាំងឡាយ ។

៣-ក្នុងករណីដែលកម្មវត្ថុនៃការលក់ទិញមានវិការៈ អ្នកទិញអាចទាមទារឱ្យអ្នកលក់ជួសជុលវត្ថុដែលជាកម្មវត្ថុនោះបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការជួសជុលវត្ថុដែលជាកម្មវត្ថុដោយអ្នកលក់ នឹងបង្កើតបន្ទុកមិនសមរម្យហួសហេតុ ដោយគិតពិចារណានូវកាលៈទេសៈជុំវិញទាំងឡាយ ។

៤-អ្នកទិញអាចកំណត់អំឡុងពេលសមរម្យបន្ថែមដើម្បីឱ្យអ្នកលក់អនុវត្តករណីយកិច្ចបាន ។ អ្នកទិញមិនអាចទាមទារការសង្គ្រោះចំពោះការបំពានកិច្ចសន្យាក្នុងអំឡុងពេលនេះទេ លើកលែងតែករណីដែលអ្នកទិញទទួលដំណឹងពីអ្នកលក់ថា អ្នកលក់មិនអនុវត្តករណីយកិច្ចរបស់ខ្លួនក្នុងអំឡុងពេលនោះ ។ ប៉ុន្តែ អ្នកទិញមិនត្រូវបាត់បង់សិទ្ធិទាមទារសំណងការខូចខាតដែលបានកើតឡើងដោយសារការយឺតយ៉ាវក្នុងការអនុវត្តករណីយកិច្ច តាមពេលកំណត់ដើមទេ ។

(កំណត់)

ការ "ទាមទារការសង្គ្រោះដែលមិនសមស្របនឹងការទាមទារឱ្យអនុវត្តករណីយកិច្ចនោះ" នៅក្នុងកថាខណ្ឌទី ១ មានន័យថា ការទាមទារឱ្យរំលាយ ឬ ឱ្យបន្ថយនូវតម្លៃលក់ ។

**មាត្រា ៥៤៣**.- សិទ្ធិរំលាយកិច្ចសន្យារបស់អ្នកទិញ

ក្នុងករណីដែលអ្នកទិញមិនអាចសម្រេចគោលបំណងនៃកិច្ចសន្យាលក់ទិញបាន ដោយសារវត្ថុដែលត្រូវបានប្រគល់មានវិការៈ អ្នកទិញនោះអាចរំលាយកិច្ចសន្យានោះបាន ។

(កំណត់)

ឧទាហរណ៍ ក្នុងករណីនៃការលក់ទិញគ្រឿងចក្រ (ម៉ូតូ) ប្រសិនបើគ្រឿងចក្រនោះមានកម្លាំងខ្សោយជាងល័ក្ខខ័ណ្ឌដែលមានក្នុងកិច្ចសន្យា ហើយអ្នកទិញមិនអាចប្រើតាមបំណងរបស់ខ្លួនបានទេ នោះអ្នកទិញអាចរំលាយកិច្ចសន្យាលក់ទិញនេះតាមមាត្រានេះ ហើយអាចទៅទិញគ្រឿងចក្រដែលមានគុណភាពល្អពីអ្នកផ្សេងវិញ ដោយមិនចាំបាច់ប្រើពេលវេលាវែងដើម្បីជួសជុលគ្រឿងចក្រនោះ ។

**មាត្រា ៥៤៤**.- សិទ្ធិទាមទារឱ្យបន្ថយថ្លៃលក់របស់អ្នកទិញ

ក្នុងករណីវត្ថុដែលត្រូវបានប្រគល់មានវិការៈ ទោះបីជាថ្លៃលក់ត្រូវបានបង់រួចហើយក៏ដោយ ឬ មិនទាន់បង់ក៏ដោយ ក៏អ្នកទិញអាចទាមទារបន្ថយថ្លៃលក់នោះ តាមសមាមាត្រនៃភាពខុសគ្នានៅពេលប្រគល់រវាងតម្លៃនៃវត្ថុដែលគ្មានវិការៈ និង តម្លៃនៃវត្ថុដែលត្រូវបានប្រគល់បានដែរ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកលក់ជួសជុលវិការៈនោះដោយស្របទៅតាមមាត្រា ៥៤២ (សិទ្ធិទាមទារឱ្យអនុវត្តពេញលេញរបស់អ្នកទិញ) នៃក្រមនេះ ឬ ករណីដែលអ្នកទិញមិនព្រមទទួលសេចក្តីស្នើផ្តល់ការជួសជុលរបស់អ្នកលក់ដោយគ្មាន

មូលហេតុត្រឹមត្រូវ នោះអ្នកទិញមិនអាចទាមទារឱ្យបន្ថយថ្លៃលក់បានឡើយ ។

(កំណត់)

ជាឧទាហរណ៍ ភាគីបានធ្វើកិច្ចសន្យាលក់ទិញនូវវត្ថុមួយតម្លៃ ១ ម៉ឺនរៀល ដោយយកហេតុដែលគ្មានវិការៈមកធ្វើជាមូលដ្ឋាន ប៉ុន្តែ តាមការពិតទៅ វត្ថុនោះមានវិការៈកំបាំងវិញ ហើយមានតម្លៃតែ ៨ ពាន់រៀលប៉ុណ្ណោះ ។ ក្នុងករណីនេះ ទោះបីជាអ្នកលក់មានហេតុ ឬ គ្មានហេតុដែលនាំឱ្យមានការទទួលខុសត្រូវក៏ដោយ ក៏អ្នកទិញអាចទាមទារឱ្យបន្ថយថ្លៃលក់មកត្រឹម ៨ ពាន់រៀលបានដែរ (ប្រសិនបើអ្នកទិញបានបង់ថ្លៃទិញហើយ អាចទាមទារឱ្យអ្នកលក់សង ២ ពាន់រៀលវិញបាន) ។ ប៉ុន្តែ ក្នុងករណីដែលអ្នកលក់បានជួសជុលវិការៈវិញ ថ្លៃលក់មិនត្រូវចុះបន្ថយទេ ។ ក្នុងករណីដែលអ្នកទិញបានប្រកែកមិនឱ្យអ្នកលក់ជួសជុលវិការៈវិញ ដោយគ្មានហេតុផលត្រឹមត្រូវ ក៏មិនអាចបន្ថយតម្លៃបានដែរ ។

**មាត្រា ៥៤៥**.- សិទ្ធិទាមទារសំណងនៃការខូចខាតរបស់អ្នកទិញ

អ្នកទិញមិនត្រូវបានរារាំងក្នុងការទាមទារសំណងនៃការខូចខាតដោយស្របទៅតាមបញ្ញត្តិនៃផ្នែកទី ៣ (សំណងនៃការខូចខាត) ជំពូកទី ៤ នៃគន្ថីទី ៤ ដោយមិនអនុវត្ត ឬ ដោយអនុវត្តព្រមគ្នានូវសិទ្ធិដែលបានកំណត់នៅក្នុងបញ្ញត្តិពីមាត្រា ៥៤២ (សិទ្ធិទាមទារឱ្យអនុវត្តពេញលេញរបស់អ្នកទិញ) ដល់មាត្រា ៥៤៤ (សិទ្ធិទាមទារឱ្យបន្ថយថ្លៃលក់របស់អ្នកទិញ) នៃក្រមនេះទេ ។

**មាត្រា ៥៤៦**.- បញ្ញត្តិពិសេសស្តីពីដីដែលមានទំហំខ្វះ ឬ លើស

១-ចំពោះដីដែលបានកំណត់ជាក់លាក់ណាមួយ ក្នុងករណីដែលការលក់ទិញត្រូវបានធ្វើឡើងដោយបញ្ជាក់ទំហំ និង កំណត់នូវតម្លៃតាមខ្នាតដីច្បាស់លាស់ តែតាមការពិតទំហំដីដែលមាននោះមិនគ្រប់នឹងទំហំដែលបានបញ្ជាក់ អ្នកទិញអាចទាមទារឱ្យអ្នកលក់ផ្តល់តាវកាលិកនូវផ្នែកដែលខ្វះ ឬ បន្ថយនូវតម្លៃដីនោះទៅតាមទំហំដីដែលខ្វះ ឬ រំលាយកិច្ចសន្យា និង ទាមទារសំណងនៃការខូចខាត តាមបញ្ញត្តិពីមាត្រា ៥៤២ (សិទ្ធិទាមទារឱ្យអនុវត្តពេញលេញរបស់អ្នកទិញ) ដល់មាត្រា ៥៤៥ (សិទ្ធិទាមទារសំណងនៃការខូចខាតរបស់អ្នកទិញ) នៃក្រមនេះបាន លើកលែងតែមានការព្រមព្រៀងផ្សេងរវាងភាគី ។

២-ចំពោះដីដែលបានកំណត់ជាក់លាក់ណាមួយ ក្នុងករណីដែលការលក់ទិញត្រូវបានធ្វើឡើងដោយបញ្ជាក់ទំហំ និង កំណត់នូវតម្លៃ តាមខ្នាតដីច្បាស់លាស់ តែតាមការ ពិត

ទំហំដីដែលមាននោះលើសពីទំហំដែលបានបញ្ជាក់ អ្នកលក់ដែលមិនបានដឹងអំពីការលើសទំហំនោះ ហើយពុំមានកំហុសក្នុងការមិនបានដឹងនោះ អាចទាមទារឱ្យអ្នកទិញបន្ថែមតម្លៃដីដែលលើសនោះបាន លើកលែងតែមានការព្រមព្រៀងផ្សេងរវាងភាគី ។

៣-ចំពោះដីដែលបានកំណត់ជាក់លាក់ណាមួយ ក្នុងករណីដែលការលក់ទិញត្រូវបានធ្វើឡើងដោយបញ្ជាក់ទំហំ និង កំណត់តែតម្លៃដីទាំងមូល ទោះបីជាទំហំដីនោះមិនគ្រប់នឹងទំហំដែលបានបញ្ជាក់ក៏ដោយ ក៏អ្នកទិញមិនអាចទាមទារឱ្យអ្នកលក់ផ្តល់តាវកាលិកនូវផ្នែកដែលខ្វះ ឬ បន្ថយនូវតម្លៃដីនោះទៅតាមទំហំដីដែលខ្វះ ឬ រំលាយកិច្ចសន្យា ឬ ទាមទារសំណងនៃការខូចខាតបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកលក់បានដឹងអំពីការខ្វះទំហំដីនោះ ឬ ករណីដែលអ្នកលក់បានធានានូវទំហំដីនោះ ឬ ករណីដែលទំហំខ្វះនោះច្រើនជាង ១ ភាគ ២០ (មួយភាគម្ភៃ) ។

៤-ចំពោះដីដែលបានកំណត់ជាក់លាក់ណាមួយ ក្នុងករណីដែលការលក់ទិញត្រូវបានធ្វើឡើងដោយបញ្ជាក់ទំហំ និង កំណត់តែតម្លៃដីទាំងមូល ទោះបីជាតាមការពិតទំហំដីដែលមាននោះលើសពីទំហំដែលបានបញ្ជាក់ក៏ដោយ ក៏អ្នកលក់មិនអាចទាមទារឱ្យអ្នកទិញបន្ថែមតម្លៃដីបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលទំហំលើសនោះច្រើនជាង ១ ភាគ ២០ (មួយភាគម្ភៃ) ហើយអ្នកលក់មិនបានដឹងអំពីការលើសទំហំ និង ពុំមានកំហុសក្នុងការមិនបានដឹងនោះ ។

៥-ក្នុងករណីដែលអ្នកលក់ទាមទារបន្ថែមតម្លៃ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ឬ កថាខណ្ឌទី ៤ នៃមាត្រានេះ អ្នកទិញអាចរំលាយកិច្ចសន្យាបាន ។

**មាត្រា ៥៤៧**.- អំឡុងពេលដែលអាចអនុវត្តសិទ្ធិ

១-សិទ្ធិដែលបានកំណត់ក្នុងមាត្រា ៥៤២ (សិទ្ធិទាមទារឱ្យអនុវត្តពេញលេញរបស់អ្នកទិញ) ដល់មាត្រា ៥៤៤ (សិទ្ធិទាមទារឱ្យបន្ថយថ្លៃលក់របស់អ្នកទិញ) និង មាត្រា ៥៤៦ (បញ្ញត្តិពិសេសស្តីពីដីដែលមានទំហំខ្វះ ឬ លើស) នៃក្រមនេះ ត្រូវអនុវត្តនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ។ ប៉ុន្តែ ចំពោះសិទ្ធិទាមទារសំណងនៃការខូចខាតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង វាក្យខណ្ឌទី ២ កថាខណ្ឌទី ៣ នៃមាត្រា ៥៤៦ (បញ្ញត្តិពិសេស

ស្តីពីដីដែលមានទំហំខ្វះ ឬ លើស) ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ៤៨២ (អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ) នៃក្រមនេះ ។

២-អំឡុងពេលដែលបានកំណត់ក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវគិតចាប់តាំងពីពេលដែលអ្នកទិញបានដឹង ឬ គួរបានដឹងអំពីវិការៈ និង ការខូចខាត រីឯអ្នកលក់វិញ ត្រូវគិតចាប់តាំងពីពេលធ្វើកិច្ចសន្យា ។

**មាត្រា ៥៤៨**.- កិច្ចសន្យាពិសេសដែលអនុគ្រោះ ឬ កម្រិតនូវការទទួលខុសត្រូវក្នុងការធានាវិការៈ

ទោះបីជាមានការព្រមព្រៀងអនុគ្រោះ ឬ កម្រិតនូវការទទួលខុសត្រូវក្នុងការធានាវិការៈដែលអ្នកលក់ត្រូវមាន តាមបញ្ញត្តិនៃមាត្រា ៥៤០ (ការទទួលខុសត្រូវក្នុងការធានាវិការៈ) នៃក្រមនេះ ក៏ដោយ ចំពោះវិការៈដែលអ្នកលក់បានដឹង តែមិនបានប្រាប់ទេ ក៏អ្នកលក់នេះមិនអាចយកការព្រមព្រៀងអនុគ្រោះ ឬ កម្រិតនូវការទទួលខុសត្រូវនោះ មកអះអាងបានឡើយ ។

**មាត្រា ៥៤៩**.- ករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុ

១-អ្នកលក់ត្រូវមានករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុទៅឱ្យអ្នកទិញ តាមកាលបរិច្ឆេទ និង តាមទីកន្លែងដែលបានកំណត់នៅក្នុងកិច្ចសន្យា ។

២-ក្នុងករណីដែលកំណត់តែពេលត្រូវបង់ថ្លៃលក់ប៉ុណ្ណោះ នោះត្រូវសន្មតថា ពេលកំណត់នៃការប្រគល់វត្ថុដែលជាកម្មវត្ថុ ក៏ដូចពេលកំណត់នៃការបង់ថ្លៃលក់ដែរ ។

៣-ក្នុងករណីដែលមិនបានកំណត់កាលបរិច្ឆេទដែលត្រូវប្រគល់ផង មិនបានកំណត់កាលបរិច្ឆេទដែលត្រូវបង់ថ្លៃលក់ផង អ្នកលក់មានករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុទៅឱ្យអ្នកទិញ នៅពេលដែលអ្នកទិញទាមទារឱ្យប្រគល់ ។

៤-ក្នុងករណីដែលមិនបានកំណត់ទីកន្លែងដែលត្រូវប្រគល់ទេ ចំពោះការលក់វត្ថុដែលបានកំណត់ជាក់លាក់ អ្នកលក់ត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនៅទីកន្លែងដែលវត្ថុនោះស្ថិតនៅ នៅពេលធ្វើកិច្ចសន្យា និង ចំពោះករណីក្រៅពីនេះ ត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនោះ នៅលំនៅឋានរបស់អ្នកទិញ ។

៥-អ្នកលក់ត្រូវចេញសោហ៊ុយសម្រាប់ប្រគល់ លើកលែងតែមានការព្រមព្រៀងគ្នាពិសេស ។ ប៉ុន្តែ ប្រសិនបើសោហ៊ុយប្រគល់នោះកើនឡើងដោយសារអ្នកទិញបានប្តូរលំនៅឋាន ឬ ដោយសារអំពើអ្វីមួយរបស់អ្នកទិញ អ្នកទិញត្រូវទទួលបន្ទុកបង់នូវចំនួនកំណើននៃសោហ៊ុយនេះ ។

**មាត្រា ៥៥០**.- វិធីប្រគល់

ការប្រគល់វត្ថុត្រូវធ្វើឡើងតាមវិធីប្រគល់កម្មវត្ថុដោយជាក់ស្តែង វិធីប្រគល់ដោយសង្ខេប វិធីផ្ទេរការកាន់កាប់ដោយបញ្ជា ឬ វិធីប្តូរលក្ខណៈនៃការកាន់កាប់ តាមបញ្ញត្តិនៃមាត្រា ២២៩ (ការផ្ទេរការកាន់កាប់) នៃក្រមនេះ ។ ការប្រគល់អចលនវត្ថុអាចធ្វើឡើងបាន ដោយការប្រគល់សោនៃអាគារ ឬ ប្រគល់ប័ណ្ណបញ្ជាក់សិទ្ធិ ។

**មាត្រា ៥៥១**.- សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា និង សិទ្ធិតវ៉ាដោយមានការបារម្ភ

១-អ្នកលក់អាចប្រកែកមិនព្រមផ្ទេរសិទ្ធិដែលជាកម្មវត្ថុ និង មិនព្រមប្រគល់វត្ថុដែលជាកម្មវត្ថុទៅអ្នកទិញបាន រហូតដល់ពេលដែលអ្នកទិញបានផ្តល់ការសង ចំពោះកាតព្វកិច្ចបង់ថ្លៃលក់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកាតព្វកិច្ចរបស់អ្នកទិញនោះ ពុំទាន់ដល់ពេលកំណត់ត្រូវសង ឬ ករណីដែលមានការព្រមព្រៀងគ្នាអំពីការអនុវត្តករណីយកិច្ចផ្ទេរសិទ្ធិ ឬ កាតព្វកិច្ចប្រគល់ជាមុន ។

២-ទោះបីជាអ្នកលក់បានអនុញ្ញាតឱ្យអ្នកទិញមានពេលកំណត់ដើម្បីសងថ្លៃកម្មវត្ថុក៏ដោយ ប្រសិនបើអ្នកទិញបានក្ស័យធន ឬ បានក្លាយទៅជាមានកង្វះនូវទ្រព្យធន ក្រោយពេលធ្វើកិច្ចសន្យាលក់ទិញ ឬ បានលាក់នូវកង្វះនៃទ្រព្យធន មុនពេលធ្វើកិច្ចសន្យាក៏អ្នកលក់អាចប្រកែកមិនផ្ទេរសិទ្ធិ និង មិនប្រគល់កម្មវត្ថុនោះបានដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកទិញបានដាក់ប្រាតិភោគ ឬ ចាត់ចែងវិធានការដើម្បីរំលត់ការបារម្ភនោះ ។

**មាត្រា ៥៥២**.- ករណីយកិច្ចរក្សាទុកវត្ថុដែលជាកម្មវត្ថុ

១-អ្នកលក់វត្ថុដែលបានកំណត់ជាក់លាក់ ត្រូវរក្សាទុកវត្ថុនោះដោយប្រុងប្រយ័ត្ន

ក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ រហូតដល់ពេលប្រគល់វត្ថុនោះទៅអ្នកទិញ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះវត្ថុដែលមិនកំណត់ ក្រោយពីបានកំណត់វត្ថុនោះជាក់លាក់ហើយ ។

២-ក្នុងករណីដែលអ្នកលក់បានធ្វើឱ្យបាត់បង់ ឬ ធ្វើឱ្យខូចខាតវត្ថុដែលជាកម្មវត្ថុ ដោយសារខ្លួនធ្វេសប្រហែសមិនបានគោរពករណីយកិច្ចត្រូវប្រុងប្រយ័ត្នដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកលក់ត្រូវទទួលខុសត្រូវ ចំពោះអ្នកទិញ តាមកិច្ចសន្យា និង បញ្ញត្តិនៃផ្នែកទី ៣ (សំណងនៃការខូចខាត) ជំពូកទី ៤ គន្ថីទី ៤ នៃក្រមនេះ ។

**មាត្រា ៥៥៣**.- សិទ្ធិទទួលផល

ក្នុងករណីដែលកម្មវត្ថុនៃការលក់បានបង្កើតផលធម្មជាតិមុនពេលប្រគល់ទៅអ្នកទិញ ផលនេះត្រូវទុកជាកម្មសិទ្ធិរបស់អ្នកលក់ លើកលែងតែមានការព្រមព្រៀងគ្នាពិសេសរវាងគូភាគី ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកម្មវត្ថុនៃការលក់បង្កើតផលស៊ីវិលដូចជាថ្លៃឈ្នួល ជាអាទិ៍ ។

## កថាភាគទី ២ ករណីយកិច្ចរបស់អ្នកទិញ

**មាត្រា ៥៥៤**.- ករណីយកិច្ចទូទៅរបស់អ្នកទិញ

អ្នកទិញត្រូវមានករណីយកិច្ចបង់ថ្លៃជាប្រាក់ដែលសន្យា និង ករណីយកិច្ចទទួលវត្ថុដែលខ្លួនបានទិញ ។

**មាត្រា ៥៥៥**.- ករណីយកិច្ចបង់ថ្លៃទិញ

១-អ្នកទិញមានករណីយកិច្ចបង់ថ្លៃទិញជាប្រាក់ដែលបានកំណត់ក្នុងកិច្ចសន្យា តាមកាលបរិច្ឆេទ និង នៅទីកន្លែងដែលបានកំណត់ក្នុងកិច្ចសន្យា ។

២-ក្នុងករណីនៃការលក់ចលនវត្ថុដែលមានតែកំណត់ពេលនៃការប្រគល់ចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ប៉ុណ្ណោះ ឬ ក្នុងករណីនៃការលក់អចលនវត្ថុដែលមានតែកំណត់ពេលនៃការធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ប៉ុណ្ណោះ នោះត្រូវសន្មតថា ពេលកំណត់នៃការបង់ថ្លៃទិញ ក៏ដូចពេលកំណត់នៃការប្រគល់ ឬ ការ

ធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីដែរ។

៣-ក្នុងករណីដែលមិនបានកំណត់ពេលប្រគល់ចលនវត្ថុដែលជាកម្មវត្ថុ ឬ ពេលធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុដែលជាកម្មវត្ថុផង មិនបានកំណត់ពេលបង់ថ្លៃផង អ្នកទិញមានករណីយកិច្ចបង់ថ្លៃទៅអ្នកលក់ នៅពេលដែលអ្នកលក់ទាមទារឱ្យអ្នកទិញបង់ ។

៤-ក្នុងករណីដែលមិនបានកំណត់ទីកន្លែងដែលត្រូវបង់ថ្លៃទិញនៅក្នុងកិច្ចសន្យាទេ ប្រសិនបើការបង់ថ្លៃត្រូវធ្វើព្រមគ្នានឹងការប្រគល់ចលនវត្ថុដែលជាកម្មវត្ថុ ឬ ព្រមគ្នានឹងការធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុដែលជាកម្មវត្ថុនោះ អ្នកទិញត្រូវបង់ថ្លៃនៅទីកន្លែងដែលអ្នកលក់ត្រូវប្រគល់ចលនវត្ថុដែលជាកម្មវត្ថុ ឬ ត្រូវធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុដែលជាកម្មវត្ថុ ។

(កំណត់)

ក្នុងករណីដែលមិនបានបញ្ជាក់នូវកន្លែងដែលត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនៅក្នុងកិច្ចសន្យាទេ កន្លែងដែលត្រូវប្រគល់វត្ថុ គឺជាកន្លែងដែលកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ៥៤៩ (ករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុ) ។

**មាត្រា ៥៥៦.-** ការប្រាក់នៃថ្លៃទិញ និង ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ

អ្នកទិញមិនចាំបាច់ត្រូវបង់ការប្រាក់នៃថ្លៃទិញ ឬ ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ រហូតដល់ពេលដែលវត្ថុដែលជាកម្មវត្ថុត្រូវបានប្រគល់ឡើយ ។

(កំណត់)

ជាគោលការណ៍ ការប្រគល់វត្ថុដែលជាកម្មវត្ថុ និង ការបង់ថ្លៃទិញ ត្រូវអនុវត្តព្រមគ្នា ហេតុដូច្នេះ អ្នកទិញមិនចាំបាច់បង់ការប្រាក់ ឬ ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ រហូតដល់ពេលខ្លួនទទួលការប្រគល់វត្ថុនោះ ទោះបីជាមានការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចបង់ថ្លៃទិញក៏ដោយ (ចំពោះទំនាក់ទំនងជាមួយនឹងសិទ្ធិទទួលផលដែលកើតឡើងពីវត្ថុដែលជាកម្មវត្ថុ សូមមើលមាត្រា ៥៥៣) ។ ប៉ុន្តែ ភាគីមានសេរីភាពក្នុងការព្រមព្រៀងខុសពីនេះបាន ។

**មាត្រា ៥៥៧.-** សិទ្ធិបដិសេធមិនបង់ថ្លៃទិញ ក្នុងករណីដែលតតិយជនអះអាងសិទ្ធិរបស់ខ្លួនលើវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ

១-ក្នុងករណីដែលមានអ្នកអះអាងសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ ហើយមានការបារម្ភថា អ្នកទិញនឹងបាត់បង់នូវសិទ្ធិទាំងអស់ ឬ មួយភាគដែលខ្លួនបានទិញនោះ អ្នកទិញអាចបដិសេធមិនបង់ថ្លៃទិញទាំងអស់ ឬ មួយភាគ ទៅតាមទំហំនៃហានិភ័យនោះបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកលក់បានដាក់ប្រាតិភោគសមរម្យ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកលក់អាចទាមទារឱ្យអ្នកទិញតម្កល់ថ្លៃទិញបាន ។

**មាត្រា ៥៥៨**.- សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា និង សិទ្ធិតវ៉ាដោយមានការបារម្ភ

១-អ្នកទិញអាចមិនព្រមបង់ថ្លៃទិញបាន រហូតដល់ពេលដែលអ្នកលក់បានផ្តល់នូវការសងចំពោះកាតព្វកិច្ចរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកាតព្វកិច្ចរបស់អ្នកលក់មិនទាន់ដល់ពេលកំណត់ត្រូវសង ឬ ករណីដែលមានការព្រមព្រៀងគ្នាអំពីការអនុវត្តកាតព្វកិច្ចបង់ថ្លៃជាមុន ។

២-ទោះបីជាអ្នកទិញបានអនុញ្ញាតឱ្យអ្នកលក់មានពេលកំណត់ដើម្បីអនុវត្តកាតព្វកិច្ចក៏ដោយ ប្រសិនបើមានការបារម្ភយ៉ាងជាក់ស្តែងថា អ្នកលក់នឹងមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ក៏អ្នកទិញអាចប្រកែកមិនបង់ថ្លៃទិញបានដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកលក់បានដាក់ប្រាតិភោគ ឬ ចាត់ចែងវិធានការដើម្បីរំលត់ការបារម្ភនោះ ។

**មាត្រា ៥៥៩**.- ការយឺតយ៉ាវក្នុងការបំពេញករណីយកិច្ចទទួល

១-ក្នុងករណីដែលអ្នកទិញមានការយឺតយ៉ាវក្នុងការបំពេញករណីយកិច្ចទទួល អ្នកលក់អាចទាមទារសំណងនៃការខូចខាត ឬ រំលាយកិច្ចសន្យា តាមបញ្ញត្តិនៃផ្នែកទី ៣ (សំណងនៃការខូចខាត) និង ផ្នែកទី ៤ (ការរំលាយកិច្ចសន្យា) ជំពូកទី ៤ នៃគន្ថីទី ៤ បាន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើវត្ថុដែលជាកម្មវត្ថុត្រូវបានបាត់បង់ ឬ ខូចខាត ដោយគ្មានកំហុសរបស់អ្នកលក់ អ្នកទិញត្រូវទទួលបន្ទុកហានិភ័យនោះ ។

៣-ក្នុងករណីដែលអ្នកលក់បានផ្តល់នូវការសង តែអ្នកទិញនៅតែមិនព្រមទទួលវត្ថុដែលជាកម្មវត្ថុ អ្នកលក់អាចតម្កល់ ឬ លក់វត្ថុដែលជាកម្មវត្ថុនោះ តាមបញ្ញត្តិនៃមាត្រា ៤៩៧ (ការតម្កល់) និង មាត្រា ៤៩៨ (សិទ្ធិលក់ដោយខ្លួនឯង) នៃក្រមនេះ បាន ។

## ផ្នែកទី ៤ ការរំលាយកិច្ចសន្យាលក់ទិញដោយអនុវត្តសិទ្ធិលោះ

**មាត្រា ៥៦០**.- ការសន្យាពិសេសនៃការលោះ

អ្នកលក់អាចរំលាយកិច្ចសន្យាលក់ទិញ ដោយសងប្រាក់ដែលអ្នកទិញបានបង់ និងសងសោហ៊ុយដែលបានកំណត់ក្នុងមាត្រា ៥៦៣ (វិធីអនុវត្តសិទ្ធិលោះ) នៃក្រមនេះ បាន ដោយផ្អែកលើការសន្យាពិសេសនៃសិទ្ធិលោះដែលបានកំណត់ច្បាស់លាស់ នៅក្នុងលិខិតនៃកិច្ចសន្យា ។

(កំណត់)

មាត្រានេះទទួលស្គាល់នូវការបង្កើតកិច្ចសន្យាលក់ទិញដោយមានការសន្យាពិសេសនៃការលោះ ក្នុងគោលបំណងជាប្រាតិភោគ ជាអាទិ៍ ប៉ុន្តែ ដើម្បីបង្ការនូវអំពើកេងយកចំណេញហួសហេតុ មាត្រានេះក៏ចែងកម្រិតនូវសោហ៊ុយនៃការលោះ ហើយទាមទារឱ្យមានកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរដើម្បីធ្វើការលក់ទិញដែលមានសិទ្ធិលោះពិសេសនេះ ។

(មាត្រាពាក់ព័ន្ធ)

វាក្យខណ្ឌទី ១ នៃមាត្រា ៥៧៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៥៦១**.- អំឡុងពេលនៃការលោះ

១-អំឡុងពេលនៃការលោះ ចំពោះអចលនវត្ថុ គឺមិនអាចឱ្យលើសពី ៥ (ប្រាំ) ឆ្នាំ បានទេ ចំណែកឯចលនវត្ថុវិញ គឺមិនអាចឱ្យលើសពី ២ (ពីរ) ឆ្នាំ បានទេ ។ ប្រសិនបើបានកំណត់អំឡុងពេលវែងជាងនេះ ត្រូវតែបន្ថយកំណត់នោះដោយស្វ័យប្រវត្តិ មកត្រឹម ៥ (ប្រាំ) ឆ្នាំ ចំពោះអចលនវត្ថុ ហើយមកត្រឹម ២ (ពីរ) ឆ្នាំ វិញ ចំពោះចលនវត្ថុ ។

២-ក្នុងករណីដែលគូភាគីបានកំណត់នូវអំឡុងពេលសម្រាប់ការលោះរួចហើយ គូភាគីនោះមិនអាចពន្យារអំឡុងពេល ថែមទៀតបានឡើយ ។

៣-ក្នុងករណីដែលមិនបានកំណត់អំឡុងពេលសម្រាប់ការលោះទេ អ្នកលក់ត្រូវអនុវត្តសិទ្ធិលោះនោះនៅក្នុងអំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៨០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៥៦២.-** ការតតាំងនៃការសន្យាពិសេសនៃការលោះ ជាអាទិ៍

១-អ្នកទិញអាចអនុវត្តសិទ្ធិទាំងឡាយក្នុងនាមជាកម្មសិទ្ធិករ ។ ប៉ុន្តែ ក្នុងករណីដែលការអនុវត្តសិទ្ធិនោះ ផ្ទុយនឹងអត្ថន័យនៃការសន្យាពិសេសនៃការលោះ អ្នកទិញត្រូវទទួលខុសត្រូវក្នុងការមិនអនុវត្តកាតព្វកិច្ចចំពោះអ្នកលក់ ។

២-ការសន្យាពិសេសនៃការលោះនឹងមានអានុភាពចំពោះតតិយជន លុះត្រាតែការសន្យាពិសេសនោះត្រូវបានចុះបញ្ជី ព្រមគ្នានឹងកិច្ចសន្យាលក់ទិញ ។

(កំណត់)

"តតិយជន" ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ គឺជាអ្នកដែលបានទទួលបន្តនូវវត្ថុ និង បុគ្គលដែលបានទទួលការបង្កើតសិទ្ធិប្រាតិភោគប្រត្យក្ស ឬ សិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល ពីអ្នកទិញ ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ១ នៃមាត្រា ៥៨១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៥៦៣.-** វិធីអនុវត្តសិទ្ធិលោះ

១-អ្នកលក់ត្រូវបង់ថ្លៃលក់ និង បង់សោហ៊ុយក្នុងការធ្វើកិច្ចសន្យា ក្នុងអំឡុងពេលដែលបានកំណត់ ដើម្បីលោះវិញ ។

២-ក្នុងករណីដែលអ្នកទិញ ឬ អ្នកទទួលបន្តវត្ថុពីអ្នកទិញ បានចេញចំណាយសោហ៊ុយចំពោះវត្ថុដែលជាកម្មវត្ថុ អ្នកលក់ត្រូវសងទៅវិញនូវចំណាយជាចាំបាច់សម្រាប់គ្រប់គ្រង និង ថែរក្សាវត្ថុទាំងអស់ រីឯការចំណាយបង្កើនតម្លៃវិញ អ្នកលក់ត្រូវសងទៅអ្នកទិញវិញនូវសោហ៊ុយដែលអ្នកទិញ ឬ អ្នកទទួលបន្តវត្ថុពីអ្នកទិញបានចេញ ឬ តម្លៃប្រាក់ដែលកើននោះ ទៅតាមការជ្រើសរើសរបស់អ្នកលក់ ក្នុងកម្រិតដែលកំណើនតម្លៃនោះនៅតែមាន ។

(កំណត់)

ក្រមរដ្ឋប្បវេណីកម្ពុជាចាស់ ទទួលស្គាល់នូវការយកការប្រាក់ពីថ្លៃលក់ ប៉ុន្តែ មាត្រានេះមិនទទួលស្គាល់ការយកការ

ប្រាក់នេះដោយស្វ័យប្រវត្តិទេ ដោយស្របតាមច្បាប់នៃបណ្តាប្រទេសនានា (សូមមើលមាត្រា ៥៦០) ។ ចំពោះអានុភាព នៃការសន្យាពិសេសអំពីការបង់ការប្រាក់ នឹងអាស្រ័យទៅលើការបកស្រាយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៨៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៥៦៤**.- ការលក់វត្ថុដែលជាកម្មសិទ្ធិអវិភាគ ដោយមានការសន្យាពិសេសនៃការលោះ

១-ក្នុងករណីដែលម្ចាស់កម្មសិទ្ធិអវិភាគ បានលក់វត្ថុរួមទាំងមូលដោយមានការសន្យាពិសេសនៃការលោះ តាមកិច្ចសន្យាតែមួយ ហើយបុគ្គលម្នាក់ក្នុងចំណោមម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់បានទាមទារឱ្យលោះវត្ថុមួយភាគដែលជាកម្មសិទ្ធិរបស់ខ្លួន ឬ វត្ថុទាំងមូលនោះ អ្នកទិញមិនចាំបាច់យល់ព្រមក៏បានដែរ ។

២-ប្រសិនបើម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់ បានលក់ភាគដែលជាកម្មសិទ្ធិរបស់ខ្លួនម្នាក់ៗទៅអ្នកទិញតែម្នាក់ តាមកិច្ចសន្យាដោយឡែក ដោយមានការសន្យាពិសេសនៃការលោះវិញ ម្ចាស់កម្មសិទ្ធិអវិភាគនីមួយៗនោះអាចលោះមកវិញ នូវភាគដែលជាកម្មសិទ្ធិរបស់ខ្លួនបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៨៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៥៦៥**.- អានុភាពនៃការមិនអនុវត្តសិទ្ធិលោះ

ប្រសិនបើអ្នកលក់មិនអនុវត្តសិទ្ធិលោះក្នុងអំឡុងពេលដែលបានកំណត់នៅក្នុង មាត្រា ៥៦១ (អំឡុងពេលនៃការលោះ) នៃក្រមនេះទេ សិទ្ធិលោះត្រូវរលត់ ហើយកម្មសិទ្ធិរបស់អ្នកទិញនឹងក្លាយជាស្ថាពរ ។

## ជំពូកទី ២ ការដូរ

**មាត្រា ៥៦៦**.- អត្ថន័យ

ការដូរ ត្រូវមានអានុភាព តាមការសន្យាដែលភាគីទាំងសងខាង ធ្វើការផ្ទេរសិទ្ធិ

លើទ្រព្យសម្បត្តិ ក្រៅពីប្រាក់ទៅវិញទៅមក ។

(កំណត់)

ការដូរ គឺជាកិច្ចសន្យាផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិឱ្យគ្នាទៅវិញទៅមក ក្រៅពីកម្មសិទ្ធិលើប្រាក់ ។ ឧទាហរណ៍ កិច្ចសន្យាផ្ទេររវាងកម្មសិទ្ធិលើកុំព្យូទ័រជាមួយនឹងកម្មសិទ្ធិលើម៉ាស៊ីនថតរូប ។ ការដូរ គឺជាកិច្ចសន្យាដែលធ្វើឡើង ដោយគ្រាន់តែមានការព្រមព្រៀងគ្នាពីភាគីទាំងពីរប៉ុណ្ណោះ ហើយជាកិច្ចសន្យាអញ្ញមញ្ញ ដែលយកតម្លៃថ្នូរ (មូលា) ។

(មាត្រាយោង)

កថាខណ្ឌទី ១ មាត្រា ៥៨៦ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៧០២ ដល់មាត្រា ១៧០៧ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៥១៥ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៥៦៧.-** ការយកបញ្ញត្តិនៃការលក់ទិញមកអនុវត្តដូចគ្នា

បញ្ញត្តិស្តីអំពីការលក់ទិញ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការដូរ ។

(កំណត់)

កថាខណ្ឌទី ២ មាត្រា ៥៨៦ នៃក្រមរដ្ឋប្បវេណីជប៉ុន បានចែងជាពិសេសស្តីពីការដូរដែលមានប្រាក់បន្ថែម (ដែលភាគីណាមួយសន្យាថា នឹងផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិក្រៅពីប្រាក់ ជាមួយគ្នានឹងប្រាក់បន្ថែម) ហើយចែងថា បញ្ញត្តិទាំងឡាយដែលទាក់ទងនឹងថ្លៃលក់ក្នុងកិច្ចសន្យាលក់ទិញ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះប្រាក់នោះ ។ យើងសម្រេចថា បញ្ញត្តិដែលពាក់ព័ន្ធទៅនឹងការលក់ទិញ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការដូរ ដោយរួមបញ្ចូលទាំងករណីការដូរដែលមានប្រាក់បន្ថែម ពីព្រោះវានឹងមិនបង្កឱ្យមានបញ្ហាអ្វីជាពិសេសណាមួយនោះទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៨៦ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៧០២ ដល់មាត្រា ១៧០៧ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៥១៥ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## ជំពូកទី ៣ ប្រទានកម្ម

**មាត្រា ៥៦៨.-** និយមន័យ

ប្រទានកម្ម សំដៅទៅលើកិច្ចសន្យាមួយ ដែលត្រូវមានអានុភាព ដោយភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ទៅឱ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិ ដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល ។

(កំណត់)

ប្រទានកម្ម គឺជាកិច្ចសន្យាមួយប្រភេទដែលតាមរយៈនោះ ភាគីម្ខាងផ្តល់ ឧទាហរណ៍ថា កុំព្យូទ័ររបស់ខ្លួន ឱ្យទៅភាគីម្ខាងទៀតដោយឥតគិតថ្លៃ ហើយជាកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ និង កិច្ចសន្យាឯកតោភាគីដែលទាយកទទួលនូវកាតព្វកិច្ចតែឯកឯងចំពោះបដិគ្គាហក ។ ប្រទានកម្ម ក៏ជាកិច្ចសន្យាដែលតម្រូវឱ្យមានការព្រមព្រៀងរវាងទាយក និង បដិគ្គាហក ហើយដែលត្រូវបានបង្កើតឡើងដោយគ្រាន់តែមានការព្រមព្រៀងរវាងគូភាគីតែប៉ុណ្ណោះ ។

ប្រទានកម្មទ្រព្យសម្បត្តិមានន័យថា ជាការបង្កើននូវទ្រព្យសម្បត្តិរបស់បដិគ្គាហក ដោយបន្ថយនូវទ្រព្យសម្បត្តិរបស់ទាយក ហេតុដូច្នេះ ការទទួលការព្វកិច្ចរបស់ភាគីម្ខាងទៀត (បដិគ្គាហក) ដោយឱ្យភាគីនោះរួចផុតពីកាតព្វកិច្ចនេះ ក៏ជាប្រទានកម្មដែរ ។

កិច្ចសន្យាដែលភាគីម្ខាងណាមួយអនុញ្ញាតឱ្យភាគីម្ខាងទៀតប្រើប្រាស់នូវវត្ថុដោយមិនយកតម្លៃថ្នូរ រាប់បញ្ចូលការខ្ចីប្រើ (មាត្រា ៦២៥ និង មាត្រាបន្តបន្ទាប់) និង កិច្ចសន្យាខ្ចីបរិភោគដោយមិនយកតម្លៃថ្នូរ (មាត្រា ៥៧៨ និង មាត្រាបន្តបន្ទាប់) ។ បន្ថែមពីលើនេះទៀត កិច្ចសន្យាស្តីពីការផ្តល់នូវពលកម្ម សម្រាប់បំពេញកិច្ចការដោយមិនយកកម្រៃ ត្រូវបានចាត់ទុកថាជាអាណត្តិដោយមិនយកកម្រៃ (សូមមើលមាត្រា ៦៣៨) ។ កិច្ចសន្យាប្រភេទទាំងនេះមិនត្រូវបានចាត់ទុកថាជាប្រទានកម្មទេ ប៉ុន្តែ គឺជាកិច្ចសន្យាដែលមិនយកតម្លៃថ្នូរដោយឡែកដែលមានលក្ខណៈពិសេស ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៤៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៨៩៤ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៥១៦ និង មាត្រា ៥១៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៥៦៩.- ការផ្ទេរកម្មសិទ្ធិ

ការផ្ទេរកម្មសិទ្ធិនៃវត្ថុដែលជាកម្មវត្ថុ នៅក្នុងកិច្ចសន្យាប្រទានកម្ម ត្រូវអនុលោមតាមគោលការណ៍ទូទៅដែលកំណត់នៅក្នុងមាត្រា ១៣៣ (ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស ដោយការព្រមព្រៀង) មាត្រា ១៣៤ (ល័ក្ខខ័ណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស) មាត្រា ១៣៥ (ល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង) មាត្រា ១៦០ (លទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ) និង មាត្រា ១៨៧ (លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ។

(កំណត់)

តាមកិច្ចសន្យាប្រទានកម្ម សិទ្ធិលើទ្រព្យសម្បត្តិត្រូវបានផ្ទេរពីទាយកទៅបដិគ្គាហក ហើយក្នុងចំណោមសិទ្ធិលើទ្រព្យសម្បត្តិទាំងនេះ សិទ្ធិចម្បងគឺជាកម្មសិទ្ធិ ។ ដូច្នេះហើយបានជាយើងដាក់បញ្ចូលមាត្រានេះដើម្បីសម្គាល់ថា

ប្រសិនបើកម្មសិទ្ធិត្រូវបានផ្ទេរ តាមរយៈប្រទានកម្ម មាត្រាទាំងឡាយដែលពាក់ព័ន្ធនឹងការផ្ទេរកម្មសិទ្ធិ ត្រូវយកមកអនុវត្ត ដូចគ្នាផងដែរ ។

**មាត្រា ៥៧០**.- ប្រទានកម្មដែលមិនធ្វើជាលាយលក្ខណ៍អក្សរ

ទោះបីជាបានធ្វើការសន្យាប្រទានកម្មក៏ដោយ ប្រសិនបើមិនបានធ្វើជាលាយលក្ខណ៍អក្សរស្ដីអំពីប្រទានកម្មទេ ភាគីនៃកិច្ចសន្យា អាចលុបចោលកិច្ចសន្យា ដោយដកការបង្ហាញឆន្ទៈនៃការធ្វើប្រទានកម្មវិញបាន ។ ប៉ុន្តែ ចំពោះផ្នែកដែលបានអនុវត្តហើយ មិនអាចដកការបង្ហាញឆន្ទៈនៃការធ្វើប្រទានកម្មវិញបានឡើយ ។

(កំណត់)

ដោយសារតែមានបញ្ញត្តិដែលចែងថា កិច្ចសន្យាប្រទានកម្ម ជាកិច្ចសន្យាដែលធ្វើឡើងតាមការព្រមព្រៀងតែប៉ុណ្ណោះ ដោយមិនទាមទារនូវលិខិតយថាភូត ជាអាទិ៍ មាត្រានេះយកលំនាំតាមក្រមរដ្ឋប្បវេណីជប៉ុន ហើយចែងថា ផ្នែកដែលមិនទាន់បានអនុវត្តនៃកិច្ចសន្យាប្រទានកម្មដែលមិនសរសេរជាលាយលក្ខណ៍អក្សរ អាចដកវិញបាន ។ ជាធម្មតា ប្រសិនបើឆន្ទៈរបស់ទាយកត្រូវបានបង្ហាញតាមរូបភាពជាលាយលក្ខណ៍អក្សរ ការបង្ហាញឆន្ទៈរបៀបនេះ គឺជាលទ្ធផលនៃការវិនិច្ឆ័យដោយប្រុងប្រយ័ត្នរបស់ទាយក ហើយឆន្ទៈនោះអាចត្រូវបានធ្វើការបញ្ជាក់យ៉ាងច្បាស់លាស់តាមលិខិតជាលាយលក្ខណ៍អក្សរនោះ ។ ដោយហេតុនេះ បដិគ្គាហកអាចបង្ខំឱ្យទាយកអនុវត្តនូវប្រទានកម្មបាន ។ ក៏ប៉ុន្តែ ចំពោះប្រទានកម្មដែលមិនធ្វើជាលាយលក្ខណ៍អក្សរ មានករណីជាច្រើនដែរដែលទាយកសន្យាធ្វើប្រទានកម្មដោយមិនមបានគិតពិចារណាដោយប្រុងប្រយ័ត្ន ។ ហេតុដូច្នេះ មាត្រានេះចែងអំពីលទ្ធភាពនៃការដក ។ ប្រភេទនៃកិច្ចសន្យាជាលាយលក្ខណ៍អក្សរដែលតម្រូវឱ្យធ្វើ អាស្រ័យទៅតាមការបកស្រាយនាពេលអនាគត ។ តាមការបកស្រាយក្រមរដ្ឋប្បវេណីជប៉ុនវិញ លិខិតទាំងឡាយដែលចង្អុលទៅរកឆន្ទៈនៃប្រទានកម្ម ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាជាលិខិតដែលត្រូវបានយល់ឃើញថា មានគោលបំណងធ្វើប្រទានកម្ម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៥០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៥៧១**.- ការលុបចោលប្រទានកម្មដោយសារអំពើរំលោភលើទំនុកចិត្ត ជាអាទិ៍

១-ក្នុងករណីដែលបដិគ្គាហកបានធ្វើអំពើរំលោភលើទំនុកចិត្តធ្ងន់ធ្ងរចំពោះទាយក ទាយកអាចលុបចោលប្រទានកម្មបាន ។

២-ចំពោះផ្នែកដែលបានអនុវត្តហើយ ការលុបចោលប្រទានកម្មដែលកំណត់នៅ

ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបានតែក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលមានអំពើរំលោភលើទំនុកចិត្តធ្ងន់ធ្ងរនោះ ។

(កំណត់)

ដោយសារការធ្វើប្រទានកម្ម ជាចម្មតា ជាសកម្មភាពដែលមិនគិតកម្រៃថ្នូរ ដោយផ្អែកលើសុឆន្ទៈ ហើយត្រូវបានធ្វើដោយផ្អែកលើស្ថានភាពហិរញ្ញវត្ថុធូរធាររបស់ទាយក ក្រមរដ្ឋប្បវេណីនៃប្រទេសខ្លះបានផ្តល់ឱ្យទាយកនូវសិទ្ធិទាមទារឱ្យយកមកវិញនូវអំណោយដែលបានធ្វើប្រទានកម្មហើយនោះ ប្រសិនបើមានស្ថានភាពផ្លាស់ប្តូរក្រោយពេលធ្វើប្រទានកម្ម ដូចជាករណីដែលបដិគ្គាហកបង្ហាញនូវភាពអកតញ្ញូតាចំពោះទាយក ឬ ករណីដែលទាយកធ្លាក់ខ្លួនក្រ ។ មាត្រានេះ និង មាត្រា ៥៧២ ចែងអំពីសិទ្ធិលុបចោល ក្នុងករណីទាំងនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩៥៣ និង មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៥៣០ ដល់មាត្រា ៥៣៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៥៧២**.- ការលុបចោលប្រទានកម្មដោយសារភាពទីទ័លក្ររបស់ទាយក

១-ប្រសិនបើទាយកធ្លាក់ខ្លួនក្នុងស្ថានភាពទីទ័លក្រ មិនអាចរក្សាជីវភាពរស់នៅរបស់ខ្លួនផ្ទាល់ និង បុគ្គលដែលត្រូវមានអាហារកាតព្វកិច្ច ក្រោយពីបានបង្ហាញឆន្ទៈធ្វើប្រទានកម្មហើយ ទាយកអាចលុបប្រទានកម្មនោះចោលបាន ។

២-ចំពោះផ្នែកដែលបានអនុវត្តហើយ ការលុបចោលប្រទានកម្មដែលកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបានតែក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលបានអនុវត្ត ។

(កំណត់)

សូមមើលសេចក្តីកំណត់នៃមាត្រា ៥៧១ (ការលុបចោលប្រទានកម្មដោយសារអំពើរំលោភលើទំនុកចិត្ត ជាអាទិ៍) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥២៨ និង មាត្រា ៥២៩ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៥៧៣**.- អានុភាពនៃការលុបចោលប្រទានកម្ម

ក្នុងករណីដែលបានលុបចោលប្រទានកម្មតាមបញ្ញត្តិនៃមាត្រា ៥៧១ (ការលុប

ចោលប្រទានកម្មដោយសារអំពើរំលោភលើទំនុកចិត្ត ជាអាទិ៍) និង មាត្រា ៥៧២ (ការលុបចោលប្រទានកម្មដោយសារភាពទីទ័លក្ររបស់ទាយក) ខាងលើនេះ ទាយកអាចទាមទារឱ្យសងទ្រព្យសម្បត្តិដែលបានធ្វើប្រទានកម្មនោះ ដោយផ្អែកតាមបញ្ញត្តិស្ដីពីការសងនៃសេចក្ដីចម្រើនដោយឥតហេតុបាន ។

(កំណត់)

មាត្រានេះចែងអំពីអានុភាពនៃការអនុវត្តនូវសិទ្ធិលុបចោលប្រទានកម្ម ។

## មាត្រា ៥៧៤.- ការបន្ថយនូវការទទួលខុសត្រូវក្នុងការធានា

ទាយក ពុំមានបន្ទុកទទួលខុសត្រូវក្នុងការធានា ចំពោះវិការៈ ឬ ការខ្វះវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃប្រទានកម្មឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើទាយកបានដឹងអំពីវិការៈ ឬ ការខ្វះនោះហើយ តែមិនបានផ្ដល់ដំណឹងទៅបដិគ្គាហក ។

(កំណត់)

ទាយកមិនត្រូវទទួលខុសត្រូវក្នុងការធានាចំពោះវិការៈនៃគុណភាពនៃវត្ថុដែលជាកម្មវត្ថុនៃប្រទានកម្ម ឬ វិការៈនៃសិទ្ធិនោះឡើយ ។ ចំពោះកិច្ចសន្យាប្រទានកម្ម ដែលជាកិច្ចសន្យាមិនយកកម្រៃថ្នូរ ខុសគ្នាពីកិច្ចសន្យាលក់ទិញ ឬកិច្ចសន្យាផ្សេងទៀត ដែលយកកម្រៃថ្នូរ ទោះបីជាវត្ថុដែលជាកម្មវត្ថុនៃប្រទានកម្មមានវិការៈនៅពេលធ្វើកិច្ចសន្យាក៏ដោយ ក៏វាមិនសមរម្យដែរ ដែលដាក់បន្ទុកធ្ងន់ទៀតទៅទាយក បន្ថែមពីលើបន្ទុកចំពោះការប្រគល់នូវវត្ថុ ទៅតាមស្ថានភាពបច្ចុប្បន្នរបស់វានោះ ។ ចំពោះប្រទានកម្មដែលមានភ្ជាប់បន្ទុក កថាខណ្ឌទី ៣ នៃមាត្រា ៥៧៦ ចែងអំពីករណីលើកលែង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៥១ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៥២៣ មាត្រា ៥២៤ និង មាត្រា ៥២៦ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៥៧៥.- ប្រទានកម្មដោយមានកំណត់ពេល

ប្រទានកម្មដែលធ្វើឡើងក្នុងគោលបំណងផ្ដល់តាវកាលិកដោយមានកំណត់ពេល ត្រូវបាត់បង់អានុភាព ដោយមរណភាពរបស់ទាយក ឬ បដិគ្គាហក ។

(កំណត់)

ប្រទានកម្មដោយមានកំណត់ពេល គឺជាប្រទានកម្មដែលមានលក្ខណៈបន្ត ហើយជាប្រទានកម្មដែលមានកំណត់ពេល

ចំពោះវត្ថុមួយចំនួន ឧទាហរណ៍ដូចជា ប្រទានកម្ម ៥០ ០០០ រៀល ប្រចាំខែ សម្រាប់ចំណាយក្នុងជីវភាពរស់នៅ ។ ដោយការពិចារណាអំពីឆន្ទៈនៃភាគីកិច្ចសន្យាប្រទានកម្មដោយមានកំណត់ពេល អានុភាពនៃកិច្ចសន្យាប្រទានកម្មត្រូវបាត់បង់នៅពេលដែលទាយក ឬ បដិគ្គាហកទទួលមរណភាព លើកលែងតែគូភាគីបានសន្យាពិសេស ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៥២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៥២០ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៥៧៦**.- ប្រទានកម្មដែលមានភ្ជាប់បន្ទុក

១-ប្រទានកម្ម ដែលបដិគ្គាហកមានករណីយកិច្ចត្រូវអនុវត្តការផ្តល់តាវកាលិកជាកំណត់ ដើម្បីទទួលទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃប្រទានកម្ម ត្រូវហៅថា ប្រទានកម្មដែលមានភ្ជាប់បន្ទុក ។

២-នៅក្នុងប្រទានកម្មដែលមានភ្ជាប់បន្ទុក ទាយកត្រូវទទួលខុសត្រូវលើប្រាតិភោគដូចគ្នានឹងអ្នកលក់ផងដែរ ត្រឹមកម្រិតនៃបន្ទុកនោះ ។

៣-ក្នុងករណីដែលភាគីម្ខាងបានធ្វើការផ្តល់តាវកាលិក នៅក្នុងប្រទានកម្មដែលមានភ្ជាប់បន្ទុក បុគ្គលនោះអាចទាមទារ ចំពោះភាគីម្ខាងទៀតឱ្យផ្តល់តាវកាលិកបាន ។

៤-នៅក្នុងប្រទានកម្មដែលមានភ្ជាប់បន្ទុក បើគ្មានកិច្ចសន្យាពិសេសទេ លុះត្រាតែភាគីម្ខាងមិនបានធ្វើការផ្តល់តាវកាលិកទេ ទើបភាគីម្ខាងទៀតនៃកិច្ចសន្យា អាចមិនផ្តល់តាវកាលិករបស់ខ្លួនបាន ។

៥-ទាយកនៃប្រទានកម្មដែលមានភ្ជាប់បន្ទុក អាចរំលាយកិច្ចសន្យាប្រទានកម្មដែលមានភ្ជាប់បន្ទុកនោះ តាមបញ្ញត្តិនៃការរំលាយកិច្ចសន្យាបាន នៅក្នុងករណីដែលភាគីម្ខាងទៀតមិនបានអនុវត្តបន្ទុក ។

(កំណត់)

ដូចដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ប្រទានកម្មដែលមានភ្ជាប់បន្ទុក គឺជាប្រទានកម្មដែលបដិគ្គាហកទទួលបន្ទុកនូវករណីយកិច្ចក្នុងការផ្តល់តាវកាលិកជាក់លាក់ណាមួយ ។ ក៏ប៉ុន្តែ ដោយសារតែប្រទានកម្មដែលមានភ្ជាប់បន្ទុកនៅតែជាកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ ករណីយកិច្ចក្នុងការផ្តល់តាវកាលិករបស់បដិគ្គាហក ត្រូវតែមានតម្លៃទាបជាងសិទ្ធិលើទ្រព្យសម្បត្តិដែលត្រូវធ្វើប្រទានកម្មដោយទាយក ។ ក្នុងប្រទានកម្មដែលមានភ្ជាប់បន្ទុក ភាគីទាំងពីរទទួលបន្ទុកនូវករណីយកិច្ចក្នុងការផ្តល់តាវកាលិក ហេតុដូច្នេះ បញ្ញត្តិទាំងឡាយដែលទាក់ទងនឹងកិច្ចសន្យាអញ្ញមញ្ញ អាចយក

មកអនុវត្តដូចគ្នាផងដែរ ។ កថាខណ្ឌទី ២ និង កថាខណ្ឌបន្តបន្ទាប់ ចែងច្បាស់អំពីបន្ទុកទទួលខុសត្រូវក្នុងការធានាសិទ្ធិតវ៉ា ក្នុងការអនុវត្តព្រមគ្នា និង សិទ្ធិរំលាយ ដោយអាស្រ័យទៅតាមគោលបំណងនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៥៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៩៥៤ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៥៧៧.-** ប្រទានកម្មដោយមូលហេតុមរណភាព

១-ប្រទានកម្មដែលបង្កើតអានុភាពដោយមរណភាពរបស់ទាយក ត្រូវហៅថា ប្រទានកម្មដោយមូលហេតុមរណភាព ។

២-បញ្ញត្តិនៃអច្ច័យទាន ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអានុភាពនៃប្រទានកម្មដោយមូលហេតុមរណភាព ។

(កំណត់)

ប្រទានកម្មដោយមូលហេតុមរណភាព គឺជាប្រទានកម្មដែលយកមរណភាពរបស់ទាយកមកធ្វើជាល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាព តាមរយៈកិច្ចសន្យាដែលទាយកនោះបានធ្វើជាមួយបដិគ្គាហកក្នុងអំឡុងពេលដែលទាយកនោះនៅរស់ ។ ប្រទានកម្មដោយមូលហេតុមរណភាព គឺស្រដៀងគ្នាទៅនឹងអច្ច័យទានត្រង់ថា មិនមានការផ្លាស់ប្តូរស្ថានភាពទ្រព្យសម្បត្តិក្នុងអំឡុងពេលដែលទាយករស់នៅ ហើយទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់សន្តតិជនថយចុះនៅពេលដែលសន្តតិកម្មចាប់ផ្តើមនៅពេលដែលមតកជនទទួលមរណភាព ។ ដូច្នេះ មាត្រានេះចែងថា បញ្ញត្តិដែលទាក់ទងនឹងអច្ច័យទាន ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះប្រទានកម្មដោយមូលហេតុមរណភាព ។ ដោយសារតែប្រទានកម្មដោយមូលហេតុមរណភាពគឺជាកិច្ចសន្យា (មិនមែនជាសកម្មភាពឯកតោភាគី) បញ្ញត្តិដែលទាក់ទងនឹងសមត្ថភាព ទម្រង់ ការយល់ព្រម និង ការលះបង់អច្ច័យទាន ដែលជាបញ្ញត្តិត្រូវបានរៀបចំដោយសារលក្ខណៈជាសកម្មភាពឯកតោភាគីនៃអច្ច័យទាន មិនត្រូវយកមកអនុវត្តឡើយ ។ មានតែបញ្ញត្តិស្តីពីអានុភាពនៃអច្ច័យទានទេដែលអាចយកមកអនុវត្តដូចគ្នាបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៥៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៩៤៣ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ២៣០ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## ជំពូកទី ៤ ការខ្ចីបរិភោគ

### ផ្នែកទី ១ និយមន័យ និង ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ

**មាត្រា ៥៧៨.-** និយមន័យនៃការខ្ចីបរិភោគ

ការខ្ចីបរិភោគ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ហៅថាអ្នកឱ្យខ្ចី មានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ ស្បៀងអាហារ ស្រូវ ឬ វត្ថុជំនួស[៤] ផ្សេងទៀត ក្នុងអំឡុងពេលដែលមានកំណត់ ឱ្យទៅភាគីម្ខាងទៀត ហៅថា អ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឱ្យអ្នកឱ្យខ្ចីវិញ នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឱ្យខ្ចីនោះ ។[៥]

(កំណត់)

ក្នុងករណីដែលអ្នកឱ្យខ្ចី បានឱ្យអ្នកខ្ចី ខ្ចីប្រាក់ ឬ ស្រូវ អ្នកខ្ចីមានសេរីភាពក្នុងការប្រើប្រាស់ ឬ បរិភោគប្រាក់ ឬ ស្រូវនោះបាន ហើយអ្នកខ្ចីនោះមានករណីយកិច្ចសងទៅអ្នកឱ្យខ្ចីវិញ នូវប្រាក់ដែលមានចំនួនស្មើគ្នា ឬ នូវស្រូវដែលមានប្រភេទ និង ប្រមាណដូចគ្នា ក្រោយពីអំឡុងពេលកំណត់មួយបានកន្លងផុតទៅ ។ មានករណីពីរ គឺ ករណីដែលមានការប្រាក់ និង ករណីដែលគ្មានការប្រាក់ ហើយកិច្ចសន្យាខ្ចីបរិភោគប្រាក់ដោយភ្ជាប់ការប្រាក់ គឺជាវិធីដ៏សំខាន់មួយសម្រាប់សកម្មភាពសេដ្ឋកិច្ច ។

**មាត្រា ៥៧៩**.- ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ

កិច្ចសន្យាខ្ចីបរិភោគត្រូវបង្កើតឡើង ដោយការព្រមព្រៀងរវាងអ្នកឱ្យខ្ចី និង អ្នកខ្ចីតែប៉ុណ្ណោះ ។

(កំណត់)

នៅប្រទេសជាច្រើន កិច្ចសន្យាខ្ចីបរិភោគ គឺជាកិច្ចសន្យាដែលចាំបាច់ត្រូវប្រគល់វត្ថុ (កិច្ចសន្យាដែលបង្កើតអានុភាពដោយប្រគល់វត្ថុ) ។ ក៏ប៉ុន្តែ ក្រៅពីកិច្ចសន្យាប្រភេទនេះ នៅក្នុងប្រទេសទាំងអស់ គេទទួលស្គាល់កិច្ចសន្យាខ្ចីបរិភោគដែលបង្កើតឡើងដោយតែកិច្ចព្រមព្រៀង (កិច្ចសន្យាខ្ចីបរិភោគដោយការព្រមព្រៀង ឬ ការសន្យាជាមុននូវការខ្ចីបរិភោគ កិច្ចសន្យាដែលមានខ្លឹមសារថា នឹងផ្តល់ឥណទាននាអនាគត ជាអាទិ៍) ហើយគេប្រើកិច្ចសន្យាប្រភេទនេះទូលំទូលាយក្នុងកិច្ចការជាធម្មតា ។ ដូច្នេះហើយ ក្នុងក្រមនេះ កិច្ចសន្យាខ្ចីបរិភោគអាចបង្កើតឡើង ដោយតែការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះបាន (កិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយគ្រាន់តែមានការព្រមព្រៀងប៉ុណ្ណោះ) ។ ប៉ុន្តែ តាមគោលការណ៍សេរីភាពក្នុងការធ្វើកិច្ចសន្យា ភាគីអាចកំណត់ថា អានុភាពនៃកិច្ចសន្យានឹងកើតឡើង នៅពេល

---

[៤] "វត្ថុជំនួស" សំដៅទៅលើវត្ថុដែលអាចត្រូវបានជំនួសដោយវត្ថុផ្សេងដែលមានប្រភេទ គុណភាព និង ចំនួនដូចគ្នា

[៥] មាត្រា ៥៧៨ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

ដែលធ្វើលិខិតកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរ ឬ នៅពេលប្រគល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យានោះបាន ។

**មាត្រា ៥៨០.-** ការដកកិច្ចសន្យាខ្ចីបរិភោគមិនយកការប្រាក់ដែលមិនធ្វើជាលិខិតលាយល័ក្ខណ៍អក្សរ

ចំពោះកិច្ចសន្យាខ្ចីបរិភោគមិនយកការប្រាក់ដែលមិនធ្វើជាលិខិតលាយល័ក្ខណ៍អក្សរ ភាគីនីមួយៗនៃកិច្ចសន្យា អាចដកកិច្ចសន្យានោះនៅពេលណាក៏បាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះផ្នែកនៃវត្ថុដែលជាកម្មវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ហើយ ។

(កំណត់)

កិច្ចសន្យាខ្ចីបរិភោគដែលមិនយកការប្រាក់ គឺជាកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ ។ យើងអាចថែងថា កិច្ចសន្យានេះជាកិច្ចសន្យាដែលត្រូវបានបង្កើតឡើង ដោយការប្រគល់វត្ថុ ឬ ដោយបំពេញទម្រង់ណាមួយជាកំណត់បាន ដោយសារតែលក្ខណៈពិសេសនៃកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ ។ ក៏ប៉ុន្តែ កិច្ចសន្យាខ្ចីបរិភោគដោយមិនយកការប្រាក់ ដែលធ្វើឡើងដោយការព្រមព្រៀងដោយផ្ទាល់មាត់ ត្រូវបានប្រើយ៉ាងទូលំទូលាយ ក្នុងជីវភាពប្រចាំថ្ងៃ ដូចជាការខ្ចីលុយទៅវិញទៅមករវាងមិត្តភក្តិ ជាដើម ។ ហេតុនេះហើយមិនចាំបាច់បដិសេធទាំងស្រុងនូវអានុភាពនេះទេ គ្រាន់តែបន្ថយអានុភាពចងនៃកិច្ចសន្យាបែបនេះគ្រប់គ្រាន់ហើយ ។ ហេតុនេះហើយ ប្រសិនបើបានធ្វើកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរ អ្នកឱ្យខ្ចីមានករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុតាមកិច្ចសន្យា ក៏ប៉ុន្តែ ក្នុងករណីដែលកិច្ចសន្យាឱ្យខ្ចីលុយដែលមិនយកការប្រាក់ត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ប្រសិនបើអ្នកឱ្យខ្ចីមិនទាន់ប្រគល់លុយខ្ចីជាក់លាក់នៅឡើយទេ អ្នកឱ្យខ្ចីអាចបញ្ឈប់ការឱ្យខ្ចីលុយនោះបានដែរ ដោយមិនចាំបាច់មានមូលហេតុច្បាស់លាស់ទេ ។

**មាត្រា ៥៨១.-** ការរំលាយដោយការធ្លាក់ចុះនូវទំនុកចិត្តចំពោះអ្នកខ្ចី

១-នៅក្នុងចន្លោះពេលដែលកិច្ចសន្យាបានបង្កើតឡើង រហូតទៅដល់ពេលប្រគល់វត្ថុដែលជាកម្មវត្ថុ ប្រសិនបើស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចី ធ្លាក់ចុះយ៉ាងខ្លាំង ដែលនឹងធ្វើឱ្យមានឧបសគ្គដល់ការអនុវត្តកាតព្វកិច្ចសង អ្នកឱ្យខ្ចីអាចរំលាយកិច្ចសន្យាខ្ចីបរិភោគបាន ។

២-បើអ្នកឱ្យខ្ចីបានរំលាយកិច្ចសន្យាដោយផ្អែកតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ នៅក្នុងករណីដែលបានទទួលការប្រាក់កម្រៃជើងសារ ឬ តម្លៃថ្នូរផ្សេងទៀត ជាមុន អ្នកឱ្យខ្ចីនោះត្រូវសងទៅឱ្យអ្នកខ្ចីវិញ ។

(កំណត់)

នៅពេលបានធ្វើកិច្ចសន្យាខ្ចីបរិភោគ អ្នកឱ្យខ្ចីមានករណីយកិច្ចប្រគល់នូវវត្ថុដែលជាកម្មវត្ថុនោះ ។ ក៏ប៉ុន្តែ ក្នុងករណីដែលស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចីបានត្រូវចុះអន់ថយ ក្រោយពេលធ្វើកិច្ចសន្យា រហូតដល់ពេលប្រគល់នោះ ប្រសិនបើអ្នកឱ្យខ្ចីនៅតែមានករណីយកិច្ចប្រគល់នេះ នោះនឹងបង្កើតឱ្យមានលទ្ធផលអសមភាពមួយ ហេតុនេះហើយ ក្រមនេះចែងឱ្យអ្នកឱ្យខ្ចីអាចរំលាយកិច្ចសន្យាបាន បើមានមូលហេតុវិបត្តិឥណទាន ។

ម្យ៉ាងទៀត ក្នុងករណីដែលស្ថានភាពឥណទានរបស់កូនបំណុលបានចុះអន់ថយមុនពេលធ្វើកិច្ចសន្យា តែអ្នកឱ្យខ្ចីមិនបានដឹងមុននឹងធ្វើកិច្ចសន្យា បញ្ញត្តិនៃមាត្រានេះមិនអាចយកមកអនុវត្តបានឡើយ ប៉ុន្តែ អ្នកឱ្យខ្ចីមានលទ្ធភាពក្នុងការទទួលការការពារ តាមបញ្ញត្តិស្តីពីការឆបោក ការភាន់ច្រឡំ ជាអាទិ៍ ។ ចំពោះការចុះអន់ថយនៃស្ថានភាពឥណទានក្រោយការប្រគល់វត្ថុដែលជាកម្មវត្ថុនោះ មាត្រានេះមិនត្រូវយកមកអនុវត្តទេ គឺត្រូវចាត់ចែងតាមគោលការណ៍ផ្លាស់ប្តូរស្ថានភាព ឬ គោលការណ៍ទូទៅផ្សេងទៀត ។

**មាត្រា ៥៨២**.- ឧបសន្យានៃការខ្ចីបរិភោគ

១-បុគ្គលដែលមានករណីយកិច្ចផ្តល់តាវកាលិកជាប្រាក់ ឬ វត្ថុជំនួសផ្សេងទៀត ដោយមូលហេតុក្រៅអំពីការខ្ចីបរិភោគ ប្រសិនបើបានព្រមព្រៀងជាមួយម្ចាស់បំណុលថា យកវត្ថុនោះធ្វើជាកម្មវត្ថុនៃការខ្ចីបរិភោគ ការខ្ចីបរិភោគត្រូវបានបង្កើតឡើងដោយការព្រមព្រៀងនេះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រាតិភោគសម្រាប់កាតព្វកិច្ចចាស់ ត្រូវបានសន្មតថា ត្រូវក្លាយទៅជាប្រាតិភោគសម្រាប់កាតព្វកិច្ចថ្មី ។

(កំណត់)

ឧទាហរណ៍ ក្នុងករណីដែលអ្នកទិញមិនអាចបង់ថ្លៃលក់ ១ ម៉ឺនរៀលបានទេ ហើយអ្នកទាំងពីរបានព្រមព្រៀងថា អ្នកលក់ឱ្យអ្នកទិញខ្ចីប្រាក់ ១ ម៉ឺនរៀល តាមការពិត អ្នកលក់មិនបានឱ្យអ្នកទិញខ្ចី ១ ម៉ឺនរៀលទេ ក៏ប៉ុន្តែ ទំនាក់ទំនងនៃកិច្ចសន្យាខ្ចីបរិភោគ ត្រូវបានបង្កើតឡើង រវាងអ្នកលក់ និង អ្នកទិញ ។ ពីព្រោះករណីនេះមិនខុសពីករណីដែលអ្នកលក់ឱ្យអ្នកទិញខ្ចី ១ ម៉ឺនរៀល ហើយអ្នកទិញយកលុយនោះទៅបង់ថ្លៃលក់ឱ្យអ្នកលក់វិញ ។ ក្នុងករណីនេះ ប្រសិនបើមានការធានា ឬ សិទ្ធិហ៊ីប៉ូតែក ដើម្បីធ្វើជាប្រាតិភោគសម្រាប់សិទ្ធិលើបំណុលដែលជាតម្លៃលក់ទិញ ក្រោយមកប្រាតិភោគទាំងនេះនឹងក្លាយជាប្រាតិភោគដែលធានាកាតព្វកិច្ចនៃឧបសន្យាខ្ចីបរិភោគ លើកលែងតែមានកិច្ចព្រមព្រៀងផ្ទុយពីនោះ ។

## ផ្នែកទី ២ ការខ្ចីបរិភោគដោយភ្ជាប់ការប្រាក់

**មាត្រា ៥៨៣.-** សិទ្ធិលើបំណុលដែលជាការប្រាក់

១-ការប្រាក់ សំដៅទៅលើចំនួនទឹកប្រាក់ ឬ វត្ថុផ្សេងទៀត ដែលត្រូវបានផ្តល់ទៅឱ្យតាមសមាមាត្រនៃអំឡុងពេលនៃការប្រើប្រាស់ ក្នុងនាមជាតម្លៃតបចំពោះការប្រើប្រាស់ប្រាក់ ឬ វត្ថុ ដែលត្រូវបានប្រគល់ឱ្យអ្នកខ្ចី ហើយដែលត្រូវគណនាដោយយកចំនួនទឹកប្រាក់ ឬ វត្ថុ ដែលបានខ្ចី មកគុណជាមួយនឹងអត្រាដែលត្រូវបានកំណត់ ។

២-នៅក្នុងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ វត្ថុដែលត្រូវបានប្រគល់ឱ្យអ្នកខ្ចី ហៅថា ប្រាក់ដើម ភាគដែលបានកំណត់ ដែលត្រូវបានដាក់ចូលទៅក្នុងចំនួនទឹកប្រាក់នៃប្រាក់ដើម ហៅថាអត្រាការប្រាក់ ។

៣-ភាគីនៃកិច្ចសន្យាខ្ចីបរិភោគ អាចយកកម្មវត្ថុនៃការសងការប្រាក់មកបង្កើតជាសិទ្ធិលើបំណុល តាមការព្រមព្រៀងបាន ។ ប៉ុន្តែ ចំពោះការព្រមព្រៀងបង្កើតសិទ្ធិលើបំណុលនៃការប្រាក់ ប្រសិនបើពុំបានធ្វើតាមលិខិតជាលាយល័ក្ខណ៍អក្សរ ដោយមានចុះហត្ថលេខារបស់អ្នកខ្ចីទេ ពុំមានអានុភាពឡើយ ។

៤-នៅក្នុងការព្រមព្រៀងបង្កើតសិទ្ធិលើបំណុលនៃការប្រាក់ ដោយមិនយោលតាមលិខិតជាលាយល័ក្ខណ៍អក្សរ ដែលមានចុះហត្ថលេខារបស់អ្នកខ្ចី ប្រសិនបើអ្នកខ្ចីបានសងដោយដឹងអំពីការអនុវត្តបញ្ញត្តិវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ៣ ខាងលើនេះ ការសងមានអានុភាពត្រឹមកម្រិតដែលត្រូវបានសងនោះតែប៉ុណ្ណោះ ។

(កំណត់)

ប្រាក់ ឬ វត្ថុជំនួសផ្សេងទៀតដែលបង់ដោយយកអត្រាកំណត់មួយ តាមសមាមាត្រនៃចំនួនប្រាក់ដើម ឬ វត្ថុដើម និងអំឡុងពេលនៃប្រើប្រាស់ ក្នុងនាមជាតម្លៃថ្នូរនៃការប្រើប្រាក់ដើម ឬ វត្ថុដើមដោយអ្នកខ្ចី (តម្លៃថ្នូរចំពោះការដែលអ្នកឱ្យខ្ចីមិនអាចប្រើវត្ថុដែលជាកម្មវត្ថុរបស់ខ្លួន ក្នុងអំឡុងពេលកំណត់មួយ) ត្រូវហៅថាជាការប្រាក់ ។ ឧទាហរណ៍ដូចជាក្នុងករណីគិតការប្រាក់លើតម្លៃលក់ទិញ គេអាចគិតការប្រាក់ចំពោះសិទ្ធិលើបំណុលក្រៅពីសិទ្ធិលើបំណុលនៃការខ្ចីបរិភោគបានដែរ ។ ក៏ប៉ុន្តែ ដើម្បីយកការប្រាក់ ចាំបាច់ត្រូវមានប្រាក់ដើមជាប្រាក់ ឬ ជាវត្ថុជំនួសផ្សេងទៀត ។ រីឯក្នុងករណីដូចជាថ្លៃឈ្នួលផ្ទះវិញ តម្លៃថ្នូរដែលបង់ចំពោះការប្រើវត្ថុដែលជាកម្មវត្ថុនោះ តាមកិច្ចសន្យាខ្ចីវត្ថុកំណត់ពិសេសមួយ ហើយនឹងសងវត្ថុនោះទៅវិញ (ភតិសន្យា) មិនមែនជា "ការប្រាក់" ទេ ។

ការប្រាក់អាចជាបន្ទុកមួយដ៏ធ្ងន់សម្រាប់កូនបំណុល ហេតុនេះហើយប្រសិនបើកិច្ចព្រមព្រៀងនោះមិនបានធ្វើដោយ

លិខិតជាលាយល័ក្ខណ៍អក្សរដែលមានចុះហត្ថលេខារបស់អ្នកខ្ចីទេ ជាគោលការណ៍ សិទ្ធិលើបំណុលចំពោះការប្រាក់ មិនត្រូវកើតឡើងទេ ។ ក៏ប៉ុន្តែ ក្នុងជីវភាពរៀងរាល់ថ្ងៃ អាចមានការសន្យាបង់ការប្រាក់ដោយផ្ទាល់មាត់ ។ ក្នុងករណីនេះ ដើម្បីការពារកុំឱ្យមានវិវាទដែលអ្នកខ្ចីទាមទារឱ្យសងវិញនូវការប្រាក់ដែលខ្លួនបានបង់ដោយស្ម័គ្រចិត្តរួចហើយ កថាខណ្ឌទី ៤ ដូចខាងលើនេះ ត្រូវបានរៀបចំឡើង ។

**មាត្រា ៥៨៤**.- អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ និង អត្រាការប្រាក់ក្នុងកិច្ចសន្យា

១-អត្រាការប្រាក់ អាចកំណត់បានតាមបញ្ញត្តិច្បាប់ ឬ ដោយការព្រមព្រៀងរបស់ភាគី ។

២-ក្នុងករណីដែលត្រូវបង់ការប្រាក់ តាមការព្រមព្រៀងរវាងភាគី ឬ បញ្ញត្តិច្បាប់ ប្រសិនបើភាគីពុំបានកំណត់អំពីអត្រាការប្រាក់ទេនោះ ត្រូវអនុលោមតាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ដែលបញ្ញត្តនៅក្នុងក្រមនេះ ឬ ច្បាប់ពិសេស ។

៣-អត្រាការប្រាក់ដែលកំណត់តាមការព្រមព្រៀងរបស់ភាគី ហើយដែលហួសអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ពុំមានអានុភាពឡើយ បើពុំបានកំណត់តាមលិខិតជាលាយល័ក្ខណ៍អក្សរ យោងតាមរូបមន្តដែលកំណត់ក្នុងកថាខណ្ឌទី ៣ មាត្រា ៥៨៣ (សិទ្ធិលើបំណុលដែលជាការប្រាក់) ខាងលើទេ ។

(កំណត់)

ជាគោលការណ៍ អត្រាការប្រាក់ត្រូវកំណត់តាមការព្រមព្រៀងរបស់ភាគី (អត្រាការប្រាក់នេះ ហៅថា "អត្រាការប្រាក់ក្នុងកិច្ចសន្យា") ។ ក្នុងករណីដែលភាគីបានសន្យាបង់ការប្រាក់ តែមិនបានកំណត់នូវអត្រាការប្រាក់នេះទេ ត្រូវយកអត្រាការប្រាក់ដែលបានកំណត់ដោយក្រមនេះ ឬ ច្បាប់ផ្សេង (អត្រាការប្រាក់នេះ ហៅថា "អត្រាការប្រាក់កំណត់ដោយច្បាប់") ។ ក្នុងករណីដែលត្រូវបង់ការប្រាក់ ដោយយោងតាមបញ្ញត្តិនៃច្បាប់ (កថាខណ្ឌទី ៣ នៃមាត្រា ៤១១, កថាខណ្ឌទី ២ នៃមាត្រា ៤៦១, មាត្រា ៦៤៣, កថាខណ្ឌទី ១ នៃមាត្រា ៦៤៦, កថាខណ្ឌទី ៤ នៃមាត្រា ៧១២, កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃមាត្រា ៧៣៧, កថាខណ្ឌទី ២ នៃមាត្រា ៩១១, កថាខណ្ឌទី ២ នៃមាត្រា ៩១៥, កថាខណ្ឌទី ២ នៃមាត្រា ៩១៦, កថាខណ្ឌទី ២ នៃមាត្រា ៩៣២, មាត្រា ១១០១, មាត្រា ១១៣២, កថាខណ្ឌទី ២ នៃមាត្រា ១៣០៣ ជាដើម) ក៏ត្រូវអនុវត្តដូចគ្នាដែរ ។

ម្យ៉ាងទៀត ចំពោះអត្រាក្នុងកិច្ចសន្យាដែលខ្ពស់ជាងអត្រាការប្រាក់កំណត់ដោយច្បាប់ ចាំបាច់ត្រូវកំណត់ជាលាយល័ក្ខណ៍អក្សរ ដោយមានហត្ថលេខារបស់ភាគី ។ ដូច្នេះ ក្នុងករណីដែលការបង់ការប្រាក់នោះ ត្រូវកំណត់ជាលាយល័ក្ខណ៍

អក្សរ ដោយមានហត្ថលេខារបស់កូនបំណុល ប៉ុន្តែ អត្រាការប្រាក់នោះត្រូវបានសន្យាដោយផ្ទាល់មាត់ ពេលនោះ ប្រសិនបើអត្រាការប្រាក់ដែលបានសន្យានេះ ខ្ពស់ជាងអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ត្រូវយកអត្រាការប្រាក់ដែលកំណត់ដោយច្បាប់នេះមកគណនាការប្រាក់ ហើយប្រសិនបើអត្រាការប្រាក់ដែលបានសន្យានេះ ទាបជាងអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ត្រូវយកអត្រាការប្រាក់ក្នុងកិច្ចសន្យានេះមកគណនាការប្រាក់ ។

**មាត្រា ៥៨៥**.- ការកម្រិតការប្រាក់

១-អត្រាការប្រាក់ដែលត្រូវបានកម្រិត សំដៅទៅលើអត្រាការប្រាក់អតិបរមាដែលអាចកំណត់បានដោយស្របច្បាប់ តាមការព្រមព្រៀងរបស់ភាគី ដែលកំណត់ដោយច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀត ។

២-ភាគីអាចកំណត់ការប្រាក់ ខ្ពស់ជាងអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ដែលបានបញ្ញត្តក្នុងកថាខណ្ឌទី ២ នៃមាត្រា ៥៨៤ (អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ និង អត្រាការប្រាក់ក្នុងកិច្ចសន្យា) ខាងលើនេះ បាន តែមិនអាចកំណត់លើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិតបានឡើយ ។

៣-ប្រសិនបើភាគីបានកំណត់អត្រាការប្រាក់លើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិត កិច្ចសន្យានៃភាគដែលលើសពីកម្រិតនៃអត្រាការប្រាក់នោះ ត្រូវទុកជាមោឃៈ រីឯអ្នកខ្ចីមានករណីយកិច្ចសងតែចំពោះការប្រាក់ដែលត្រូវបានគណនា តាមអត្រាការប្រាក់ដែលត្រូវបានកម្រិតនោះ តែប៉ុណ្ណោះ ។

៤-នៅក្នុងករណីដែលបានសងការប្រាក់ដែលលើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិតហើយ ត្រូវចាត់ទុកថាភាគដែលលើសពីការកម្រិតនោះ ជាការកាត់បំណុលទៅលើប្រាក់ដើម ។ នៅក្នុងករណីដែលបានកាត់បំណុលទៅលើប្រាក់ដើម ចំពោះផ្នែកដែលលើសពីការកម្រិតហើយ តែនៅមានសេសសល់ទៀត អ្នកឱ្យខ្ចីត្រូវសងទៅឱ្យអ្នកខ្ចីដោយភ្ជាប់ជាមួយ នូវប្រាក់សំណងនៃការខូចខាត ដោយគណនាតាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ដោយគិតចាប់ពីថ្ងៃដែលបានបង្កើតឱ្យមានការសេសសល់នៃការសងរហូតដល់ថ្ងៃដែលបានសងនោះ ។

៥-ចំពោះការអនុវត្តមាត្រានេះ នៅក្នុងករណីដែលចំនួនប្រាក់ដើមលើកិច្ចសន្យាខុសគ្នាពីចំនួនទឹកប្រាក់នៃវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ដោយជាក់ស្តែង ដូចជាករណីនៃ

ការប្រគល់ប្រាក់ដើមដោយដកការប្រាក់ដែលត្រូវបង់នាពេលអនាគត ជាអាទិ៍ ចំនួនទឹកប្រាក់នៃវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ដោយជាក់ស្តែងទៅឱ្យអ្នកខ្ចីនោះ ត្រូវទុកជាចំនួនប្រាក់ដើម ។

៦-ចំពោះការអនុវត្តមាត្រានេះ ប្រាក់ និង វត្ថុផ្សេងទៀត ដែលអ្នកឱ្យខ្ចីបានទទួលក្រៅពីប្រាក់ដើម ទាក់ទងទៅនឹងកិច្ចសន្យាខ្ចីបរិភោគ ទោះបីជាបានទទួលនៅក្នុងនាមជាប្រាក់រង្វាន់ កម្រៃជើងសារ កម្រៃស៊ើបអង្កេត និង កម្រៃផ្សេងៗទៀតក៏ដោយ ត្រូវចាត់ទុកថាជាការប្រាក់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសោហ៊ុយនៃការធ្វើកិច្ចសន្យា និង សោហ៊ុយនៃការសង ។

(កំណត់)

តាមប្រវត្តិសាស្ត្រ រហូតដល់សព្វថ្ងៃនេះ ឧបសគ្គនៃការឱ្យខ្ចីប្រាក់ដោយយកការប្រាក់ខ្ពស់ កើតឡើងមិនចេះដាច់សោះ ។ ហេតុនេះហើយបានជាប្រទេសជាច្រើន បានបង្កើតបញ្ញត្តិធ្វើការកម្រិតនូវការឱ្យខ្ចីប្រាក់ដោយយកការប្រាក់ខ្ពស់ ដូច្នេះក្រមនេះក៏មានបញ្ញត្តិដូចគ្នាដែរ ។

ដើម្បីឱ្យរួចផុតពីការអនុវត្តនៃបញ្ញត្តិកម្រិតការប្រាក់នេះ គេច្រើនតែកាត់យកការប្រាក់ជាមុន ឬ គេយកជាសោហ៊ុយ ឬ យកដោយប្រើឈ្មោះប្រភេទកម្រៃផ្សេងៗ ។ ហេតុនេះហើយ កថាខណ្ឌទី ៥ និង កថាខណ្ឌទី ៦ នេះត្រូវបានបញ្ញត្តឡើងដើម្បីធ្វើការកម្រិតនូវអំពើជៀសវាងច្បាប់ទាំងនេះ ។

ឧទាហរណ៍ ក្នុងករណីដែលអត្រាការប្រាក់ដែលត្រូវបានកម្រិតនោះគឺ ២០% ក្នុងមួយឆ្នាំ ប្រសិនបើបានធ្វើកិច្ចសន្យាខ្ចីបរិភោគប្រាក់ ១ ម៉ឺនរៀល ដោយគិតការប្រាក់ក្នុងកិច្ចសន្យា ៣០% ក្នុងមួយឆ្នាំ ហើយអ្នកខ្ចីបានទទួល ៧ ពាន់រៀលក្រោយពីត្រូវគេកាត់យកការប្រាក់សម្រាប់ឆ្នាំទីមួយ ហើយអ្នកខ្ចីបានបង់ការប្រាក់ ៣ ពាន់រៀលក្នុងមួយឆ្នាំ ជារៀងរាល់ឆ្នាំ ។ ប្រសិនបើមើលទៅតាមបែបបទ ដោយសារតែកូនបំណុលបានបង់តែការប្រាក់ ហេតុនេះហើយ ប្រាក់ដើម ១ ម៉ឺនរៀលនៅសល់ដដែល ។ ប៉ុន្តែ តាមការពិត កូនបំណុលបានទទួលតែ ៧ ពាន់រៀលប៉ុណ្ណោះ ដូច្នេះការប្រាក់នៃឆ្នាំទីមួយគឺ ២០% = ១៤០០ រៀល ជាការប្រាក់ដែលមានអានុភាពត្រឹមត្រូវ ។ ហេតុនេះហើយ ១៦០០ រៀលដែលបានបង់លើស ១៤០០ រៀល ក្នុងចំនួនប្រាក់ ៣០០០ រៀលនោះ ត្រូវយកមកកាត់បំណុលនៃប្រាក់ដើមដោយយោងទៅតាមកថាខណ្ឌទី ៤ ហើយប្រាក់ដើមនៃឆ្នាំទី២ គឺ ៧០០០ - ១៦០០ = ៥៤០០ រៀល ។ រីឯការប្រាក់សម្រាប់ឆ្នាំទី ២ ដែលគណនាតាមការប្រាក់កម្រិត ២០% នោះ គឺ ៥៤០០ x ០,២០ = ១០៨០ រៀល ដូច្នេះក្នុងចំនួនប្រាក់ ៣០០០ រៀលនោះ ចំនួនប្រាក់ ១៩២០ រៀល ដែលបានបង់លើសការប្រាក់កម្រិតនៅក្នុងឆ្នាំទី ២ នោះត្រូវយកមកធ្វើការកាត់បំណុលនៃប្រាក់ដើម ។ ហេតុនេះហើយ ប្រាក់ដើមដែលនៅសល់សម្រាប់ឆ្នាំទី ៣ គឺ ៥៤០០- ១៩២០ = ៣៤៨០ រៀល ។ ដូច្នេះ ត្រូវគណនាជាបន្តបន្ទាប់ រហូតដល់សងប្រាក់ដើមរួចរាល់ ហើយប្រាក់ដែលបានបង់

ក្រោយប្រាក់ដើមនៅសល់សូន្យនោះ គឺជាសេចក្ដីចម្រើនដោយឥតហេតុ ដូច្នេះ យោងទៅតាមបញ្ញត្តិនៃវាក្យខណ្ឌទី ២ កថាខណ្ឌទី ៤ នៃមាត្រានេះ អ្នកឱ្យខ្ចីត្រូវសងប្រាក់នេះទៅអ្នកខ្ចីវិញ ដោយបូកទាំងការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវផង ។

**មាត្រា ៥៨៦**.- ពេលវេលានៃការបង់ការប្រាក់ និង ការប្រាក់សមាសដែលកំណត់ដោយច្បាប់

១-បើគ្មានការកំណត់ពិសេសទេ ការប្រាក់ ត្រូវបង់នៅរៀងរាល់ពេលដែលពេលវេលា ១ (មួយ) ឆ្នាំ បានកន្លងផុត គិតចាប់ពីពេលដែលបានប្រគល់វត្ថុដែលជាកម្មវត្ថុ ។ ប៉ុន្តែ ប្រសិនបើត្រូវសងវត្ថុដែលជាកម្មវត្ថុនោះ នៅមុនពេលដែលពេលវេលា ១ (មួយ) ឆ្នាំមិនទាន់បានកន្លងផុត ត្រូវបង់ការប្រាក់នៅពេលប្រគល់វត្ថុដែលជាកម្មវត្ថុនោះ ។

២-ក្នុងករណីដែលមានការយឺតយ៉ាវមិនបានសងការប្រាក់ សម្រាប់រយៈពេលចាប់ពី ១ (មួយ) ឆ្នាំ ឡើងទៅ ហើយទោះបីជាអ្នកឱ្យខ្ចីបានដាស់តឿនឱ្យសងយ៉ាងណាក៏ដោយ ក៏អ្នកខ្ចីមិនព្រមសងការប្រាក់នោះ អ្នកឱ្យខ្ចីអាចបូកការប្រាក់បញ្ចូលទៅក្នុងប្រាក់ដើមបាន ។

(កំណត់)

តាមរយៈការបូកបញ្ចូលការប្រាក់ទៅក្នុងប្រាក់ដើម ការប្រាក់នឹងត្រូវគិតទៅលើការប្រាក់ជាបន្តទៀត (នេះគេហៅថា "ការប្រាក់សមាស") ។ ឧទាហរណ៍ ការប្រាក់ត្រូវបង់ជារៀងរាល់ខែ តែប្រសិនបើមិនបានបង់ទេ គេនឹងបូកបញ្ចូលទៅក្នុងប្រាក់ដើមដោយស្វ័យប្រវត្តិ ហើយការបូកបញ្ចូលទៅក្នុងប្រាក់ដើមក្នុងរយៈពេលដ៏ខ្លី ជាសារធាតុ នឹងធ្វើឱ្យការប្រាក់កើនយ៉ាងលឿន ។ ដូច្នេះហើយ ប្រសិនជាគ្មានការព្រមព្រៀងពិសេសរវាងភាគីទេ ការប្រាក់ត្រូវសងដោយគិតជាឆ្នាំ ហើយទទួលស្គាល់ឱ្យគិតការប្រាក់សមាស តែក្នុងករណីដែលមានការយឺតយ៉ាវក្នុងការបង់ការប្រាក់សម្រាប់អំឡុងពេលចាប់ពីមួយឆ្នាំ ឡើងទៅ ហើយអ្នកខ្ចីមិនបានបង់ ទោះបីជាត្រូវបានដាស់តឿនក៏ដោយ ។ម្យ៉ាងទៀត ប្រសិនបើមានកិច្ចព្រមព្រៀងពិសេសដោយបូកបញ្ចូលការប្រាក់ទៅក្នុងប្រាក់ដើមច្រើនដងក្នុងមួយឆ្នាំ ចំពោះការអនុវត្តមាត្រា ៥៨៥ ត្រូវគិតមើលទំនាក់ទំនងរវាងការប្រាក់សរុបក្នុងមួយឆ្នាំ និង ប្រាក់ដើមនៃឆ្នាំនោះ ហើយសម្រេចថាតើការប្រាក់សុបនោះលើសការប្រាក់ដែលត្រូវបានកម្រិតក្នុងមាត្រានោះ ឬទេ ។

## ផ្នែកទី ៣ករណីយកិច្ចឱ្យខ្ចីរបស់អ្នកឱ្យខ្ចី

**មាត្រា ៥៨៧**.- ករណីយកិច្ចឱ្យខ្ចីវត្ថុដែលជាកម្មវត្ថុ

១-អ្នកឱ្យខ្ចី មានករណីយកិច្ចឱ្យអ្នកខ្ចីប្រើប្រាស់វត្ថុ ដោយសមស្របតាមកិច្ចសន្យា ។

២-អ្នកខ្ចី អាចប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងវត្ថុ ដោយសេរីបាន ហើយត្រូវទទួលបន្ទុកហានិភ័យ លើការបាត់បង់ ឬ ខូចខាត ចំពោះវត្ថុដែលជាកម្មវត្ថុ ដែលកើតឡើងដោយសារមូលហេតុដែលមិនមែនជាបន្ទុករបស់អ្នកឱ្យខ្ចី ក្នុងនាមជាកម្មសិទ្ធិករ គិតចាប់ពីថ្ងៃដែលបានទទួលការប្រគល់វត្ថុដែលជាកម្មវត្ថុ ។

(កំណត់)

កិច្ចសន្យាខ្ចីបរិភោគខុសគ្នានឹងកិច្ចសន្យាខ្ចីប្រើ ឬ ភតិសន្យា ដែលអ្នកខ្ចីមានករណីយកិច្ចសងនូវវត្ថុដដែលដែលខ្លួនបានខ្ចីនោះ ពីព្រោះក្នុងកិច្ចសន្យាខ្ចីបរិភោគ អ្នកខ្ចីដែលទទួលការប្រគល់នូវវត្ថុជំនួស (វត្ថុដែលអាចត្រូវបានជំនួសដោយវត្ថុផ្សេងដែលមានប្រភេទ គុណភាព និង ចំនួនដូចគ្នា) ធ្វើលទ្ធកម្មនូវកម្មសិទ្ធិនៃវត្ថុនោះ និង ប្រើប្រាស់ អាស្រ័យផល ចាត់ចែងវត្ថុនោះ ដោយសេរី ហើយសងទៅឱ្យអ្នកខ្ចីវិញ នូវវត្ថុដែលមានប្រភេទដូចគ្នា ចំនួនដូចគ្នា ។

មាត្រានេះបញ្ញត្តឱ្យអ្នកឱ្យខ្ចីមានករណីយកិច្ចឱ្យអ្នកខ្ចីប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនោះ ក្នុងអំឡុងពេលកំណត់មួយ (ផលប្រយោជន៍សេដ្ឋកិច្ចដែលបានមកពីការប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនោះ អ្នកឱ្យខ្ចីមិនអាចទទួលដោយខ្លួនឯងបានទេ ត្រូវឱ្យអ្នកខ្ចីទទួលផលប្រយោជន៍នោះទៅវិញ) ។ ជាលទ្ធផលនេះ កិច្ចសន្យាខ្ចីបរិភោគដោយមានការប្រាក់ ក្លាយទៅជាកិច្ចសន្យាអញ្ញមញ្ញដែលយកតម្លៃថ្នូរ (មូលា) ។

**មាត្រា ៥៨៨**.- ការទទួលខុសត្រូវក្នុងការធានា របស់អ្នកឱ្យខ្ចី ក្នុងការប្រគល់វត្ថុរបស់អ្នកដទៃ

១-នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ អ្នកឱ្យខ្ចីដែលបានប្រគល់វត្ថុដែលមិនស្ថិតនៅក្រោមកម្មសិទ្ធិរបស់ខ្លួន មានករណីយកិច្ចត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិនៃវត្ថុនោះ ហើយផ្ទេរទៅឱ្យអ្នកខ្ចី ឬ ត្រូវប្តូរជាមួយនឹងវត្ថុផ្សេងទៀតដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់ខ្លួន ។ ប៉ុន្តែ នៅក្រោយពេលដែលអ្នកខ្ចីបានបរិភោគវត្ថុនោះរួចហើយ ពុំអាចទាមទារឱ្យប្រគល់វត្ថុជំនួសបានឡើយ ។

២-ប្រសិនបើអ្នកឱ្យខ្ចី ពុំអាចអនុវត្តកាតព្វកិច្ចដែលបានបញ្ញត្តក្នុងកថាខណ្ឌទី ១ ខាងលើនេះទេ អ្នកខ្ចីអាចរំលាយកិច្ចសន្យាបាន ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ប្រសិនបើបានទទួលការប្រគល់ដោយពុំបានដឹងថាអ្នកឱ្យខ្ចីនោះគ្មានសិទ្ធិ អ្នកខ្ចីអាចទាមទារឱ្យ

អ្នកឱ្យខ្ចីសងសំណងនៃការខូចខាតបាន ។

៤-នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដោយគ្មានការប្រាក់ បញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះតែករណីដែលអ្នកឱ្យខ្ចីបានដឹងថាខ្លួនគ្មានសិទ្ធិចាត់ចែងវត្ថុដែលជាកម្មវត្ថុ ហើយបានប្រគល់វត្ថុរបស់អ្នកដទៃនោះដោយពុំបានជូនដំណឹងទៅឱ្យអ្នកខ្ចី ។

៥-លើកលែងតែករណីដែលបានទទួលការប្រគល់វត្ថុជំនួស ដោយផ្អែកតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ៤ ខាងលើនេះ ប្រសិនបើអ្នកខ្ចីវត្ថុរបស់អ្នកដទៃ បានសងវត្ថុដែលត្រូវបានផ្តល់ ឬ តម្លៃនៃវត្ថុនោះ ឱ្យទៅកម្មសិទ្ធិករ អ្នកខ្ចីវត្ថុរបស់អ្នកដទៃនោះ ត្រូវរួចផុតពីករណីយកិច្ចសង ចំពោះអ្នកឱ្យខ្ចី ។

(កំណត់)

ប្រសិនបើវត្ថុដែលអ្នកឱ្យខ្ចីប្រគល់ទៅឱ្យអ្នកខ្ចី ជាកម្មសិទ្ធិរបស់អ្នកផ្សេង កិច្ចសន្យាខ្ចីបរិភោគមិនមែនក្លាយទៅជាមោឃៈទេ ប៉ុន្តែ អ្នកឱ្យខ្ចីមានករណីយកិច្ចធ្វើឱ្យអ្នកខ្ចីធ្វើលទ្ធកម្មនូវកម្មសិទ្ធិនៃវត្ថុនោះ ឬ ប្រគល់វត្ថុផ្សេងជំនួសវត្ថុនោះចំពោះអ្នកខ្ចីនោះ ។ ប្រសិនបើអ្នកឱ្យខ្ចីមិនអាចធ្វើដូច្នោះបានទេ អ្នកខ្ចីអាចរំលាយនូវកិច្ចសន្យាបាន ទោះបីជាអ្នកខ្ចីនោះសុចរិតក៏ដោយ ឬ ទុច្ចរិតក៏ដោយ ។ម្យ៉ាងទៀត អ្នកខ្ចីសុចរិត អាចទាមទារនូវសំណងនៃការខូចខាតចំពោះអ្នកឱ្យខ្ចីបាន (មិនចាំបាច់មានហេតុដែលនាំឱ្យអ្នកឱ្យខ្ចីត្រូវទទួលខុសត្រូវទេ) ។ ប៉ុន្តែ ក្នុងករណីដែលជាការខ្ចីបរិភោគដោយឥតមានការប្រាក់ មានតែអ្នកឱ្យខ្ចីទុច្ចរិតប៉ុណ្ណោះទេដែលត្រូវទទួលខុសត្រូវ ។ ម្យ៉ាងទៀត ចំពោះរូបិយវត្ថុវិញ ជាគោលការណ៍អ្នកដែលកាន់កាប់រូបិយវត្ថុនោះ ត្រូវបានចាត់ទុកថាជាកម្មសិទ្ធិករ ហេតុនេះហើយ មាត្រានេះ និង មាត្រាបន្ទាប់មិនត្រូវយកមកអនុវត្តទេ ។

**មាត្រា ៥៨៩**.- សិទ្ធិរំលាយរបស់អ្នកឱ្យខ្ចីវត្ថុអ្នកដទៃ

អ្នកឱ្យខ្ចីដែលបានប្រគល់វត្ថុដែលជាកម្មវត្ថុ ដោយពុំដឹងថាជាវត្ថុរបស់អ្នកដទៃ ប្រសិនបើពុំអាចធ្វើឱ្យអ្នកខ្ចីបានលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុ ឬ វត្ថុជំនួសទេ អាចរំលាយកិច្ចសន្យាបាន ។ ប៉ុន្តែ ប្រសិនបើអ្នកខ្ចីសុចរិត មានសិទ្ធិទាមទារសំណងនៃការខូចខាតដោយផ្អែកតាមបញ្ញត្តិនៃមាត្រា ៥៨៨ (ការទទួលខុសត្រូវក្នុងការធានា របស់អ្នកឱ្យខ្ចី ក្នុងការប្រគល់វត្ថុរបស់អ្នកដទៃ) ខាងលើនេះ លុះត្រាតែក្នុងករណីដែលបានសងសំណងនៃការខូចខាតនោះ ទើបអាចរំលាយកិច្ចសន្យាបាន ។

(កំណត់)

ប្រសិនបើអ្នកឱ្យខ្ចីបានប្រគល់ស្រូវ ជាដើម ដោយយល់ច្រឡំថាជារបស់ខ្លួនទៅឱ្យអ្នកខ្ចី ប៉ុន្តែ មិនមែនជាកម្មសិទ្ធិរបស់ខ្លួនទេនោះ ជាដំបូង អ្នកឱ្យខ្ចីមានករណីយកិច្ចធ្វើឱ្យអ្នកខ្ចីធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុនោះ ឬ ប្រគល់វត្ថុផ្សេងជំនួសវត្ថុនោះទៅឱ្យអ្នកខ្ចី ។ ប៉ុន្តែ ប្រសិនបើមិនអាចធ្វើបានទេ អ្នកឱ្យខ្ចីអាចរំលាយកិច្ចសន្យានោះបាន លុះត្រាតែអ្នកឱ្យខ្ចីនោះសុចរិត ។ ម្យ៉ាងទៀត ចំពោះការខ្ចីបរិភោគដោយមានការប្រាក់ ប្រសិនបើអ្នកខ្ចីសុចរិត អ្នកឱ្យខ្ចីត្រូវសងនូវសំណងនៃការខូចខាតចំពោះអ្នកខ្ចី ដោយយោងតាមបញ្ញត្តិនៃមាត្រាមុននេះ ។

**មាត្រា ៥៩០**.- ការទទួលខុសត្រូវក្នុងការធានារបស់អ្នកឱ្យខ្ចីនូវវត្ថុដែលមានវិការៈ

១-នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ ប្រសិនបើមានវិការៈកំបាំងនៅក្នុងវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ អ្នកខ្ចីដែលបានទទួលការប្រគល់ដោយមិនបានដឹងអំពីវិការៈនោះ អាចទាមទារឱ្យប្តូរជាមួយនឹងវត្ថុដែលគ្មានវិការៈ និង អាចទាមទារសំណងនៃការខូចខាតបាន ។

២-នៅក្នុងកិច្ចសន្យាខ្ចីបរិភោគដែលគ្មានការប្រាក់ អ្នកខ្ចីដែលបានទទួលការប្រគល់វត្ថុដែលមានវិការៈ អាចសងតម្លៃនៃវត្ថុដែលមានវិការៈបាន ។ ប៉ុន្តែ បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកឱ្យខ្ចីបាន ដឹងអំពីវិការៈនោះហើយ តែពុំបានជូនដំណឹងទៅឱ្យអ្នកខ្ចី ។

(កំណត់)

ក្នុងករណីដែលអ្នកឱ្យខ្ចីនៃកិច្ចសន្យាខ្ចីបរិភោគដែលភ្ជាប់ការប្រាក់ បានប្រគល់ស្រូវ ជាអាទិ៍ ដល់អ្នកខ្ចី ប៉ុន្តែ ស្រូវនោះមានជម្ងឺ អ្នកខ្ចីដែលបានទទួលស្រូវនោះ ដោយមិនបានដឹងថា ស្រូវនោះមានជម្ងឺ អាចទាមទារឱ្យអ្នកឱ្យខ្ចីប្តូរស្រូវល្អដែលគ្មានជម្ងឺឱ្យខ្លួនវិញបាន ហើយអាចទាមទារនូវសំណងនៃការខូចខាត ដោយសារការឆ្លងជម្ងឺដល់ស្រូវដែលអ្នកខ្ចីមាន ដោយសារស្រូវដែលមានជម្ងឺនោះ ជាអាទិ៍ បាន ។

អ្នកខ្ចីស្រូវ ជាអាទិ៍ ដោយគ្មានការប្រាក់ មិនអាចទាមទារឱ្យអ្នកឱ្យខ្ចីប្តូរនូវស្រូវល្អវិញ ឬ មិនអាចទាមទារឱ្យអ្នកឱ្យខ្ចីសងនូវសំណងនៃការខូចខាតបានឡើយ ទោះបីជាស្រូវនោះមានវិការៈក៏ដោយ ។ ក្នុងករណីនេះ តាមតក្កសាស្ត្រ អ្នកខ្ចីត្រូវសងនូវស្រូវដែលមានវិការៈដូចគ្នាវិញ ប៉ុន្តែ នេះមិនស្របនឹងភាពជាក់ស្តែងទេ ហេតុនេះហើយ មាត្រានេះចែងថា អ្នកខ្ចីអាចឱ្យសងជាប្រាក់ស្មើនឹងតម្លៃស្រូវដែលមានវិការៈទៅវិញបាន ។ ប៉ុន្តែ ក្នុងករណីដែលអ្នកឱ្យខ្ចីដឹងថាមានវិការៈ ហើយបានលាក់ចំពោះអ្នកខ្ចី អ្នកឱ្យខ្ចីត្រូវសងនូវសំណងនៃការខូចខាតដែលអ្នកខ្ចីបានទទួលរងគ្រោះដោយសារវិការៈនោះ ។

## ផ្នែកទី ៤ ករណីយកិច្ចសងរបស់អ្នកខ្ចី

**មាត្រា ៥៩១**.- ករណីយកិច្ចត្រូវសងប្រាក់ដើម និង បង់ការប្រាក់របស់អ្នកខ្ចី

១-អ្នកខ្ចី មានករណីយកិច្ចត្រូវសងទៅអ្នកឱ្យខ្ចី នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលការប្រគល់ នៅថ្ងៃដែលត្រូវសង ។

២-អ្នកខ្ចីនៃកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ ត្រូវបង់ការប្រាក់ តាមបញ្ញត្តិពីមាត្រា ៥៨៤ (អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ និង អត្រាការប្រាក់ក្នុងកិច្ចសន្យា) ដល់មាត្រា ៥៨៦ (ពេលវេលានៃការបង់ការប្រាក់ និង ការប្រាក់សមាសដែលកំណត់ដោយច្បាប់) នៃក្រមនេះ ។

(កំណត់)

ឧទាហរណ៍ អ្នកដែលបានខ្ចីអង្ករដែលមានគុណភាពល្អ ១០ គីឡូ ក្នុងរយៈពេលមួយឆ្នាំ ដោយមានអត្រាការប្រាក់ក្នុងកិច្ចសន្យា ១០% អាចបរិភោគអង្ករនោះដោយសេរីបាន ប៉ុន្តែ មួយឆ្នាំក្រោយមក ត្រូវសងអង្ករដែលមានគុណភាពដូចគ្នាចំនួន ១១ គីឡូ ទៅអ្នកឱ្យខ្ចីវិញ ។ ប្រសិនបើអង្ករដែលសងដោយអ្នកខ្ចី មានគុណភាពមិនល្អ ឬ មានទម្ងន់តែ ១០ គីឡូ អ្នកឱ្យខ្ចីអាចបដិសេធមិនទទួលនូវការសងនោះដោយយកមូលហេតុថា សំណើផ្តល់ការសងនោះ មិនស្របតាមខ្លឹមសារនៃកាតព្វកិច្ចបាន ហើយអាចទាមទារឱ្យអ្នកខ្ចីទទួលខុសត្រូវចំពោះការមិនបានអនុវត្តរបស់អ្នកខ្ចីបាន ។

**មាត្រា ៥៩២**.- ការសងដោយយោលតាមតម្លៃ

១-ប្រសិនបើពុំអាចសងដោយផ្អែកតាមបញ្ញត្តិនៃមាត្រា ៥៩១ (ករណីយកិច្ចត្រូវសងប្រាក់ដើម និង បង់ការប្រាក់របស់អ្នកខ្ចី) ខាងលើបានទេ អ្នកខ្ចីមានករណីយកិច្ចត្រូវបង់ប្រាក់ដែលសមរម្យនឹងតម្លៃនៃវត្ថុដែលជាកម្មវត្ថុ នៅទីកន្លែង និង ថ្ងៃដែលត្រូវសង ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើពុំបានកំណត់ថ្ងៃ ឬ ទីកន្លែងដែលត្រូវសងទេ ត្រូវចាត់ទុកថាត្រូវបង់ចំនួនប្រាក់ដែលសមរម្យនឹងតម្លៃនោះ នៅថ្ងៃ និង ទីកន្លែងដែលបានធ្វើកិច្ចសន្យា ។

(កំណត់)

ឧទាហរណ៍ ក្នុងករណីដែលបានធ្វើកិច្ចសន្យាខ្ចីបរិភោគថ្នាំសម្លាប់សត្វល្អិតសម្រាប់កសិកម្មចំនួន ៥០ គីឡូ ហើយក្រោយពីបានប្រគល់វត្ថុដែលជាកម្មវត្ថុនោះ រហូតដល់កាលបរិច្ឆេទដែលត្រូវសងតាមកិច្ចសន្យាវិញ ផលិតកម្ម និង

ការលក់ថ្នាំសម្លាប់សត្វល្អិតនោះ ត្រូវបានហាមឃាត់ ។ ក្នុងករណីនេះ អ្នកខ្ចីមិនអាចសងថ្នាំសម្លាប់សត្វល្អិតដែលមានប្រភេទដូចគ្នាបានទេ ហេតុនេះហើយ ដោយយោងតាមមាត្រានេះ អ្នកខ្ចីអាចសងជាប្រាក់ដែលស្មើនឹងតម្លៃថ្នាំនោះបាន ។

**មាត្រា ៥៩៣**.- ការប្រែប្រួលនៃតម្លៃរូបិយវត្ថុ ជាអាទិ៍

ទោះបីជាតម្លៃរូបិយវត្ថុ ឬ តម្លៃនៃវត្ថុ មានការប្រែប្រួល នៅមុនពេលសងក៏ដោយ លើកលែងតែក្នុងករណីដែលមានការព្រមព្រៀងពិសេស អ្នកខ្ចីត្រូវសងនូវចំនួនទឹកប្រាក់ដូចគ្នានឹងចំនួនទឹកប្រាក់ដែលទទួលបានពីការប្រគល់ ។

(កំណត់)

ឧទាហរណ៍ ក្រោយពីឱ្យខ្ចី ១ ម៉ឺនរៀល ដល់ពេលដែលត្រូវសងវិញ ទោះបីជាតម្លៃរូបិយវត្ថុនោះបានចុះក៏ដោយ អ្នកខ្ចីគ្រាន់តែសងជាទឹកប្រាក់ចំនួន ១ ម៉ឺនរៀល គ្រប់គ្រាន់ហើយ (គោលការណ៍នាមករណ៍) ។ ប្រសិនបើចង់ទទួលនូវតម្លៃសារធាតុ ចាំបាច់ត្រូវធ្វើការសន្យាពិសេស ដោយគិតប្រាក់ដែលត្រូវសងទៅតាមការផ្លាស់ប្តូរនៃតម្លៃរូបិយវត្ថុ តម្លៃមាស តម្លៃទំនិញ ជាអាទិ៍ ។ ក្នុងករណីដែលបានទទួលលទ្ធផលមួយដែលមានអសមភាពយ៉ាងខ្លាំងដោយសារតែការគោរពនូវគោលការណ៍នាមករណ៍នេះ គេអាចកែប្រែវិញ ទៅតាមគោលការណ៍ទូទៅដូចជា "គោលការណ៍នៃការផ្លាស់ប្តូរស្ថានភាព" ជាអាទិ៍ បាន ។

**មាត្រា ៥៩៤**.- ពេលវេលានៃការសង

១-ប្រសិនបើភាគីបានកំណត់កាលបរិច្ឆេទនៃការសង អ្នកឱ្យខ្ចីមិនអាចទាមទារឱ្យសងវត្ថុដែលជាកម្មវត្ថុបានឡើយ រហូតដល់ពេលកំណត់ត្រូវសង តាមកាលបរិច្ឆេទនៃកិច្ចសន្យា ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលហេតុដែលបានកំណត់នៅក្នុងមាត្រា ៣៣១ (ការបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល) នៃក្រមនេះ បានកើតឡើង ។

២-ប្រសិនបើភាគីមិនបានកំណត់កាលបរិច្ឆេទនៃការសងទេ អ្នកឱ្យខ្ចីអាចដាស់តឿនឱ្យសង ដោយកំណត់អំឡុងពេលសមរម្យបាន ។

៣-អ្នកខ្ចីនៃកិច្ចសន្យាខ្ចីបរិភោគដោយគ្មានការប្រាក់ អាចសងនៅពេលណាក៏បាន ។

៤-អ្នកខ្ចីនៃកិច្ចសន្យាខ្ចីបរិភោគដែលមានការប្រាក់ អាចសងនៅមុនកាលបរិច្ឆេទសងដែលបានកំណត់ដោយកិច្ចសន្យាបាន ។ ប៉ុន្តែ នៅក្នុងករណីដែលធ្វើឱ្យមានការខូច

ខាតដល់អ្នកឱ្យខ្ចីដោយសារការសងនោះ អ្នកខ្ចីត្រូវសងសំណងនៃការខូចខាត ដោយផ្អែកតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៣៣០ (ប្រយោជន៍នៃការកំណត់ពេល) នៃក្រមនេះ ។

(កំណត់)

កថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ គ្រាន់តែចែងថា គោលការណ៍ទូទៅនៃពេលសងកាតព្វកិច្ច ត្រូវយកមកអនុវត្តចំពោះការខ្ចីបរិភោគប៉ុណ្ណោះ (សូមមើលមាត្រា ៣២៩ ដល់មាត្រា ៣៣១ និង មាត្រា ៣៩១) ។

ចំពោះកាតព្វកិច្ចដែលឥតមានកំណត់ពេលវេលាសងវិញ ជាគោលការណ៍ នៅពេលដែលម្ចាស់បំណុលដាស់តឿនពេលដែលត្រូវសងបំណុលមកដល់ (មាត្រា ៣៨៨ ចំណុច គ) ប៉ុន្តែ ប្រសិនបើយកគោលការណ៍នេះមកអនុវត្តចំពោះការខ្ចីបរិភោគ ពេលណាក៏អ្នកខ្ចីត្រូវត្រៀមសងវិញដែរ ហើយការខ្ចីបរិភោគក្លាយទៅជាគ្មានន័យទៅវិញ ហេតុនេះហើយបានជាកថាខណ្ឌទី ២ នៃមាត្រានេះបញ្ញត្តថា ក្រោយអំឡុងពេលសមរម្យមួយបានកន្លងផុតពីពេលដាស់តឿនសងទើបដល់ពេលត្រូវសង (ក្នុង "អំឡុងពេលសមរម្យ" នោះ អ្នកខ្ចីអាចត្រៀមដើម្បីសងបាន) ។

ចំពោះកិច្ចសន្យាខ្ចីបរិភោគដែលមានការប្រាក់ ការសងមុនពេលកំណត់ នឹងធ្វើឱ្យខូចផលប្រយោជន៍ដល់ការទទួលការប្រាក់របស់អ្នកឱ្យខ្ចី ហេតុនេះហើយបានជាមានចម្ងល់មួយកើតឡើងថា ប្រហែលជាអ្នកខ្ចីគ្មានសេរីភាពក្នុងការបោះបង់ចោលនូវផលប្រយោជន៍នៃការកំណត់ពេលទេ ហេតុដូច្នេះ កថាខណ្ឌទី ៤ ចែងបញ្ជាក់ថា អ្នកខ្ចីអាចបោះបង់ចោលនូវផលប្រយោជន៍នៃការកំណត់ពេលបាន (អ្នកឱ្យខ្ចីមិនអាចទាមទារឱ្យសងមុនពេលកំណត់បានទេ) ។ ក្នុងករណីនេះ អ្នកខ្ចីមានករណីយកិច្ចត្រូវសងនូវការខូចខាតរបស់អ្នកឱ្យខ្ចី ដោយស្របតាមកថាខណ្ឌទី ២ នៃមាត្រា ៣៣០ ។ អ្វីទៅដែលជា "ការខូចខាត" នេះ អាស្រ័យទៅលើការបកស្រាយ ។ នៅប្រទេសជប៉ុន ការប្រាក់គឺជាតម្លៃថ្នូរនៃការប្រើប្រាក់ដើម (តម្លៃថ្នូរនឹងហេតុដែលអ្នកឱ្យខ្ចីមិនអាចប្រើប្រាក់ដើមរបស់ខ្លួន) ហើយអ្នកឱ្យខ្ចីអាចប្រើប្រាក់ដើមរបស់ខ្លួន បន្ទាប់ពីពេលដែលបានទទួលការសងមុនពេលកំណត់ ហេតុនេះហើយបានជាភាគច្រើនបកស្រាយថា ការប្រាក់ដែលនឹងកើតឡើងពីថ្ងៃសង រហូតដល់ថ្ងៃកំណត់សងក្នុងកិច្ចសន្យា មិនមែនជាការខូចខាតទេ ។ ដូច្នេះ "ការខូចខាត" ដែលមាននៅក្នុងនេះ មានដូចជាសោហ៊ុយដែលកើតឡើងដើម្បីទទួលនូវការសងមុនពេលកំណត់នោះ ដែលត្រូវបានបន្ថែមពីសោហ៊ុយទទួលការសងនៅពេលកំណត់ (ឧទាហរណ៍ សោហ៊ុយដើម្បីគណនាការប្រាក់សារជាថ្មី សោហ៊ុយបន្ថែមដើម្បីរក្សាទុកនូវវត្ថុដែលជាកម្មវត្ថុ ដោយសារបានទទួលការសងមុនពេលកំណត់ ជាអាទិ៍) ។

### មាត្រា ៥៩៥.- ទីកន្លែងនៃការសង

ប្រសិនបើពុំមានការព្រមព្រៀងរវាងភាគី អំពីទីកន្លែងនៃការសងទេ អ្នកខ្ចីត្រូវយកវត្ថុដែលជាកម្មវត្ថុនោះ ទៅសង នៅលំនៅឋានរបស់អ្នកឱ្យខ្ចី ។

(កំណត់)

យោងទៅតាមគោលការណ៍ទូទៅនៃច្បាប់កាតព្វកិច្ច ទីកន្លែងនៃការសង គឺលំនៅឋានរបស់ម្ចាស់បំណុល ។ ប៉ុន្តែ ភាគីមានសេរីភាពក្នុងការកំណត់នូវទីកន្លែងនៃការសងផ្សេងពីនេះ ។

# ជំពូកទី ៥ ភតិសន្យា

## ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៩៦**.- និយមន័យនៃភតិសន្យា

១-ភតិសន្យា សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ឱ្យភាគីម្ខាងទៀតប្រើប្រាស់ និង អាស្រ័យផល ពីវត្ថុណាមួយ ដោយយកថ្លៃ ។

២-វត្ថុដែលជាកម្មវត្ថុនៃភតិសន្យា មានចលនវត្ថុ និង អចលនវត្ថុ ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីនិយមន័យនៃភតិសន្យា ។ នៅក្នុងមាត្រា ១១០១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា និង ក្រមរដ្ឋប្បវេណីផ្សេងទៀតដែលយកក្រមរដ្ឋប្បវេណីបារាំងមកធ្វើជាគំរូ ចែងអំពីការជួលវត្ថុ ហើយក្រៅពីនេះ ចែងអំពី ការជួលពលកម្ម ឬ ការជួលប្រាក់ផងដែរ ក៏ប៉ុន្តែ នៅក្នុងជំពូកនេះ ចែងតែអំពីការជួលវត្ថុប៉ុណ្ណោះ ។

ជាគោលការណ៍ ជំពូកនេះចែងអំពីវិន័យដែលត្រូវអនុវត្តជាទូទៅ ចំពោះវត្ថុដែលជាកម្មវត្ថុនៃភតិសន្យា ដោយមិន បែងចែកចលនវត្ថុ និង អចលនវត្ថុទេ ។ ក៏ប៉ុន្តែ ចំពោះបញ្ញត្តិពិសេសសម្រាប់អចលនវត្ថុវិញ មានការបញ្ជាក់ច្បាស់លាស់ ថា បញ្ញត្តិនោះជាបញ្ញត្តិពិសេសអំពីអចលនវត្ថុ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៩៩, មាត្រា ១១០០ និង មាត្រា ១១០១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ៥៩៧**.- ការបង្កើតភតិសន្យា

ភតិសន្យា ត្រូវមានអានុភាព ដោយភាគីម្ខាង សន្យាថាឱ្យភាគីម្ខាងទៀតប្រើប្រាស់ និង អាស្រ័យផល ពីវត្ថុណាមួយ ចំណែកឯភាគីម្ខាងទៀត សន្យាថាបង់ថ្លៃឈ្នួលចំពោះ វត្ថុនោះ ។

(កំណត់)

មាត្រានេះចែងអំពីល័ក្ខខ័ណ្ឌបង្កើតភតិសន្យា ។ ភតិសន្យាគឺជា កិច្ចសន្យាអញ្ញមញ្ញ ហើយជាកិច្ចសន្យាដែលមានតម្លៃ

ថ្នូរ (កិច្ចសន្យាមូលា) ព្រមទាំងជាកិច្ចសន្យាដែលត្រូវបានបង្កើតដោយកិច្ចព្រមព្រៀងតែប៉ុណ្ណោះ ។ ចាំបាច់ត្រូវកំណត់តម្លៃឈ្នួល ។ ទោះបីជាពុំបានកំណត់អំឡុងពេលជួលក៏ដោយ ក៏ភតិសន្យានេះមានសុពលភាពដែរ ។ ក្នុងករណីនេះ យោងតាមមាត្រា ៦១៥ នៃក្រមនេះ ភាគីនីមួយៗអាចស្នើសុំឱ្យរំលាយភតិសន្យាពេលណាក៏បានដែរ ហើយបន្ទាប់ពីអំឡុងពេលកំណត់មួយ បានកន្លងផុតក្រោយការស្នើសុំនេះ ភតិសន្យានឹងត្រូវបានបញ្ចប់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦០១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៥៩៨**.- ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិជួលអចលនវត្ថុ

១-ដោយយោងតាមលទ្ធកម្មនៃការកាន់កាប់ និង ការប្រើប្រាស់និងអាស្រ័យផលជាបន្តបន្ទាប់ នូវវត្ថុជួល ភតិកៈនៃភតិសន្យាអចលនវត្ថុ អាចតតាំងចំពោះជនដែលបានធ្វើលទ្ធកម្មនូវសិទ្ធិប្រត្យក្សលើអចលនវត្ថុ នៅក្រោយពេលដែលភតិកៈបានទទួលការកាន់កាប់ បាន ។

២-ភតិកៈដែលកំពុងតែកាន់កាប់វត្ថុជួល អាចអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វិញ សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំង និង សិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំង ចំពោះការបំពានសិទ្ធិជួល ដូចសិទ្ធិដែលកម្មសិទ្ធករមាន ។

(កំណត់)

មាត្រានេះចែងថា ភតិសន្យាអចលនវត្ថុ អាចតតាំងចំពោះតតិយជនបាន ដោយការកាន់កាប់ ព្រមទាំងការប្រើប្រាស់និងការអាស្រ័យផលជាបន្តបន្ទាប់ ហើយអាចអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សបាន ចំពោះតតិយជនដែលបំពានសិទ្ធិជួល ។

សិទ្ធិជួលអចលនវត្ថុជាសិទ្ធិលើបំណុល លើកលែងតែសិទ្ធិជួលអចិន្ត្រៃយ៍ ដូច្នេះហើយ ក្នុងករណីដែលតតិយជនបានធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ ក្រោយពេលធ្វើភតិសន្យា ជាគោលការណ៍ ភតិកៈពុំអាចអះអាងនូវអានុភាពនៃសិទ្ធិជួលចំពោះតតិយជននោះបានឡើយ ។ ក៏ប៉ុន្តែ ដោយសារតែសិទ្ធិជួលអចលនវត្ថុ មានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងជីវភាពរស់នៅរបស់ភតិកៈ ហេតុនេះហើយបានជាកថាខណ្ឌទី ១ នៃមាត្រានេះចែងថា ប្រសិនជាភតិកៈបានធ្វើលទ្ធកម្មនូវការកាន់កាប់ជាក់ស្តែងនូវអចលនវត្ថុនោះ ភតិកៈនោះត្រូវបានការពារ ។ ក្នុងករណីដែលភតិកៈបានទទួលនូវការប្រគល់ដោយការប្តូរលក្ខណៈនៃការកាន់កាប់[៦] តែពុំប្រើនិងអាស្រ័យផលជាក់ស្តែងទេ ពុំចាំបាច់ការពារឱ្យបានខ្លាំងទេ ដូច្នេះហើយ

[៦] សូមមើលកថាខណ្ឌទី ២ នៃមាត្រា ២២៩ ។

ក្នុងករណីនេះ ពុំអាចអនុវត្តមាត្រានេះបានឡើយ ។

មាត្រា ៦០៥ នៃក្រមរដ្ឋប្បវេណីជប៉ុន ទទួលស្គាល់នូវអានុភាពតតាំងចំពោះតតិយជន តែក្នុងករណីដែលបានចុះបញ្ជីនូវសិទ្ធិជួលនោះប៉ុណ្ណោះ ហេតុដូច្នេះ មាត្រានេះការពារភតិកៈនៃអចលនវត្ថុនោះយ៉ាងខ្លាំងជាងក្រមរដ្ឋប្បវេណីជប៉ុន ។

កថាខណ្ឌទី ២ នៃមាត្រានេះត្រូវបានចែងឡើងដោយឈរលើទស្សនៈមួយរបស់បណ្ឌិតសភាច្បាប់នៃប្រទេសជប៉ុន ។ ក្នុងករណីដែលមានតតិយជនបំពានជាក់ស្តែង ឬ ត្រៀមនឹងបំពានសិទ្ធិរបស់ខ្លួន ម្ចាស់សិទ្ធិភតិសន្យាអចលនវត្ថុដែលត្រូវបានទទួលស្គាល់នូវអានុភាពតតាំងដោយផ្អែកលើការកាន់កាប់ជាក់ស្តែង អាចទាមទារឱ្យបញ្ឈប់ ឬ បង្ការនូវការបំពាននោះបាន ។ នេះគឺមានន័យថា ទទួលស្គាល់នូវសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស ចំពោះសិទ្ធិជួលដែលមានអានុភាពតតាំង ។

យោងតាមបញ្ញត្តិនៃមាត្រា ២៤៤ នៃក្រមនេះ សិទ្ធិជួលរយៈពេលវែង ដែលមានការកំណត់រយៈពេលចាប់ពី ១៥ ឆ្នាំឡើងទៅ ត្រូវក្លាយទៅជាសិទ្ធិជួលអចិន្ត្រៃយ៍ ដែលជាសិទ្ធិប្រត្យក្ស ។ សិទ្ធិជួលអចិន្ត្រៃយ៍ គឺជាសិទ្ធិប្រត្យក្ស ហេតុនេះហើយអ្នកជួលអចិន្ត្រៃយ៍អាចចាត់ចែងបាន ដូចជាការធ្វើអនុប្បទានសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ការបង្កើតហ៊ីប៉ូតែកលើសិទ្ធិជួលអចិន្ត្រៃយ៍នោះ ជាអាទិ៍ ដោយមិនចាំបាច់មានការយល់ព្រមពីកម្មសិទ្ធិករនៃអចលនវត្ថុនោះទេ ។ ផ្ទុយទៅវិញ ចំពោះសិទ្ធិជួលអចលនវត្ថុដែលមិនមែនជាសិទ្ធិជួលអចិន្ត្រៃយ៍ មាត្រានេះទទួលស្គាល់អានុភាពដូចគ្នានឹងករណីនៃសិទ្ធិប្រត្យក្ស ចំពោះអានុភាពតតាំង និង សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សតែប៉ុណ្ណោះ ហើយមិនទទួលស្គាល់រហូតដល់សិទ្ធិចាត់ចែងនៃសិទ្ធិជួលអចលនវត្ថុ ដោយពុំមានការយល់ព្រមពីភតិបតីឡើយ ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ៦០៥ នៃក្រមរដ្ឋប្បវេណីជប៉ុន ។

**មាត្រា ៥៩៩.-** អំឡុងពេលដែលភតិសន្យាមានអត្ថិភាព

១-ភតិសន្យា អាចធ្វើឡើងដោយកំណត់ ឬ មិនកំណត់អំឡុងពេលបាន ។

២-ភតិសន្យាអចលនវត្ថុ ដែលមិនបានធ្វើជាលាយល័ក្ខណ៍អក្សរ ត្រូវចាត់ទុកថាជាភតិសន្យាដែលគ្មានកំណត់អំឡុងពេល ។

៣-ភតិសន្យាអចលនវត្ថុដែលមានកំណត់អំឡុងពេលចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំឡើងទៅ ត្រូវអនុលោមតាមបញ្ញត្តិចាប់ពីមាត្រា ២៤៤ (និយមន័យនៃសិទ្ធិជួលអចិន្ត្រៃយ៍) ទៅ នៃក្រមនេះ ។

(កំណត់)

មាត្រានេះចែងអំពីអំឡុងពេលដែលភតិសន្យាមានអត្ថិភាព ។ អំឡុងពេលនេះ អាចកំណត់ក៏បាន មិនកំណត់ក៏បាន ។

ក្នុងករណីដែលមិនបានកំណត់អំឡុងពេលនេះទេ ភាគីនីមួយៗអាចស្នើសុំរំលាយភតិសន្យា ដោយយោងតាមមាត្រា ៦១៥ ហើយអាចបញ្ឈប់ភតិសន្យា ក្រោយពេលកំណត់មួយបានកន្លងផុតទៅបាន ។

ទោះបីជាភតិសន្យាអចលនវត្ថុក៏ដោយ ក៏មិនចាំបាច់ធ្វើជាលិខិតយថាភូតក៏បានដែរ ។ ម្យ៉ាងទៀត មិនចាំបាច់ធ្វើជាលាយល័ក្ខណ៍អក្សរក៏បានដែរ ។ មានន័យថា ភតិសន្យាអចលនវត្ថុដែលបានធ្វើឡើងដោយផ្ទាល់មាត់ក៏មានសុពលភាព ដែរ ។ ក៏ប៉ុន្តែ ក្នុងករណីដែលមិនបានធ្វើជាលាយល័ក្ខណ៍អក្សរទេ យោងតាមកថាខណ្ឌទី ២ នៃមាត្រានេះ ភតិសន្យានេះត្រូវបានចាត់ទុកថាជាភតិសន្យាដែលពុំបានកំណត់អំឡុងពេល ដូច្នេះ ភាគីនីមួយៗអាចស្នើសុំរំលាយភតិសន្យា ដោយយោងតាមមាត្រា ៦១២ នៃក្រមនេះបាន ហើយសិទ្ធិរបស់ភតិកៈ រវាងភាគីនៃភតិសន្យានេះ មានភាពខ្សោយណាស់ ។ ទោះជាក្នុងករណីនេះក៏ដោយ ភតិកៈដែលកំពុងកាន់កាប់ ហើយប្រើប្រាស់និងអាស្រ័យផលអចលនវត្ថុនោះ អាចតតាំងសិទ្ធិជួលនេះចំពោះតតិយជនបាន ម្យ៉ាងទៀត ថែមទាំងអាចអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សបាន ចំពោះការបំពានរបស់តតិយជន ។

កថាខណ្ឌទី ៣ នៃមាត្រានេះ ចែងថា បញ្ញត្តិចាប់ពីមាត្រា ២៤៤ ទៅ ក្នុងក្រមនេះ ត្រូវយកមកអនុវត្តចំពោះសិទ្ធិភតិសន្យាដែលមានកំណត់អំឡុងពេលចាប់ពី ១៥ ឆ្នាំឡើងទៅ ។ កថាខណ្ឌទី ៣ នេះគឺជាបញ្ញត្តិដែលមានគោលគំនិតដូច មាត្រា ២៤៤ នៃក្រមនេះដែរ ។

ម្យ៉ាងទៀត មាត្រា ៦០៤ នៃក្រមរដ្ឋប្បវេណីជប៉ុនចែងថា អំឡុងពេលនៃភតិសន្យាណាដែលបានកំណត់ពេលលើស ២០ ឆ្នាំ ត្រូវបង្រួញមកនៅត្រឹមតែ ២០ ឆ្នាំ ។ តាមកថាខណ្ឌទី ២ នៃមាត្រា ១០៦ នៃច្បាប់ភូមិបាលកម្ពុជា ការជួលអចលនវត្ថុមាន ៣ ប្រភេទ គឺ ការជួលរយៈពេលមិនកំណត់ ការជួលរយៈពេលវែង ១៥ ឆ្នាំ ឬ លើស និង ការជួលរយៈពេលខ្លី ក្រោម ១៥ ឆ្នាំ តែពុំមានការកំណត់អំឡុងពេលអតិបរិមាទេ ។ មាត្រា ១១០៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា (ធ្វើវិសោធនកម្មនៅឆ្នាំ ១៩៥៧) មិនទទួលស្គាល់នូវភតិសន្យាដែលមិនមានកំណត់អំឡុងពេលទេ ហើយក្នុងករណីដែលបានធ្វើភតិសន្យាដោយគ្មានការកំណត់អំឡុងពេល ត្រូវសន្និដ្ឋានថាជាភតិសន្យាដែលមានអំឡុងពេល ៣ ឆ្នាំ ។ លើសពីនេះ ពុំអាចធ្វើភតិសន្យាដោយកំណត់អំឡុងពេលលើស ៩៩ ឆ្នាំបានឡើយ ។ កថាខណ្ឌទី ១ មាត្រា ១១០៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា (វិសោធនកម្មនៅឆ្នាំ ១៩៥៧) ថា ភតិសន្យាដែលជួលលើសពីកំណត់ ១ ឆ្នាំឡើងទៅ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរជរាប ហើយភតិសន្យាអចលនវត្ថុដែលកំណត់រយៈពេលលើសពី ៣ ឆ្នាំ ត្រូវធ្វើជាលិខិតបញ្ជាក់ ឬ ធ្វើនៅមន្ទីសារការី ។ ម្យ៉ាងទៀត ដើម្បីចុះបញ្ជី ត្រូវមានលិខិតយថាភូត ហើយប្រសិនបើចុះបញ្ជីទៅ នឹងអាចតតាំងចំពោះតតិយជនបាន ។ កថាខណ្ឌទី ២ មាត្រា ១០៩ នៃច្បាប់ភូមិបាលកម្ពុជា ទាមទារឱ្យធ្វើជាលាយល័ក្ខណ៍អក្សរ ហើយក្នុងករណីដែលពុំមានសរសេរជាលាយល័ក្ខណ៍អក្សរនូវល័ក្ខខ័ណ្ឌនៃកិច្ចសន្យាទេ ត្រូវចាត់ទុកថាជាភតិសន្យាដែលពុំមានការកំណត់អំឡុងពេល ហើយអាចបញ្ឈប់ភតិសន្យានេះ ដោយជូនដំណឹងជាមុន ក្នុងរយៈពេលស្មើនឹងរយៈពេលបង់ប្រាក់ឈ្នួល ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១១០៥, មាត្រា ១១០៦, មាត្រា ១១០៧ និង មាត្រា ១១៤១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, កថាខណ្ឌទី ២ មាត្រា ១០៦ នៃច្បាប់ភូមិបាលកម្ពុជា, មាត្រា ៦០៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ២ អានុភាពនៃភតិសន្យា

**មាត្រា ៦០០**.- សិទ្ធិ និង ករណីយកិច្ចនៃការប្រើប្រាស់ និង អាស្រ័យផល ផ្អែកតាមវិធីប្រើប្រាស់ របស់ភតិកៈ

១-ភតិកៈ មានសិទ្ធិ និង ករណីយកិច្ច លើការប្រើប្រាស់ និង អាស្រ័យផល លើវត្ថុជួល ដោយផ្អែកទៅតាមវិធីប្រើប្រាស់ ដែលត្រូវបានកំណត់នៅក្នុងកិច្ចសន្យា ឬ តាមលក្ខណៈនៃវត្ថុជួលនោះ ។

២-បើភតិកៈ បានធ្វើខុសនឹងករណីយកិច្ចនៃបញ្ញត្តិកថាខណ្ឌទី ១ ខាងលើនេះ ភតិបតីអាចរំលាយកិច្ចសន្យានោះបាន ។

៣-ភតិបតី មិនត្រូវធ្វើឱ្យរាំងស្ទះក្នុងការប្រើប្រាស់ និង អាស្រ័យផល ដែលភតិកៈធ្វើដោយផ្អែកតាមវិធីប្រើប្រាស់ឡើយ ។

(កំណត់)

មាត្រានេះចែងថា ភតិកៈមានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើវត្ថុជួល ដោយផ្អែកតាមវិធីប្រើប្រាស់ ហើយមានករណីយកិច្ចដូចនេះដែរ ។ ភតិបតីមិនត្រូវរារាំងនូវការប្រើប្រាស់ និង អាស្រ័យផលរបស់ភតិកៈ ដែលធ្វើតាមតាមវិធីប្រើប្រាស់នេះទេ ។

កថាខណ្ឌទី ២ នៃមាត្រានេះចែងអំពីសិទ្ធិរំលាយកិច្ចសន្យារបស់ភតិបតី ក្នុងករណីដែលមានការបំពានករណីយកិច្ចក្នុងការប្រើប្រាស់ និង អស្រ័យផលតាមវិធីប្រើប្រាស់ ក៏ប៉ុន្តែ ទោះបីជាគ្មានបញ្ញត្តិនេះក៏ដោយ ក៏សិទ្ធិរំលាយកិច្ចសន្យានេះត្រូវបានទទួលស្គាល់ ដោយយោងតាមបញ្ញត្តិទូទៅនៃការមិនអនុវត្តកាតព្វកិច្ច និង ការបំពានកិច្ចសន្យាដែរ ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើល មាត្រា ៦១៦, កថាខណ្ឌទី ១ មាត្រា ៥៩៤ ក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ១១១៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។ ចំពោះកថាខណ្ឌទី ៣ សូមមើលមាត្រា ១១២ នៃច្បាប់ភូមិបាលកម្ពុជា ។

**មាត្រា ៦០១**.- ករណីយកិច្ចប្រុងប្រយ័ត្នក្នុងការគ្រប់គ្រងដោយសុចរិត របស់ភតិកៈ

១-ភតិកៈ មានករណីយកិច្ចគ្រប់គ្រងវត្ថុជួល ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នក

គ្រប់គ្រងដោយសុចរិត ។

២-បើភតិកៈ បានធ្វើខុសនឹងករណីយកិច្ចនៃបញ្ញត្តិកថាខណ្ឌទី ១ ខាងលើនេះ ភតិបតីអាចរំលាយកិច្ចសន្យានោះបាន ។

(កំណត់)

មាត្រានេះចែងអំពីករណីយកិច្ចរបស់ភតិកៈ ក្នុងការគ្រប់គ្រងវត្ថុជួល ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

ក្នុងក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មានចែងអំពីករណីយកិច្ចសងនូវសំណងនៃការខូចខាត ក្នុងករណីដែលមានការបាត់បង់ ឬ ខូចខាត ក្នុងមាត្រា ១១១៨ ស្ដីពីអចលនវត្ថុ ក្នុងមាត្រា ១១៤២ ស្ដីពីសត្វ ក្នុងមាត្រា ១១៤៣ ស្ដីពីសំពៅ សំប៉ាន ទូកក្ដារ និង ក្នុងមាត្រា ១១៤៤ ស្ដីពីរទេះសាឡី សារពើគ្រឿងប្រដាប់ធ្វើកសិកម្ម ឬ ឧស្សាហកម្ម ។

កថាខណ្ឌទី ២ នៃមាត្រានេះ ចែងអំពីសិទ្ធិរំលាយកិច្ចសន្យារបស់ភតិបតី ក្នុងករណីដែលមានការបំពានករណីយកិច្ចប្រុងប្រយ័ត្នក្នុងការគ្រប់គ្រងដោយសុចរិត ក៏ប៉ុន្តែ ទោះពីជាគ្មានបញ្ញត្តិនេះក៏ដោយ ក៏សិទ្ធិរំលាយកិច្ចសន្យាត្រូវបានទទួលស្គាល់ ដោយយោងតាមបញ្ញត្តិទូទៅនៃការមិនអនុវត្តកាតព្វកិច្ច និង ការបំពានកិច្ចសន្យាដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤០០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១១១៨, មាត្រា ១១៤២, មាត្រា ១១៤៣ និង មាត្រា ១១៤៤ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## **មាត្រា ៦០២**.- ករណីយកិច្ចជួសជុលរបស់ភតិបតី

ភតិបតី មានករណីយកិច្ចធ្វើការជួសជុលដែលចាំបាច់ សម្រាប់ការប្រើប្រាស់ និង អាស្រ័យផល នៃវត្ថុជួលនោះ ។

(កំណត់)

មាត្រានេះចែងអំពីករណីយកិច្ចជួសជុលវត្ថុជួលរបស់ភតិបតី ។ "មានករណីយកិច្ចជួសជុល" មានន័យថា ភតិបតីត្រូវទទួលបន្ទុកនូវសោហ៊ុយជួសជុលដែលចាំបាច់ដើម្បីប្រើប្រាស់ និង អាស្រ័យផលលើវត្ថុជួល ដោយផ្អែកទៅតាមវិធីប្រើប្រាស់ ដែលត្រូវបានកំណត់នៅក្នុងកិច្ចសន្យា ឬ តាមលក្ខណៈនៃវត្ថុជួលនោះ ។ម្យ៉ាងទៀត មាត្រា ១១១ នៃច្បាប់ភូមិបាលកម្ពុជាចែងថា ការថែទាំធម្មតានៃអចលនវត្ថុ គឺជាការទទួលខុសត្រូវរបស់ភតិកៈ ហើយមាត្រានេះអាចត្រូវបានយល់ឃើញថា សោហ៊ុយសម្រាប់ការជួសជុលចាំបាច់ធម្មតា (ពាក្យពេចន៍ក្នុងច្បាប់ភូមិបាល គឺ សោហ៊ុយសម្រាប់ការ "ថែទាំ") គឺជាបន្ទុករបស់ភតិកៈ ។

ជាការច្បាស់ណាស់ហើយដែលថា ភាគីអាចធ្វើការសន្យាពិសេសអំពីករណីយកិច្ចជួសជុល ឬ បន្ទុកនៃសោហ៊ុយជួសជុល ដោយខុសពីក្រមរដ្ឋប្បវេណីក៏បានដែរ ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ១ មាត្រា ៦០៦ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៧២០ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១១១១ និង មាត្រា ១១១២ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។

## **មាត្រា ៦០៣**.- សកម្មភាពថែរក្សារបស់ភតិបតី

១-បើភតិបតី មានបំណងចង់អនុវត្តសកម្មភាពដែលចាំបាច់ក្នុងការថែរក្សាវត្ថុជួល ភតិកៈមិនអាចបដិសេធបានឡើយ ។

២-ក្នុងករណីដែលភតិបតីមានបំណងចង់អនុវត្តសកម្មភាពដែលចាំបាច់ក្នុងការថែរក្សាវត្ថុជួល ផ្ទុយពីឆន្ទៈរបស់ភតិកៈ ប្រសិនបើហេតុនោះ បណ្ដាលឱ្យភតិកៈពុំអាចសម្រេចគោលបំណងនៃការជួលទេ ភតិកៈអាចទាមទារឱ្យបន្ថយថ្លៃឈ្នួល ឬ អាចរំលាយកិច្ចសន្យាបាន ។

(កំណត់)

មាត្រានេះចែងថា ភតិបតីអាចធ្វើសកម្មភាពចាំបាច់ដើម្បីថែរក្សាវត្ថុជួល ដូចជាការជួសជុលវត្ថុជួល ជាអាទិ៍ ។ ភតិកៈមិនអាចបដិសេធនឹងសកម្មភាពនេះបានឡើយ ក៏ប៉ុន្តែ ឧទាហរណ៍ ក្នុងករណីដែលការជួសជុលអាគារប៊ុលឌិញទាំងស្រុង ត្រូវប្រើពេលវេលាច្រើន ហើយភតិកៈមិនអាចសម្រេចនូវគោលដៅនៃភតិសន្យា ភតិកៈអាចរំលាយភតិសន្យាដោយយោងតាមកថាខណ្ឌទី ២ នៃមាត្រានេះបាន ។ ការ "រំលាយ" ដែលមានក្នុងនេះ មានន័យថាជាការ "ជូនដំណឹងរំលាយកិច្ចសន្យា" [៧] ។ ក្នុងករណីដែលគោលដៅនៃកិច្ចសន្យាមិនមែនត្រូវបានរារាំងទាំងស្រុងទេ ប៉ុន្តែ គោលដៅដែលមានពីដំបូងត្រូវបានរារាំងមួយភាគ ហើយតម្លៃនៃការប្រើប្រាស់វត្ថុជួលសម្រាប់ភតិកៈត្រូវបានចុះថយ ពេលនោះភតិកៈអាចអនុវត្តសិទ្ធិទាមទារឱ្យចុះបន្ថយថ្លៃឈ្នួលក៏បានដែរ ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ២ មាត្រា ៦០៦ និង មាត្រា ៦០៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៧២៤ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១១១៣ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## **មាត្រា ៦០៤**.- សិទ្ធិទាមទារឱ្យសងវិញ នូវសោហ៊ុយរបស់ភតិកៈ

១-បើភតិកៈបានចំណាយសោហ៊ុយចាំបាច់ ដែលត្រូវជាបន្ទុករបស់ភតិបតី ចំពោះ

---

[៧] ចំពោះ "ការជូនដំណឹងរំលាយកិច្ចសន្យា" សូមមើលសេចក្តីកំណត់នៃមាត្រា ៦១៧ ។

វត្ថុជួល ភតិកៈអាចទាមទារសំណងនោះ ពីភតិបតី ជាបន្ទាន់បាន ។

២-បើភតិកៈបានចំណាយសោហ៊ុយដើម្បីកែលំអវត្ថុជួល ឬ ចំណាយផ្សេងទៀត ដើម្បីបង្កើនតម្លៃ លុះត្រាតែនៅក្នុងករណីដែលកម្រិតនៃកំណើនតម្លៃនោះនៅតែមាន នាពេលបញ្ចប់ភតិសន្យាតែប៉ុណ្ណោះទេ ទើបភតិកៈអាចទាមទារចំពោះភតិបតី ឱ្យសងវិញនូវប្រាក់ដែលបានចំណាយ ឬ តម្លៃប្រាក់ដែលកើននោះ ដោយផ្អែកតាមការជ្រើសរើសរបស់ភតិបតីបាន ។ ប៉ុន្តែ តុលាការអាចអនុញ្ញាត ដោយកំណត់អំឡុងពេលសមរម្យ ឱ្យសងវិញ យោលតាមការទាមទាររបស់ភតិបតីបាន ។

(កំណត់)

មាត្រានេះចែងអំពីសិទ្ធិទាមទារឱ្យភតិបតីសងវិញនូវសោហ៊ុយ ក្នុងករណីដែលភតិកៈបានចេញសោហ៊ុយជួសជុលវត្ថុជួល ឬ ក្នុងករណីដែលបានចេញសោហ៊ុយសម្រាប់កែលំអវត្ថុជួល ។

ជាគោលការណ៍ ភតិបតីត្រូវទទួលបន្ទុកសោហ៊ុយចាំបាច់សម្រាប់ថែរក្សាវត្ថុជួល ដូចជាសោហ៊ុយជួសជុល ជាអាទិ៍ (ត្រូវហៅថា "សោហ៊ុយចាំបាច់") ដោយយោងតាមមាត្រា ៦០២ នៃក្រមនេះ ហើយក្នុងករណីដែលភតិកៈបានចេញជំនួសសិននោះ ភតិកៈអាចទាមទារឱ្យភតិបតីសងសោហ៊ុយនោះមកវិញបាន ។

ក្នុងករណីដែលមិនមែនជាការចាំបាច់ដើម្បីថែរក្សាទេ ក៏ប៉ុន្តែ ប្រសិនបើវត្ថុជួលត្រូវបានកែលំអ និង បង្កើនតម្លៃ ភតិកៈអាចឱ្យភតិបតីសងវិញនូវសោហ៊ុយដែលភតិកៈបានចំណាយពិតប្រាកដ ឬ ចំនួនទឹកប្រាក់នៃតម្លៃដែលត្រូវបានបង្កើនតាមការជ្រើសរើសរបស់ភតិបតីបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦០៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៦០៥**.- ការទទួលខុសត្រូវរបស់ភតិបតី ចំពោះវិការៈនៃវត្ថុជួល

១-ប្រសិនបើភតិកៈមិនបានពិនិត្យស្ថានភាពនៃវត្ថុដែលជាកម្មវត្ថុនៃភតិសន្យាថាត្រឹមត្រូវតាមស្ថានភាពដែលបានកំណត់នៅក្នុងលិខិតកិច្ចសន្យា នៅពេលទទួលការប្រគល់វត្ថុដែលជាកម្មវត្ថុនោះ ភតិកៈមិនអាចទាមទារឱ្យភតិបតី ទទួលខុសត្រូវបានឡើយ ចំពោះភាពខុសពីស្ថានភាពដែលបានកំណត់នៅក្នុងលិខិតកិច្ចសន្យាដែលខ្លួនអាចដឹងដោយងាយស្រួលបើពិនិត្យ ។

២-នៅក្នុងករណីដែលវត្ថុជួលមានវិការៈកំបាំង បើភតិកៈមិនបានដឹងអំពីវិការៈនោះទេ ភតិកៈអាចទាមទារឱ្យជួសជុលវិការៈនោះ ឬ ឱ្យដូរវត្ថុដែលគ្មាន វិការៈ និង អាច

ទាមទារសំណងនៃការខូចខាតបាន ។

៣-ភតិបតីអាចជួសជុលវិការៈ ដោយសោហ៊ុយខ្លួនបាន លុះត្រាតែមិនធ្វើឱ្យមានការខូចខាតដោយមិនត្រឹមត្រូវនូវផលប្រយោជន៍របស់ភតិកៈ ។ ប៉ុន្តែ ភតិកៈមិនត្រូវបានរារាំងក្នុងការអនុវត្តសិទ្ធិទាមទារសំណងនៃការខូចខាតឡើយ ។

៤-ជំនួសនឹងការទាមទារដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ភតិកៈអាចទាមទារឱ្យបន្ថយថ្លៃឈ្នួលដែលសមរម្យនឹងវិការៈបាន ដោយគិតតាំងពីពេលដែលបានប្រគល់ ។[៨]

៥-បើពុំអាចសម្រេចនូវគោលបំណងដែលបានធ្វើកិច្ចសន្យា ដោយសារមូលហេតុនៃវិការៈកំបាំងនោះទេ ភតិកៈអាចរំលាយភតិសន្យានោះបាន ។

៦-ការទាមទារឱ្យជួសជុល ឱ្យដូរ ឱ្យបន្ថយថ្លៃឈ្នួល និង ការរំលាយ ត្រូវអនុវត្តនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលភតិកៈបានដឹង ឬ ពេលដែលត្រូវដឹងអំពីហេតុនោះបាន ។

(កំណត់)

មាត្រានេះចែងអំពីការទទួលខុសត្រូវរបស់ភតិបតីក្នុងការធានានូវវិការៈនៃវត្ថុជួល ក្នុងករណីដែលវត្ថុជួលមានវិការៈ ។ យោងតាមមាត្រា ៥៥៩ នៃក្រមរដ្ឋប្បវេណីជប៉ុន បញ្ញត្តិស្តីពីការលក់ទិញ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះកិច្ចសន្យាដែលយកតម្លៃថ្នូរ ក្រៅពីកិច្ចសន្យាលក់ទិញ ។ មាត្រានេះជាបញ្ញត្តិដែលត្រូវបានចែងឡើង ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់នូវគោលគំនិតដូចមាត្រា ៥៧០ និង មាត្រា៥៦៦ នៃក្រមរដ្ឋប្បវេណីជប៉ុន ។

ខ្លឹមសារនៃការទទួលខុសត្រូវក្នុងការធានាវិការៈ មានដូចជាសំណងនៃការខូចខាត ការរំលាយកិច្ចសន្យា ព្រមទាំងការជួសជុលវិការៈ ការប្តូរនឹងវត្ថុដែលពុំមានវិការៈ ការទាមទារឱ្យចុះបន្ថយថ្លៃឈ្នួល ។

ដូចករណីលក់ទិញដែរ គឺភតិបតីមានសិទ្ធិជួសជុលវិការៈ (សិទ្ធិអនុវត្តពេញលេញ) ដែរ ហើយអាចរួចផុតពីការទទួលខុសត្រូវក្នុងការធានាវិការៈនេះបាន តាមរយៈការជួសជុលវិការៈ ។

ការ "រំលាយ" ដែលបានកំណត់ក្នុងកថាខណ្ឌទី ៥ នៃមាត្រានេះ មានន័យថាជាការ "ជូនដំណឹងរំលាយកិច្ចសន្យា" ។

កថាខណ្ឌទី ១ នៃមាត្រា ១១០ នៃច្បាប់ភូមិបាលកម្ពុជា ចែងអំពីករណីយកិច្ចរបស់ភតិកៈក្នុងការពិនិត្យ មុននឹងទទួលការប្រគល់វត្ថុជួល ហើយប្រសិនបើមិនបានពិនិត្យទេ ត្រូវចាត់ទុកថា ត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងភតិសន្យា ។ នៅក្នុងច្បាប់ភូមិបាលនេះ មិនមានបញ្ញត្តិណាមួយចែងផ្ទាល់ទេ ប៉ុន្តែ អាចបកស្រាយថា ក្នុងករណីនេះ

[៨] កថាខណ្ឌទី ៤ នៃមាត្រា ៦០៥ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

ទោះបីជារកឃើញចំណុចណាមួយខុសនឹងល័ក្ខខ័ណ្ឌនៃភតិសន្យាក្រោយការទទួលក៏ដោយ ក៏ភតិកៈមិនអាចទាមទារឱ្យភតិបតីទទួលខុសត្រូវបានទេ ។ ដូច្នេះហើយ ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ក៏ចែងដូចគោលគំនិតនេះដែរ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ១១១៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ១៧២១ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១១០ នៃច្បាប់ភូមិបាលកម្ពុជា

**មាត្រា ៦០៦**.- សិទ្ធិរំលាយ និង សិទ្ធិទាមទារឱ្យបន្ថយថ្លៃឈ្នួល នៅក្នុងករណីដែលចំណូលថយចុះ

១-បើភតិកៈនៃដីដែលមានគោលបំណងអាស្រ័យផលពីដី ទទួលផលបានតិចជាងថ្លៃឈ្នួល ដោយសារករណីប្រធានសក្តិ ភតិកៈអាចទាមទារឱ្យបន្ថយថ្លៃឈ្នួល រហូតដល់ត្រឹមចំនួនទឹកប្រាក់នៃការអាស្រ័យផលនោះបាន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើការទទួលផលបានតិចជាងថ្លៃឈ្នួល លើសពី ២ (ពីរ) ឆ្នាំ ជាបន្តបន្ទាប់ ដោយសារករណីប្រធានសក្តិ ភតិកៈអាចរំលាយភតិសន្យាបាន ។

( កំណត់)

មាត្រានេះចែងអំពីសិទ្ធិទាមទារបន្ថយថ្លៃឈ្នួល ក្នុងករណីដែលចំណូលដែលភតិកៈទទួលពីដីធ្លីថយចុះ ។

មាត្រានេះគឺជាបញ្ញត្តិចែងពិសេសសម្រាប់ករណីដែលប្រមូលផលដំណាំពីដីស្រែចំការដែលជួល មិនបានល្អ ដោយសារគ្រោះធម្មជាតិ តែមិនរាប់បញ្ចូលករណីដែលបានជួលដីសាងសង់រោងចក្រសម្រាប់ផលិតទំនិញ តែទំនិញនោះលក់មិនបាន ហើយចំណូលមិនបានតាមគម្រោងឡើយ ។ ចំណូលពីការលក់ទំនិញដែលបានផលិតដោយរោងចក្រដែលស្ថិតលើដីជួលនោះ មិនអាចចាត់ទុកថាជា "ផលពីដី" បានឡើយ ។ ចំពោះករណីដែលមិនមែនជាផលដំណាំ មិនបានល្អទេ តែជាករណីដែលចំណូលពីដីបានថយចុះទាបជាងថ្លៃឈ្នួល ដោយសារការធ្លាក់ចុះតម្លៃដំណាំដែលមិនអាចព្យាករបានវិញ សូមទុកឱ្យចៅក្រមកម្ពុជាធ្វើការវិនិច្ឆ័យនាពេលអនាគត ។

ការ "រំលាយ" ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ មានន័យថាជាការ "ជូនដំណឹងរំលាយកិច្ចសន្យា" ។

តាមធម្មតា នៅកម្ពុជា ក្នុងករណីច្រើន ការជួលដីស្រែចំការ មានអំឡុងពេល ១ ឆ្នាំ ហើយភាគច្រើនមានការព្រមព្រៀងរវាងភាគីអំពីការបន្ថយថ្លៃឈ្នួល ហេតុនេះហើយ ត្រូវគេសង្កេតឃើញថា រឿងវិវាទនេះមិនសូវកើតឡើងទេ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៦០៩ និង មាត្រា ៦១០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៦០៧.-** សិទ្ធិរំលាយ និង សិទ្ធិទាមទារបន្ថយថ្លៃឈ្នួល ដោយសារការបាត់បង់ ឬ វិនាសវត្ថុជួលមួយភាគ

១-បើវត្ថុជួលមួយភាគត្រូវបានបាត់បង់ ឬ វិនាស ដោយមិនមែនជាកំហុសរបស់ភតិកៈទេ ភតិកៈអាចទាមទារឱ្យបន្ថយថ្លៃឈ្នួល ទៅតាមសមាមាត្រនៃភាគដែលត្រូវបានបាត់បង់ ឬវិនាសនោះបាន ។

២-ក្នុងករណីនៃកថាខណ្ឌទី ១ ខាងលើនេះ បើភតិកៈពុំអាចសម្រេចគោលបំណងដែលបានធ្វើកិច្ចសន្យាជួល ទៅលើភាគដែលនៅសេសសល់នោះទេ ភតិកៈអាចរំលាយភតិសន្យាបាន ។

(កំណត់)

មាត្រានេះចែងអំពីសិទ្ធិទាមទារឱ្យបន្ថយថ្លៃឈ្នួល ព្រមទាំងសិទ្ធិរំលាយ ក្នុងករណីដែលវត្ថុជួលបានវិនាសមួយភាគនៃវត្ថុជួល ។

ការ "រំលាយ" ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ មានន័យថាជាការ "ជូនដំណឹងរំលាយកិច្ចសន្យា" ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦១១ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៦០៨.-** អនុប្បទានសិទ្ធិជួល និង ការជួលបន្ត នូវវត្ថុជួល

១-បើគ្មានការយល់ព្រមពីភតិបតីទេ ភតិកៈពុំអាចធ្វើអនុប្បទានសិទ្ធិជួល ឬ ជួលបន្តនូវវត្ថុជួលបានឡើយ លើកលែងតែករណីនៃសិទ្ធិជួលអចិន្ត្រៃយ៍ ។

២-បើភតិកៈបានឱ្យតតិយជនប្រើប្រាស់ ឬ អាស្រ័យផលពីវត្ថុជួល ផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ភតិបតីអាចរំលាយកិច្ចសន្យាបាន ។

(កំណត់)

មាត្រានេះចែងហាមមិនឱ្យភតិកៈធ្វើអនុប្បទានសិទ្ធិជួល ឬ ជួលបន្តដោយគ្មានការយល់ព្រមពីភតិបតី ហើយព្រមជាមួយគ្នានេះ ចែងអំពីសិទ្ធិរំលាយភតិសន្យារបស់ភតិបតី ក្នុងករណីដែលភតិកៈបានធ្វើអនុប្បទានសិទ្ធិជួល ឬ បានជួលបន្ត ដោយគ្មានការយល់ព្រមពីភតិបតី ។ ម្យ៉ាងទៀត យោងតាមយុត្តិសាស្ត្ររបស់ជប៉ុន ទោះបីជាមានអនុប្បទាន

សិទ្ធិជួល ឬ ការជួលបន្តដោយគ្មានការយល់ព្រមក៏ដោយ ប្រសិនបើមិនអាចទទួលស្គាល់ថា អំពើរបស់ភតិកៈនោះ មានលក្ខណៈរំលោភលើទំនុកចិត្តទេ ភតិបតីមិនអាចរំលាយភតិសន្យាបានឡើយ ។ នៅកម្ពុជា ក៏អាចមានករណីខ្លះដែលមិនអនុញ្ញាតឱ្យប្រើសិទ្ធិរំលាយបានដោយសារការរំលាយនេះគឺជាការប្រើសិទ្ធិដោយបំពាន ។

ការ "រំលាយ" ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ មានន័យថាជាការ "ជូនដំណឹងរំលាយកិច្ចសន្យា" ។

សិទ្ធិជួលអចិន្ត្រៃយ៍ គឺជាសិទ្ធិប្រត្យក្ស ដែលអាចធ្វើអនុប្បទាន ឬ ជួលបន្តដោយសេរីបាន ហេតុនេះហើយ ជាការធម្មតាទេ ក៏ប៉ុន្តែ ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ បានជានៅក្នុងកថាខណ្ឌទី ១ បន្ថែមពាក្យ "លើកលែងតែករណីនៃសិទ្ធិជួលអចិន្ត្រៃយ៍" ។ សូមមើលមាត្រា ២៥២ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦១២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១១២៣ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## មាត្រា ៦០៩.- ការជួលបន្ត

១-បើភតិកៈបានជួលបន្ត នូវវត្ថុជួលដោយត្រឹមត្រូវតាមច្បាប់ ភតិកៈបន្តត្រូវមានករណីយកិច្ចដោយផ្ទាល់ ចំពោះភតិបតី ។ ចំពោះករណីយកិច្ចបង់ថ្លៃឈ្នួលជួលបន្ត ភតិកៈបន្តពុំអាចយកការបង់ថ្លៃជាមុនទៅឱ្យភតិកៈ មកតតាំងជាមួយភតិបតី បានឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងដល់ការអនុវត្តសិទ្ធិរបស់ភតិបតីចំពោះភតិកៈឡើយ ។

(កំណត់)

មាត្រានេះចែងស្តីពីករណីយកិច្ចរបស់ភតិកៈបន្ត ចំពោះភតិបតី ក្នុងករណីដែលភតិកៈបានជួលបន្តនូវវត្ថុជួល ដោយត្រឹមត្រូវតាមច្បាប់ ។ ពាក្យ "ដោយត្រឹមត្រូវតាមច្បាប់" ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ មានន័យថា ភាគច្រើនគឺជាករណីដែលបានទទួលការយល់ព្រមពីភតិបតី ក៏ប៉ុន្តែ ទោះបីជាពុំមានការយល់ព្រមពីភតិបតីក៏ដោយ តែប្រសិនបើការរំលាយដោយភតិបតី ដោយផ្អែកលើកថាខណ្ឌទី ២ នៃមាត្រា ៦០៨ មិនអាចទទួលស្គាល់ ដោយសារការរំលាយនោះគឺជាការប្រើសិទ្ធិដោយបំពាន ជាអាទិ៍ ក៏ត្រូវចាត់ទុកថា "ដោយត្រឹមត្រូវតាមច្បាប់" ដែរ ។ ចំពោះការជួលអចិន្ត្រៃយ៍ក៏ដូចគ្នាដែរ ទោះបីជាពុំមានការយល់ព្រមពីភតិបតីក៏ដោយ ក៏អាចជួលបន្តបានដែរ ហើយក្នុងករណីនេះ ក៏ជាករណីជួលបន្ត "ដោយត្រឹមត្រូវតាមច្បាប់" ដែរ ដូច្នេះហើយ ត្រូវអនុវត្តមាត្រានេះដែរ ។

គោលគំនិតនៃកថាខណ្ឌទី ២ នៃមាត្រានេះ គឺ ឧទាហរណ៍ ចំពោះការទាមទារថ្លៃឈ្នួល ភតិបតីអាចយកជម្រើសទាមទារពីភតិកៈជួលបន្តបាន ឬ ក៏ទាមទារពីភតិកៈបានដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦១៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៦១០**.- ករណីយកិច្ច និង ពេលវេលានៃការបង់ថ្លៃឈ្នួល

១-ភតិកៈ មានករណីយកិច្ចបង់ថ្លៃឈ្នួល ទៅឱ្យភតិបតី ទៅតាមពេលវេលាដែលបានកំណត់ ។

២-នៅក្នុងករណីដែលមិនបានកំណត់ជាពិសេសនៅក្នុងកិច្ចសន្យា អំពីពេលវេលាដែលត្រូវបង់ថ្លៃឈ្នួលទេ ចំពោះចលនវត្ថុ និង ផ្ទះ ឬ អាគារ ត្រូវបង់នៅរៀងរាល់ចុងខែ ចំពោះដីធ្លីវិញ ត្រូវបង់នៅរៀងរាល់ចុងឆ្នាំ ។ ប៉ុន្តែ ចំពោះវត្ថុដែលមានរដូវប្រមូលផល ត្រូវបង់នៅក្រោយពេលដែលរដូវនោះកន្លងផុត ដោយគ្មានការយឺតយ៉ាវ ។

(កំណត់)

មាត្រានេះចែងអំពីករណីយកិច្ច និង ពេលវេលាដែលត្រូវបង់ថ្លៃឈ្នួលដោយភតិកៈ ។ តាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីជាគោលការណ៍ ភតិកៈត្រូវបង់ថ្លៃឈ្នួលនៅរាល់ពេលដែលអំឡុងពេលកំណត់មួយបានកន្លងផុតទៅ ក៏ប៉ុន្តែ ភាគីអាចធ្វើការសន្យាពិសេសអំពីការបង់ថ្លៃឈ្នួលមុនរាល់អំឡុងពេលដែលបានកំណត់នោះក៏បានដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦១៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១១១៩ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ៦១១**.- ករណីយកិច្ចជូនដំណឹង របស់ភតិកៈ

បើមានការចាំបាច់លើការជួសជុលវត្ថុជួល ឬ បើមានតតិយជនអះអាងអំពីសិទ្ធិចំពោះវត្ថុជួល ភតិកៈត្រូវជូនដំណឹងនោះទៅឱ្យភតិបតី ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើភតិបតីបានដឹងអំពីហេតុនោះរួចហើយ ។

(កំណត់)

មាត្រានេះចែងអំពីករណីយកិច្ចជូនដំណឹងរបស់ភតិកៈ ទៅភតិបតី ក្នុងករណីដែលមានការចាំបាច់ត្រូវជួសជុលវត្ថុជួល ឬ ក្នុងករណីដែលមានតតិយជនដែលអះអាងអំពីសិទ្ធិពាក់ព័ន្ធនឹងវត្ថុជួលនោះ ។

ចំពោះផលុបភោគវិញ កថាខណ្ឌទី ២ មាត្រា ២៦៦ នៃក្រមនេះ ចែងអំពីការសងនូវសំណងនៃការខូចខាតក្នុងករណីដែលមានការបំពានករណីយកិច្ចជូនដំណឹង ដោយផលុបភោគី ។ ក៏ប៉ុន្តែ ករណីយកិច្ចដែលបានកំណត់នៅក្នុងមាត្រានេះ គឺជាករណីយកិច្ចលើកិច្ចសន្យា (កាតព្វកិច្ច) ដូច្នេះហើយ ពេលមានការបំពានករណីយកិច្ច ការដែល

អ្នកបំពានត្រូវសងនូវសំណងនៃការខូចខាត គឺជាការធម្មតាទេ ។ ផ្ទុយទៅវិញ ករណីយកិច្ចជូនដំណឹងរបស់ផលុបភោគី មិនមែនជាករណីយកិច្ចតាមផ្លូវច្បាប់សិទ្ធិលើបំណុលទេ គឺជាករណីយកិច្ចតាមផ្លូវច្បាប់សិទ្ធិប្រត្យក្ស ហេតុនេះហើយ ប្រសិនបើគ្មានបញ្ញត្តិដូចកថាខណ្ឌទី ២ មាត្រា ២៦៦ ទេ ទោះបីជាមានការខូចខាតកើតឡើង ដោយសារការធ្វេស ប្រហែសក្នុងការជូនដំណឹងដោយផលុបភោគីក៏ដោយ បើការធ្វេសប្រហែសនេះមិនបំពេញល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូល ទេ កម្មសិទ្ធិករមិនអាចទាមទារឱ្យផលុបភោគីទទួលខុសត្រូវនូវសំណងនៃការខូចខាតបានឡើយ ។ ដូច្នេះហើយ ចាំបាច់ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ថា ការទទួលខុសត្រូវរបស់ផលុបភោគីនោះ គឺជាការទទួលខុសត្រូវដែលច្បាប់បានកំណត់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦១៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៣ ការបញ្ចប់ភតិសន្យា

**មាត្រា ៦១២**.- ការផុតអំឡុងពេលកំណត់

ភតិសន្យាដែលមានកំណត់អំឡុងពេល ត្រូវបញ្ចប់ដោយការផុតអំឡុងពេលដែលបានកំណត់នោះ ។

(កំណត់)

មាត្រានេះចែងថា ភតិសន្យាត្រូវបញ្ចប់ដោយការផុតអំឡុងពេលកំណត់ដោយភតិសន្យានោះ ។ ដោយសារតែ នេះគឺជាខ្លឹមសារធម្មតា មិនចាំបាច់បញ្ញត្តក៏បានដែរ ហេតុនេះហើយបានជា ក្នុងក្រមរដ្ឋប្បវេណីជប៉ុន ពុំមានបញ្ញត្តិដូច មាត្រានេះទេ ។

**មាត្រា ៦១៣**.- ការបដិសេធការបន្តជាថ្មី នូវភតិសន្យាអចលនវត្ថុ

ចំពោះភតិសន្យាអចលនវត្ថុ បើភាគីម្ខាងពុំបានបង្ហាញឆន្ទៈបដិសេធការបន្តជាថ្មី នៅមុនរយៈពេល ៣ (បី) ខែ មុនផុតកំណត់អំឡុងពេល ចំពោះផ្ទះ ឬ អាគារ ឬ នៅមុន រយៈពេល ១ (មួយ) ឆ្នាំ មុនផុតកំណត់អំឡុងពេល ចំពោះដីធ្លី ទៅភាគីម្ខាងទៀតទេ ត្រូវចាត់ទុកថាបានយល់ព្រមក្នុងការបន្តជាថ្មី ។ ប៉ុន្តែ ក្នុងករណីនេះ ភតិសន្យាដែលត្រូវ បានបន្តជាថ្មីនេះ គឺជាភតិសន្យាដែលពុំមានកំណត់អំឡុងពេល ។

(កំណត់)

មាត្រានេះចែងអំពីការបន្តភតិសន្យាអចលនវត្ថុដែលកំណត់អំឡុងពេល ក្នុងករណីដែលភាគីម្ខាងពុំបានជូនដំណឹងទៅ

ភាគីម្ខាងទៀតថា បដិសេធនូវការបន្តជាថ្មីនូវភតិសន្យា នៅមុនរយៈពេលកំណត់មួយ មុនពេលផុតអំឡុងពេលនៃភតិសន្យា ។ ក៏ប៉ុន្តែ សិទ្ធិជួលក្រោយពេលបន្តជាថ្មី ពុំមានកំណត់អំឡុងពេលទេ ហេតុនេះហើយ ភាគីណាម្ខាងក៏អាចស្នើសុំរំលាយភតិសន្យានេះ យោងតាមមាត្រា ៦១៥ នៃក្រមនេះ នៅពេលណាក៏បានដែរ ហើយភតិសន្យានឹងត្រូវបញ្ចប់ ៣ ខែក្រោយការស្នើសុំរំលាយ ក្នុងករណីជួលអាគារ និង ១ ឆ្នាំ ក្រោយការស្នើសុំរំលាយ ក្នុងករណីជួលដីធ្លី ។ មានន័យថា ការការពារភតិកៈមានភាពខ្សោយជាង បើប្រៀបធៀបទៅនឹងមុនពេលបន្តភតិសន្យាជាថ្មី ។

ប្រសិនបើភតិបតីបានបង្ហាញឆន្ទៈបដិសេធការបន្តជាថ្មីហើយ តែក្រោយពេលផុតអំឡុងពេល ពុំបានទាមទារឱ្យភតិកៈចេញទេ អាចបកស្រាយបានថាជាការបង្ហាញឆន្ទៈបន្តជាថ្មីដោយតុណ្ហីភាព ដោយបានដកឆន្ទៈបដិសេធពីមុនបាន ។ ក៏ប៉ុន្តែ ក្នុងក្រមនេះ បញ្ញត្តិសន្មតដោយច្បាប់អំពីចំណុចនេះ មិនត្រូវបានរៀបចំទេ ។

ម្យ៉ាងទៀត មាត្រា ១១៣៣ និង មាត្រា ១១៣៤ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ក៏តម្រូវឱ្យមានអំឡុងពេលកំណត់មួយ សម្រាប់ជូនដំណឹងជាមុន ក្នុងករណីបដិសេធការបន្តជាថ្មី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ២៦ នៃច្បាប់ស្តីពីការជួលដី និង ការជួលផ្ទះរបស់ជប៉ុន, មាត្រា ១១៣៣ និង មាត្រា ១១៣៤ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## មាត្រា ៦១៤.- ការបន្តជាថ្មីដោយតុណ្ហីភាព

ចំពោះភតិសន្យាចលនវត្ថុ នៅក្នុងករណីដែលភតិកៈបានបន្តការប្រើប្រាស់ ឬ អាស្រ័យផលលើវត្ថុជួលនោះ ទោះនៅក្រោយអំឡុងពេលនៃភតិសន្យា បានផុតកំណត់ហើយក៏ដោយ បើភតិបតីបានដឹងអំពីហេតុនោះហើយ តែមិនបានធ្វើការតវ៉ាទេ ត្រូវសន្មតថាជាភតិសន្យាដែលបានបន្តជាថ្មី ដោយគ្មានកំណត់អំឡុងពេល ហើយមានល័ក្ខខ័ណ្ឌដូចគ្នានឹងកិច្ចសន្យាដែលបានជួលពីមុន លើកលែងតែអំឡុងពេលចេញ ។

(កំណត់)

មាត្រានេះចែងអំពីការបន្តជាថ្មីនូវភតិសន្យាចលនវត្ថុ ក្នុងករណីដែលភតិបតីបានដឹងថា ភតិកៈបន្តការប្រើប្រាស់ និង អាស្រ័យផលលើវត្ថុជួល ក្រោយអំឡុងពេលនៃភតិសន្យា បានកន្លងផុត តែពុំបានធ្វើការតវ៉ាចំពោះហេតុនេះ ។ ក៏ប៉ុន្តែ សិទ្ធិជួលដែលបង្កើតឡើងក្រោយការបន្តជាថ្មីនោះ ក្លាយទៅជាសិទ្ធិជួលដែលគ្មានកំណត់អំឡុងពេល ហេតុនេះហើយ ភាគីណាម្ខាងក៏អាចស្នើសុំរំលាយភតិសន្យា ដោយយោងតាមមាត្រា ៦១៥ នៃក្រមនេះ នៅពេលណាក៏បានដែរ ហើយភតិសន្យានឹងត្រូវបញ្ចប់ ឱ្យតែ ១ ថ្ងៃបានកន្លងផុតទៅ ហេតុដូច្នេះ ការការពារភតិកៈនឹងមានភាពខ្សោយជាងសិទ្ធិជួលដែលមានមុនពេលបន្តជាថ្មីនោះ ។

ក្នុងករណីដែលជាភតិសន្យាអចលនវត្ថុ យោងតាមមាត្រាមុន ប្រសិនបើភាគីម្ខាងពុំបានបង្ហាញឆន្ទៈបដិសេធការបន្តជាថ្មី ចំពោះភាគីម្ខាងទៀត នៅមុនពេលកំណត់មួយ មុនពេលផុតអំឡុងពេលនៃភតិសន្យាទេ ភតិសន្យានោះនឹងត្រូវបន្តជាថ្មីដោយស្វ័យប្រវត្តិ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦១៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៧៣៨ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៦១៥**.- ការស្នើសុំឱ្យរំលាយភតិសន្យាដែលពុំមានកំណត់អំឡុងពេល

១-បើពុំបានកំណត់អំឡុងពេលជួលនៅក្នុងកិច្ចសន្យាទេ ភាគីនីមួយៗអាចស្នើសុំឱ្យរំលាយកិច្ចសន្យា នៅពេលណាក៏បាន ។ ក្នុងករណីដែលការស្នើសុំឱ្យរំលាយ មិនបានបញ្ជាក់អំពីពេលរលាយ និង ក្នុងករណីដែលអំឡុងពេលចាប់ពីពេលស្នើសុំឱ្យរំលាយរហូតដល់ពេលរលាយដែលបានបញ្ជាក់នៅក្នុងការស្នើសុំឱ្យរំលាយនោះ តិចជាងអំឡុងពេលដូចបានកំណត់ខាងក្រោមនេះ ភតិសន្យាត្រូវរលាយ នៅពេលដែលអំឡុងពេលដូចបានកំណត់ខាងក្រោមនេះ បានកន្លងហួស គិតចាប់ពីពេលស្នើសុំឱ្យរំលាយ :

ក-១ (មួយ) ថ្ងៃ ចំពោះចលនវត្ថុ ។

ខ-៣ (បី) ខែ ចំពោះអាគារ ។

គ-១ (មួយ) ឆ្នាំ ចំពោះដីធ្លី ។

២-ចំពោះភតិសន្យាដីធ្លីដែលមានរដូវប្រមូលផល ត្រូវធ្វើការស្នើសុំរំលាយកិច្ចសន្យានៅក្រោយរដូវនោះ មុនការចាប់ផ្តើមការធ្វើកសិកម្ម សម្រាប់រដូវបន្ទាប់ ។

(កំណត់)

មាត្រានេះចែងថា ក្នុងករណីដែលពុំបានកំណត់អំឡុងពេលនៃភតិសន្យាទេ ភាគីណាម្ខាងក៏អាចស្នើសុំឱ្យរំលាយភតិសន្យា នៅពេលណាក៏បានដែរ ហើយភតិសន្យានោះនឹងត្រូវបញ្ចប់ នៅពេល ១ ថ្ងៃ បានកន្លងផុតទៅ ចំពោះចលនវត្ថុ ពេល ៣ ខែ បានកន្លងផុតទៅ ចំពោះអាគារ និង ពេល ១ ឆ្នាំ បានកន្លងផុតទៅ ចំពោះដីធ្លី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦១៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៦១៦**.- ការរក្សាទុកសិទ្ធិរំលាយកិច្ចសន្យា

ទោះនៅក្នុងករណីដែលភាគីបានកំណត់អំឡុងពេលនៃភតិសន្យាក៏ដោយ បញ្ញត្តិនៃមាត្រា ៦១៥ (ការស្នើសុំឱ្យរំលាយភតិសន្យាដែលពុំមានកំណត់អំឡុងពេល) ខាងលើនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ បើភាគីតែម្ខាង ឬ ភាគីទាំងសងខាង បានរក្សាទុកនូវសិទ្ធិអំណាចអនុវត្តការរំលាយកិច្ចសន្យា នៅក្នុងអំឡុងពេលនោះ ។

(កំណត់)

មាត្រានេះចែងថា ទោះបីជាភតិសន្យាមានកំណត់អំឡុងពេលក៏ដោយ ក្នុងករណីដែលភាគីម្ខាង ឬ ភាគីទាំងសងខាងបានរក្សាទុកនូវសិទ្ធិរំលាយកិច្ចសន្យា ប្រសិនបើសិទ្ធិរំលាយកិច្ចសន្យានោះត្រូវបានអនុវត្ត ក៏ភតិសន្យានោះនឹងត្រូវបញ្ចប់ក្រោយការកន្លងផុតទៅនៃអំឡុងពេលមួយ បន្ទាប់ពីពេលបានអនុវត្តសិទ្ធិរំលាយនេះ ដោយយកបញ្ញត្តិនៃមាត្រា ៦១៥ មកអនុវត្តដូចគ្នាផងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦១៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៦១៧**.- ភាពគ្មានអានុភាពប្រតិសកម្មនៃការរំលាយកិច្ចសន្យា

នៅក្នុងករណីដែលបានរំលាយភតិសន្យា ការរំលាយកិច្ចសន្យានោះ ត្រូវមានអានុភាពឆ្ពោះទៅអនាគតតែប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះចែងថា ការរំលាយភតិសន្យា ពុំមានអានុភាពប្រតិសកម្មទេ មានន័យថា ភតិសន្យានេះ ពុំមែនគ្មានកំណើតឡើងតាំងពីដំបូងនោះមកទេ ។ ដើម្បីធ្វើការបែងចែកឱ្យបានច្បាស់លាស់រវាងការរំលាយភតិសន្យាដែលគ្មានអានុភាពប្រតិសកម្មនៃការរំលាយ និង ការរំលាយធម្មតាដែលមានអានុភាពប្រតិសកម្ម តាមនីតិសាស្ត្រ ត្រូវប្រើពាក្យ "ការជូនដំណឹងរំលាយកិច្ចសន្យា" ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦២០ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៦១៨**.- ករណីយកិច្ចប្រគល់វត្ថុជួល

១-បើភតិសន្យាត្រូវបានបញ្ចប់ហើយ ភតិកៈមានករណីយកិច្ចធ្វើបដិទានវត្ថុជួលប្រគល់ទៅឱ្យភតិបតីវិញ ជាបន្ទាន់ ។

២-លើកលែងតែការបាក់បែក ខូចខាតដែលកើតឡើងដោយសារការប្រើប្រាស់ជាធម្មតា ភតិកៈត្រូវជួសជុលការខូចខាតដែលកើតឡើងដោយសារមូលហេតុជាបន្ទុករបស់ខ្លួនឡើងវិញ ឬ ត្រូវមានករណីយកិច្ចសងសំណងនៃការខូចខាតនោះ ។

(កំណត់)

មាត្រានេះចែងអំពីករណីយកិច្ចរបស់ភតិកៈ ក្នុងការធ្វើបដិទានវត្ថុជួល និង ក្នុងការប្រគល់វត្ថុនោះទៅឱ្យភតិបតីវិញ នៅពេលដែលភតិសន្យាត្រូវបានបញ្ចប់ ។ ភតិកៈត្រូវជួសជុលឡើងវិញ នូវការខូចខាតដែលកើតឡើងដោយសារសារមូលហេតុជាបន្ទុករបស់ខ្លួន ហើយក្នុងករណីដែលមិនអាចជួសជុលវិញបានទេ ត្រូវសងនូវសំណងនៃការខូចខាតនោះ ក៏ប៉ុន្តែចំពោះការខូចខាតដែលកើតឡើងជាធម្មជាតិ ដោយសារការប្រើប្រាស់ធម្មតា ដូចជាការប្តូរពណ៌នៃក្រដាស់ជញ្ជាំងដោយសារពន្លឺព្រះអាទិត្យ ឬ ការប្រឡាក់នៃកម្រាល ជាអាទិ៍ ភតិកៈពុំមានករណីយកិច្ចធ្វើការបដិទាន ឬ ករណីយកិច្ចសងនូវសំណងនៃការខូចខាតឡើយ ។ តម្លៃចុះថយនៃវត្ថុជួល ដោយសារការខូចខាតជាធម្មជាតិនោះ ត្រូវបានបញ្ចូលទៅក្នុងថ្លៃឈ្នួលរួចស្រេចទៅហើយ ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ៥៩៧ នៃក្រមរដ្ឋប្បវេណីជប៉ុន ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ ដោយមាត្រា ៦១៦ នៃក្រមដដែលនេះ ហើយចំពោះកថាខណ្ឌទី ២ វិញ សូមមើលមាត្រា ១១២១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា និង មាត្រា ១១១ នៃច្បាប់ភូមិបាលកម្ពុជា ។

**មាត្រា ៦១៩.-** សិទ្ធិរុះរើចេញរបស់ភតិកៈ

បើភតិសន្យាត្រូវបានបញ្ចប់ហើយ ភតិកៈអាចរុះរើចេញ នូវវត្ថុដែលបានភ្ជាប់ជាមួយនឹងវត្ថុជួលនោះ បាន ។

(កំណត់)

មាត្រានេះចែងអំពីសិទ្ធិរុះរើរបស់ភតិកៈ នូវវត្ថុដែលខ្លួនបានភ្ជាប់ជាមួយនឹងវត្ថុជួល នៅពេលបញ្ចប់ភតិសន្យា ។ ភតិកៈមានសិទ្ធិរុះរើ ព្រមជាមួយគ្នានេះ មានករណីយកិច្ចរុះរើដែរ (មានន័យថា ករណីយកិច្ចធ្វើបដិទាន) ។ ភតិបតីអាចអនុគ្រោះករណីយកិច្ចធ្វើបដិទានបាន តែមិនអាចដកហូតនូវសិទ្ធិរុះរើរបស់ភតិកៈ ដោយទំនើងចិត្តខ្លួនបានឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៩៨ នៃក្រមរដ្ឋប្បវេណីជប៉ុន ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ ដោយមាត្រា ៦១៦ នៃក្រមដដែល

**មាត្រា ៦២០**.- សិទ្ធិរំលាយកិច្ចសន្យារបស់សន្តតិជន នៅក្នុងករណីដែលភតិកៈទទួលមរណភាព

ប្រសិនបើគ្មានបំណងចង់បន្តភតិសន្យាតទៅទៀតទេ សន្តតិជនរបស់ភតិកៈ អាចរំលាយកិច្ចសន្យានោះបាន ។

(កំណត់)

មាត្រានេះចែងទទួលស្គាល់នូវសិទ្ធិរំលាយរបស់សន្តតិជននៃភតិកៈ ដោយគិតឃើញថា ទោះបីជាភតិកៈ ឬ ភតិបតី បានទទួលមរណភាពក៏ដោយ ទំនាក់ទំនងនៃភតិសន្យានឹងត្រូវបានទទួលបន្តដោយសន្តតិជនរបស់អ្នកនោះ តែក្នុងករណីដែលភតិកៈបានទទួលមរណភាព ហើយប្រសិនបើសន្តតិជនរបស់ភតិកៈនោះ មិនមានផលប្រយោជន៍ពីការបន្តភតិសន្យានេះទេ ហើយនៅឱ្យអ្នកនេះទទួលករណីយកិច្ចបង់ថ្លៃឈ្នួល វាគឺជាការមិនសមរម្យ ហេតុនេះហើយ មាត្រានេះទទួលស្គាល់នូវសិទ្ធិរំលាយភតិសន្យារបស់សន្តតិជនខាងភតិកៈ ។ ពាក្យ "រំលាយ" នៅក្នុងនេះ មានន័យថា "ជូនដំណឹងរំលាយកិច្ចសន្យា" ។

ម្យ៉ាងទៀត មាត្រា ១១៣០ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ចែងថា ក្នុងករណីដែលភតិកៈទទួលមរណភាព ប្រសិនបើសន្តតិជនរបស់ភតិកៈនោះ មិនចង់បន្តភតិសន្យាទេ ភតិសន្យានោះនឹងត្រូវបញ្ចប់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១១៣០ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ៦២១**.- អំឡុងពេលប្រើសិទ្ធិទាមទារសំណងនៃការខូចខាត និង ការទាមទារឱ្យសងសោហ៊ុយមកវិញ

សំណងនៃការខូចខាតដែលកើតឡើងដោយសារភតិកៈ ក្នុងការប្រើប្រាស់ និង អាស្រ័យផលដែលផ្ទុយនឹងអត្ថន័យដើមនៃកិច្ចសន្យា និង ការសងមកវិញនូវសោហ៊ុយដែលភតិកៈបានចេញ ត្រូវទាមទារនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលភតិបតីបានទទួលការសងវត្ថុជួលនោះ ។

(កំណត់)

មាត្រានេះចែងថា សិទ្ធិរបស់ភតិបតីក្នុងការទាមទារនូវសំណងនៃការខូចខាត ចំពោះការខូចខាតដែលបានកើតឡើងដោយសារការប្រើ និង អាស្រ័យផលដែលផ្ទុយនឹងអត្ថន័យនៃភតិសន្យា របស់ភតិកៈ និង សិទ្ធិរបស់ភតិកៈក្នុងការទាមទារឱ្យសងមកវិញនូវសោហ៊ុយរបស់ភតិកៈចេញ ចាំបាច់ត្រូវអនុវត្តក្នុងអំឡុងពេល ១ ឆ្នាំ ក្រោយការប្រគល់វិញនូវវត្ថុជួល

ទៅឱ្យភតិបតី ។ អំឡុងពេលនេះពុំមែនជាអំឡុងពេលសម្រាប់ការដាក់ពាក្យបណ្តឹងទេ ។ មានន័យថា ប្រសិនបើគ្រាន់តែជូនដំណឹងអំពីឆន្ទៈអនុវត្តសិទ្ធិរបស់ខ្លួនក្រៅតុលាការទៅ ក្នុងអំឡុងពេល ១ ឆ្នាំនេះ វាជាការគ្រប់គ្រាន់ហើយ ដើម្បីកុំឱ្យរំលត់សិទ្ធិ ទាមទារនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦០០ នៃក្រមរដ្ឋប្បវេណីជប៉ុន ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ ដោយមាត្រា ៦២២ នៃក្រមដដែល

## ផ្នែកទី ៤ កិច្ចសន្យាប្រវាស់

(កំណត់)

នៅក្នុងក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មានបញ្ញត្តិស្តីពីកិច្ចសន្យាប្រវាស់ (métayage) ខ្លះៗដែរ ។ ក៏ប៉ុន្តែ ក្រមរដ្ឋប្បវេណីជប៉ុន និង ច្បាប់ភូមិបាលកម្ពុជាវិញ គ្មានបញ្ញត្តិស្តីពីការប្រវាស់ទេ ។ រីឯនៅក្នុងក្រមរដ្ឋប្បវេណីបារាំង មានតែបញ្ញត្តិស្តីពីការជួលសត្វពាហនៈ ចាប់ពីមាត្រា ១៨២៧ ទៅ ។

កិច្ចសន្យាប្រវាស់ គឺជាប្រភេទពិសេសនៃភតិសន្យា ក៏ប៉ុន្តែ ដោយផ្អែកលើគោលការណ៍សេរីភាពក្នុងការធ្វើកិច្ចសន្យា ឱ្យតែភាគីទាំងសងខាងព្រមព្រៀងគ្នា គឺអាចបង្កើតភតិសន្យាដែលមានខ្លឹមសារដូចនេះបាន ។ នៅប្រទេសកម្ពុជា គេសង្កេតឃើញថា តាមជនបទ កិច្ចសន្យាប្រវាស់ដូចនេះ មានមិនត្រឹមតែការប្រវាស់ដីស្រែចំការប៉ុណ្ណោះទេ គឺមានទាំងការប្រវាស់សំពៅសំប៉ាន សត្វពាហនៈ ជាដើម ដែរ ។ ក៏ប៉ុន្តែ ប្រសិនបើបណ្តោយឱ្យធ្វើកិច្ចសន្យាប្រវាស់ទូលាយខ្លាំងពេកទៅ នឹងក្លាយជាមិនអាចបែងចែកពីកិច្ចសន្យាក្រុមហ៊ុនបានទេ ហេតុនេះហើយ ក្នុងនេះ ត្រូវកម្រិតត្រឹមតែការប្រវាស់ដីធ្លី និង សត្វពាហនៈប៉ុណ្ណោះ ។

### មាត្រា ៦២២.- អត្ថន័យនៃកិច្ចសន្យាប្រវាស់

កិច្ចសន្យាដែលកម្មសិទ្ធិករ ឱ្យភតិកៈខ្ចីដី ឬ សត្វពាហនៈ ដើម្បីទាញយកផល ហើយយកផលនោះ មកបែងចែកគ្នា រវាងភតិបតី និង ភតិកៈ ហៅថា កិច្ចសន្យាប្រវាស់ ។

(កំណត់)

មាត្រានេះចែងអំពីនិយមន័យនៃកិច្ចសន្យាប្រវាស់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១១៣៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

### មាត្រា ៦២៣.- របៀបបែងចែកផល

បើពុំបានកំណត់អំពីរបៀបបែងចែកផលទេ ត្រូវចាត់ទុកថា ត្រូវបែងចែកស្មើៗភាគគ្នា ។

(កំណត់)

មាត្រានេះចែងថា ក្នុងកិច្ចសន្យាប្រវាស់ ក្នុងករណីដែលពុំមានកំណត់ពិសេសអ្វីអំពីវិធីបែងចែកផលទេ ត្រូវធ្វើការបែងចែកឱ្យស្មើភាពគ្នា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១១៣៧ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ៦២៤.-** សិទ្ធិចាត់ចែងផលរបស់ភតិកៈ

លុះត្រាតែនៅក្រោយពេលដែលបានបញ្ចប់ការចែកភាគនៃផលទៅឱ្យភតិបតីរួចហើយ ទើបភតិកៈនៃការប្រវាស់ អាចចាត់ចែងផលដែលជាចំណែករបស់ខ្លួនបាន ។

(កំណត់)

មាត្រានេះចែងថា សិទ្ធិចាត់ចែងផលរបស់ភតិកៈ ពុំអាចអនុវត្តបានឡើយ ប្រសិនបើមិនទាន់បានបែងចែកផលដល់ភតិបតីទេ ។ បញ្ញត្តិនេះមានគោលគំនិតដែលមានខ្លឹមសារថា ត្រូវបែងចែកផលជាក់ស្តែងដែលបានទទួល ជាមុនសិន ក្នុងកិច្ចសន្យាប្រវាស់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១១៣៩ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## ជំពូកទី ៦ ការខ្ចីប្រើ

**មាត្រា ៦២៥.-** និយមន័យនៃការខ្ចីប្រើ

ការខ្ចីប្រើ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ឱ្យភាគីម្ខាងទៀត ប្រើប្រាស់ និង អាស្រ័យផល នូវវត្ថុណាមួយ ដោយមិនឱ្យបង់ថ្លៃ ។

(កំណត់)

មាត្រានេះចែងអំពីនិយមន័យនៃការខ្ចីប្រើ ។

**មាត្រា ៦២៦.-** លក្ខខណ្ឌនៃការបង្កើតការខ្ចីប្រើ

កិច្ចសន្យាខ្ចីប្រើ ត្រូវមានអានុភាព ដោយភាគីម្ខាង ទទួលយកវត្ថុណាមួយពីភាគីម្ខាងទៀត ហើយសន្យាថានឹងសងវត្ថុនោះ ក្រោយពីបានប្រើប្រាស់ និង អាស្រ័យផល ដោយមិនបង់ថ្លៃ ។

(កំណត់)

មាត្រានេះចែងអំពីល័ក្ខខ័ណ្ឌនៃការបង្កើតកិច្ចសន្យាខ្ចីប្រើ ។ កិច្ចសន្យាខ្ចីប្រើ គឺជាកិច្ចសន្យាដែលត្រូវបានបង្កើតដោយការប្រគល់វត្ថុ ហើយនឹងមានសុពលភាពនៅពេលដែលអ្នកខ្ចីប្រើបានទទួលការប្រគល់ជាក់ស្តែងនូវវត្ថុខ្ចី ។ ម្យ៉ាងទៀត កិច្ចសន្យាខ្ចីប្រើ គឺជាកិច្ចសន្យាឯកតោភាគី (contrat unilatéral) ហើយជាកិច្ចសន្យាដែលមិនយកតម្លៃថ្នូរទេ (កិច្ចសន្យាមុធា) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៩៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៨៧៥ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៦២៧**.- ករណីយកិច្ចរបស់អ្នកខ្ចី នៅក្នុងការប្រើប្រាស់ និង អាស្រ័យផល

១-អ្នកខ្ចី ត្រូវរក្សាទុកវត្ថុខ្ចី ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-អ្នកខ្ចី ត្រូវប្រើប្រាស់ និង អាស្រ័យផលវត្ថុនោះ តាមកិច្ចសន្យា ឬ ដោយផ្អែកតាមវិធីប្រើ ដែលត្រូវបានកំណត់តាមនិស្ស័យនៃវត្ថុដែលជាកម្មវត្ថុនោះ ។

៣-បើគ្មានការយល់ព្រមពីអ្នកឱ្យខ្ចីទេ អ្នកខ្ចីពុំអាចឱ្យតតិយជនប្រើប្រាស់ ឬ អាស្រ័យផល ពីវត្ថុខ្ចីនោះបានឡើយ ។

៤-ក្នុងករណីដែលអ្នកខ្ចីធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ ឬ ទី ៣ ខាងលើនេះ អ្នកឱ្យខ្ចីអាចរំលាយកិច្ចសន្យាបាន ។

(កំណត់)

មាត្រានេះចែងអំពីករណីយកិច្ចរបស់អ្នកខ្ចីប្រើ ចំពោះការប្រើប្រាស់ និង អាស្រ័យផលពីវត្ថុខ្ចី ។ ក្នុងករណីដែលមានការបំពាននឹងករណីយកិច្ចនេះ អ្នកឱ្យខ្ចីអាចរំលាយកិច្ចសន្យាបាន ។ មាត្រានេះស្របនឹងមាត្រា ៦០០ មាត្រា ៦០១ និង មាត្រា ៦០៨ ស្តីពីភតិសន្យា ក្នុងក្រមនេះ ។ ពាក្យ "រំលាយ" ក្នុងមាត្រានេះ មានន័យថា "ជូនដំណឹងរំលាយកិច្ចសន្យា" ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤០០ និង មាត្រា ៥៩៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៨៨០ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៦២៨.-** បន្ទុកលើសោហ៊ុយ

១-អ្នកខ្ចី ត្រូវទទួលបន្ទុកលើសោហ៊ុយចាំបាច់ធម្មតា នៃវត្ថុខ្ចី ។

២-ប្រសិនបើអ្នកខ្ចីបានចេញចំណាយសោហ៊ុយចាំបាច់លើការជួសជុលធំៗ ជាអាទិ៍ ក្រៅពីសោហ៊ុយចាំបាច់ធម្មតា ឬ បានចំណាយប្រាក់ដើម្បីកែលំអ ឬ ចំណាយផ្សេងដើម្បីបង្កើនតម្លៃ នៅពេលដែលការខ្ចីប្រើត្រូវបានបញ្ចប់ អ្នកខ្ចីអាចទាមទារចំពោះអ្នកឱ្យខ្ចី ឱ្យសងវិញនូវប្រាក់ដែលបានចំណាយ ឬ តម្លៃប្រាក់ដែលកើននោះ តាមការជ្រើសរើសរបស់អ្នកឱ្យខ្ចី ក្នុងកម្រិតដែលកំណើនតម្លៃនោះនៅតែមាន ។ ប៉ុន្តែ តុលាការអាចអនុញ្ញាតឱ្យសង ដោយកំណត់អំឡុងពេលសមរម្យ យោលតាមការទាមទាររបស់អ្នកឱ្យខ្ចីបាន ។

(កំណត់)

មាត្រានេះគឺជាបញ្ញត្តិចែងអំពីបន្ទុករបស់អ្នកឱ្យខ្ចី ឬ អ្នកខ្ចី លើចំណាយដើម្បីធ្វើការថែរក្សា ឬ កែលំអវត្ថុខ្ចី ។ ខុសពីមាត្រា ៦០២ និង មាត្រា ៦០៤ ស្តីពីភតិសន្យា នៃក្រមនេះ ចំពោះកិច្ចសន្យាខ្ចីប្រើ ដែលជាកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ (កិច្ចសន្យាមុធា) អ្នកខ្ចីប្រើត្រូវទទួលបន្ទុកនូវសោហ៊ុយចាំបាច់ធម្មតា ដូចជាសោហ៊ុយសម្រាប់ជួសជុលតូចៗ ។ រីឯសោហ៊ុយសម្រាប់ការជួសជុលធំៗ ឬ សោហ៊ុយបង្កើតតម្លៃដើម្បីកែលំអ ត្រូវឱ្យអ្នកឱ្យខ្ចីបង់ដោយធ្វើការជ្រើសរើសសោហ៊ុយដែលបានចំណាយជាក់ស្តែង ឬ ចំនួនទឹកប្រាក់ដែលបានបង្កើនតម្លៃនៃវត្ថុឱ្យខ្ចីនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៩៥ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៨៨៦ និង មាត្រា ១៨៩០ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៦២៩.-** ការទទួលខុសត្រូវក្នុងការធានារបស់អ្នកឱ្យខ្ចី

អ្នកឱ្យខ្ចី ពុំទទួលខុសត្រូវក្នុងការធានា ចំពោះវិការៈនៃវត្ថុដែលជាកម្មវត្ថុនៃការខ្ចីប្រើ ឬ ការខ្វះសិទ្ធិទេ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើអ្នកឱ្យខ្ចីបានដឹងអំពីវិការៈ ឬ ការខ្វះសិទ្ធិនោះហើយ តែពុំបានជូនដំណឹងទៅអ្នកខ្ចី ។

(កំណត់)

មាត្រានេះចែងថា អ្នកឱ្យខ្ចីមិនទទួលខុសត្រូវក្នុងការធានាឡើយ ទោះបីជាក្នុងករណីដែលវត្ថុឱ្យខ្ចីនោះ មានវិការៈ ឬ សិទ្ធិលើវត្ថុនោះមានវិការៈក៏ដោយ លើកលែងតែក្នុងករណីដែលអ្នកឱ្យខ្ចីបានដឹងអំពីវិការៈនោះ តែមិនបានប្រាប់ដល់អ្នកខ្ចី ។ កិច្ចសន្យាខ្ចីប្រើ គឺជាកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ (កិច្ចសន្យាមុធា) ហេតុនេះហើយ ជាគោលការណ៍ អ្នកឱ្យខ្ចីមិនទទួលបន្ទុកក្នុងការធានាទេ ។

ចំពោះខ្លឹមសារនៃការទទួលខុសត្រូវក្នុងការធានា ក្នុងករណីពិសេសដែលអ្នកឱ្យខ្ចីត្រូវទទួលខុសត្រូវវិញ សូមមើល មាត្រា ៦០៥ នៃក្រមនេះ ស្តីពីភតិសន្យា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៥១ នៃក្រមរដ្ឋប្បវេណីជប៉ុន ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ ដោយមាត្រា ៥៩៦ នៃក្រមដដែល

## មាត្រា ៦៣០.- ការបញ្ចប់ការខ្ចីប្រើ យោលតាមការផុតកំណត់អំឡុងពេល ឬ ចប់ការប្រើប្រាស់ និង អាស្រ័យផល

១-ការខ្ចីប្រើដែលមានកំណត់អំឡុងពេល ត្រូវបញ្ចប់ដោយការផុតកំណត់អំឡុងពេល ។

២-នៅក្នុងករណីដែលភាគីមិនបានកំណត់អំឡុងពេល ប្រសិនបើបានកំណត់អំពីគោលបំណងនៃការខ្ចីប្រើ ការខ្ចីប្រើនឹងត្រូវបញ្ចប់ នៅពេលដែលអ្នកខ្ចីបានបញ្ចប់ការប្រើប្រាស់ និង អាស្រ័យផលវត្ថុខ្ចី តាមគោលបំណងនោះ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកខ្ចីពុំបានបញ្ចប់ការប្រើប្រាស់ និង អាស្រ័យផល ដោយសារការធ្វេសប្រហែសក្នុងការប្រើប្រាស់ និង អាស្រ័យផល ការខ្ចីប្រើនឹងត្រូវបញ្ចប់ បន្ទាប់ពីអំឡុងពេលដែលគ្រប់គ្រាន់ដើម្បីអនុវត្តការប្រើប្រាស់ និង អាស្រ័យផលនោះ បានកន្លងផុត ។

(កំណត់)

មាត្រានេះចែងអំពីពេលបញ្ចប់កិច្ចសន្យាខ្ចីប្រើ សម្រាប់ករណីនៃកិច្ចសន្យាខ្ចីប្រើដែលមានការកំណត់អំឡុងពេល នៅក្នុងកថាខណ្ឌទី ១ និង សម្រាប់ករណីនៃកិច្ចសន្យាខ្ចីប្រើដែលមានកំណត់តែគោលបំណងនៃការប្រើប្រាស់ តែពុំមានកំណត់អំឡុងពេលប្រើប្រាស់ នៅក្នុងកថាខណ្ឌទី ២ ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ មាត្រា ៥៩៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៨៨៨ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៦៣១.- ការស្នើសុំឱ្យរំលាយកិច្ចសន្យាពីអ្នកឱ្យខ្ចី

១-បើពុំបានកំណត់ទាំងអំឡុងពេល និង គោលបំណងផងទេ អ្នកឱ្យខ្ចីអាចស្នើសុំរំលាយកិច្ចសន្យាខ្ចីប្រើ នៅពេលណាក៏បាន ។

២-ទោះជានៅមុនការផុតកំណត់អំឡុងពេល ឬ នៅមុនការបញ្ចាប់ការប្រើប្រាស់ និង អាស្រ័យផលក៏ដោយ ប្រសិនបើមានករណីបន្ទាន់ និង ចាំបាច់កើតមានឡើងចំពោះវត្ថុខ្ចី ដែលអ្នកឱ្យខ្ចីពុំអាចព្យាករបាន អ្នកឱ្យខ្ចីអាចស្នើសុំរំលាយកិច្ចសន្យាខ្ចីប្រើបាន ។

(កំណត់)

មាត្រានេះចែងអំពីករណីពីរ ដែលអ្នកឱ្យខ្ចីអាចស្នើសុំរំលាយកិច្ចសន្យាបាន ។ មានន័យថា កថាខណ្ឌទី ១ ចែងអំពីករណីដែលកិច្ចសន្យាពុំមានការកំណត់នូវអំឡុងពេលប្រើប្រាស់ និង គោលបំណងប្រើប្រាស់ រីឯកថាខណ្ឌទី ២ ចែងអំពីករណីដែលអ្នកឱ្យខ្ចី មានការបន្ទាន់ ព្រមទាំងមានការចាំបាច់ដែលមិនអាចព្យាករបាន ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលកថាខណ្ឌទី ៣ មាត្រា ៥៩៧ នៃក្រមរដ្ឋប្បវេណីជប៉ុន ចំពោះកថាខណ្ឌទី ២ សូមមើលមាត្រា ១៨៨៩ នៃក្រមរដ្ឋប្បវេណីបារាំង ។

**មាត្រា ៦៣២.-** ការស្នើសុំឱ្យរំលាយកិច្ចសន្យាពីអ្នកខ្ចី

ទោះបីបានកំណត់ ឬ មិនបានកំណត់អំឡុងពេលក៏ដោយ អ្នកខ្ចីអាចស្នើសុំរំលាយកិច្ចសន្យាខ្ចីប្រើ នៅពេលណាក៏បាន ។ ប៉ុន្តែ ក្នុងករណីដែលអ្នកឱ្យខ្ចីមានផលប្រយោជន៍ទៅលើអំឡុងពេលនោះ អ្នកខ្ចីមានករណីយកិច្ចសងសំណងនៃការខូចខាត ដែលកើតឡើងដោយសារការស្នើសុំរំលាយកិច្ចសន្យានោះ ។

(កំណត់)

មាត្រានេះចែងថា អ្នកខ្ចីអាចស្នើសុំរំលាយកិច្ចសន្យាខ្ចីពេលណាក៏បានដែរ ហើយបញ្ញត្តិនេះត្រូវបានធ្វើឡើងដោយផ្អែកលើទ្រឹស្តីនីតិសាស្ត្រជប៉ុន ។ វាក្យខណ្ឌទី ២ នៃមាត្រានេះចែងសម្រាប់ករណីដូចជា ករណីដែលអ្នកឱ្យខ្ចីបានទៅធ្វើការនៅបរទេសរយៈពេលវែង ហើយបានឱ្យអ្នកផ្សេងខ្ចីផ្ទះរបស់ខ្លួនដោយមិនយកតម្លៃថ្នូរ ដើម្បីឱ្យអ្នកនោះជួយគ្រប់គ្រង ប្រសិនបើអ្នកខ្ចីស្នើសុំរំលាយកិច្ចសន្យានោះ ផ្ទះនេះបាត់អ្នកគ្រប់គ្រង ការខូចខាតអាចកើតឡើង ដោយសារអវត្តមានរបស់អ្នកគ្រប់គ្រងនោះ ។

**មាត្រា ៦៣៣.-** ការបញ្ចប់ការខ្ចីប្រើដោយសារមរណភាពរបស់អ្នកខ្ចី

ការខ្ចីប្រើ នឹងត្រូវបញ្ចប់ដោយសារមរណភាពរបស់អ្នកខ្ចី ។

(កំណត់)

មាត្រានេះចែងអំពីការបញ្ចប់ការខ្ចីប្រើ ក្នុងករណីដែលអ្នកខ្ចីបានទទួលមរណភាព ។ បញ្ញត្តិនេះផ្អែកទៅលើលក្ខណៈពិសេសនៃការខ្ចីប្រើ មានន័យថា ក្នុងការខ្ចីប្រើនេះ អ្នកឱ្យខ្ចីមានទំនុកចិត្តទៅលើអ្នកខ្ចី ទើបឱ្យខ្ចីប្រើដោយពុំយកតម្លៃថ្នូរ ។ ហេតុនេះហើយ ទោះបីជាអ្នកឱ្យខ្ចីបានទទួលមរណភាពក៏ដោយ ប្រសិនបើពុំមានល័ក្ខខ័ណ្ឌពិសេសទេ ការខ្ចីប្រើនេះមិនត្រូវបានបញ្ចប់ឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៩៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៦៣៤.- ករណីយកិច្ចប្រគល់វត្ថុខ្ចី

១-នៅពេលដែលការខ្ចីប្រើត្រូវបានបញ្ចប់ហើយ អ្នកខ្ចីមានករណីយកិច្ចត្រូវធ្វើបដិទានវត្ថុខ្ចីនោះ ហើយប្រគល់ទៅឱ្យអ្នកឱ្យខ្ចីវិញ ជាបន្ទាន់ ។

២-លើកលែងតែការបាក់បែក ការខូចខាតដែលកើតឡើងដោយសារការប្រើប្រាស់ជាធម្មតា អ្នកខ្ចីត្រូវជួសជុលការខូចខាតដែលកើតឡើងដោយសារមូលហេតុជាបន្ទុករបស់ខ្លួនឡើងវិញ ឬ ត្រូវមានករណីយកិច្ចសងសំណងនៃការខូចខាតនោះ ។

(កំណត់)

មាត្រានេះចែងអំពីករណីយកិច្ចធ្វើបដិទាន និង ករណីយកិច្ចប្រគល់សងវិញនូវវត្ថុខ្ចីប្រើរបស់អ្នកខ្ចី ពេលបញ្ចប់ការខ្ចីប្រើ ។ អ្នកខ្ចីត្រូវជួសជុលនូវការខូចខាតដែលកើតឡើងដោយសារមូលហេតុជាបន្ទុករបស់ខ្លួន ហើយប្រសិនបើមិនអាចជួសជុលឡើងវិញបានទេ ត្រូវសងនូវសំណងនៃការខូចខាតនោះ ។ ក៏ប៉ុន្តែ ចំពោះការខូចខាតដែលកើតឡើងដោយធម្មជាតិ ដោយការប្រើប្រាស់ធម្មតា ដូចជាក្រដាស់ជញ្ជាំងដែលប្តូរពណ៌ ឬ កម្រាលដែលប្រឡាក់ ជាអាទិ៍ អ្នកខ្ចីប្រើពុំមានករណីយកិច្ចជួសជុល ឬ សងនូវសំណងនៃការខូចខាតនោះឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៩៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៦៣៥.- សិទ្ធិរុះរើចេញរបស់អ្នកខ្ចី

បើកិច្ចសន្យាខ្ចីប្រើ ត្រូវបានបញ្ចប់ហើយ អ្នកខ្ចីអាចរុះរើចេញ នូវវត្ថុដែលបានភ្ជាប់ជាមួយនឹងវត្ថុខ្ចីនោះបាន ។

(កំណត់)

មាត្រានេះចែងអំពីសិទ្ធិរុះរើរបស់អ្នកខ្ចី នូវវត្ថុដែលខ្លួនបានភ្ជាប់ជាមួយនឹងវត្ថុខ្ចី នៅពេលបញ្ចប់កិច្ចសន្យាខ្ចីប្រើ ។

អ្នកខ្ចីមានសិទ្ធិរុះរើ ព្រមជាមួយគ្នានេះ មានករណីយកិច្ចរុះរើដែរ (មានន័យថា ករណីយកិច្ចធ្វើបដិទាន) ។ អ្នកឱ្យខ្ចីអាច អនុគ្រោះចំពោះករណីយកិច្ចធ្វើបដិទានបាន តែមិនអាចដកហូតនូវសិទ្ធិរុះរើរបស់អ្នកខ្ចី តាមទំនើងចិត្តខ្លួនបានឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៩៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៦៣៦**.- អំឡុងពេលប្រើសិទ្ធិទាមទារសំណងនៃការខូចខាត និង ទាមទារឱ្យសងសោហ៊ុយមកវិញ

សំណងនៃការខូចខាតដែលកើតឡើងដោយសារអ្នកខ្ចី ក្នុងការប្រើប្រាស់ ឬ អាស្រ័យផលដែលផ្ទុយនឹងអត្ថន័យដើមនៃកិច្ចសន្យា និង ការសងមកវិញនូវសោហ៊ុយដែលអ្នកខ្ចីបានចេញ ត្រូវទាមទារនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលអ្នកឱ្យខ្ចីបានទទួលការសងវត្ថុខ្ចីនោះ ។

(កំណត់)

មាត្រានេះចែងថា សិទ្ធិទាមទាររបស់អ្នកឱ្យខ្ចី ក្នុងការទាមទារសំណងនៃការខូចខាតដែលបានកើតឡើង ដោយសារការប្រើប្រាស់ និង អាស្រ័យផលដែលផ្ទុយនឹងអត្ថន័យនៃកិច្ចសន្យាខ្ចីប្រើរបស់អ្នកខ្ចី ឬ សិទ្ធិទាមទាររបស់អ្នកខ្ចីក្នុងការទាមទារឱ្យសងវិញនូវសោហ៊ុយ (សោហ៊ុយក្រៅពីសោហ៊ុយចាំបាច់ធម្មតា និង សោហ៊ុយដើម្បីបង្កើនតម្លៃ) ដោយផ្អែកលើកថាខណ្ឌទី ២ មាត្រា ៦២៨ នៃក្រមនេះ ចាំបាច់ត្រូវអនុវត្តក្នុងអំឡុងពេល ១ ឆ្នាំ ក្រោយការប្រគល់វិញនូវវត្ថុខ្ចី ទៅឱ្យអ្នកឱ្យខ្ចី ។ អំឡុងពេលនេះពុំមែនជាអំឡុងពេលដែលត្រូវតែដាក់ពាក្យបណ្តឹងទេ ។ មានន័យថា ប្រសិនបើគ្រាន់តែជូនដំណឹងអំពីឆន្ទៈអនុវត្តសិទ្ធិរបស់ខ្លួនក្រៅតុលាការទៅ ក្នុងអំឡុងពេល ១ ឆ្នាំនេះ វាជាការគ្រប់គ្រាន់ហើយ ដើម្បីកុំឱ្យរំលត់សិទ្ធិទាមទារនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦០០ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ជំពូកទី ៧ អាណត្តិ

(កំណត់)

ជំពូកទី ៧ នេះ ចែងអំពីកិច្ចសន្យាអាណត្តិ ។ ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មានបញ្ញត្តិស្តីពីកិច្ចសន្យាអាណត្តិចំនួន ១៩ មាត្រា ចាប់ពីមាត្រា ១២៦៨ ដល់មាត្រា ១២៨៦ ។

ប្រសិនបើប្រៀបធៀបច្បាប់នៃបណ្តាប្រទេសនានា មានប្រទេសជាច្រើនដែលបានរៀបចំបញ្ញត្តិស្តីពីអាណត្តិ នៅក្នុង

ក្រមរដ្ឋប្បវេណី ។ ឧទាហរណ៍ មាត្រា ៦៤៣ ដល់មាត្រា ៥៦៥ នៃក្រមរដ្ឋប្បវេណីជប៉ុន (១៤ មាត្រា), មាត្រា ២២៩ ដល់មាត្រា ២៥៩ នៃគន្ថីស្តីពីលទ្ធកម្មទ្រព្យសម្បត្តិ នៃក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន (៣១ មាត្រា), មាត្រា ១៩៨៤ ដល់មាត្រា ២០១០ នៃក្រមរដ្ឋប្បវេណីបារាំង (២៧ មាត្រា), មាត្រា ១៩៨៤ ដល់មាត្រា ២០១០ នៃក្រមរដ្ឋប្បវេណីបែលហ្សិក (២៧ មាត្រា), មាត្រា ១៧០៣ ដល់មាត្រា ១៧៤១ នៃក្រមរដ្ឋប្បវេណីអ៊ីតាលី (៣៩ មាត្រា), មាត្រា ១៧០៩ ដល់មាត្រា ១៧៣៩ នៃក្រមរដ្ឋបមវេណីអេស្ប៉ាញ (៣១ មាត្រា), មាត្រា ៦៦២ ដល់មាត្រា ៦៧៦ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ (១៥ មាត្រា), មាត្រា ៣៩៤ ដល់មាត្រា ៤១៨ នៃច្បាប់ស្តីពីកាតព្វកិច្ចរបស់ប្រទេសស្វីស (២៦ មាត្រា), មាត្រា ២១៣០ ដល់មាត្រា ២១៨៥ នៃក្រមរដ្ឋប្បវេណីកេបិច (៥៦ មាត្រា) ជាអាទិ៍ ។ ប៉ុន្តែ នៅក្នុងក្រមរដ្ឋប្បវេណីនៃប្រទេសមួយចំនួន បញ្ញត្តិស្តីពីអាណត្តិ រាប់បញ្ចូលផងដែរនូវបញ្ញត្តិស្តីពីប្រព័ន្ធដែលមានលក្ខណៈស្រដៀងគ្នានឹងអាណត្តិ ដូចជាការតំណាង (ការតំណាងដែលច្បាប់បានកំណត់) (ក្រមរដ្ឋប្បវេណីបារាំង និង កេបិច) ជើងសារ និង ដឹកជញ្ជូន (ក្រមរដ្ឋប្បវេណីអ៊ីតាលី) ឈ្មួញកណ្តាល និង ឈ្មួញលក់ដុំ (មាត្រា ៤១៨ a ដល់មាត្រា ៤១៨ v នៃច្បាប់ស្តីពីកាតព្វកិច្ចរបស់ប្រទេសស្វីស) ។

ក្នុងចំណោមក្រមរដ្ឋប្បវេណីនៃបណ្តាប្រទេសនានា បញ្ញត្តិស្តីពីអាណត្តិ នៃក្រមនេះ ត្រូវបានរៀបចំឡើង ដោយយកក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ក្រមរដ្ឋប្បវេណីជប៉ុន និង ក្រមរដ្ឋប្បវេណីបារាំង ជាអាទិ៍ មកធ្វើជាមូលដ្ឋានចម្បង ។

## មាត្រា ៦៣៧.- និយមន័យនៃអាណត្តិ

អាណត្តិសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថា អាណត្តិទាយក ប្រគល់សិទ្ធិអំណាចឱ្យភាគីម្ខាងទៀត ហៅថា អាណត្តិគាហក ធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក ។

(កំណត់)

(១) សេចក្តីពិស្តារស្តីពីនីតិកម្ម

យោងតាមមាត្រា ១២៦៨ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រានេះត្រូវបានធ្វើឡើងជាបញ្ញត្តិដែលកំណត់និយមន័យ ។ ចំពោះចំណុចនេះ ខុសគ្នាពីមាត្រា ៦៤៣ នៃក្រមរដ្ឋប្បវេណីជប៉ុន ។ ប៉ុន្តែ ឃ្លាថា "ក្នុងនាមខ្លួន" និង "តាងខ្លួន" ដែលត្រូវបានប្រើនៅក្នុងមាត្រា ១២៦៨ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ត្រូវបានលុបចោល ។ មូលហេតុដែលយើងធ្វើការលុបចោលនេះ ដោយសារតែមានការទិតៀនពីអ្នកច្បាប់កម្ពុជាថា មិនដឹងជាឃ្លានេះចង់សំដៅទៅលើអ្នកណាឱ្យប្រាកដ ។ លើសពីនេះទៅទៀត មាត្រានេះមិនបានបញ្ជាក់ឱ្យបានច្បាស់លាស់អំពីទម្រង់នៃសកម្មភាពរបស់អាណត្តិគាហកថា តើធ្វើក្នុងនាមអាណត្តិគាហក ឬ ក្នុងនាមអាណត្តិទាយកទេ ។ ក្នុងន័យនេះ ក្រមនេះមិនខុសពីក្រមរដ្ឋប្បវេណីជប៉ុនទេ ។ ទម្រង់នៃការតាក់តែងឃ្លា គឺយកតាមបញ្ញត្តិស្តីពីនិយមន័យនៃការលក់ទិញ (បញ្ញត្តិស្តីពី

និយមន័យនៃកិច្ចសន្យាម៉ៅការ និង កិច្ចសន្យាផ្សេងទៀត មិនស្របនឹងទម្រង់នេះទេ) ។ ជាលទ្ធផល មិនចាំបាច់រៀបចំបញ្ញត្តិផ្សេងស្តីពីនិយមន័យនៃអាណត្តិទាយក និង អ្វីទៅជាអាណត្តិគាហកទេ ។

តាមក្រមរដ្ឋប្បវេណីជប៉ុន ខ្លឹមសារនៃកិច្ចការអាណត្តិ គឺជាសកម្មភាពគតិយុត្ត (មាត្រា ៦៤៣) ហើយការប្រគល់សិទ្ធិអំណាចឱ្យអ្នកដទៃធ្វើកិច្ចការក្រៅពីសកម្មភាពគតិយុត្ត ហៅថាជាឧបអាណត្តិ (មាត្រា ៦៥៦) ។ ប៉ុន្តែ នៅក្នុងមាត្រានេះ ខ្លឹមសារនៃកិច្ចការអាណត្តិ មិនកម្រិតត្រឹមសកម្មភាពគតិយុត្តទេ ប៉ុន្តែ មានរាប់បញ្ចូលយ៉ាងទូលំទូលាយនូវ "ការចាត់ចែងកិច្ចការ" ។ ជាលទ្ធផល ការប្រគល់សិទ្ធិអំណាចឱ្យធ្វើកិច្ចការក្រៅពីសកម្មភាពគតិយុត្ត ក៏ត្រូវបានបញ្ចូលក្នុងចំណុចអាណត្តិដែរ ហើយមិនចាំបាច់រៀបចំបញ្ញត្តិដោយឡែកស្តីពីឧបអាណត្តិទេ ។

(២) ទំនាក់ទំនងរវាងអាណត្តិ និង ការតំណាង

ការតំណាងមានន័យថា អានុភាពនៃសកម្មភាពរវាងអ្នកតំណាង និង ភាគីម្ខាងទៀត មានចំពោះម្ចាស់សិទ្ធិ (មាត្រា ៣៦៤) ។ ចំពោះទំនាក់ទំនងរវាងម្ចាស់សិទ្ធិ និង អ្នកតំណាង មានករណីជាច្រើនដែលសិទ្ធិតំណាងត្រូវបានប្រគល់តាមរយៈកិច្ចសន្យាអាណត្តិ ប៉ុន្តែ ការប្រគល់សិទ្ធិតំណាងមិនមែនត្រូវបានប្រគល់តាមកិច្ចសន្យាអាណត្តិជានិច្ចកាលឡើយ (សូមមើលមាត្រា ៣៦៨) ។

(៣) កិច្ចសន្យាអាណត្តិ និង កិច្ចសន្យាការងារ

កិច្ចសន្យាការងារបង្កើតនូវទំនាក់ទំនងបន្ទាប់បន្សំ ដែលតាមរយៈនោះ ការងារពលកម្មនោះត្រូវបានផ្តល់ទៅតាមការបង្គាប់របស់និយោជក ។ ប្រាក់ឈ្នួលត្រូវបានផ្តល់ឱ្យជាតម្លៃថ្នូរទៅនឹងការផ្តល់ការងារពលកម្មនោះ ។ ផ្ទុយទៅវិញ កិច្ចសន្យាអាណត្តិមិនបង្កើតនូវទំនាក់ទំនងបន្ទាប់បន្សំរវាងអាណត្តិទាយក និង អាណត្តិគាហកទេ ហើយដូចដែលបានចែងនៅក្នុងមាត្រា ៦៣៨ ខាងក្រោមនេះ មិនចាំបាច់យកកម្រៃទេ ។

(៤) កិច្ចសន្យាអាណត្តិ និង កិច្ចសន្យាម៉ៅការ

ទោះបីជាកិច្ចសន្យាម៉ៅការទាក់ទងទៅនឹងការផ្តល់ការងារពលកម្មក៏ដោយ ក៏គោលបំណងនៃកិច្ចសន្យាម៉ៅការ គឺធ្វើឱ្យសម្រេចកិច្ចការដែរ ។ ដូច្នេះ ប្រសិនបើកិច្ចការមិនត្រូវបានសម្រេចទេ អ្នកម៉ៅការត្រូវបានចាត់ទុកថា មិនបានអនុវត្តកាតព្វកិច្ច ហើយមិនអាចទាមទារកម្រៃបានទេ ។ ផ្ទុយទៅវិញ គោលបំណងនៃកិច្ចសន្យាអាណត្តិ គឺសំដៅដល់ការផ្តល់ការងារពលកម្មដោយផ្ទាល់ ហើយអាណត្តិគាហកអាចទាមទារកម្រៃបាន ទោះបីជាកិច្ចការមិនបានសម្រេចក៏ដោយ (ក្នុងករណីកិច្ចសន្យាអាណត្តិដោយយកកម្រៃ) ។

(៥) ឧទាហរណ៍ជាក់លាក់នៃកិច្ចសន្យាអាណត្តិ

ឧទាហរណ៍នៃកិច្ចសន្យាអាណត្តិ មានដូចជាករណីដែលលោក A ប្រគល់សិទ្ធិលក់អចលនវត្ថុឱ្យទៅលោក B ។ ការប្រគល់សិទ្ធិឱ្យទៅមេធាវីធ្វើសកម្មភាពបណ្តឹង ក៏ជាឧទាហរណ៍សាមញ្ញមួយដែរ ។ ទំនាក់ទំនងកិច្ចសន្យាព្យាបាលរវាងគ្រូពេទ្យ និង អ្នកជម្ងឺ ក៏ចាត់ទុកជាអាណត្តិ ឬ ប្រហាក់ប្រហែលគ្នាទៅនឹងអាណត្តិដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៤៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១២៦៨ និង មាត្រា ១២៦៩ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ១៩៨៤ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៦៣៨.-** គោលការណ៍នៃអាណត្តិដោយមិនយកកម្រៃ

១-អាណត្តិអាចធ្វើដោយយកកម្រៃ ឬ មិនយកកម្រៃបាន ។ បើពុំបានបង្ហាញឆន្ទៈអំពីការធ្វើដោយយកកម្រៃទេ ត្រូវសន្មតថាជាអាណត្តិដោយមិនយកកម្រៃ ។

២-បញ្ញត្តិនៃមាត្រា ៦៤៤ (សិទ្ធិទាមទារកម្រៃរបស់អាណត្តិគាហក) នៃក្រមនេះ ត្រូវយកមកអនុវត្តចំពោះកម្រៃ នៅក្នុងករណីនៃអាណត្តិដោយយកកម្រៃ ។

(កំណត់)

(១) គោលគំនិតនៃកថាខណ្ឌទី ១

កថាខណ្ឌទី ១ ចែងថា អាណត្តិអាចធ្វើដើម្បីយកកម្រៃ ឬ មិនយកកម្រៃបាន ប៉ុន្តែ ប្រសិនបើមិនមានការបង្ហាញអំពីការធ្វើអាណត្តិដោយយកកម្រៃទេ នឹងត្រូវសន្មតថាជាអាណត្តិដោយមិនយកកម្រៃ ។ ដូចបានចែងនៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន ជាគោលការណ៍ អាណត្តិត្រូវធ្វើឡើងដោយមិនយកកម្រៃ ។ ការកំណត់របៀបនេះ គឺផ្អែកលើទស្សនៈជាប្រពៃណីតាំងពីសម័យច្បាប់រ៉ូម៉ាំងមក ។ ប៉ុន្តែ ការអនុវត្តបែបនេះមិនបដិសេធមិនឱ្យធ្វើអាណត្តិដោយយកកម្រៃទេ ។ ភាគីអាចធ្វើអាណត្តិដោយយកកម្រៃ ដោយការព្រមព្រៀងគ្នាទៅវិញទៅមកបាន ។

(២) អត្ថន័យនៃបញ្ញត្តិសន្មត

វាក្យខណ្ឌទី ២ នៃកថាខណ្ឌ ១ ជាបញ្ញត្តិសន្មត ហេតុដូច្នេះ មិនមែនតែក្នុងករណីដែលមានការបង្ហាញឆន្ទៈច្បាស់លាស់អំពីការធ្វើអាណត្តិដោយយកកម្រៃប៉ុណ្ណោះទេ ព្រមទាំងក្នុងករណីដែលមិនមានការបង្ហាញឆន្ទៈច្បាស់លាស់ តែមានការព្រមព្រៀងដោយតុណ្ហីភាព ក៏អាណត្តិនេះក៏ត្រូវបានគេបកស្រាយថាជាអាណត្តិដោយយកកម្រៃដែរ ។ ដូច្នេះ ប្រសិនបើមានការបញ្ជាក់ថា ភាគីទាំងពីរមានការព្រមព្រៀងគ្នា ដើម្បីធ្វើអាណត្តិដោយយកកម្រៃ ទោះបីជាដោយជាក់លាក់ ឬ ដោយតុណ្ហីភាពក៏ដោយ ក៏ការសន្មតថាជាអាណត្តិដោយមិនយកកម្រៃត្រូវបានបដិសេធដែរ ហើយអាចត្រូវបានបកស្រាយថាជាអាណត្តិដោយយកកម្រៃ ។ តាមសភាពជាក់ស្តែងនាពេលបច្ចុប្បន្ន អាណត្តិជាច្រើនត្រូវបានបកស្រាយថាជាអាណត្តិដែលយកកម្រៃ ។

ទាក់ទងទៅនឹងអាណត្តិរវាងពាណិជ្ជករ និង ពាណិជ្ជករ បញ្ញត្តិដែលចែងថា ជាគោលការណ៍ អាណត្តិត្រូវយកកម្រៃ គួរតែបញ្ចូលទៅក្នុងក្រមពាណិជ្ជកម្ម (ឬ ច្បាប់ពិសេស) (សូមមើលមាត្រា ៥១២ នៃក្រមពាណិជ្ជកម្មជប៉ុន) ។

(៣) គោលគំនិតនៃកថាខណ្ឌទី ២

កថាខណ្ឌទី ២ ចែងថា មាត្រា ៦៤៤ ត្រូវយកមកអនុវត្តចំពោះសិទ្ធិទាមទារកម្រៃរបស់អាណត្តិគាហក ក្នុងករណីនៃ

អាណត្តិដែលយកកម្រៃ ។ ទោះបីជាគ្មានកថាខណ្ឌទី ២ នៃមាត្រានេះក៏ដោយ ក៏មានភាពច្បាស់លាស់ថា អាណត្តិគាហក នៃអាណត្តិដែលយកកម្រៃ មានសិទ្ធិទាមទារកម្រៃ ហើយមាត្រា ៦៤៤ ត្រូវយកមកអនុវត្តដែរ ប៉ុន្តែ បញ្ញត្តិនេះត្រូវបាន ធ្វើឡើងដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ១ មាត្រា ៦៤៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១២៧០ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ១៩៨៦ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៦៣៩.- ភាពចាំបាច់នៃទម្រង់កិច្ចសន្យា

កិច្ចសន្យាអាណត្តិត្រូវបង្កើតដោយការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះចែងថា កិច្ចសន្យាអាណត្តិត្រូវបង្កើតឡើងដោយការព្រមព្រៀងរវាងភាគីទាំងពីរតែប៉ុណ្ណោះ ហើយមិន តម្រូវឱ្យមានលិខិតជាលាយល័ក្ខណ៍អក្សរ ជាល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពនោះទេ ។ ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា កំណត់ថា កិច្ចសន្យាអាណត្តិត្រូវតែធ្វើជាលាយល័ក្ខណ៍អក្សរ ចំណែកឯក្រមរដ្ឋប្បវេណីជប៉ុន និង ក្រមរដ្ឋប្បវេណីបារាំងវិញ ចែងថា កិច្ចសន្យាអាណត្តិត្រូវមានអានុភាពដោយការព្រមព្រៀងគ្នាតែប៉ុណ្ណោះ (ក៏ប៉ុន្តែ ក្រមរដ្ឋប្បវេណីបារាំងតម្រូវឱ្យ មានការបញ្ជាក់ដោយសាក្សី) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៧១ និង មាត្រា ១២៨៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ១៩៨៥ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៦៤០.-ករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក

១-អាណត្តិគាហក មានករណីយកិច្ចចាត់ចែងកិច្ចការអាណត្តិ ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត ដោយផ្អែកតាមអត្ថន័យនៃអាណត្តិ ។ ប៉ុន្តែ បញ្ញត្តិនេះមិន រារាំងចំពោះការបន្ថយករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក តាមការព្រមព្រៀង របស់ភាគីឡើយ ។

២-ក្នុងករណីដែលអាណត្តិគាហក ធ្វើផ្ទុយនឹងករណីយកិច្ចប្រុងប្រយ័ត្ននៃកថាខណ្ឌ ទី ១ ខាងលើនេះ ហើយបានធ្វើឱ្យមានការខូចខាតដល់អាណត្តិទាយក អាណត្តិទាយកអាច ទាមទារសំណងនៃការខូចខាតនោះពីអាណត្តិគាហកបាន ។ នៅក្នុងករណីនេះ ប្រសិនបើ

ជាអាណត្តិដោយមិនយកកម្រៃ តុលាការអាចបន្ថយចំនួនទឹកប្រាក់សំណងនៃការខូចខាតបាន ។

(កំណត់)

(១) គោលគំនិតកថាខណ្ឌទី ១

វាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ចែងថា អាណត្តិគាហកត្រូវទទួលនូវករណីយកិច្ចប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត ។ "ការប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត" នៅក្នុងនេះ មានន័យថា ករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក ជាករណីយកិច្ចធ្ងន់ធ្ងរ ។ ហេតុផលនេះគឺដោយសារតែកិច្ចសន្យាអាណត្តិកើតឡើងដោយការទុកចិត្តគ្នារវាងភាគី ។ និយាយឱ្យចំទៅ អាណត្តិគាហកដែលជាកូនបំណុល ត្រូវបំពេញករណីយកិច្ចប្រុងប្រយ័ត្នក្នុងកម្រិតដែលជាទូទៅ អាណត្តិគាហកត្រូវបានតម្រូវឱ្យមាន ទៅតាមវិជ្ជាជីវៈដែលអាណត្តិគាហកធ្វើ ឋានៈផ្នែកសង្គម និង ផ្នែកសេដ្ឋកិច្ចរបស់អាណត្តិគាហកនោះ ។

ដោយសារតែមិនមានភាពខុសគ្នារវាងអាណត្តិដោយយកកម្រៃ និង អាណត្តិដោយមិនយកកម្រៃ ទាក់ទងទៅនឹងករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក អាណត្តិគាហកមានករណីយកិច្ចប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងសុចរិតដូចគ្នា ក្នុងករណីនៃអាណត្តិដោយយកកម្រៃក្តី ឬ អាណត្តិដោយមិនយកកម្រៃក្តី ។ វាជាការធម្មតា ពីព្រោះអាណត្តិទាយកធ្វើអាណត្តិទៅឱ្យអាណត្តិគាហក ដោយមានការជឿជាក់អាណត្តិគាហកនោះ ។ ក៏ប៉ុន្តែ ចំពោះសំណងការខូចខាត ក្នុងករណីនៃការបំពានករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក កថាខណ្ឌទី ២ ចាត់ចែងផ្សេងគ្នារវាងអាណត្តិដោយយកកម្រៃ និង អាណត្តិដោយមិនយកកម្រៃ ។

វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ចែងថា ករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក អាចត្រូវបានបន្ធូរបន្ថយតាមការព្រមព្រៀងរវាងភាគីបាន ។ ទោះបីជាវាហាក់ដូចជាការធម្មតាក៏ដោយ ក៏បញ្ញត្តិនេះត្រូវបានធ្វើឡើងដើម្បីបញ្ជាក់កាន់តែច្បាស់ថែមទៀតដែរ ។ ឧទាហរណ៍ នៅក្នុងករណីនៃអាណត្តិដោយមិនយកកម្រៃ ករណីកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហកនឹងអាចត្រូវបានបន្ធូរបន្ថយបាន ។

ម្យ៉ាងទៀត ដោយសារអាណត្តិផ្អែកលើទំនាក់ទំនងផ្ទាល់នៃការទុកចិត្តគ្នារវាងភាគី វាត្រូវបានបកស្រាយថា ជាគោលការណ៍ អាណត្តិគាហកត្រូវតែចាត់ចែងកិច្ចការដោយខ្លួនផ្ទាល់ ។

(២) គោលគំនិតកថាខណ្ឌទី ២

វាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ២ ចែងថា ប្រសិនបើអាណត្តិគាហកបង្កឱ្យមានការខូចខាតដល់អាណត្តិទាយកដោយសារការបំពានករណីយកិច្ចប្រុងប្រយ័ត្នដែលបានកំណត់ក្នុងកថាខណ្ឌទី ១ អាណត្តិគាហកត្រូវទទួលខុសត្រូវក្នុងការសងនូវសំណងនៃការខូចខាតនោះទៅអាណត្តិទាយក ។ ខ្លឹមសារនេះជាការធម្មតា ដោយយោងតាមគោលការណ៍ទូទៅអំពីការមិនអនុវត្តកាតព្វកិច្ច ប៉ុន្តែ បញ្ញត្តិនេះត្រូវបានធ្វើឡើងក្នុងមាត្រានេះ ដោយយោងទៅតាមមាត្រា ១២៧៩ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា (កថាខណ្ឌទី ២ មាត្រា ១៩៩២ នៃក្រមរដ្ឋប្បវេណីបារាំង ក៏មានគោលគំនិតដូច្នេះដែរ) ។

វាក្យខណ្ឌទី ២ មានសារៈសំខាន់ នៅត្រង់ដែលបញ្ញត្តិដែលចែងថា តុលាការអាចបន្ថយចំនួនទឹកប្រាក់សំណងនៃការខូចខាតបាន ចំពោះសំណងការខូចខាតដោយសារការបំពានករណីយកិច្ចប្រុងប្រយ័ត្ន ក្នុងករណីអាណត្តិដោយមិនយកកម្រៃ ។ ឈរលើទស្សនៈសមភាពរវាងភាគី បញ្ញត្តិនេះបានកំណត់អំពីភាពខុសគ្នា រវាងអាណត្តិគាហកនៃអាណត្តិដោយយកកម្រៃ និង អាណត្តិគាហកនៃអាណត្តិដោយមិនយកកម្រៃ ។ ទោះបីជាក្រមរដ្ឋប្បវេណីជប៉ុនមិនមានបញ្ញត្តិបែបដូច្នេះក៏ដោយ ក៏ក្រុមអ្នកច្បាប់ខ្លះទទួលឥទ្ធិពលពីការសិក្សាច្បាប់ប្រៀបធៀប ធ្វើការបកស្រាយថា ក្នុងករណីនៃអាណត្តិដោយយកកម្រៃ ការទទួលខុសត្រូវរបស់អាណត្តិគាហក ក្នុងការសងសំណងការខូចខាត គួរតែត្រូវបានបន្ធូរបន្ថយ ។ ទស្សនៈនេះត្រូវបានដាក់បញ្ចូលទៅក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៤៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១២៨០ មាត្រា ១២៧៨ (វាក្យខណ្ឌទី២) និង មាត្រា ១២៧៩ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ១៩៩២ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៦៤១.- ករណីយកិច្ចរាយការណ៍របស់អាណត្តិគាហក

បើមានការទាមទាររបស់អាណត្តិទាយក អាណត្តិគាហកត្រូវរាយការណ៍អំពីស្ថានភាពនៃកិច្ចការចាត់ចែងអាណត្តិ ទោះបីនៅពេលណាក៏ដោយ ឬ ត្រូវរាយការណ៍អំពីហេតុការណ៍នោះដោយគ្មានការយឺតយ៉ាវ នៅក្រោយពេលដែលបានបញ្ចប់អាណត្តិហើយ ។

(កំណត់)

មាត្រានេះដាក់បន្ទុកលើអាណត្តិគាហកនូវករណីយកិច្ចរាយការណ៍អំពីស្ថានភាពអំពីការចាត់ចែងកិច្ចការអាណត្តិ ដែលជាករណីយកិចបន្ទាប់បន្សំភ្ជាប់នឹងការចាត់ចែងកិច្ចការអាណត្តិ ដែលជាគោលបំណងដើមនៃអាណត្តិ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៤៥ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១២៧៧ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ១៩៩៣ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៦៤២.- ករណីយកិច្ចប្រគល់របស់អាណត្តិគាហក

១-អាណត្តិគាហកត្រូវប្រគល់ប្រាក់ និង វត្ថុផ្សេងៗទៀតដែលទទួលបានតាមការចាត់ចែងកិច្ចការអាណត្តិ ឱ្យទៅអាណត្តិទាយក ។ អាណត្តិគាហកក៏ត្រូវប្រគល់ផលដែលប្រមូលបានឱ្យទៅអាណត្តិទាយកផងដែរ ។

២-សិទ្ធិដែលអាណត្តិគាហកបានលទ្ធកម្មនៅក្នុងនាមរបស់ខ្លួនដើម្បីអាណត្តិទាយក ត្រូវផ្ទេរសិទ្ធិនោះឱ្យទៅអាណត្តិទាយក ។

(កំណត់)

ដូចគ្នាទៅនឹងមាត្រា ៦៤១ ខាងលើនេះដែរ មាត្រានេះចែងអំពីករណីយកិច្ចបន្ទាប់បន្សំរបស់អាណត្តិគាហក ក្នុងការប្រគល់ប្រាក់ និង វត្ថុផ្សេងទៀតដែលអាណត្តិគាហកទទួលបាន នៅក្នុងដំណើរការនៃការចាត់ចែងកិច្ចការអាណត្តិ (រួមទាំងផលដែលបានទទួល) ឱ្យទៅអាណត្តិទាយក ។ ចំពោះសិទ្ធិដែលអាណត្តិគាហកបានធ្វើលទ្ធកម្ម នៅក្នុងនាមរបស់ខ្លួនដើម្បីអាណត្តិទាយក ក៏ដូចគ្នានេះផងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៤៦ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១២៧៨ (វាក្យខណ្ឌទី ១) នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ១៩៩៣ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៦៤៣.- ករណីយកិច្ចសងសំណងនៃការខូចខាតរបស់អាណត្តិគាហកដែលបានប្រើប្រាក់

ប្រសិនបើអាណត្តិគាហកបានប្រើប្រាក់ដែលត្រូវប្រគល់ទៅឱ្យអាណត្តិទាយក ឬបានប្រើប្រាក់ដែលទុកប្រើសម្រាប់ផលប្រយោជន៍នោះ ដើម្បីខ្លួន ត្រូវបង់ការប្រាក់ដោយគិតចាប់ពីថ្ងៃដែលបានប្រើប្រាក់នោះ ។ ប្រសិនបើមានការខូចខាត ត្រូវទទួលខុសត្រូវសងសំណងនោះ ។

(កំណត់)

ដោយសារតែប្រាក់ដែលអាណត្តិគាហកទទួលបានពីតតិយជនក្នុងអំឡុងពេលចាត់ចែងកិច្ចការអាណត្តិគួរតែជាទ្រព្យសម្បត្តិរបស់អាណត្តិទាយក ហើយមាត្រានេះចែងអំពីករណីយកិច្ចសងការខូចខាតទៅឱ្យអាណត្តិទាយក ប្រសិនបើអាណត្តិគាហកប្រើប្រាស់ប្រាក់នោះ ។ អាណត្តិគាហកមានករណីយកិច្ចសងការខូចខាតមិនមែនត្រឹមតែការប្រាក់ក្នុងអំឡុងពេលនៃការឃឹតយ៉ាវប៉ុណ្ណោះទេ តែថែមទាំងសម្រាប់ការខូចខាតដទៃផ្សេងៗទៀតផងដែរ ។ បញ្ញត្តិនេះ ខុសគ្នាពីគោលការណ៍នៃការខូចខាតធម្មតា ដែលទាក់ទងទៅនឹងកាតព្វកិច្ចជាប្រាក់ឯទៀត (មាត្រា ៣៩៩) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៤៧ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ១៩៩៦ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៦៤៤.- សិទ្ធិទាមទារកម្រៃរបស់អាណត្តិគាហក

១-អាណត្តិគាហក ពុំអាចទាមទារកម្រៃចំពោះអាណត្តិទាយកបានឡើយ ក្នុងករណីដែលពុំបានកំណត់ជាពិសេស ក្នុងកិច្ចសន្យា ។

២-នៅក្នុងករណីនៃអាណត្តិដោយយកកម្រៃ អាណត្តិគាហកមិនអាចទាមទារកម្រៃបានឡើយ បើមិនបានបញ្ចប់ការអនុវត្តករណីយកិច្ចដែលត្រូវតាមអាណត្តិនោះរួចហើយទេ ។ ប៉ុន្តែ បើបានកំណត់កម្រៃតាមអំឡុងពេល អាចទាមទារបាន នៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត ។

៣-បើអាណត្តិត្រូវបានបញ្ចប់ការអនុវត្ត នៅពាក់កណ្តាលទី ដោយសារមូលហេតុដែលមិនមែនជាការទទួលខុសត្រូវរបស់អាណត្តិគាហក អាណត្តិគាហកអាចទាមទារកម្រៃបានតាមសមាមាត្រនៃភាគដែលបានអនុវត្តរួចហើយនោះ ។

(កំណត់)

ដូចបានចែងនៅក្នុងមាត្រា ៦៣៨ ជាគោលការណ៍ កិច្ចសន្យាអាណត្តិមិនយកកម្រៃ ប៉ុន្តែ មាត្រានេះចែងអំពីសិទ្ធិទាមទារកម្រៃ ក្នុងករណីនៃអាណត្តិដោយយកកម្រៃ និង កំណត់អំពីគោលការណ៍នៃការបង់កម្រៃតាមក្រោយ ។ មាត្រានេះ ក៏បានចែងផងដែរថា ប្រសិនបើអាណត្តិត្រូវបានបញ្ចប់នៅពាក់កណ្តាលទី ដោយសារមូលហេតុដែលមិនមែនជាការទទួលខុសត្រូវរបស់អាណត្តិគាហក អាណត្តិគាហកអាចទាមទារកម្រៃបានតាមសមាមាត្រនៃភាគដែលបានអនុវត្តរួចហើយ ។ ក្នុងកិច្ចសន្យាម៉ៅការ អ្នកម៉ៅការមានករណីយកិច្ចសម្រេចការងារ (កាតព្វកិច្ចសម្រេចលទ្ធផល) ហើយប្រសិនបើកិច្ចសន្យាត្រូវបានបញ្ចប់នៅពាក់កណ្តាលទី ដោយមិនបានសម្រេចការងារ នោះអ្នកម៉ៅការទទួលបន្ទុកនូវហានិភ័យនេះ (មានន័យថា អ្នកម៉ៅការមិនអាចទាមទារកម្រៃពីម្ចាស់ការបានឡើយ) ។ រីឯចំពោះករណីកិច្ចសន្យាអាណត្តិវិញ ដោយសារអាណត្តិគាហកមានករណីយកិច្ចចាត់ចែងកិច្ចការអាណត្តិ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត ដោយផ្អែកតាមអត្ថន័យនៃអាណត្តិ ប៉ុន្តែ មិនមានករណីយកិច្ចសម្រេចកិច្ចការអាណត្តិឱ្យចប់សព្វគ្រប់ទេ (កាតព្វកិច្ចផ្តល់មធ្យោបាយ) ទោះបីជាកិច្ចការអាណត្តិ ត្រូវបានបញ្ចប់នៅពាក់កណ្តាលទីក៏ដោយ ក៏អាណត្តិគាហកមានសិទ្ធិទាមទារកម្រៃក្នុងទំហំសមរម្យដែរ ។ ក្នុងន័យនេះ អាណត្តិខុសគ្នាខ្លាំងពីកិច្ចសន្យាម៉ៅការ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៤៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៩៩៩ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៦៤៥**.- ករណីយកិច្ចបង់សោហ៊ុយជាមុនរបស់អាណត្តិទាយក

ប្រសិនបើមានតម្រូវការចាំបាច់លើសោហ៊ុយសម្រាប់ការចាត់ចែងកិច្ចការអាណត្តិ អាណត្តិទាយកត្រូវបង់សោហ៊ុយនោះជាមុន តាមការទាមទាររបស់អាណត្តិគាហក ។

(កំណត់)

មាត្រានេះចែងអំពីករណីយកិច្ចរបស់អាណត្តិទាយក ក្នុងការបង់សោហ៊ុយទៅឱ្យអាណត្តិគាហកសម្រាប់ការចាត់ចែងកិច្ចការអាណត្តិ ។ ទោះបីជាអាណត្តិដោយយកកម្រៃក៏ដោយ ឬ មិនយកកម្រៃក៏ដោយ ប្រសិនបើអាណត្តិគាហកទាមទារសោហ៊ុយ ក៏អាណត្តិទាយកត្រូវបង់សោហ៊ុយនោះជាមុន ។ ការចែងបែបនេះ គឺដោយឈរលើគោលគំនិតមួយថា ការដាក់បន្ទុកពិសេសណាមួយលើអាណត្តិគាហក ដែលចាត់ចែងកិច្ចការអាណត្តិសម្រាប់អាណត្តិទាយក មានភាពមិនសមរម្យ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៤៩ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៦៤៦**.- សិទ្ធិទាមទារឱ្យសងមកវិញ ជាអាទិ៍ នូវសោហ៊ុយរបស់អាណត្តិគាហក

១-ប្រសិនបើបានចំណាយប្រាក់ដែលទទួលស្គាល់ថាចាំបាច់សម្រាប់ធ្វើការចាត់ចែងកិច្ចការអាណត្តិ អាណត្តិគាហកអាចទាមទារចំពោះអាណត្តិទាយកឱ្យសងមកវិញ នូវសោហ៊ុយ និង ការប្រាក់បាន ដោយគិតចាប់ពីក្រោយថ្ងៃដែលបានចំណាយសោហ៊ុយនោះ ។

២-ប្រសិនបើបានទទួលបន្ទុកកាតព្វកិច្ចដែលទទួលស្គាល់ថាចាំបាច់សម្រាប់ធ្វើការចាត់ចែងកិច្ចការអាណត្តិ អាណត្តិគាហកអាចឱ្យអាណត្តិទាយកសងកាតព្វកិច្ចនោះជំនួសខ្លួន ឬ បើពុំទាន់ដល់កំណត់ពេលដែលត្រូវសងកាតព្វកិច្ចនោះទេ អាចឱ្យដាក់ប្រាតិភោគដែលសមរម្យបាន ។

៣-ប្រសិនបើបានទទួលការខូចខាត ដែលមិនមែនបណ្ដាលមកពីកំហុសរបស់ខ្លួននៅក្នុងការចាត់ចែងកិច្ចការអាណត្តិទេ អាណត្តិគាហកអាចទាមទារសំណងនោះ ពីអាណត្តិទាយកបាន ។ ប៉ុន្តែ ប្រសិនបើការខូចខាតនោះ កើតឡើងដោយចេតនា ឬ កំហុសរបស់តតិយជន អាណត្តិគាហកអាចទាមទារសំណងចំពោះអាណត្តិទាយកបាន ត្រឹមកម្រិតដែលពុំបានទទួលសំណងពីតតិយជននោះតែប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះ (ជាពិសេសកថាខណ្ឌទី ១ និង កថាខណ្ឌទី ២) មានគោលបំណងដូចគ្នានឹងគោលបំណងនៃមាត្រា ៦៤៥ ខាងលើនេះដែរ ។ ការទទួលខុសត្រូវរបស់អាណត្តិទាយកដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ គឺជាការទទួលខុសត្រូវដោយគ្មានកំហុស មានន័យថា ទោះបីជាអណត្តិទាយកគ្មានកំហុសក៏ដោយ ក៏ត្រូវទទួលខុសត្រូវដែរ (មិនចាំបាច់មានកំហុសរបស់អាណត្តិទាយក ដើម្បីទាមទារឱ្យអាណត្តិទាយកទទួលខុសត្រូវទេ) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៥០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១២៨១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ១៩៩៩ មាត្រា ២០០១ និង មាត្រា ២០០០ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៦៤៧**.- ការរំលាយកិច្ចសន្យាអាណត្តិ

១-ភាគីនីមួយៗ អាចរំលាយកិច្ចសន្យាអាណត្តិ នៅពេលណាក៏បាន ។

២-ភាគីម្ខាងត្រូវសងសំណងនៃការខូចខាត ប្រសិនបើបានរំលាយកិច្ចសន្យាអាណត្តិ នៅក្នុងអំឡុងពេលដែលធ្វើឱ្យខូចផលប្រយោជន៍ចំពោះភាគីម្ខាងទៀត ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើមានមូលហេតុដែលមិនអាចជៀសវាងបាន ។

(កំណត់)

មាត្រានេះបញ្ជាក់យ៉ាងច្បាស់លាស់ថា កិច្ចសន្យាអាណត្តិគឺពឹងផ្អែកលើទំនាក់ទំនងផ្ទាល់នៃការទុកចិត្តរវាងគូភាគី ។ ភាគីនីមួយៗអាចរំលាយកិច្ចសន្យាអាណត្តិ នៅពេលណាក៏បាន ។ ចំណុចនេះ គឺជាអញ្ញត្រកម្មដ៏ពិសេសមួយ ចំពោះគោលការណ៍ "កិច្ចសន្យាត្រូវតែគោរពតាម (pacta sunt servanda)" ។ ការរំលាយនេះ អាចធ្វើបានដោយអាណត្តិទាយកផង ដោយអាណត្តិគាហកផង ហើយក៏អាចធ្វើបានដែរ ដោយមិនចាំបាច់មានហេតុផលសមរម្យឡើយ ។ ប៉ុន្តែ ប្រសិនបើភាគីណាបានរំលាយកិច្ចសន្យាអាណត្តិនៅក្នុងអំឡុងពេលដែលធ្វើឱ្យខូចផលប្រយោជន៍របស់ភាគីម្ខាងទៀត ភាគីនោះត្រូវសងសំណងនៃការខូចខាត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៥១ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១២៨៣ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ២០០៤ និង មាត្រា ២០០៧ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៦៤៨**.- ការរំលាយកិច្ចសន្យាដែលពុំមានអានុភាពប្រតិសកម្ម

នៅក្នុងករណីដែលបានរំលាយកិច្ចសន្យាអាណត្តិ អានុភាពនៃការរំលាយកិច្ចសន្យានោះកើតមានឡើងដោយឆ្ពោះទៅអនាគតតែប៉ុណ្ណោះ ។ ប៉ុន្តែ ករណីនេះពុំរារាំងលើការទាមទារសំណងនៃការខូចខាតចំពោះការរំលាយកិច្ចសន្យានោះឡើយ ប្រសិនបើភាគីណាម្ខាងមានកំហុស ។

(កំណត់)

ជាគោលការណ៍ ប្រសិនបើកិច្ចសន្យាត្រូវបានរំលាយ អានុភាពនៃការរំលាយនោះមានប្រតិសកម្ម ហើយកិច្ចសន្យា

នោះត្រូវចាត់ទុកថា គ្មានតាំងតែពីដំបូងមក ។ ភាគីទាំងសងខាងក៏ត្រូវរួចផុតពីករណីកិច្ចក្នុងកិច្ចសន្យាដែរ ។ ប្រសិនបើកាតព្វកិច្ចត្រូវបានអនុវត្តរួចហើយ ភាគីដែលបានទទួលការអនុវត្តកាតព្វកិច្ចនោះ ត្រូវធ្វើបដិទាន (មាត្រា ៤១១) ។ ប៉ុន្តែដោយសារកិច្ចសន្យាអាណត្តិជាកិច្ចសន្យាជាបន្ត មាត្រានេះចែងថា អានុភាពនៃការរំលាយនោះកើតមានឡើងដោយឆ្ពោះទៅអនាគតតែប៉ុណ្ណោះ ហើយមិនមានអានុភាពប្រតិសកម្ម ដូចកិច្ចសន្យាជាបន្តផ្សេងទៀតទេ (ឧទាហរណ៍ មាត្រា ៦១៧ ស្តីពីភតិសន្យា) ។

(មាត្រាយោង)

មាត្រា ៦៥២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៦៤៩**.- មូលហេតុនៃការបញ្ចប់អាណត្តិ

១-ក្រៅពីការរំលាយកិច្ចសន្យាអាណត្តិដោយបញ្ញត្តិនៃមាត្រា ៦៤៧ (ការរំលាយកិច្ចសន្យាអាណត្តិ) នៃក្រមនេះ អាណត្តិត្រូវបញ្ចប់ដោយមូលហេតុដូចខាងក្រោមនេះ :

ក-ប្រសិនបើអាណត្តិទាយក ឬ អាណត្តិគាហក បានទទួលមរណភាព ។

ខ-ប្រសិនបើអាណត្តិទាយក ឬ អាណត្តិគាហក ត្រូវបានប្រកាសធនក្ស័យ ។

គ-ប្រសិនបើអាណត្តិទាយកត្រូវបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ឬ ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ ។

ឃ-ប្រសិនបើអាណត្តិគាហក ត្រូវបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ឬ ការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ ។

ង-ប្រសិនបើអាណត្តិទាយក ឬ អាណត្តិគាហកដែលជានីតិបុគ្គល បានរលាយ ។

ច-ប្រសិនបើអាណត្តិទាយក ឬ អាណត្តិគាហកដែលជានីតិបុគ្គល បានរួមបញ្ចូលជាមួយនីតិបុគ្គលផ្សេង ។

ឆ-ប្រសិនបើមូលហេតុផ្សេងៗដែលបានកំណត់តាមការព្រមព្រៀងរបស់ភាគីបានកើតឡើង ។

២-ភាគីអាចព្រមព្រៀងអំពីការណ៍ដែលអាណត្តិមិនបញ្ចប់ ទោះបីជាមូលហេតុដែលបានកំណត់ចាប់ពីចំណុច ក ដល់ ចំណុច ច នៃកថាខណ្ឌទី ១ ខាងលើនេះ បានកើតឡើងក៏ដោយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះមរណភាពរបស់អាណត្តិគាហក ការចាប់ផ្តើមអាណាព្យាបាលទូទៅសម្រាប់អាណត្តិគាហក ឬ ការរលាយ

ឬ ការបញ្ចូលនៃអាណត្តិគាហកដែលជានីតិបុគ្គល ។

(កំណត់)

មាត្រានេះបញ្ជាក់អំពីមូលហេតុនៃការបញ្ចប់អាណត្តិ ។ ក៏ប៉ុន្តែ ដោយសារតែបញ្ញត្តិទាំងនេះមិនមែនជាបញ្ញត្តិដែលត្រូវអនុវត្តជាដាច់ខាតទេ (គឺជា default provisions) ភាគីអាចព្រមព្រៀងគ្នាផ្សេងពីនេះបាន មានន័យថា ភាគីអាចសន្យាបានដែរថា ទោះបីជាមានមូលហេតុណាមួយក្នុងចំណោមមូលហេតុដែលបានកំណត់ក្នុងមាត្រានេះក៏ដោយ ក៏អាណត្តិមិនបញ្ចប់ដែរ ។ លើសពីនេះទៅទៀត ភាគីក៏អាចយកហេតុផ្សេងទៀត ក្រៅពីមូលហេតុដែលបានកំណត់ក្នុងមាត្រានេះមកបញ្ចូលនូវមូលហេតុនៃការបញ្ចប់អាណត្តិ ក្នុងកិច្ចសន្យារបស់ខ្លួនបានដែរ ។ ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ពីលក្ខណៈមិនដាច់ខាតនៃមាត្រានេះ ចំណុច ឆ នៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ត្រូវបានរៀបចំឡើង ។ ប៉ុន្តែប្រសិនបើអាណត្តិគាហកទទួលមរណភាព នឹងមិនមានអ្នកចាត់ចែងកិច្ចការអាណត្តិទៀតឡើយ ដូច្នេះ កិច្ចសន្យាអាណត្តិត្រូវតែបញ្ចប់ ។ ក្នុងន័យនេះ ការព្រមព្រៀងណាផ្សេងពីចំណុចនេះ មិនអាចធ្វើទៅបានទេ ។ ហេតុដូច្នេះ មរណភាព ការរំលាយ ឬ ការបញ្ចូលគ្នានៃអាណត្តិគាហក មិនត្រូវបានរាប់បញ្ចូលថាជាមូលហេតុសម្រាប់ការព្រមព្រៀងផ្សេងទេ ដោយចាត់ទុកថា អាណត្តិត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ (បញ្ញត្តិនេះមិនរារាំងដល់នីតិបុគ្គលថ្មីដែលកើតឡើងក្រោយការរួមបញ្ចូលគ្នានៃនីតិបុគ្គល ចំពោះការបង្កើតនូវកិច្ចសន្យាអាណត្តិថ្មី ដើម្បីបន្តអាណត្តិតទៅទៀតទេ) ។

ចំណុច គ មិនមាននៅក្នុងក្រមរដ្ឋប្បវេណីជប៉ុនទេ ប៉ុន្តែ ត្រូវបានបញ្ចូលនៅក្នុងមូលហេតុនៃការបញ្ចប់អាណត្តិតាមក្រមរដ្ឋប្បវេណីបារាំង និង ច្បាប់ស្តីពីកាតព្វកិច្ចរបស់ប្រទេសស្វីស ។ ប៉ុន្តែ ប្រសិនបើទៅថ្ងៃខាងមុខ ប្រទេសកម្ពុជាបង្កើតប្រព័ន្ធអាណាព្យាបាលទូទៅដោយស្ម័គ្រចិត្ត ដូចនៅប្រទេសជប៉ុន ភាគីនឹងអាចព្រមព្រៀងគ្នាដកចេញនូវចំណុច គ នេះ ពីមូលហេតុនៃការបញ្ចប់អាណត្តិបាន ។

ខុសគ្នាពីក្រមរដ្ឋប្បវេណីជប៉ុន ចំពោះចំណុច ឃ ដើម្បីឱ្យមានតុល្យភាពគ្នាជាមួយចំណុច គ មិនត្រឹមតែការចាប់ផ្តើមអាណាព្យាបាលទូទៅប៉ុណ្ណោះទេ គឺការចាប់ផ្តើមហិតូបត្ថម្ភផងដែរ ត្រូវបានដាក់បញ្ចូល ក្នុងមូលហេតុនៃការបញ្ចប់អាណត្តិ (ក្រមរដ្ឋប្បវេណីជប៉ុនដាក់បញ្ចូលតែការចាប់ផ្តើមអាណាព្យាបាលទូទៅប៉ុណ្ណោះ ប្រហែលជាដោយសារតែភាពស៊ីសង្វាក់គ្នាជាមួយបញ្ញត្តិដែលចែងថា បុគ្គលដែលត្រូវបានកម្រិតសមត្ថភាព អាចក្លាយជាអ្នកតំណាងបាន) ។

ម្យ៉ាងទៀត បញ្ញត្តិជាក់លាក់ពាក់ព័ន្ធទៅនឹងករណីដែលភាគីណាមួយជានីតិបុគ្គល ត្រូវបានរៀបចំឡើង (ចំណុច ង និង ចំណុច ច) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៥៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១២៨៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ២០០៣ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៦៥០**.- ករណីយកិច្ចសង្គ្រោះបន្ទាន់ របស់អាណត្តិគាហក នៅក្រោយពេលបញ្ចប់អាណត្តិ

នៅក្នុងករណីដែលបានបញ្ចប់អាណត្តិហើយ ប្រសិនបើមានស្ថានភាពបន្ទាន់ អាណត្តិគាហក សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អាណត្តិគាហកនោះ ត្រូវធ្វើការចាត់ចែងដែលចាំបាច់រហូតដល់ពេលដែលអាណត្តិទាយក សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អាណត្តិទាយកនោះ អាចចាត់ការកិច្ចការនោះបាន ។

(កំណត់)

មាត្រានេះមានគោលបំណងការពារអាណត្តិទាយក ពីការរងការខូចខាតដែលកើតឡើងដោយសារហេតុការណ៍ណាមួយដែលមិនអាចព្យាករបាន ក្នុងអំឡុងពេលចាប់ពីការបញ្ចប់អាណត្តិ រហូតដល់អាណត្តិទាយក ឬ អ្នកផ្សេងទៀតទទួលបន្តនូវការចាត់ចែងកិច្ចអាណត្តិ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៥៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២០១០ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៦៥១**.- ល័ក្ខខ័ណ្ឌតតាំងនៃការបញ្ចប់អាណត្តិ

មូលហេតុនៃការបញ្ចប់អាណត្តិ ទោះបីជាមូលហេតុនោះកើតឡើងចំពោះអាណត្តិ-ទាយកក៏ដោយ ឬ ចំពោះអាណត្តិគាហកក៏ដោយ ពុំអាចយកមកតតាំងជាមួយនឹងភាគីម្ខាងទៀតបានឡើយ បើមិនបានជូនដំណឹងទៅឱ្យភាគីម្ខាងទៀត ឬ បើភាគីម្ខាងទៀតពុំបានដឹងអំពីមូលហេតុនោះទេ ។

(កំណត់)

មាត្រានេះមានគោលបំណងការពារភាគីនៃកិច្ចសន្យាអាណត្តិដែលមិនដឹងអំពីការបញ្ចប់អាណត្តិ ពីហេតុការណ៍ដែលមិនអាចព្យាករបាន ដែលអាចកើតឡើងដោយសារការបញ្ចប់នូវអាណត្តិនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៥៥ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២០០៨ នៃក្រមរដ្ឋប្បវេណីបារាំង

## ជំពូកទី ៨ កិច្ចសន្យាម៉ៅការ

**មាត្រា ៦៥២**.- និយមន័យនៃកិច្ចសន្យាម៉ៅការ

កិច្ចសន្យាម៉ៅការ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាងមានករណីយកិច្ចសម្រេចការងារដែលបានព្រមព្រៀង ហើយភាគីម្ខាងទៀតមានករណីយកិច្ចផ្តល់កម្រៃចំពោះលទ្ធផលនៃការងារដែលបានធ្វើនោះ ។

(កំណត់)

មាត្រានេះចែងអំពីនិយមន័យនៃកិច្ចសន្យាម៉ៅការ ដែលបញ្ជាក់ច្បាស់លាស់ថា ក្នុងកិច្ចសន្យាម៉ៅការនេះ គេសង្កត់ធ្ងន់នៅត្រង់ចំណុចថា អ្នកម៉ៅការត្រូវធ្វើការដើម្បីសម្រេចការងារណាមួយ ។

កិច្ចសន្យាម៉ៅការនេះ មានច្រើនប្រភេទណាស់ ដូចជា កិច្ចសន្យាសង់នាវា កិច្ចសន្យាបោកអ៊ុត កិច្ចសន្យាជួសជុល កិច្ចសន្យាធ្វើបាឋកថា កិច្ចសន្យាដឹកជញ្ជូន កិច្ចសន្យាម៉ៅការសាងសង់ ជាអាទិ៍ ។

កិច្ចសន្យាម៉ៅការ ចាំបាច់មានកម្រៃចំពោះការធ្វើការងារ ហេតុដូច្នេះ ឧទាហរណ៍ កិច្ចសន្យាធ្វើបាឋកថាដោយមិនយកកម្រៃវិញ តាមនិយមន័យ ពុំមែនជាកិច្ចសន្យាម៉ៅការទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៣២ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៦៥៣**.- ពេលដែលត្រូវបង់កម្រៃ

កម្រៃត្រូវបង់ដំណាលគ្នានឹងការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ ។ បើពុំចាំបាច់ក្នុងការប្រគល់វត្ថុទេ ក្រោយពីបានសម្រេចការងារហើយ អ្នកម៉ៅការអាចទាមទារឱ្យបង់កម្រៃបាន ។

(កំណត់)

បញ្ញត្តិនេះចែងអំពីពេលដែលត្រូវបង់កម្រៃ ។ ក្នុងករណីដែលអ្នកម៉ៅការចាំបាច់ត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ កម្រៃត្រូវបង់ព្រមជាមួយគ្នានឹងពេលដែលបានប្រគល់វត្ថុដែលជាកម្មវត្ថុនោះ ហើយក្នុងករណីដែលមិនចាំបាច់ប្រគល់វត្ថុទេ អ្នកម៉ៅការអាចទាមទារឱ្យបង់កម្រៃបាន ក្រោយពេលបានសម្រេចការងារ ។ ប៉ុន្តែ តាមភាពជាក់ស្តែង មានករណីជាច្រើនដែលអ្នកម៉ៅការពុំមែនជាអ្នកមានធនធានគ្រប់គ្រាន់ ដើម្បីបង់សោហ៊ុយជំនួសជាមុនទាំងអស់ រហូតដល់សម្រេចការងារនោះ ។ម្យ៉ាងទៀត អ្នកម៉ៅការមានការបារម្ភថា តើម្ចាស់ការច្បាស់ជានឹងបង់កម្រៃឱ្យខ្លួនឬទេ ពេលសម្រេចការងារ ។ តាមធម្មតា ជាឧទាហរណ៍ ក្នុងករណីម៉ៅការសាងសង់ផ្ទះ ភាគីច្រើនធ្វើកិច្ចព្រមព្រៀងបង់កម្រៃម្តង ពេលចាប់ផ្តើមសាងសង់ ម្តងទៀត ពេលធ្វើគ្រោងផ្ទះ និង បង់កម្រៃដែលនៅសល់ ពេលសាងសង់រួចហើយប្រគល់សំណង់ ជាអាទិ៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៣៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៦៥៤**.- ករណីយកិច្ចសម្រេចការងារដោយគ្មានវិការៈ

១-អ្នកម៉ៅការ មានករណីយកិច្ចសម្រេចការងារដោយគ្មានវិការៈចំពោះម្ចាស់ការ ។

២-បើការងារពុំមានលក្ខណៈដូចបានព្រមព្រៀងទេ ត្រូវចាត់ទុកថា ជាការងារមានវិការៈ ។ ក្នុងករណីដែលមិនបានព្រមព្រៀងអំពីលក្ខណៈ បើការងារនោះពុំត្រឹមត្រូវក្នុងការប្រើប្រាស់ដែលបានសន្មតនៅក្នុងកិច្ចសន្យា ឬ ក្នុងករណីដែលពុំបានសន្មតនៅក្នុងកិច្ចសន្យានៃការប្រើប្រាស់ដែលបានកំណត់ បើការងារនោះមិនត្រឹមត្រូវក្នុងការប្រើប្រាស់ជាប្រក្រតីទេ ត្រូវចាត់ទុកថា ជាការងារមានវិការៈ ។

៣-ប្រសិនបើអ្នកម៉ៅការបានធ្វើការផ្ទុយនឹងការបញ្ជា ឬ បើការងារដែលបានធ្វើនោះមិនគ្រប់ចំនួនទេ ត្រូវចាត់ទុកថា ជាការងារមានវិការៈ ។

(កំណត់)

មាត្រានេះបានចែងច្បាស់លាស់នៅក្នុងកថាខណ្ឌទី ១ អំពីករណីយកិច្ចរបស់អ្នកម៉ៅការ ក្នុងការសម្រេចការងារដោយគ្មានវិការៈ ។ ដូច្នេះ ការទទួលខុសត្រូវដែលអ្នកម៉ៅការត្រូវទទួលបន្ទុកក្នុងករណីដែលការងារនោះមានវិការៈ គឺជាប្រភេទមួយនៃការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច ។ បញ្ញត្តិជាច្រើនខាងក្រោមនេះ ចែងលំអិតច្បាស់លាស់អំពីការអនុវត្តនូវគោលការណ៍ទូទៅនៃការមិនអនុវត្តកាតព្វកិច្ច ចំពោះករណីដែលការងារម៉ៅការមានវិការៈ ។

កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ នៃមាត្រានេះ ចែងអំពីបទដ្ឋានសម្រាប់វិនិច្ឆ័យថា តើក្នុងករណីណាទើបចាត់ទុកថាការងារមានវិការៈ ។

ឧទាហរណ៍ ក្នុងករណីនៃកិច្ចសន្យាម៉ៅការសាងសង់អាគារ ដែលបានព្រមព្រៀងលាបជញ្ជាំងពណ៌ពងមាន់ តែប្រសិនបើលាបពណ៌សទៅវិញ ទោះបីជាពណ៌សក៏ដោយ ពណ៌ពងមាន់ក៏ដោយ ក៏គ្មានបញ្ហាអ្វីដែរដើម្បីរស់នៅ ប៉ុន្តែ ពុំមានលក្ខណៈដូចកិច្ចព្រមព្រៀងទេ ហេតុនេះហើយ ត្រូវចាត់ទុកថា ការងារមានវិការៈ (វាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ២) ។ ម្យ៉ាងទៀត ក្នុងករណីដែលបានទៅហាងកាត់ខោអាវ ឱ្យគេកាត់ខោអាវធំសម្រាប់រដូវរងារ ដើម្បីទៅប្រទេសជប៉ុន នៅរដូវរងារ តែប្រសិនបើហាងកាត់ដេរបានកាត់ខោអាវធំសម្រាប់រដូវក្ដៅ ដូចនៅប្រទេសកម្ពុជា ការងារនោះមិនត្រឹមត្រូវក្នុងការប្រើប្រាស់ដែលបានសន្មតនៅក្នុងកិច្ចសន្យាទេ ហេតុនេះហើយ ទោះបីជាខោអាវធំនោះ ដេរបានល្អយ៉ាងណាក៏ដោយ ក៏ការងារនោះមានវិការៈដែរ (ប្រយោគខាងដើមនៃវាក្យខណ្ឌទី ២ កថាខណ្ឌទី ២) ។ លើសពីនេះ អ្នកម៉ៅការ A បានសាងសង់ផ្ទះលើដីរបស់ម្ចាស់ការ B ហើយក្រោយពេលប្រគល់ផ្ទះនោះទៅឱ្យ B ប្រសិនបើទឹកភ្លៀងបានជ្រាបពីពិតាន នៅរដូវភ្លៀង ហើយលេចទឹកភ្លៀង ទោះបីជាពុំមានការសន្មតអំពីការប្រើប្រាស់ពិសេសក្នុងកិច្ចសន្យាក៏ដោយ

តាមធម្មតា ផ្ទះដែលលេចទឹកភ្លៀង មិនអាចប្រើប្រាស់ជាប្រក្រតីបានឡើយ ដូច្នេះ ការងារនេះត្រូវបានចាត់ទុកថាជាការងារមានវិការៈ ( ប្រយោគខាងក្រោយនៃវាក្យខណ្ឌទី ២ កថាខណ្ឌទី ២ ) ។

កថាខណ្ឌទី ៣ ជាបញ្ញត្តិថា ក្នុងករណី ដូចជា ករណីដែលម្ចាស់ការបានបញ្ជាឱ្យហាងកាត់ខោអាវ កាត់ខោ តែគេបែរជាកាត់សំពត់ទៅវិញ ការងារនោះក៏មានវិការៈដែរ ។ មិនត្រឹមតែប៉ុណ្ណោះទេ ក្នុងករណីដែលលក្ខណៈនៃការងារមានគម្លាតយ៉ាងខ្លាំងពីកិច្ចសន្យា ដោយច្បាស់ជាមិនអាចទទួលស្គាល់ថាជាការអនុវត្តកិច្ចសន្យាទាល់តែសោះ តើត្រូវអនុវត្តតាមបញ្ញត្តិនៃជំពូកនេះ ឬ ត្រូវអនុវត្តតាមតែបញ្ញត្តិនៃជំពូកទី ៤ នៃគន្ថីស្តីពីកាតព្វកិច្ច បញ្ហានេះ សូមទុកឱ្យមានការបកស្រាយ និង ការអនុវត្ត នាអនាគត ។

( មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ១ នឹង ២ មាត្រា ៦៣៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៦៥៥**.- ការទាមទារឱ្យអនុវត្តការងារពេញលេញ

១-បើការងារមានវិការៈ ម្ចាស់ការអាចទាមទារចំពោះអ្នកម៉ៅការ ឱ្យអនុវត្តការងារពេញលេញ ដោយកំណត់អំឡុងពេលសមរម្យបាន ។ ក្នុងករណីនេះ អ្នកម៉ៅការអាចជួសជុលវិការៈនៃការងារនោះ ឬ អាចធ្វើការងារនោះសាជាថ្មីឡើងវិញ ដោយផ្អែកតាមការជ្រើសរើសបាន ។

២-បើការអនុវត្តការងារឱ្យពេញលេញនេះ ចាំបាច់ត្រូវចំណាយសោហ៊ុយច្រើនហួសហេតុ បើប្រៀបធៀបទៅនឹងការខូចខាតផលប្រយោជន៍ដោយវិការៈនោះ អ្នកម៉ៅការអាចបដិសេធបាន ។

៣-បើអ្នកម៉ៅការបានចាប់ផ្តើមធ្វើការងារនោះឡើងវិញ អ្នកម៉ៅការនោះអាចទាមទារឱ្យម្ចាស់ការសងការងារដែលមានវិការៈមកវិញបាន ។

( កំណត់)

មាត្រានេះចែងអំពីការទាមទារឱ្យអនុវត្តការងារពេញលេញ ក្នុងករណីដែលការងារមានវិការៈ ។ ការអនុវត្តការងារពេញលេញ ដែលប្រើក្នុងនេះ មានន័យថាជាទស្សនៈមួយ រួមទាំងការជួសជុលនូវវិការៈ និង ការធ្វើការងារឡើងវិញ ។

វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ផ្តល់នូវជម្រើសស្តីពីវិធីដកវិការៈចេញ ទៅអ្នកម៉ៅការ ក្នុងករណីដែលការងារមានវិការៈ ហើយប្រសិនជាអ្នកម៉ៅការមានបំណងចង់ធ្វើការងារឡើងវិញ ជាគោលការណ៍ បញ្ញត្តិនេះអនុញ្ញាតឱ្យធ្វើឡើងវិញ ។ ឧទាហរណ៍ ក្នុងករណីដែលបានឱ្យកាត់ខោអាវសម្រាប់រដូវរងារ តែបែរជាកាត់ខោអាវសម្រាប់រដូវក្តៅទៅវិញ ការកែខោអាវសម្រាប់រដូវក្តៅ ឱ្យទៅជាខោអាវសម្រាប់រដូវរងារ មិនអាចធ្វើបាន ឬ ត្រូវការពេលវេលាយ៉ាងច្រើន ។

ក្នុងករណីនេះ ការកាត់ថ្មីជាការងាយស្រួលជាង ហេតុនេះហើយ បញ្ញត្តិនេះផ្តល់នូវជម្រើសធ្វើជាថ្មី ។

ម្យ៉ាងទៀត កថាខណ្ឌទី ២ គឺជាបញ្ញត្តិសម្រាប់អនុវត្តក្នុងករណីដែលជាឧទាហរណ៍ ៖ អាគារដែលត្រូវប្រើឥដ្ឋ ក៏ប៉ុន្តែក្នុងនោះ មានប្រើប្រាស់ឥដ្ឋមួយដុំដែលមានពណ៌ផ្សេងពីគេ ។ ក៏ប៉ុន្តែ ក្នុងករណីនេះ ប្រសិនបើប្តូរឥដ្ឋដែលមានពណ៌ខុសគេនោះ តាមបច្ចេកទេស ត្រូវវាយបំបែកជញ្ជាំងនៅជុំវិញនោះសិន ហើយត្រូវធ្វើឱ្យអស់សោហ៊ុយយ៉ាងច្រើនផង ។ ឥដ្ឋមួយដុំពណ៌ខុសគេ មិនមែនជាវិការៈធ្ងន់ធ្ងរប៉ុន្មានទេ គ្រាន់តែមិនសូវល្អមើលបន្តិចប៉ុណ្ណោះ ។ ថែមទាំងចំណាយសម្រាប់ការជួសជុលច្រើនជ្រុល មិនសមរម្យនឹងទម្ងន់នៃវិការៈផង ។ ក្នុងករណីនេះ មិនអាចទាមទារឱ្យជួសជុលឡើងវិញទេ ហើយនេះគឺជាគោលគំនិតនៃកថាខណ្ឌទី ២ ។

កថាខណ្ឌទី ៣ គឺជាបញ្ញត្តិកំណត់អំពីករណីដូចជា ក្នុងករណីកាត់ខោអាវដែលបានលើកឡើងខាងលើនេះ ប្រសិនបើហាងកាត់ដេរបានកាត់ខោអាវធំសម្រាប់រដូវរងាវិញ អ្នកកាត់ខោអាវអាចទទួលបាននៅខោអាវធំសម្រាប់រដូវក្តៅដែលខ្លួនបានប្រគល់ទៅម្ចាស់ការ ហើយនេះគឺជាការធម្មតា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៣៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៣៤ និង ៦៣៥ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៦៥៦.- ការជួសជុលវិការៈដោយម្ចាស់ការ

១-នៅក្រោយពេលដែលអំឡុងពេលសមរម្យដែលបានកំណត់ដើម្បីអនុវត្តការងារឱ្យពេញលេញនោះ បានកន្លងផុតហើយ ម្ចាស់ការអាចជួសជុលវិការៈដោយខ្លួនឯងផ្ទាល់ ហើយអាចទាមទារសោហ៊ុយដែលចាំបាច់លើការជួសជុលវិការៈនោះ ពីអ្នកម៉ៅការបាន ។

២-ក្នុងករណីដែលការអនុវត្តការងារឱ្យពេញលេញ មិនបានសម្រេច ឬ ក្នុងករណីដែលវាយតម្លៃថា ការអនុវត្តការងារឱ្យពេញលេញដោយអ្នកម៉ៅការ នឹងធ្វើឱ្យមានការខូចខាតផលប្រយោជន៍ដោយមិនត្រឹមត្រូវ ចំពោះម្ចាស់ការ ម្ចាស់ការអាចជួសជុលវិការៈដោយខ្លួនឯង ហើយអាចទាមទារសោហ៊ុយដែលចាំបាច់ក្នុងការជួសជុលវិការៈ ពីអ្នកម៉ៅការបាន ។

៣-ក្នុងករណីនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ម្ចាស់ការអាចទាមទារចំពោះអ្នកម៉ៅការ ឱ្យបង់សោហ៊ុយដែលចាំបាច់ លើការជួសជុលវិការៈជាមុនបាន ។

៤-បញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ បើអ្នកម៉ៅការបានបដិសេធការអនុវត្តការងារឱ្យពេញលេញ យោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៦៥៥ (ការទាមទារឱ្យអនុវត្តការងារពេញលេញ)ខាងលើនេះ ។

(កំណត់)

មាត្រានេះចែងអំពីការជួសជុលវិការៈដោយម្ចាស់ការ ។

កថាខណ្ឌទី ១ គឺជាបញ្ញត្តិចែងដោយមានខ្លឹមសារថា ឧទាហរណ៍ ក្នុងករណីដែលម្ចាស់ការបានឱ្យអ្នកម៉ៅការធ្វើផ្ទះ ក៏ប៉ុន្តែ ផ្ទះនោះលេចទឹកភ្លៀង ម្ចាស់ការអាចដាស់តឿនឱ្យអ្នកម៉ៅការសាងសង់ឱ្យអនុវត្តការងារពេញលេញ ដោយកំណត់អំឡុងពេលសមរម្យមួយ តែប្រសិនបើអ្នកម៉ៅការពុំបានអនុវត្តការងារពេញលេញ ទោះបីជាអំឡុងពេលនោះបានកន្លងផុតហើយក៏ដោយ នោះម្ចាស់ការអាចជួសជុលកន្លែងលេចទឹកភ្លៀងដោយខ្លួនឯងបាន ឬ អាចឱ្យជាងផ្ទះផ្សេងទៀត ជាអាទិ៍ ជួសជុល ហើយអាចទាមទារសោហ៊ុយនៃការជួសជុលនោះពីអ្នកម៉ៅការបាន ។

ក្នុងករណីដែលអ្នកម៉ៅបានបរាជ័យក្នុងការជួសជុល ឬ ធ្វើឡើងវិញ នឹងមានបញ្ហាថា តើត្រូវចាត់ចែងយ៉ាងណា ហេតុដូច្នេះ កថាខណ្ឌទី ២ ត្រូវបានរៀបចំឡើងដើម្បីបញ្ជាក់អំពីចំណុចនេះ ។

កថាខណ្ឌទី ៣ គឺជាបញ្ញត្តិចែងទទួលស្គាល់ឱ្យម្ចាស់ការទាមទារឱ្យបង់ជាមុន នូវសោហ៊ុយដែលចាំបាច់សម្រាប់ការជួសជុលវិការៈ ។

ដូចដែលបានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ៦៥៥ "បើការអនុវត្តការងារឱ្យពេញលេញនេះ ចាំបាច់ត្រូវចំណាយសោហ៊ុយច្រើនហួសហេតុ បើប្រៀបធៀបទៅនឹងការខូចខាតផលប្រយោជន៍ដោយវិការៈនោះ អ្នកម៉ៅការអាចបដិសេធបាន" ។ ក្នុងករណីនេះ ម្ចាស់ការដែលត្រូវអ្នកម៉ៅការបដិសេធការអនុវត្តការងារពេញលេញនោះ បានជួសជុលដោយខ្លួនឯង ឬ បានពឹងឱ្យជាងផ្ទះផ្សេងទៀតជួសជុលវិការៈនោះ ហើយបានទាមទារសោហ៊ុយជួសជុលនោះចំពោះអ្នកម៉ៅការ តើយ៉ាងម្ដេចដែរ ? ប្រសិនបើអាចបដិសេធការជួសជុលនោះ តែមិនអាចបដិសេធនូវការទាមទារសោហ៊ុយជួសជុលវិញ ហើយអ្នកម៉ៅការត្រូវបង់ជាប្រាក់នូវសោហ៊ុយច្រើនហួសហេតុនោះ ទៅឱ្យម្ចាស់ការទៅ នេះគឺជាការមួយមិនស៊ីសង្វាក់គ្នា ។ ដូច្នេះហើយ កថាខណ្ឌទី ៤ នេះចែងថា ក្នុងករណីដែលអ្នកម៉ៅការបានបដិសេធមិនអនុវត្តការងារពេញលេញ ដោយសារតែត្រូវចំណាយសោហ៊ុយហួសហេតុ ម្ចាស់ការពុំអាចទាមទារសោហ៊ុយជួសជុល ឬ ទាមទារឱ្យបង់ជាមុននូវសោហ៊ុយជួសជុលបានឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៣៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៣៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៦៥៧.- សិទ្ធិរំលាយរបស់ម្ចាស់ការ

១-ម្ចាស់ការ អាចរំលាយកិច្ចសន្យា ដោយយកមូលហេតុវិការៈនៃការងារ ផ្អែកតាមបញ្ញត្តិនៃផ្នែកទី ៤ (ការរំលាយកិច្ចសន្យា) ជំពូកទី ៤ នៃគន្ថីទី ៤ បាន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលការអនុវត្តការងារឱ្យពេញលេញ មិនបាន

សម្រេច ឬ ក្នុងករណីដែលវាយតម្លៃថា ការអនុវត្តការងារឱ្យពេញលេញដោយអ្នកម៉ៅការ នឹងធ្វើឱ្យមានការខូចខាតផលប្រយោជន៍ដោយមិនត្រឹមត្រូវ ចំពោះម្ចាស់ការ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តចំពោះអាគារ ឬ សំណង់លើដីផ្សេងទៀតឡើយ ។ ប៉ុន្តែ បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ បើសំណង់នោះពុំមានតម្លៃនឹងប្រើប្រាស់ ចំពោះម្ចាស់ការ ដោយសារវិការៈធ្ងន់ធ្ងរពេក ។

(កំណត់)

មាត្រានេះចែងអំពីសិទ្ធិរំលាយរបស់ម្ចាស់ការ ដោយយកវិការៈមកធ្វើជាមូលហេតុ ។

កថាខណ្ឌទី ១ ចែងថា ម្ចាស់ការអាចរំលាយកិច្ចសន្យាបាន តាមបញ្ញត្តិទូទៅស្ដីពីការរំលាយ នៃគន្ថីស្ដីពីកាតព្វកិច្ច ។ វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ត្រូវបានចែងឡើងដើម្បីសម្របសម្រួលទំនាក់ទំនងរវាងការអនុវត្តការងារពេញលេញដោយអ្នកម៉ៅការ និង សិទ្ធិរំលាយរបស់ម្ចាស់ការ ហើយ ជាគោលការណ៍ ការអនុវត្តការងារពេញលេញដោយអ្នកម៉ៅការមានអាទិភាពជាង ក៏ប៉ុន្តែ ក្នុងករណីដែលមានមូលហេតុដូចដែលបានចែងក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ នេះ ម្ចាស់ការអាចរំលាយបាន ។

កថាខណ្ឌទី ២ គឺជាបញ្ញត្តិដែលមានខ្លឹមសារថា ក្នុងករណីនៃការងារសាងសង់ ជាអាទិ៍ ទោះជាមានវិការៈក៏ដោយ ក៏ម្ចាស់ការមិនអាចរំលាយកិច្ចសន្យា ហើយទាមទារឱ្យសងនូវថ្លៃសាងសង់បានឡើយ គឺម្ចាស់ការគ្រាន់តែអាចទាមទារឱ្យជួសជុល និង/ឬ ទាមទារនូវសំណងនៃការខូចខាតប៉ុណ្ណោះ ។ ចំពោះសំណង់ដែលពិតជាមានវិការៈមែន តែត្រូវបានសាងសង់រួចហើយ ប្រសិនបើទទួលស្គាល់ឱ្យរំលាយទៅ ជាលទ្ធផល អ្នកម៉ៅការមិនត្រឹមតែទទួលនូវការខូចខាតដ៏ធ្ងន់ធ្ងរប៉ុណ្ណោះទេ គឺថែមទាំងត្រូវវាយបំបែកនូវសំណង់ដែលត្រូវបានសាងសង់រួចហើយទៀតផង ។ នេះគឺជាការមួយធ្វើឱ្យបាត់បង់នូវធនធានយ៉ាងច្រើន ហើយខាតបង់កម្លាំងពលកម្ម និង ពេលវេលាផងដែរ ដូច្នេះ ត្រូវជៀសវាងអំពើនេះ ។ នេះគឺជាមូលហេតុដែលបានរៀបចំកថាខណ្ឌទី ២ ។

ក៏ប៉ុន្តែ ក្នុងករណីដែលបានឱ្យក្រុមហ៊ុនសំណង់សាងសង់ផ្ទះ ហើយផ្ទះដែលសាងសង់ហើយនោះ មានគ្រឹះមិនពេញលក្ខណៈ ការសាងសង់មិនត្រឹមត្រូវទាំងស្រុងតាមគំនូសប្លង់ ឬ ការប្រើគ្រឿងសំណង់ដែលមានគុណភាពមិនល្អនោះ ជាអាទិ៍ ហើយអាចមានគ្រោះថ្នាក់រហូតដល់អាគារនោះរលំបែកបាក់ ប្រសិនបើមិនរុះអាគារនោះ ហើយសាងសង់គ្រឹះជាថ្មីទេ នោះអាគារនោះមានវិការៈធ្ងន់ធ្ងរ ហើយមានតែសាងសង់ឡើងវិញទេទើបអាចប្រើបាន ដោយសារអាគារនោះពុំមានតម្លៃនឹងប្រើប្រាស់ទៀត ។ ដូច្នេះហើយ ការរើអាគារនោះ មិនអាចចាត់ទុកថា បានប្រើខ្ជះខ្ជាយនូវសេដ្ឋកិច្ចជាតិឡើយ ។ ម្យ៉ាងទៀត ការទទួលស្គាល់ឱ្យរំលាយកិច្ចសន្យា ហើយឱ្យសងថ្លៃសាងសង់ ឬ ទទួលបន្ទុកនូវសោហ៊ុយសម្រាប់ធ្វើការបដិទានឡើងវិញ គឺជាការកំណត់មួយដែលមិនទុកឱ្យអ្នកម៉ៅការបដិសេធបានឡើយ ។ ដោយមាន

គោលគំនិតនេះ បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ នេះត្រូវបានរៀបចំឡើង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៣៥នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៣៤ និង មាត្រា ៦៣៦ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៦៥៨.- សិទ្ធិទាមទារឱ្យបន្ថយតម្លៃរបស់ម្ចាស់ការ

១-នៅក្រោយពេលដែលអំឡុងពេលសមរម្យដែលបានកំណត់ដើម្បីអនុវត្តការងារឱ្យពេញលេញនោះ បានកន្លងផុតហើយ ម្ចាស់ការអាចទាមទារឱ្យបន្ថយថ្លៃ តាមការបង្ហាញឆន្ទៈចំពោះអ្នកម៉ៅការ ដោយយកវិការៈនៃការងារមកធ្វើជាមូលហេតុបាន ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលការអនុវត្តការងារឱ្យពេញលេញ មិនបានសម្រេច ឬ ក្នុងករណីដែលវាយតម្លៃថា ការអនុវត្តការងារឱ្យពេញលេញដោយអ្នកម៉ៅការ នឹងធ្វើឱ្យមានការខូចខាតផលប្រយោជន៍ដោយមិនត្រឹមត្រូវ ចំពោះម្ចាស់ការ ។

២-កម្រៃនឹងត្រូវបានបន្ថយចុះ តាមការទាមទារឱ្យបន្ថយថ្លៃ យោលតាមសមាមាត្រនៃតម្លៃការងារដែលមានភ្ជាប់នូវវិការៈ ជាមួយនឹងតម្លៃនៃការងារដែលគ្មានវិការៈនោះ ។

(កំណត់)

ក្នុងករណីដែលម្ចាស់ការគិតឃើញថា មិនចាំបាច់ធ្វើរហូតដល់រំលាយកិច្ចសន្យាទេ ម្ចាស់ការគ្រាន់តែអាចបន្ថយនូវកម្រៃនៃកិច្ចសន្យាក៏បានដែរ ។ ក្នុងករណីដែលមិនស្របនឹងល័ក្ខខ័ណ្ឌដើម្បីរំលាយកិច្ចសន្យា ម្ចាស់ការអាចទាមទារនូវសំណងនៃការខូចខាតបាន ដោយយោងតាមបញ្ញត្តិនៃមាត្រា ៦៥៩ ក៏ប៉ុន្តែ ក្នុងករណីដែលមិនស្របនឹងល័ក្ខខ័ណ្ឌនៃសំណងនៃការខូចខាត មានតែទាមទារឱ្យបន្ថយតម្លៃនៃកិច្ចសន្យា ដោយយោងតាមបញ្ញត្តិនៃមាត្រានេះ ។

វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ គឺជាបញ្ញត្តិចែងដើម្បីសម្របសម្រួលទំនាក់ទំនងរវាងការអនុវត្តការងារពេញលេញដោយអ្នកម៉ៅការ និង សិទ្ធិទាមទារឱ្យបន្ថយតម្លៃរបស់ម្ចាស់ការ ហើយ ជាគោលការណ៍ ការអនុវត្តការងារពេញលេញដោយអ្នកម៉ៅការ មានអាទិភាពជាង ក៏ប៉ុន្តែ វាក្យខណ្ឌទី ២ ចែងថា ក្នុងករណីដែលមានមូលហេតុដូចដែលបានចែងក្នុងវាក្យខណ្ឌទី ២ នេះ ម្ចាស់ការអាចទាមទារបន្ថយតម្លៃបាន តាមបញ្ញត្តិនេះ ។

កថាខណ្ឌទី ២ ចែងអំពីវិធីគណនាទឹកប្រាក់បន្ថយនោះ ។ ឧទាហរណ៍ កម្រៃម៉ៅការ ១០០ ។ ប្រសិនបើការងារពុំមានវិការៈទេ តម្លៃការងារនោះស្មើនឹង ៨០ តែដោយសារជាការងារដែលមានភ្ជាប់នូវវិការៈ តម្លៃការងារនោះមានតែ ៤០ ប៉ុណ្ណោះ ដូច្នេះកម្រៃគឺស្មើនឹង ១០០ x ៤០ / ៨០ = ៥០ គឺអ្នកម៉ៅការអាចទទួលបាននូវកម្រៃ ៥០ ។ មានន័យថា ក្នុងករណីនេះ ទឹកប្រាក់បន្ថយនោះគឺ ៥០ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៣៤ និង មាត្រា ៦៣៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៦៥៩**.- សិទ្ធិទាមទារសំណងនៃការខូចខាតរបស់ម្ចាស់ការ

១-ម្ចាស់ការ អាចទាមទារសំណងនៃការខូចខាត ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (សំណងនៃការខូចខាត) ជំពូកទី ៤ នៃគន្ថីទី ៤ បាន ដោយមិនអនុវត្ត ឬ ដោយអនុវត្តព្រមគ្នានូវសិទ្ធិដែលបានកំណត់ចាប់ពីមាត្រា ៦៥៥ (ការទាមទារឱ្យអនុវត្តការងារពេញលេញ) រហូតដល់មាត្រា ៦៥៨ (សិទ្ធិទាមទារឱ្យបន្ថយតម្លៃរបស់ម្ចាស់ការ) នៃក្រមនេះ ។ ប៉ុន្តែ ចំពោះការអនុវត្តការងារឱ្យពេញលេញជំនួសសំណងនៃការខូចខាត នៅក្រោយពេលដែលអំឡុងពេលសមរម្យដែលបានកំណត់ដើម្បីអនុវត្តការងារឱ្យពេញលេញនោះ បានកន្លងផុតហើយ លុះត្រាតែនៅក្នុងករណីដែលការអនុវត្តការងារឱ្យពេញលេញមិនបានសម្រេច ឬ ក្នុងករណីដែលវាយតម្លៃថា ការអនុវត្តការងារឱ្យពេញលេញដោយអ្នកម៉ៅការ នឹងធ្វើឱ្យមានការខូចខាតផលប្រយោជន៍ដោយមិនត្រឹមត្រូវចំពោះម្ចាស់ការ ទើបអាចទាមទារបាន ។

២-បើការអនុវត្តការងារឱ្យពេញលេញនេះ ចាំបាច់ត្រូវចំណាយសោហ៊ុយច្រើនហួសហេតុ បើប្រៀបធៀបទៅនឹងការខូចខាតផលប្រយោជន៍ដោយវិការៈនោះ ម្ចាស់ការមិនអាចទាមទារចំនួនទឹកប្រាក់ ដែលសមរម្យនឹងសោហ៊ុយដែលចាំបាច់ ក្នុងការជួសជុលវិការៈនោះ ថាជាសំណងនៃការខូចខាត ដោយយោលតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបានឡើយ ។

(កំណត់)

មាត្រានេះចែងអំពីសិទ្ធិទាមទារសំណងនៃការខូចខាតរបស់ម្ចាស់ការ ។

ការទទួលខុសត្រូវរបស់អ្នកម៉ៅការ ដោយសារការងារមានវិការៈ គឺជាប្រភេទមួយនៃការទទួលខុសត្រូវក្នុងការការមិនអនុវត្តកាតព្វកិច្ចដែរ ហេតុដូច្នេះ កថាខណ្ឌទី ១ បញ្ជាក់ច្បាស់លាស់ថា ម្ចាស់ការអាចទាមទារសំណងនៃការខូចខាតចំពោះអ្នកម៉ៅការបាន តាមគោលការណ៍ទូទៅនៃការមិនអនុវត្តកាតព្វកិច្ច ។

វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ គឺជាបញ្ញត្តិដើម្បីសម្របសម្រួលទំនាក់ទំនងរវាងការអនុវត្តការងារពេញលេញដោយអ្នកម៉ៅការ និង សំណងនៃការខូចខាត ហើយ ជាគោលការណ៍ ការអនុវត្តការងារពេញលេញ មានអាទិភាពជាង

ហើយការទាមទារសំណងនៃការខូចខាតជំនួសការអនុវត្តពេញលេញ ត្រូវបានអនុញ្ញាតតែក្នុងករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ នេះប៉ុណ្ណោះ ។

ដោយសារមានកថាខណ្ឌទី ២ ឧទាហរណ៍ ក្នុងករណីធ្វើនាវា ពេលបើកបរ នាវានោះញ័រ ដែលជាវិការៈតូចទេ តែបើចង់ជួសជុលវិញ ត្រូវកាត់នាវាពាក់កណ្ដាលខាងកន្ទុយ ហើយធ្វើឡើងវិញនោះ ត្រូវចំណាយសោហ៊ុយយ៉ាងច្រើនហួសហេតុ ក្នុងករណីនេះ ម្ចាស់ការពុំអាចទាមទារនូវសោហ៊ុយដើម្បីជួសជុលវិការៈឡើងវិញ ពីអ្នកម៉ៅការបានឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៣៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៣៤ និង មាត្រា ៦៣៦ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៦៦០.-** ការដោះស្រាយ ក្នុងករណីដែលវិការៈកើតឡើងដោយសម្ភារៈ ឬ ដោយការបញ្ជា របស់ម្ចាស់ការ

១-បញ្ញត្តិចាប់ពីមាត្រា ៦៥៥ (ការទាមទារឱ្យអនុវត្តការងារពេញលេញ) រហូតដល់មាត្រា ៦៥៩ (សិទ្ធិទាមទារសំណងនៃការខូចខាតរបស់ម្ចាស់ការ) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើវិការៈនៃការងារនោះ កើតឡើងពីលក្ខណៈនៃសម្ភារៈដែលបានផ្ដល់ដោយម្ចាស់ការ ឬ ដោយការបញ្ជារបស់ម្ចាស់ការនោះ ។ ការសម្ដែងប្រាប់ដែលគ្រាន់តែជាបំណងរបស់ម្ចាស់ការ ពុំត្រូវចាត់ទុកថាជាការបញ្ជាឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើអ្នកម៉ៅការបានដឹងអំពីសភាពនៃសម្ភារៈ ឬ ភាពមិនត្រឹមត្រូវនៃការបញ្ជានោះ តែមិនបានផ្ដល់ដំណឹង ។

(កំណត់)

មាត្រានេះ គឺជាបញ្ញត្តិដែលចែងថា ក្នុងករណីដែលវិការៈបានកើតឡើង ដោយសារលក្ខណៈនៃសម្ភារៈដែលបានផ្ដល់ដោយម្ចាស់ការ ឬ ដោយសារការបញ្ជារបស់ម្ចាស់ការ អ្នកម៉ៅការពុំត្រូវទទួលខុសត្រូវចំពោះវិការៈនៃការងារនោះឡើយ ។ ក៏ប៉ុន្តែ ប្រសិនបើអ្នកម៉ៅការបានដឹងថា សម្ភារៈដែលបានផ្ដល់ឱ្យខ្លួននោះ ឬ ការបញ្ជារបស់ម្ចាស់ការនោះ មានភាពមិនត្រឹមត្រូវ ហើយវិការៈបានកើតឡើង ដោយសារខ្លួនបានបំពេញការងារដោយមិនបានប្រាប់ទៅម្ចាស់ការអំពីភាពមិនត្រឹមត្រូវនោះទេ ការអនុគ្រោះមិនឱ្យអ្នកម៉ៅការទទួលខុសត្រូវក្នុងករណីនេះ មិនមានភាពសមរម្យទេ ហេតុដូច្នេះ កថាខណ្ឌទី ២ ត្រូវបានរៀបចំឡើង ដើម្បីបញ្ជាក់អំពីចំណុចនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៣៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៦៦១.-** អំឡុងពេលនៃការប្រើសិទ្ធិ

១-សិទ្ធិដែលកំណត់ក្នុងបញ្ញត្តិចាប់ពីមាត្រា ៦៥៥ (ការទាមទារឱ្យអនុវត្តការងារពេញលេញ) រហូតដល់មាត្រា ៦៥៨ (សិទ្ធិទាមទារឱ្យបន្ថយតម្លៃរបស់ម្ចាស់ការ) ខាងលើនេះ ត្រូវយកមកប្រើនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ។

២-អំឡុងពេលនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវគណនាចាប់ពីពេលដែលម្ចាស់ការបានដឹង ឬ គួរបានដឹង អំពីអត្ថិភាពនៃវិការៈនោះ ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះមានចែងថា អំឡុងពេលនៃការប្រើសិទ្ធិ គឺ ១ ឆ្នាំ សម្រាប់សិទ្ធិទាមទារឱ្យអនុវត្តការងារពេញលេញ សិទ្ធិទាមទារសោហ៊ុយជួសជុល ជាអាទិ៍ សិទ្ធិរំលាយកិច្ចសន្យា សិទ្ធិទាមទារឱ្យបន្ថយតម្លៃ របស់ម្ចាស់ការ ។ អំឡុងពេលនៃការប្រើសិទ្ធិ គឺ ១ ឆ្នាំ ដោយគ្មានពាក់ព័ន្ធនឹងខ្លឹមសារនៃការងារទេ ទោះបីជាករណីការងារធ្វើសំណង់លើដីក៏ដោយ ក៏ដូចគ្នាដែរ ។

អំឡុងពេលនេះ ត្រូវគិតចាប់ពីពេលដែលម្ចាស់ការបានដឹងថា មានវិការៈ ឬ ពីពេលដែលត្រូវដឹងអំពីវិការៈនោះ ដោយយកពេលណាមួយមុនគេ មកធ្វើជាមូលដ្ឋាននៃការគណនា (កថាខណ្ឌទី ២) មិនមែនជាពេលដែលបានប្រគល់កម្មវត្ថុនៃការងារ ឬ ពេលដែលបានបញ្ចប់ការងារនោះទេ ។

ម្យ៉ាងទៀត ចំពោះសិទ្ធិទាមទារសំណងនៃការខូចខាតវិញ ត្រូវអនុវត្តតាមអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលទូទៅ (ពីមាត្រា ៤៨០ ទៅ) ដូច្នេះ មិនត្រូវអនុវត្តតាមមាត្រានេះទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៣៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៦៦២.-** កិច្ចសន្យាពិសេសមិនទទួលខុសត្រូវក្នុងការធានា

បញ្ញត្តិចាប់ពីមាត្រា ៦៥៥ (ការទាមទារឱ្យអនុវត្តការងារពេញលេញ) រហូតដល់មាត្រា ៦៥៩ (សិទ្ធិទាមទារសំណងនៃការខូចខាតរបស់ម្ចាស់ការ) ខាងលើនេះ ទោះបីជាមានកិច្ចសន្យាពិសេសអំពីការអនុគ្រោះ ឬ កម្រិតការទទួលខុសត្រូវក៏ដោយ ចំពោះហេតុដែលបានដឹងហើយ តែបែរជាមិនបានរាយការណ៍ប្រាប់ទេនោះ អ្នកម៉ៅការមិនអាចរួចផុតពីការទទួលខុសត្រូវ ឬ ការកម្រិតការទទួលខុសត្រូវ បានឡើយ ។

(កំណត់)

ដោយផ្អែកលើគោលការណ៍សេរីភាពក្នុងការធ្វើកិច្ចសន្យា ភាគីនៃកិច្ចសន្យាម៉ៅការ អាចធ្វើការសន្យាពិសេស ដោយបំបាត់ចោល ឬ កម្រិតនូវការទទួលខុសត្រូវរបស់អ្នកម៉ៅការ ដែលបានចែងពីមាត្រា ៦៥៥ ដល់ មាត្រា ៦៥៩ ។ ក៏ប៉ុន្តែ មាត្រានេះបានចែងច្បាស់លាស់ថា មិនទទួលស្គាល់នូវការបំបាត់ចោល ឬ ការកម្រិតនូវការទទួលខុសត្រូវ ក្នុងករណីដែលអ្នកម៉ៅការពុំបានរាយការណ៍អំពីវិការៈដែលខ្លួនបានដឹងទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៤០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៣៩ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## **មាត្រា ៦៦៣**.- សិទ្ធិរំលាយរបស់ម្ចាស់ការនៅក្នុងពេលដែលការងារមិនទាន់បានសម្រេច

ម្ចាស់ការអាចរំលាយកិច្ចសន្យា នៅពេលណាក៏បាន ដោយសងសំណងនៃការខូចខាតរហូតដល់ពេលដែលអ្នកម៉ៅការបានសម្រេចការងារ ។

(កំណត់)

មាត្រានេះចែងថា ចំពោះការងារដែលម្ចាស់ការលែងត្រូវការ ម្ចាស់ការគ្មានភាពចាំបាច់ក្នុងការធ្វើឱ្យការងារនោះសម្រេចដោយបង្ខំទេ ហេតុដូច្នេះ ម្ចាស់ការអាចរំលាយកិច្ចសន្យា ពេលណាក៏បានដែរ មុនការបញ្ចប់ការងារនោះដោយអ្នកម៉ៅការ ។ ក៏ប៉ុន្តែ ក្នុងករណីនេះ ម្ចាស់ការត្រូវសងសំណងនូវសោហ៊ុយដែលអ្នកម៉ៅការបានចេញរួចហើយ ព្រមទាំងផលប្រយោជន៍ដែលអ្នកម៉ៅការអាចនឹងទទួលបាន ពេលខ្លួនសម្រេចការងារនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៤១ នៃក្រមរដ្ឋប្បវេណីជប៉ុន

# **ជំពូកទី ៩ កិច្ចសន្យាការងារ**

(កំណត់)

ចំពោះកិច្ចសន្យាការងារ ច្បាប់ការងារបានចែងអំពីទំនាក់ទំនងរវាងនិយោជក និង កម្មករនិយោជិតហើយ ហេតុនេះហើយ ក្នុងក្រមរដ្ឋប្បវេណីនេះ បានចែងតែចំណុចមូលដ្ឋាននៃកិច្ចសន្យាការងារ និង ភាគសំខាន់ៗដែលពុំមានចែងក្នុងច្បាប់ការងារប៉ុណ្ណោះ ។

## **មាត្រា ៦៦៤**.- កិច្ចសន្យាការងារ

១-កិច្ចសន្យាការងារ ត្រូវបានបង្កើតឡើង ដោយការសន្យារបស់ភាគីម្ខាងថា ធ្វើពលកម្មឱ្យភាគីម្ខាងទៀត ហើយភាគីម្ខាងទៀតសន្យាថា ផ្តល់ប្រាក់ឈ្នួល ទៅលើកិច្ចការពលកម្មនោះ ។

២-ភាគីដែលបានសន្យាថាធ្វើពលកម្ម ហៅថាកម្មករនិយោជិត ឯភាគីម្ខាងទៀតនោះ ហៅថានិយោជក ។

(កំណត់)

មាត្រានេះចែងអំពីនិយមន័យនៃកិច្ចសន្យាការងារ ជាអាទិ៍ ។ ក្នុងចំណោមកិច្ចសន្យាអញ្ញមញ្ញ មានកិច្ចសន្យាស្តីពីការផ្ទេរកម្មសិទ្ធិលើវត្ថុ ឬ សិទ្ធិប្រើប្រាស់វត្ថុ និង កិច្ចសន្យាស្តីពីការផ្តល់ពលកម្ម ឬ សេវា ជាអាទិ៍ ហើយកិច្ចសន្យាការងារគឺជាកិច្ចសន្យាផ្តល់ពលកម្ម ឬ សេវានេះ ។ កិច្ចសន្យាដែលប្រហាក់ប្រហែលនឹងកិច្ចសន្យាការងារដែរ មានដូចជាការម៉ៅការ ឬ អាណត្តិ ។ ការម៉ៅការ ឬ អាណត្តិ គឺជាកិច្ចសន្យាបញ្ចប់ការងារ ឬ អាណត្តិការចាត់ចែងកិច្ចការអ្វីមួយ ហើយវិធីចាត់ចែងការងារ ឬ កិច្ចការនេះ ជាគោលការណ៍ ត្រូវបានប្រគល់ទៅឱ្យភាគីម្ខាងទៀតធ្វើតាមបញ្ញា និងសមត្ថភាពរបស់ខ្លួន ។ ផ្ទុយទៅវិញ កិច្ចសន្យាការងារ គឺជាកិច្ចសន្យាធ្វើឡើងដោយកម្មករនិយោជិតដើម្បីបម្រើការងារឱ្យនិយោជក ហើយតើត្រូវប្រើពលកម្មនោះយ៉ាងដូចម្តេចខ្លះនោះ គឺជាការវិនិច្ឆ័យរបស់និយោជក ។ ម្យ៉ាងទៀត ក្រមរដ្ឋប្បវេណីបារាំង កំណត់និយមន័យកិច្ចសន្យាការងារថាជាភតិសន្យាពលកម្ម ។

កថាខណ្ឌទី ១ កំណត់និយមន័យនៃកិច្ចសន្យាការងារ ។ រីឯចំពោះបញ្ញត្តិស្តីពីពេលដែលត្រូវបង់ប្រាក់ឈ្នួល ជាអាទិ៍ ក្រមនេះប្រគល់តួនាទីទៅឱ្យច្បាប់ការងារវិញ ។

កថាខណ្ឌទី ២ ចែងអំពីនិយមន័យនៃភាគីនៃកិច្ចសន្យាការងារ ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ៦២៣ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ១១៤៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។

## **មាត្រា ៦៦៥**.- ការបង្ហាញល័ក្ខខ័ណ្ឌជាក់លាក់លើការងារ

១-នៅពេលធ្វើកិច្ចសន្យាការងារនិយោជកត្រូវបង្ហាញជាក់លាក់ នូវប្រាក់ឈ្នួល ពេលម៉ោងធ្វើពលកម្ម និង ល័ក្ខខ័ណ្ឌនៃការធ្វើពលកម្មផ្សេងទៀត ចំពោះកម្មករនិយោជិត ។

២-ក្នុងករណីដែលល័ក្ខខ័ណ្ឌនៃការធ្វើពលកម្មដែលត្រូវបានបង្ហាញជាក់លាក់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ខុសពីការពិត កម្មករនិយោជិតអាចរំលាយកិច្ចសន្យាការងារនោះភ្លាមៗបាន ។

(កំណត់)

មាត្រានេះចែងថា និយោជកត្រូវបង្ហាញល័ក្ខខ័ណ្ឌច្បាស់លាស់អំពីការងារ ពេលធ្វើកិច្ចសន្យាការងារ ។ ម្យ៉ាងទៀត ក្នុងករណីដែលល័ក្ខខ័ណ្ឌនៃការងារដែលបានបង្ហាញនោះ ខុសនឹងស្ថានភាពពិត កម្មករនិយោជិតអាចរំលាយកិច្ចសន្យាការងារបានភ្លាម ។

កថាខណ្ឌទី ១ ចែងអំពីករណីយកិច្ចរបស់និយោជក ។ ស្ដីពីវិធីធ្វើការបង្ហាញ គ្មានដាក់កម្រិតទេ ។ ក៏ប៉ុន្តែ ឧទាហរណ៍ ក្នុងករណីដែលនិយោជកបានកំណត់លក្ខន្តិកៈនៃការងារ និយោជកអាចបង្ហាញលក្ខន្តិកៈនោះបាន ។ ដើម្បីការពារកុំឱ្យមានវិវាទពេលក្រោយ គួរតែធ្វើការបង្ហាញនូវល័ក្ខខ័ណ្ឌនៃការងារនេះ ជាលាយល័ក្ខណ៍អក្សរ ក៏ប៉ុន្តែ អាចធ្វើដោយផ្ទាល់មាត់ក៏បានដែរ ។

កថាខណ្ឌទី ២ ចែងថា ក្នុងករណីដែលល័ក្ខខ័ណ្ឌនៃការងារដែលត្រូវបានបង្ហាញនោះ ខុសនឹងការពិត កម្មករនិយោជិតអាចរំលាយកិច្ចសន្យាការងារនោះបានភ្លាម ។ ក្នុងករណីដូចនេះ អាចលុបចោលកិច្ចសន្យាការងារដោយយកមូលហេតុឆបោក ឬ ភាន់ច្រឡំក៏បាន ។ ក៏ប៉ុន្តែ ក្នុងករណីដែលលុបចោលកិច្ចសន្យាការងារដោយយកការឆបោក មកធ្វើជាមូលដ្ឋាន កម្មករនិយោជិតត្រូវធ្វើការបញ្ជាក់ថា និយោជកមានគោលបំណងចង់បោកកម្មករនិយោជិត ហេតុនេះហើយ ដើម្បីការពារកម្មករនិយោជិត មាត្រានេះចែងថា កម្មករនិយោជិតនោះអាចរំលាយកិច្ចសន្យាការងារបាន ដោយយកអង្គហេតុដែលល័ក្ខខ័ណ្ឌនៃការងារដែលត្រូវបានបង្ហាញនោះ មិនត្រូវនឹងស្ថានភាពពិត មកធ្វើជាមូលដ្ឋាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៥ នៃច្បាប់បទដ្ឋានការងារជប៉ុន

## **មាត្រា ៦៦៦**.- ករណីយកិច្ចយកចិត្តទុកដាក់ ដល់សុវត្ថិភាព

និយោជក មានករណីយកិច្ចយកចិត្តទុកដាក់ ដល់ការរក្សារូបរាងកាយ សុខភាព ជាអាទិ៍ របស់កម្មករនិយោជិត ពីគ្រោះថ្នាក់ នៅទីកន្លែងដែលកម្មករនិយោជិតត្រូវធ្វើពលកម្ម សិល្បៈការ្យ នៅក្នុងការធ្វើឧបករណ៍ ។

(កំណត់)

មាត្រានេះចែងអំពីករណីយកិច្ចយកចិត្តទុកដាក់ដល់សុវត្ថិភាពចំពោះកម្មករនិយោជិតដោយនិយោជក ។ ករណីយកិច្ចយកចិត្តទុកដាក់ដល់សុវត្ថិភាព គឺជាករណីយកិច្ចមួយតម្រូវឱ្យភាគីម្ខាងការពារអាយុជីវិត និង សុខភាព ជាអាទិ៍ របស់ភាគីម្ខាងទៀត ដោយកុំឱ្យជួបប្រទះគ្រោះថ្នាក់ រវាងភាគីដែលមានទំនាក់ទំនងពិសេសក្នុងសង្គម ដោយផ្អែកលើទំនាក់ទំនងគតិយុត្តណាមួយ (សាលដីការបស់តុលាការកំពូលជប៉ុន ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៥) ។ មាត្រានេះគឺជាបញ្ញត្តិដែលចែងច្បាស់លាស់អំពីខ្លឹមសារនៃករណីយកិច្ចនេះ ចំពោះទំនាក់ទំនងក្នុងកិច្ចសន្យាការងារ ដោយចែងថា

និយោជកមានករណីយកិច្ចយកចិត្តទុកដាក់ ដល់ការរក្សារូបកាយ សុខភាព ជាអាទិ៍ របស់កម្មករនិយោជិត ពីគ្រោះថ្នាក់ ចំពោះការគ្រប់គ្រងការិយាល័យ រោងចក្រ ហាង និង ការដាក់គ្រឿង បរិក្ខារ គ្រឿងសម្ភារៈ ជាអាទិ៍ នៅក្នុងនោះ ។ ហើយប្រសិនបើនិយោជកមិនបានបំពេញករណីយកិច្ចយកចិត្តទុកដាក់ដល់សុវត្ថិភាពនេះ ហើយធ្វើឱ្យកម្មករនិយោជិតរងគ្រោះខាងផ្លូវកាយ ជាអាទិ៍ និយោជកត្រូវទទួលខុសត្រូវនូវសំណងនៃការខូចខាតចំពោះកម្មករនិយោជិត ដោយមូលហេតុមិនអនុវត្តកាតព្វកិច្ច ។ ឧទាហរណ៍ ចំពោះម៉ាស៊ីនសង្កត់ដែលដាក់នៅក្នុងរោងចក្រ និយោជកត្រូវដាក់គ្រឿងឧបករណ៍សុវត្ថិភាពដើម្បីការពារកុំឱ្យដាច់ដៃ ឬ ម្រាមដៃកម្មករនិយោជិត តែប្រសិនបើនិយោជកមិនបានដាក់ឧបករណ៍នោះ ហើយបណ្ដាលឱ្យដាច់ម្រាមដៃកម្មករនិយោជិត និយោជកនោះត្រូវទទួលខុសត្រូវនូវសំណងនៃការខូចខាតចំពោះកម្មករនិយោជិត ដោយសារការបំពានករណីយកិច្ចយកចិត្តទុកដាក់ដល់សុវត្ថិភាពនេះ ។

ម្យ៉ាងទៀត ករណីយកិច្ចយកចិត្តទុកដាក់ដល់សុវត្ថិភាពចំពោះកម្មករនិយោជិត ដោយនិយោជកនេះ ចេញមកពីគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។ ដូច្នេះ មាត្រានេះចែងអំពីការរៀបចំ និង គ្រប់គ្រងទីកន្លែងសិប្បកម្ម ឧបករណ៍ ជាអាទិ៍ ក៏ប៉ុន្តែ ក្រៅពីនេះ ឧទាហរណ៍ និយោជកបានបង្ខំឱ្យកម្មករនិយោជិតធ្វើការងារក្រៅម៉ោងច្រើន ហើយការនេះបានធ្វើឱ្យខូចសុខភាពកម្មករនិយោជិត ពេលនោះ និយោជកបានធ្វេសប្រហែសក្នុងការបំពេញករណីយកិច្ចការពារសុខភាពរបស់កម្មករនិយោជិតពីគ្រោះថ្នាក់ ដូច្នេះហើយ និយោជកត្រូវទទួលខុសត្រូវនូវសំណងនៃការខូចខាត ចំពោះការធ្វើឱ្យខូចសុខភាពកម្មករនិយោជិតនេះ ។

**មាត្រា ៦៦៧**.- ភាពផ្តាច់មុខលើបុគ្គល នៃកិច្ចសន្យាការងារ

១-បើគ្មានការយល់ព្រមពីកម្មករនិយោជិតទេ និយោជកពុំអាចធ្វើអនុប្បទានសិទ្ធិនោះ ឱ្យទៅតតិយជនបានឡើយ ។

២-បើគ្មានការយល់ព្រមពីនិយោជកទេ កម្មករនិយោជិត ពុំអាចឱ្យតតិយជនធ្វើពលកម្មជំនួសខ្លួនបានឡើយ ។

៣-ប្រសិនបើភាគីណាមួយនៃកិច្ចសន្យាការងារ បានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ ភាគីម្ខាងទៀត អាចរំលាយកិច្ចសន្យានោះបាន ។

(កំណត់)

មាត្រានេះចែងថា ក្នុងកិច្ចសន្យាការងារ ប្រសិនបើពុំមានការយល់ព្រមពីភាគីម្ខាងទៀតទេ កិច្ចសន្យានោះមិនអាចផ្លាស់ប្តូរភាគីបានឡើយ ។

កិច្ចសន្យាការងារ គឺជាកិច្ចសន្យាមួយដែលធ្វើឡើងដោយពិនិត្យមើលទៅលើលក្ខណៈបុគ្គលម្ខាងទៀតទៅវិញទៅមក ហេតុនេះហើយ ប្រសិនបើពុំមានការយល់ព្រមពីភាគីម្ខាងទៀតទេ និយោជកពុំអាចធ្វើអនុប្បទានឋានៈរបស់ខ្លួន ទៅឱ្យ

តតិយជនបានឡើយ រីឯកម្មករនិយោជិតវិញ ក៏ពុំអាចឱ្យតតិយជនមកធ្វើពលកម្មជំនួសខ្លួនបានឡើយ ។ ឧទាហរណ៍ ក្នុងករណីដែលនិយោជកគ្មានការងារឱ្យកម្មករនិយោជិតធ្វើពីរ ឬ បីថ្ងៃ ប្រសិនបើនិយោជកមានបំណងបញ្ជូនកម្មករនិយោជិតនោះ ទៅធ្វើការឱ្យនិយោជកផ្សេងទៀត ចាំបាច់ត្រូវមានការយល់ព្រមពីកម្មករនិយោជិតនោះ ។ម្យ៉ាងទៀត ដើម្បីឈប់សម្រាក កម្មករនិយោជិតក៏មិនអាចបញ្ជូនអ្នកផ្សេងទៅធ្វើជំនួសខ្លួនបានឡើយ ប្រសិនបើពុំមានការយល់ព្រមពីនិយោជកទេ ។ ក្នុងករណីដែលភាគីម្ខាងទៀតបានធ្វើខុសនឹងបញ្ញត្តិនេះ ភាគីម្ខាងអាចរំលាយកិច្ចសន្យាការងារបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦២៥ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១១៤៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ៦៦៨**.- ការអនុវត្តច្បាប់ការងារ

ចំពោះកិច្ចសន្យាការងារ ក្រៅពីបញ្ញត្តិដែលកំណត់នៅក្នុងក្រមនេះ ត្រូវអនុលោមទៅតាមបញ្ញត្តិនៃច្បាប់ការងារ ។

(កំណត់)

ច្បាប់ការងារ (ចូលជាធរមាននៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ១៩៩៧) មានបញ្ញត្តិលំអិតស្តីពីទំនាក់ទំនងកិច្ចសន្យាការងាររវាងនិយោជក និង កម្មករនិយោជិត ។ ម្យ៉ាងទៀត នាអនាគត អាចមានការធ្វើវិសោធនកម្មច្បាប់ការងារនោះ ឬ អាចមានបទដ្ឋានគតិយុត្តផ្សេងទៀតពាក់ព័ន្ធនឹងវិស័យការងារដែរ ហេតុនេះហើយ ចំពោះកិច្ចសន្យាការងារ ក្រៅពីបញ្ញត្តិដែលមាននៅក្នុងក្រមនេះ មាត្រានេះប្រគល់តួនាទីនេះទាំងស្រុងទៅឱ្យច្បាប់ការងារ ។

## ជំពូកទី ១០ បញ្ញើ

### ផ្នែកទី ១ បទប្បញ្ញត្តិទូទៅស្តីពីបញ្ញើ

**មាត្រា ៦៦៩**.- និយមន័យនៃបញ្ញើ

១-បញ្ញើ សំដៅទៅលើកិច្ចសន្យាដែលភាគីម្ខាងជាអ្នកទទួលបញ្ញើ សន្យាទទួលយកវត្ថុបញ្ញើ ពីភាគីម្ខាងទៀតជាអ្នកផ្ញើ មករក្សាទុកក្នុងអំឡុងពេលដែលបានកំណត់ ហើយនៅក្រោយពេលដែលអំឡុងពេលរក្សាទុកនោះត្រូវបានបញ្ចប់ ត្រូវសងវត្ថុដដែលនោះ ទៅឱ្យអ្នកផ្ញើវិញ ។

២-បើគ្មានកិច្ចសន្យាពិសេសទេ អ្នកផ្ញើពុំមានករណីយកិច្ចបង់កម្រៃឱ្យអ្នកទទួលបញ្ញើឡើយ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកទទួលបញ្ញើបានធ្វើកិច្ចសន្យានោះជាមួយអ្នកផ្ញើ

ក្នុងនាមជាអាជីវកម្មរបស់ខ្លួន ឬ ប្រសិនបើមានកំណត់ក្នុងច្បាប់ ទោះបីជាពុំបានធ្វើកិច្ចសន្យាពិសេសចំពោះកម្រៃក៏ដោយ អ្នកទទួលបញ្ញើអាចទាមទារកម្រៃសមរម្យពីអ្នកផ្ញើបាន ។

(កំណត់)

១. មាត្រានេះចែងអំពីនិយមន័យនៃបញ្ញើ ។ បញ្ញើគឺជាកិច្ចសន្យាផ្តល់សេវា ដូចជាកិច្ចសន្យាការងារ អាណត្តិ និង កិច្ចសន្យាម៉ៅការ ប៉ុន្តែ សេវាដែលអ្នកទទួលបញ្ញើត្រូវផ្តល់នោះ គ្រាន់តែជា "ការរក្សាទុកនូវវត្ថុដែលបានទទួល" តែប៉ុណ្ណោះ ។ ប្រសិនបើមានការបន្ថែមសេវាផ្សេងទៀត កិច្ចសន្យានោះនឹងអាចក្លាយទៅជាកិច្ចសន្យាម៉ៅការ ។ ជាឧទាហរណ៍ កិច្ចសន្យាមួយដែលតាមរយៈនោះ អ្នកដំណើរប្រគល់អីវ៉ាន់ ទៅក្រុមហ៊ុនដឹកជញ្ជូនតាមផ្លូវរថភ្លើង នៅឯស្ថានីយ៍ដែលអ្នកដំណើរត្រូវជិះ ហើយអ្នកដំណើរត្រូវទទួលអីវ៉ាន់នោះវិញ នៅស្ថានីយ៍ដែលខ្លួនទៅដល់ សេវាបែបនេះ មិនមែនគ្រាន់តែជាការរក្សាទុកនូវអីវ៉ាន់ប៉ុណ្ណោះទេ ។ ដោយសារតែកាតព្វកិច្ចដឹកជញ្ជូនអីវ៉ាន់ឱ្យទៅដល់គោលដៅត្រូវបានបន្ថែម ដូច្នេះ ធាតុផ្សំនៃកិច្ចសន្យាម៉ៅការ ក៏ត្រូវបានដាក់បញ្ចូលដែរ ។

២. ខាងក្រោម គឺជាឧទាហរណ៍ខ្លះៗស្តីពីបញ្ញើ :

(1) ឧទាហរណ៍ទីមួយ កិច្ចសន្យាស្តុកទំនិញក្នុងឃ្លាំង ។ អន្តរការី/ឈ្មួញកណ្តាល នៃការជួញដូរទំនិញ (អ្នកលក់ដុំ) កើតមានក្នុងដំណើរការចែកចាយទំនិញ រវាងផលិតកម្ម និង ការលក់ទៅឱ្យអ្នកប្រើប្រាស់ ។ ជាធម្មតា អ្នកលក់ដុំជាច្រើនតែងតែចូលរួមនៅក្នុងដំណើរការនេះ ។ បន្ទាប់ពីអ្នកលក់ដុំបានទិញទំនិញពីអ្នកផលិតហើយ ពួកគេត្រូវតែរក្សាទំនិញដែលបានទិញហើយនោះ ទុកទម្រាំតែពួកគេលក់ទំនិញទាំងនោះ ទៅឱ្យអ្នកលក់ដុំ ឬ អ្នកលក់រាយផ្សេងទៀត ។ ប្រសិនបើពួកគេមិនមានកន្លែងទុកដាក់ ឬ ការទុកដាក់នោះតម្រូវឱ្យមានឧបករណ៍ពិសេស (ដូចជា ឧបករណ៍ក្លាសេ ជាដើម) ពួកគេនឹងផ្ញុកផ្តាក់ទំនិញនោះទៅឱ្យអ្នកកាន់កាប់ឃ្លាំង ។ ក្នុងករណីនេះ អ្នកលក់ដុំ និង អ្នកកាន់កាប់ឃ្លាំង បង្កើតនូវ "កិច្ចសន្យាបញ្ញើ" ។

អ្នកកាន់កាប់ឃ្លាំងចេញបង្កាន់ដៃឃ្លាំងដើម្បីបញ្ជាក់អំពីសិទ្ធិរបស់អ្នកផ្ញើ ។ ប្រសិនបើអ្នកលក់ដុំលក់បន្តនូវទំនិញដែលបានផ្ញើនោះ ទៅឱ្យអ្នកលក់ដុំម្នាក់ផ្សេងទៀត អ្នកលក់នឹងប្រគល់បង្កាន់ដៃឃ្លាំងឱ្យទៅអ្នកទិញនោះ ។ ការប្រគល់នូវបង្កាន់ដៃឃ្លាំងនេះ មានន័យថាជាការប្រគល់នូវទំនិញដែលបានផ្ញើនោះ ។ តាមមធ្យោបាយនេះ ទំនិញត្រូវបានបែងចែកប្រកបដោយប្រសិទ្ធភាព ដោយមិនចាំបាច់ធ្វើបំលាស់ទីជាក់ស្តែងនៃទំនិញឡើយ ។

(2) ឧទាហរណ៍ផ្សេងទៀតនៃបញ្ញើមានដូចជា ករណីដែលភ្ញៀវបានផ្ញើវត្ថុមានតម្លៃនៅសណ្ឋាគារ ឬ អតិថិជនផ្ញើអីវ៉ាន់ជាបណ្តោះអាសន្ននៅភោជនីយដ្ឋាន ឬ អ្នកដំណើរផ្ញើអីវ៉ាន់ជាបណ្តោះអាសន្ននៅស្ថានីយ៍ ជាដើម ។ លើសពីនេះទៅទៀត ករណីបន្ទាប់នេះក៏ជាបញ្ញើដែរ គឺ នៅពេលមានវិវាទអំពីកម្មសិទ្ធិលើវត្ថុណាមួយ តតិយជនធ្វើការថែរក្សានូវវត្ថុនោះ រហូតទាល់តែវិវាទត្រូវបានដោះស្រាយចប់ ។ បញ្ញើឱ្យរក្សាទុកបែបនេះ ហៅថា " វិសុណ្ឋាប័ន" (មាត្រា ៦៩២ ដល់មាត្រា

៦៩៨) ។

៣. កិច្ចសន្យាបញ្ញើមានលក្ខណៈដូចតទៅ :

(1) កិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយការប្រគល់វត្ថុ និង កិច្ចសន្យាឯកតោភាគី : ក្នុងកិច្ចសន្យាបញ្ញើ នៅពេលដែលអ្នកទទួលបញ្ញើ "បានទទួលវត្ថុ" ករណីយកិច្ចរបស់អ្នកទទួលបញ្ញើនោះនឹងកើតឡើង (មាត្រា ៦៧០) ។ មានន័យថា ជាគោលការណ៍ កិច្ចសន្យាបញ្ញើត្រូវបានបង្កើតឡើងដោយចាំបាច់ប្រគល់វត្ថុ ។ ប៉ុន្តែ កិច្ចសន្យាបញ្ញើដែលត្រូវបានបង្កើតឡើង ដោយការព្រមព្រៀង ក៏ត្រូវបានអនុញ្ញាតឱ្យធ្វើដែរ (មាត្រា ៦៧១) ។ ការផ្ញើដោយមិនយកកម្រៃ គឺជាកិច្ចសន្យាឯកតោភាគី ពីព្រោះអ្នកទទួលបញ្ញើទទួលបន្ទុកនូវករណីយកិច្ចរក្សាទុក និង ប្រគល់វិញនូវវត្ថុផ្ញើ រីឯអ្នកផ្ញើមិនមានករណីយកិច្ចអ្វីទាំងអស់ ។

(2) គោលការណ៍មិនយកកម្រៃ (កថាខណ្ឌទី ២ នៃមាត្រានេះ) : ក្នុងសង្គមជាក់ស្តែង វត្ថុមួយចំនួនត្រូវបានគេរក្សាទុកដោយមិនយកកម្រៃ ឧទាហរណ៍ ដូចជាការថែរក្សាអីវ៉ាន់ឱ្យមានសុវត្ថិភាពនៅសារមន្ទីរ និង ការថែរក្សាវត្ថុមានតម្លៃនៅសណ្ឋាគារឱ្យមានសុវត្ថិភាព ជាដើម ។ ដូច្នេះ យើងបានបញ្ញត្តថា ជាគោលការណ៍ បញ្ញើមិនយកកម្រៃ ហើយចំពោះបញ្ញើដោយឱ្យបង់ថ្លៃវិញ ត្រូវតែមានការសន្យាពិសេស ។ ប៉ុន្តែ នៅពេលដែលអ្នកទទួលបញ្ញើទទួលនូវការផ្ញើ ក្នុងនាមជា "អាជីវកម្ម" របស់ខ្លួន ជាគោលការណ៍ បញ្ញើនោះត្រូវតែគិតថ្លៃ ។ បញ្ញើដែលអ្នកទទួលបញ្ញើបានទទួលនូវការផ្ញើក្នុងនាមជា "អាជីវកម្ម" របស់ខ្លួន គឺជាបញ្ញើដែលអ្នកទទួលបញ្ញើនោះ ទទួលម្តងហើយម្តងទៀតពីបុគ្គលផ្សេងៗ ហើយដែលអ្នកទទួលបញ្ញើនោះទទួលបាននូវចំណេញ ។ អាជីវកម្មឃ្លាំងស្តុកទំនិញជាបញ្ញើសម្រាប់អាជីវកម្ម ប៉ុន្តែ ការថែរក្សាវត្ថុមានតម្លៃនៅសណ្ឋាគារឱ្យមានសុវត្ថិភាព មិនមែនជាបញ្ញើសម្រាប់អាជីវកម្មទេ ពីព្រោះសណ្ឋាគារមិនបានទទួលផលប្រយោជន៍អ្វីពីបញ្ញើនោះទេ ។

៤. កម្មវត្ថុនៃកិច្ចសន្យាបញ្ញើ

(1) កម្មវត្ថុនៃកិច្ចសន្យាបញ្ញើ គឺជា "វត្ថុ" ។ ជាធម្មតា កម្មវត្ថុនៃកិច្ចសន្យាបញ្ញើជាចលនវត្ថុ ប៉ុន្តែ អចលនវត្ថុក៏អាចក្លាយជាកម្មវត្ថុនៃបញ្ញើដែរ ។ ប៉ុន្តែ នៅពេលដែលអចលនវត្ថុត្រូវបានដាក់ផ្ញើ វាមិនគ្រាន់តែត្រូវបានគេរក្សាទុកប៉ុណ្ណោះទេ គឺវាក៏ត្រូវបានគេគ្រប់គ្រងផងដែរ (ឧទាហរណ៍ដូចជាការប្រមូលថ្លៃឈ្នួលនៃភតិសន្យាអចលនវត្ថុ ជាអាទិ៍) ហេតុដូច្នេះ ជាទូទៅ ត្រូវបានគេបកស្រាយថាជាអាណត្តិច្រើនជាងជាបញ្ញើ ។ ប៉ុន្តែ នៅតែអាចមានបញ្ញើអចលនវត្ថុប្រសិនបើអចលនវត្ថុគាន់តែត្រូវបានរក្សាទុកដោយមិនគ្រប់គ្រង ។

(2) សិទ្ធិលើបំណុលមិនអាចក្លាយជាកម្មវត្ថុនៃបញ្ញើ ប៉ុន្តែ "ប័ណ្ណបំណុល" និង "លិខិតបញ្ជាក់បំណុល" ដែលបញ្ជាក់បង្ហាញសិទ្ធិលើបំណុល អាចក្លាយជាកម្មវត្ថុនៃបញ្ញើដែរ ។ ឧទាហរណ៍មួយ គឺប្រព័ន្ធការពាររក្សាទុកបញ្ញើដែលក្រុមហ៊ុនភាគហ៊ុនរក្សាទុកនូវភាគហ៊ុនរបស់វិនិយោគិន ។ នៅក្នុងករណីនៃបញ្ញើនូវឧបករណ៍ដែលអាចជួញដូរបាន ប្រសិនបើបញ្ញើនោះអនុញ្ញាតឱ្យមានការប្រគល់វិញនូវប័ណ្ណដែលមានប្រភេទ និង ចំនួនទឹកប្រាក់ដូចគ្នា ហើយមិនតម្រូវឱ្យមានការសងវិញនូវឧបករណ៍ដដែលនោះទេ កិច្ចសន្យានេះក្លាយជាបញ្ញើបរិភោគ ។

(3) ប្រសិនបើប្រាក់ត្រូវបានរក្សាទុក តាមទម្រង់ជាការដាក់ក្នុងស្រោមសំបុត្រ ប្រាក់នោះអាចក្លាយជាកម្មវត្ថុនៃបញ្ញើ ព្រោះប្រាក់ក្នុងស្រោមសំបុត្រនេះត្រូវបានគេចាត់ទុកដូចគ្នានឹង "វត្ថុ" ។ ប៉ុន្តែ ប្រសិនបើប្រាក់មិនត្រូវបានដាក់ក្នុងស្រោមសំបុត្រទេ កិច្ចសន្យានេះមិនមែនបញ្ញើធម្មតាទេ តែជាបញ្ញើបរិភោគ ។ បញ្ញត្តិពិសេសដែលទាក់ទងនឹងករណីនេះត្រូវបានពាក់តែងឡើង ( មាត្រា ៦៩០) ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៦៥៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៥៩៣ នៃក្រមពាណិជ្ជកម្មជប៉ុន (បញ្ញើពាណិជ្ជកម្ម) និង មាត្រា ៥៩៧ នៃក្រមពាណិជ្ជកម្មជប៉ុន ( អាជីវកម្មឃ្លាំងស្តុកទំនិញ) ។

## មាត្រា ៦៧០.- ភាពចាំបាច់ក្នុងការទទួលយកវត្ថុនៃកិច្ចសន្យាបញ្ញើ

១-កិច្ចសន្យាបញ្ញើ ត្រូវបានបង្កើតឡើង ដោយអ្នកទទួលបញ្ញើ ទទួលយកកម្មវត្ថុនៃបញ្ញើ តាមការព្រមព្រៀង ។

២-ក្នុងករណីដែលអ្នកទទួលបញ្ញើបានកាន់កាប់កម្មវត្ថុនៃបញ្ញើនោះហើយ កិច្ចសន្យាបញ្ញើត្រូវបានបង្កើតឡើងដោយការព្រមព្រៀងបង្កើតទំនាក់ទំនងបញ្ញើនោះ ។ ចំពោះវត្ថុដែលកាន់កាប់ដោយតតិយជន កិច្ចសន្យាបញ្ញើត្រូវបានបង្កើត នៅពេលដែលបានផ្ទេរការកាន់កាប់ដោយការបញ្ជា ។

( កំណត់)

១. កថាខណ្ឌទី ១ នៃមាត្រានេះចែងអំពីភាពចាំបាច់ក្នុងការទទួលវត្ថុដើម្បីបង្កើតនូវកិច្ចសន្យាបញ្ញើដែលមានអានុភាព ។ ហេតុផលដែលចែងដូច្នេះ គឺដោយសារតែ ជាគោលការណ៍ បញ្ញើគឺជាកិច្ចសន្យាដោយមិនយកកម្រៃ ដូច្នេះ វាមិនសមរម្យទេ ដែលត្រូវផ្តល់អានុភាពខ្លាំងចំពោះការសន្យា "ផ្ញើវត្ថុ" និង "ទទួលបញ្ញើ" នៅពេលដែលវត្ថុដែលជាកម្មវត្ថុមិនទាន់ត្រូវបានផ្ទេរនៅឡើយ ។

ក៏ប៉ុន្តែ ការព្រមព្រៀងគ្នាអាចចងគូភាគីបាន ប្រសិនបើភាគីទាំងពីរធ្វើការព្រមព្រៀងពិសេស ចំពោះបញ្ញើនាពេលអនាគត ហើយមានបំណងឱ្យការព្រមព្រៀងគ្នានោះឱ្យមានអានុភាពចងគូភាគី ។ ឧទាហរណ៍ ពាណិជ្ជករកំពុងនាំចូលនូវទំនិញមកពីក្រៅប្រទេស ហើយបង្កើតកិច្ចសន្យាបញ្ញើសម្រាប់ពេលអនាគតជាមួយនឹងអ្នកកាន់កាប់ឃ្លាំង ដោយសារកប៉ាល់ដែលដឹកទំនិញនឹងមកដល់កំពង់ផែនៅថ្ងៃទី ០០ ខែ ០០ ជាអាទិ៍ ។ ប្រសិនបើកិច្ចសន្យានេះមិនមានអានុភាពចងគូភាគីទេ ពាណិជ្ជករនោះនឹងជួបបញ្ហាហើយ ។ ការសន្យានេះនឹងផ្តល់ផលប្រយោជន៍ដល់អ្នកកាន់កាប់ឃ្លាំងផងដែរ ពីព្រោះអ្នកកាន់កាប់ឃ្លាំងអាចគ្រោងទុកជាមុនបានអំពីរបៀបប្រើប្រាស់ឃ្លាំងនោះ ។ ក្នុងករណីនេះ មិនមានបញ្ហាអ្វីទេចំពោះការចាត់ទុកថា ការព្រមព្រៀង (កិច្ចសន្យា) បញ្ញើនាពេលអនាគតមានអានុភាព ។ មាត្រា ៦៧១ បានចែងអំពី

កិច្ចសន្យាបញ្ញើដោយការព្រមព្រៀងបែបនេះ ។

២. កថាខណ្ឌទី ២ ចែងអំពីករណីដែលកិច្ចសន្យាបញ្ញើត្រូវបានបង្កើតឡើងដោយ "ការប្រគល់ដោយសង្ខេប" និង "ការផ្ទេរការកាន់កាប់ដោយការបញ្ជា" ។

កិច្ចសន្យាបញ្ញើតម្រូវឱ្យមានការប្រគល់នូវកម្មវត្ថុដើម្បីបង្កើតអានុភាព ប៉ុន្តែ ប្រសិនបើអ្នកដែលត្រូវទទួលបញ្ញើបានរក្សាទុកនូវវត្ថុដែលជាកម្មវត្ថុរួចហើយ វាមិនមានប្រយោជន៍អ្វីដែលត្រូវប្រគល់វត្ថុនោះទៅឱ្យអ្នកផ្ញើវិញ ដើម្បីឱ្យអ្នកផ្ញើធ្វើការប្រគល់វត្ថុនោះជាថ្មីម្តងទៀតទៅអ្នកទទួលបញ្ញើនោះទេ ។ ប្រសិនបើអ្នកទទួលបញ្ញើ និង អ្នកផ្ញើយល់ព្រមលើកិច្ចសន្យាបញ្ញើ កិច្ចសន្យាបញ្ញើនោះបង្កើតអានុភាព ។ ឧទាហរណ៍មួយ គឺករណីដែល A លក់វត្ថុមួយដែលខ្លួនកាន់កាប់ក្នុងនាមជាកម្មសិទ្ធិករឱ្យទៅ B ប៉ុន្តែ តាមការជាក់ស្តែង មិនផ្ទេរការកាន់កាប់វត្ថុនោះឱ្យទៅ B ហើយបន្តរក្សាវត្ថុនោះ ក្នុងនាមជាអ្នកទទួលបញ្ញើ ។ នេះគឺជាការបង្កើតកិច្ចសន្យាបញ្ញើដោយ "ការប្រគល់ដោយសង្ខេប" ។

កិច្ចសន្យាបញ្ញើក៏អាចត្រូវបានបង្កើតឡើងដោយ "ការផ្ទេរការកាន់កាប់ដោយការបញ្ជា" ។ ឧទាហរណ៍ នៅពេល A ជាអ្នកកាន់កាប់ឃ្លាំង (អ្នកទទួលបញ្ញើ) កំពុងរក្សាទុកវត្ថុរបស់អ្នកផ្ញើ B ប្រសិនបើ B ផ្ទេរកម្មសិទ្ធិលើវត្ថុនោះឱ្យទៅ C មានករណីខ្លះ C មានបំណងបន្តកិច្ចសន្យាស្តុកទំនិញជាមួយ A ។ ក្នុងករណីនេះ កិច្ចសន្យាបញ្ញើរវាង C និង A ត្រូវបានបង្កើតឡើង នៅពេលដែល B បញ្ជាឱ្យ A ថា ត្រូវកាន់កាប់វត្ថុនោះសម្រាប់ C ក្រោយពេលធ្វើការបញ្ជានោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៥៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៦៧១**.- អានុភាពនៃកិច្ចសន្យាបញ្ញើដោយការព្រមព្រៀង

ប្រសិនបើភាគី គ្រាន់តែបានព្រមព្រៀងថា នឹងបង្កើតទំនាក់ទំនងបញ្ញើនាពេលអនាគត ភាគីនីមួយៗអាចដកការព្រមព្រៀងនោះចេញ នៅពេលណាក៏បាន រហូតដល់ពេលដែលបានប្រគល់កម្មវត្ថុនៃបញ្ញើនោះ ។ ប៉ុន្តែ ក្នុងករណីដែលបានសន្យាបង្កើតកិច្ចសន្យាបញ្ញើដោយឱ្យបង់ថ្លៃវិញ ប្រសិនបើបានធ្វើឱ្យខូចខាតដល់ភាគីម្ខាងទៀត ដោយសារការបដិសេធមិនទទួលវត្ថុបញ្ញើផ្ទុយនឹងការសន្យានោះ ភាគីដែលជាអ្នកទទួលបញ្ញើមានករណីយកិច្ចត្រូវសងសំណងនៃការខូចខាតនោះ ឱ្យទៅភាគីម្ខាងទៀត ប្រសិនបើការបដិសេធនោះ គ្មានមូលហេតុត្រឹមត្រូវទេ ។

(កំណត់)

១. ជាករណីលើកលែងចំពោះគោលការណ៍នៃភាពចាំបាច់ក្នុងការទទួលយកវត្ថុ (មាត្រា ៦៧០) មាត្រានេះចែងថា កិច្ចសន្យាបញ្ញើដោយការព្រមព្រៀងដែលបានបង្កើតឡើងត្រឹមតាមការព្រមព្រៀងគ្នា ដោយមិនមានការប្រគល់វត្ថុ ក៏

មានអានុភាពដែរ ។ ប៉ុន្តែ តាមការជាក់ស្ដែង បញ្ញើដោយការព្រមព្រៀង ជាការសន្យាជាមុនអំពីបញ្ញើនាពេលអនាគត ហេតុដូច្នេះ វាមិនសមរម្យទេក្នុងការផ្ដល់ឱ្យមានអានុភាពចងខ្លាំងពេកនោះ ។ ម្យ៉ាងទៀត ការអនុវត្តបែបនេះ ស្របនឹងឆន្ទៈរបស់ភាគីទាំងពីរផងដែរ ។

ហេតុដូច្នេះ ប្រសិនបើកិច្ចសន្យាបញ្ញើដោយការព្រមព្រៀងជាកិច្ចសន្យាដែលមិនយកកម្រៃ (មុធា) ភាគីទាំងពីរអាចដកការសន្យានោះពេលណាក៏បាន ។ ឧទាហរណ៍មួយ ដោយសារតែ A នឹងត្រូវទៅបរទេសដើម្បីធ្វើជំនួញនៅខែក្រោយ A បានជួលផ្ទះឱ្យអ្នកផ្សេង ហើយមិត្តភក្ដិរបស់ A គឺ B បានសន្យាថា ជួយថែរក្សាវត្ថុមានតម្លៃ (ឧទាហរណ៍ ចានស្លាបព្រាប្រាក់) ឱ្យ A ដោយមិនយកកម្រៃ ។ ការសន្យានេះបង្កើតឡើងនូវកិច្ចសន្យាបញ្ញើនាពេលអនាគត រវាង A និង B ។ ប៉ុន្តែ វាមិនសមរម្យទេ ក្នុងការគិតថា ប្រសិនបើ A ខកខានមិនបានប្រគល់នូវវត្ថុមានតម្លៃទាំងនោះទៅឱ្យ B ទេ ការខកខាននេះនឹងក្លាយទៅជាការបំពានកិច្ចសន្យានោះ ។ ប្រសិនបើ A លែងចាំបាច់ត្រូវទៅបរទេស នោះ A អាចដកការសន្យាវិញ និង មិនធ្វើបញ្ញើនោះបាន ។ ម្យ៉ាងទៀត ប្រសិនបើ B ផ្លាស់ប្ដូរចិត្តវិញ B អាចបដិសេធមិនរក្សាទុកនូវវត្ថុមានតម្លៃរបស់ A បាន ។ ក្នុងករណីណាមួយក្នុងចំណោមករណីទាំងពីរនេះកើតឡើង ភាគីម្ខាងទៀតនឹងអាចមានបញ្ហា ។ ជាពិសេស ក្នុងករណីក្រោយនេះ A ដែលនឹងត្រូវទៅបរទេស នឹងមានបញ្ហា ។ ប៉ុន្តែ មិនសមនឹងដាក់បន្ទុកធ្ងន់លើ B ទេ ពីព្រោះកិច្ចសន្យារវាង A និង B ជាកិច្ចសន្យាដោយមិនយកកម្រៃ (មុធា) ហើយប្រសិនបើ A អាចទាមទារឱ្យ B ទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច នោះបន្ទុករបស់ B ធ្ងន់ធ្ងរពេកហើយ ។ ចំពោះករណីនៃកិច្ចសន្យាប្រទានកម្មដែលជាកិច្ចសន្យាដោយមិនយកតម្លៃថ្នូរដែរនោះ ប្រសិនបើប្រទានកម្មដែលមិនត្រូវបានធ្វើជាលាយល័ក្ខណ៍អក្សរ មិនទាន់ត្រូវបានអនុវត្តទេ កិច្ចសន្យានេះអាចត្រូវបានលុបចោល ។ ហេតុដូច្នេះ ដើម្បីរក្សាឱ្យមានតុល្យភាព គួរបន្ថយបន្ទុកចេញពី B ។ ដោយពិចារណាទៅលើហេតុផលទាំងអស់ខាងលើនេះហើយ មាត្រានេះចែងថា ក្នុងករណីនៃបញ្ញើដោយការព្រមព្រៀងដែលមិនយកកម្រៃ ភាគីអាចដកការព្រមព្រៀងបាន រហូតដល់ពេលមានការប្រគល់វត្ថុដែលជាកម្មវត្ថុនៃបញ្ញើ ។

ក្នុងករណីនេះបញ្ញើដោយយកតម្លៃថ្នូរដែលឱ្យអ្នកផ្ញើបង់កម្រៃវិញ មានភាពសមរម្យក្នុងការផ្ដល់ឱ្យនូវអានុភាពខ្លាំងជាងអានុភាពនៃបញ្ញើដោយមិនយកកម្រៃ ។ ឧទាហរណ៍ ប្រសិនបើ A ចង់ផ្ញើទំនិញទៅ B ដែលជាអ្នកកាន់កាប់ឃ្លាំងចាប់ពីថ្ងៃទី ១ ខែក្រោយ ហើយអ្នកកាន់កាប់ឃ្លាំងបានយល់ព្រម អ្នកកាន់កាប់ឃ្លាំងត្រូវរៀបចំកន្លែងសម្រាប់ដាក់ទំនិញផ្ញើនៅថ្ងៃដែលបានសន្យា ដែលការណ៍នេះ តម្រូវឱ្យមានការរៀបចំ និង ការគ្រប់គ្រងឃ្លាំង (ឧទាហរណ៍ ការគ្រប់គ្រងផែនការប្រើប្រាស់ឃ្លាំងដោយកុំព្យូទ័រ) ។ ចំពោះអ្នកផ្ញើវិញ A នឹងធ្វើសកម្មភាពដោយផ្អែកលើការសន្និដ្ឋានថា អ្នកកាន់កាប់ឃ្លាំង នឹងធ្វើការថែរក្សាទុកទំនិញ ចាប់តាំងពីថ្ងៃ ដូចបានព្រៀងទុកតាមការសន្យា ដោយគ្មានការខកខាន ពីព្រោះកិច្ចសន្យាស្ដុកទំនិញជាកិច្ចសន្យាដោយយកកម្រៃ ។ ហេតុដូច្នេះ វាមានភាពសមរម្យក្នុងការលើកកម្ពស់អានុភាពនៃកិច្ចសន្យាបញ្ញើដោយយកតម្លៃថ្នូរ (វាក្យខណ្ឌទី ២ នៃមាត្រានេះ) ។

២. អានុភាពនៃកិច្ចសន្យាបញ្ញើដោយការព្រមព្រៀងដោយឱ្យបង់ថ្លៃ (វាក្យខណ្ឌទី ២ នៃមាត្រានេះ)

អានុភាពនៃ "ករណីយកិច្ចរក្សាទុកនូវវត្ថុ" របស់អ្នកទទួលបញ្ញើ (អ្នកកាន់កាប់ឃ្លាំង) គឺខ្លាំង ។ ប្រសិនបើអ្នកកាន់កាប់ឃ្លាំងបដិសេធមិនទទួលការប្រគល់វត្ថុបញ្ញើដោយគ្មានហេតុផល អ្នកកាន់កាប់ឃ្លាំងត្រូវទទួលខុសត្រូវក្នុងការសំណងនៃការខូចខាត ចំពោះអ្នកផ្ញើ ។ ប៉ុន្តែ ការបង្ខំឱ្យអនុវត្តកាតព្វកិច្ចដោយផ្ទាល់ មិនត្រូវបានអនុញ្ញាតទេ ។

ចំណែកឯ "ករណីយកិច្ចផ្ញើកម្មវត្ថុនៃបញ្ញើ" របស់អ្នកផ្ញើ មិនចាំបាច់ទទួលស្គាល់ឡើយ ។ ទោះបីជាត្រូវគិតពិចារណាទៅដល់ផលប្រយោជន៍របស់អ្នកកាន់កាប់ឃ្លាំងក៏ដោយ ក៏វាមិនសមហេតុផលដែរក្នុងការថែងថា ប្រសិនបើ A ដែលជាអ្នកផ្ញើខកខានមិនបានដាក់កម្មវត្ថុនៃបញ្ញើ B ដែលជាអ្នកកាន់កាប់ឃ្លាំងអាចទាមទារឱ្យអ្នកផ្ញើដាក់កម្មវត្ថុនៃបញ្ញើបាន ។

៣. ដោយសារតែមាត្រានេះមិនមែនជាបញ្ញត្តិដែលត្រូវអនុវត្តដាច់ខាតទេ ប្រសិនបើភាគីនៃកិច្ចសន្យាបានធ្វើការសន្យាពិសេសដែលមានខ្លឹមសារផ្សេងពីមាត្រានេះ ការសន្យាពិសេសនេះនឹងមានអាទិភាពលើមាត្រានេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៧២ នៃច្បាប់ស្តីពីកាតព្វកិច្ចរបស់ប្រទេសស្វីស (បញ្ញើ គឺជាកិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយការព្រមព្រៀង)

## មាត្រា ៦៧២.- កិច្ចសន្យាបញ្ញើដែលបានផ្ញើដោយអ្នកគ្មានកម្មសិទ្ធិ

ទោះបីជាអ្នកផ្ញើគ្មានកម្មសិទ្ធិលើវត្ថុផ្ញើក៏ដោយ ក៏កិច្ចសន្យាបញ្ញើនោះ ត្រូវបានបង្កើតអានុភាពដែរ ។ នៅក្នុងករណីនេះ ទោះបីជាមានពាក្យបណ្តឹងទាមទារឱ្យសងវត្ថុរបស់កម្មសិទ្ធិករ ចំពោះអ្នកទទួលបញ្ញើក៏ដោយ ក៏អ្នកទទួលបញ្ញើអាចសងវត្ថុបញ្ញើនោះទៅឱ្យអ្នកផ្ញើវិញបានដែរ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបណ្តឹងទាមទារឱ្យសងវត្ថុរបស់កម្មសិទ្ធិករ ត្រូវបានទទួលស្គាល់ ។

(កំណត់)

មាត្រានេះពាក់ព័ន្ធនឹងទំនាក់ទំនងគតិយុត្ត ក្នុងករណីនៃបញ្ញើនូវវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃទៀត ។ ដូចគ្នានឹងករណីដែលការលក់ទិញនូវវត្ថុរបស់អ្នកដទៃមានអានុភាព កិច្ចសន្យាបញ្ញើនៃវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃក៏មានអានុភាពដែរ ។ ប៉ុន្តែ ក្នុងករណីនៃការលក់ទិញនូវវត្ថុរបស់អ្នកដទៃ អ្នកទិញអាចទាមទាររំលាយកិច្ចសន្យា ឬទាមទារសំណងការខូចខាតពីអ្នកលក់ រីឯក្នុងករណីនៃបញ្ញើវត្ថុរបស់អ្នកដទៃវិញ គ្មានបញ្ហាអ្វីកើតឡើងពាក់ព័ន្ធនឹងការទាមទារឱ្យអ្នកផ្ញើទទួលខុសត្រូវដោយអ្នកទទួលបញ្ញើទេ ពីព្រោះអ្នកទទួលបញ្ញើ មិនទទួលរងការខូចខាតអ្វីពីបញ្ញើនៃកម្មសិទ្ធិអ្នកដទៃ ។

បញ្ហាសំខាន់ជាងនេះ មាននៅត្រង់ចំណុចថា អ្នកទទួលបញ្ញើគួរធ្វើដូចម្តេច នៅពេលដែលកម្មសិទ្ធិករទាមទារឱ្យប្រគល់វិញនូវវត្ថុបញ្ញើនោះ ។ ប្រសិនបើអ្នកទទួលបញ្ញើប្រគល់នូវវត្ថុបញ្ញើទៅកម្មសិទ្ធិករវិញ ដោយសារតែកម្មសិទ្ធិករ

ទាមទារឱ្យប្រគល់វិញនូវវត្ថុបញ្ញើ អ្នកទទួលបញ្ញើអាចនឹងបំពានលើកិច្ចសន្យាដែលបានធ្វើជាមួយអ្នកផ្ញើ (ប្រសិនបើក្រោយមក គេរកឃើញថា អ្នកដែលបានទាមទារឱ្យប្រគល់វិញមិនមែនជាកម្មសិទ្ធិករពិតប្រាកដ) ។ ម្យ៉ាងវិញទៀត ប្រសិនបើអ្នកទទួលបញ្ញើមិនធ្វើតាមការទាមទាររបស់កម្មសិទ្ធិករទេ អ្នកទទួលបញ្ញើនោះនឹងត្រូវទទួលខុសត្រូវក្នុងការការបំពានកម្មសិទ្ធិចំពោះកម្មសិទ្ធិករ ។ ដើម្បីដោះស្រាយទ្វេគ្រោះរបស់អ្នកទទួលបញ្ញើ មាត្រានេះត្រូវបានតាក់តែងឡើង ។ ទីមួយ ទោះបីជាកម្មសិទ្ធិករដាក់ពាក្យបណ្ដឹងទាមទារឱ្យសងវត្ថុក៏ដោយ ក៏អ្នកទទួលបញ្ញើមិនមានការទទួលខុសត្រូវចំពោះកម្មសិទ្ធិករទេ ប្រសិនបើអ្នកទទួលបញ្ញើសងវត្ថុបញ្ញើនោះឱ្យទៅអ្នកផ្ញើវិញ ។ ប៉ុន្តែ ប្រសិនបើសេចក្ដីសម្រេចរបស់តុលាការដែលសម្រេចថា អ្នកទាមទារនោះជាកម្មសិទ្ធិករ បានចូលជាស្ថាពរ អ្នកទទួលបញ្ញើគួរតែសងវត្ថុបញ្ញើទៅកម្មសិទ្ធិករវិញ ហេតុដូច្នេះ អ្នកទទួលបញ្ញើនោះនឹងត្រូវទទួលខុសត្រូវចំពោះកម្មសិទ្ធិករ ប្រសិនបើអ្នកទទួលបញ្ញើសងវត្ថុបញ្ញើទៅអ្នកផ្ញើវិញ ។ ក្នុងករណីដែលកម្មសិទ្ធិករទាមទារឱ្យអ្នកទទួលបញ្ញើប្រគល់មកខ្លួនវិញនូវវត្ថុបញ្ញើ នៅក្រោយពេលដែលកម្មសិទ្ធិករនោះឈ្នះក្នុងបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីកម្មសិទ្ធិ អ្នកទទួលបញ្ញើក៏ត្រូវសងនូវវត្ថុទៅកម្មសិទ្ធិករវិញដែរ ។ ទីពីរ មាត្រានេះមិនបានបញ្ជាក់ថា តើអ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវក្នុងការមិនអនុវត្តកាតព្វកិច្ច ចំពោះអ្នកផ្ញើដែរ ឬ យ៉ាងណានោះទេ ប្រសិនបើអ្នកទទួលបញ្ញើសងវត្ថុបញ្ញើទៅអ្នកទាមទារ ដោយអ្នកទទួលបញ្ញើគិតថាវាទំនងខ្លាំងណាស់ ដែលអ្នកទាមទារគឺជាកម្មសិទ្ធិករ តាមរយៈការវិនិច្ឆ័យ ដោយផ្អែកលើភស្តុតាងផ្សេងៗជាច្រើន ទោះបីជាសិទ្ធិលើកម្មសិទ្ធិរបស់អ្នកទាមទារមិនទាន់ត្រូវបានកំណត់ជាស្ថាពរដោយសេចក្ដីសម្រេចរបស់តុលាការក៏ដោយ ។ ចំពោះករណីនេះ អាចបកស្រាយថា អ្នកទទួលបញ្ញើមិនទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចឡើយ ប្រសិនបើអ្នកទាមទារគឺជាកម្មសិទ្ធិករពិតប្រាកដ ដោយសារតែអ្នកទទួលបញ្ញើមិនមានកំហុសដែលជាល័ក្ខខ័ណ្ឌនៃការមិនអនុវត្តកាតព្វកិច្ចឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៥០ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ៦៧៣.-** ករណីយកិច្ចរបស់អ្នកទទួលបញ្ញើ

១-អ្នកទទួលបញ្ញើ មានករណីយកិច្ចរក្សាទុកវត្ថុបញ្ញើ ដោយព្យាយាមប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-បើគ្មានការយល់ព្រមពីអ្នកផ្ញើទេ អ្នកទទួលបញ្ញើ មិនអាចប្រើវត្ថុបញ្ញើបានឡើយ ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះ បញ្ជាក់អំពីកម្រិតនៃករណីយកិច្ចរក្សាទុកវត្ថុបញ្ញើរបស់អ្នកទទួលបញ្ញើ ។ ក្រម

រដ្ឋប្បវេណីជប៉ុនកាត់បន្ថយនូវកម្រិតនៃករណីយកិច្ចប្រុងប្រយ័ត្នក្នុងករណីនៃបញ្ញើដោយមិនយកកម្រៃ ប៉ុន្តែ បញ្ញត្តិនេះទទួលរងនូវការរិះគន់ ។ បញ្ហានេះ មិនស៊ីសង្វាក់ជាមួយករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកគ្រប់គ្រង ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ក្នុងករណីនៃអាណត្តិដោយមិនយកកម្រៃ និង អាណត្តិព្យាបាលភាព (trust) ។ ហេតុដូច្នេះ មាត្រានេះចែងថា ជាគោលការណ៍ អ្នកទទួលបញ្ញើត្រូវតែទទួលនូវករណីយកិច្ចប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ក្នុងករណីនៃបញ្ញើដោយមិនយកកម្រៃ ។

កថាខណ្ឌទី ២ បញ្ជាក់ថា អ្នកទទួលបញ្ញើគ្មានសិទ្ធិអំណាចប្រើវត្ថុបញ្ញើ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៤៩ (ករណីយកិច្ចរក្សាទុក និង ករណីយកិច្ចប្រគល់) មាត្រា ១២៥១ (អ្នកទទួលបញ្ញើមិនមានសិទ្ធិប្រើ) និង មាត្រា ១២៥២ (ការអនុញ្ញាតឱ្យប្រើត្រូវបានសន្មត ក្នុងករណីបញ្ញើដោយមិនយកកម្រៃ និង មិនត្រូវបានសន្មត ក្នុងករណីបញ្ញើដោយឱ្យបង់កម្រៃ) នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ១៩២៧ (ករណីយកិច្ចប្រុងប្រយ័ត្នដូចគ្នានឹងការថែរក្សាទ្រព្យសម្បត្តិរបស់ខ្លួន) មាត្រា ១៩២៨ (ការបន្ថែមករណីយកិច្ចប្រុងប្រយ័ត្នក្នុងករណីខ្លះ បញ្ញើតាមការទាមទារពីអ្នកទទួលបញ្ញើ បញ្ញើដោយយកកម្រៃ បញ្ញើដែលមានគោលបំណងស្ទើតែសម្រាប់ផលប្រយោជន៍របស់អ្នកផ្ញើ ជាអាទិ៍) និង មាត្រា ១៩៣០ (ការហាមការប្រើប្រាស់វត្ថុបញ្ញើ) នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៦៥៩ (ករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកទទួលបញ្ញើដោយមិនយកកម្រៃ) និង មាត្រា ៦៥៨ (ការហាមការប្រើប្រាស់វត្ថុបញ្ញើ) នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៥៩៣ ដល់មាត្រា ៥៩៦ នៃក្រមពាណិជ្ជកម្មជប៉ុន ។

**មាត្រា ៦៧៤**.- ការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើ

១-នៅក្នុងករណីដែលបានធ្វើឱ្យបាត់បង់ ឬ បានធ្វើឱ្យបែកបាក់វត្ថុបញ្ញើនោះ អ្នកទទួលបញ្ញើ ត្រូវសងសំណងនៃការខូចខាតនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើអ្នកទទួលបញ្ញើបានបញ្ជាក់អំពីការគ្មានកំហុស ចំពោះការធ្វើឱ្យបាត់បង់ ឬ បែកបាក់នោះ ។

២-ក្នុងករណីដែលបញ្ញើត្រូវបានធ្វើឡើង តាមការទាមទាររបស់អ្នកទទួលបញ្ញើ ប្រសិនបើគ្មានការបញ្ជាក់ថាជាករណីប្រធានសក្តិទេ អ្នកទទួលបញ្ញើមិនអាចរួចផុតពីការទទួលខុសត្រូវ ចំពោះការធ្វើឱ្យបាត់បង់ ឬ បែកបាក់បានឡើយ ។

៣-នៅទីកន្លែងដូចជា សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន កន្លែងងូតទឹក សិល្បៈការផ្សេងទៀតដែលមានភ្ញៀវជួបជុំ ប្រសិនបើកម្មសិទ្ធិករនៃសិល្បៈការទាំងឡាយនោះ បានទទួលវត្ថុបញ្ញើពីភ្ញៀវ ប្រសិនបើគ្មានការបញ្ជាក់ថាជាករណីប្រធានសក្តិទេ

អ្នកទទួលបញ្ញើមិនអាចរួចផុតពីការទទួលខុសត្រូវចំពោះការធ្វើឱ្យបាត់បង់ ឬ បែកបាក់បានឡើយ ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើ ។ ដោយសារមាត្រា ៦៧៣ ចែងអំពីករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកទទួលបញ្ញើក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត កថាខណ្ឌទី ១ ចែងអំពីការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើ ក្នុងករណីដែលអ្នកទទួលបញ្ញើនោះធ្វើឱ្យខូចខាតដល់វត្ថុបញ្ញើ ដោយការបំពានករណីយកិច្ចរបស់ខ្លួន ។

ការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើក្នុងការសងសំណងការខូចខាត គឺជាការទទួលខុសដោយមានកំហុស ប៉ុន្តែអ្នកទាមទារសំណងការខូចខាត មិនទទួលបន្ទុកក្នុងការបញ្ជាក់អំពីកំហុសនោះទេ ។ នេះជាការអនុវត្តនូវគោលការណ៍ទូទៅនៃការសងសំណងនៃការខូចខាតដោយយកការមិនអនុវត្តកាតព្វកិច្ចមកធ្វើជាមូលហេតុ (មាត្រា ៣៩៨) ។ម្យ៉ាងទៀត ការបាត់បង់រួមមានទាំងចោរកម្ម និង ការបាត់ ។

កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ ចែងអំពីករណីលើកលែងមួយចំនួន ។

កថាខណ្ឌទី ២ ចែងអំពីការបន្ថែមនូវការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើ ក្នុងករណីដែលបញ្ញើមិនត្រូវបានធ្វើឡើងដោយឆន្ទៈសេរីរបស់អ្នកផ្ញើ ប៉ុន្តែ ទៅតាមការទាមទាររបស់អ្នកទទួលបញ្ញើក្នុងស្ថានភាពជាក់លាក់ណាមួយ ។ ឧទាហរណ៍ នៅពេលអ្នកណាម្នាក់ចូលទៅក្នុងបណ្ណាល័យ ឬ សារមន្ទីរ គាត់ត្រូវបានទាមទារឱ្យផ្ញើអីវ៉ាន់របស់គាត់នៅបណ្ណាល័យ ឬ សារមន្ទីរនោះ ។ ការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើ គឺជាការទទួលខុសត្រូវដោយគ្មានកំហុស ។ គោលការណ៍នេះ គឺផ្អែកលើមាត្រា ១៩២៨ នៃក្រមរដ្ឋប្បវេណីបារាំង និង ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។

កថាខណ្ឌទី ៣ ចែងថា សណ្ឋាគារ ភោជនីយដ្ឋាន និង សិប្បកម្មៈការផ្សេងទៀតដែលមានភ្ញៀវជួបជុំ ត្រូវទទួលខុសត្រូវដោយគ្មានកំហុស (" receptum" liability) ។ កថាខណ្ឌទី ២ ជាន់គ្នាជាមួយផ្នែកខ្លះ នៃកថាខណ្ឌទី ៣ ប៉ុន្តែតាមកថាខណ្ឌទី ៣ អ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវដោយគ្មានកំហុសផងដែរ ក្នុងករណីដែលអ្នកផ្ញើបានផ្ញើវត្ថុដោយស្ម័គ្រចិត្ត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៥៩៤ (ការទទួលខុសត្រូវដោយគ្មានកំហុសរបស់សណ្ឋាគារ ភោជនីយដ្ឋាន និង កន្លែងស្រដៀងគ្នាផ្សេងទៀត) នៃក្រមពាណិជ្ជកម្មជប៉ុន, មាត្រា ១៩២៨ (ការបន្ថែមករណីយកិច្ចរក្សាទុក ក្នុងករណីនៃបញ្ញើតាមការទាមទាររបស់អ្នកទទួលបញ្ញើ និង បញ្ញើដោយយកកម្រៃ ជាអាទិ៍) និង មាត្រា ១៩២៩ (ការរួចផុតពីការទទួលខុសត្រូវ ក្នុងករណីប្រធានសក្តិ និង ការទទួលខុសត្រូវក្នុងអំឡុងពេលយឺតយ៉ាវក្នុងការអនុវត្តករណីយកិច្ចសងទៅវិញ ទោះបីជាករណីប្រធានសក្តិ) នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១២៥៣ ដល់មាត្រា ១២៥៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ២២៨៩ នៃក្រមរដ្ឋប្បវេណីកេបិច ។

**មាត្រា ៦៧៥**.- ការបន្ថយការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើដោយមិនយកកម្រៃ

នៅក្នុងបញ្ញើដោយមិនយកកម្រៃ តុលាការអាចបន្ថយការទទួលខុសត្រូវសងសំណង នៃការខូចខាតរបស់អ្នកផ្ញើ ដោយពិចារណាទៅលើស្ថានភាពនៃទ្រព្យសម្បត្តិភាគីទាំងសង ខាង និង កាលៈទេសៈផ្សេងៗទៀតបាន ។

(កំណត់)

មាត្រានេះសម្រាលការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើដោយមិនយកកម្រៃ ។ អ្នកទទួលបញ្ញើដោយមិនយកកម្រៃមានករណីយកិច្ចប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិតផងដែរ (មាត្រា ៦៧៣) ប៉ុន្តែ ដោយសារមានករណីខ្លះដែលការទទួលខុសត្រូវមានទម្ងន់ធ្ងន់ធ្ងរតាមស្ថានភាពមួយចំនួន មាត្រានេះទទួលស្គាល់សិទ្ធិអំណាចរបស់តុលាការក្នុងការបន្ថយការទទួលខុសត្រូវដោយឆន្ទានុសិទ្ធិ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៥៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២២៩០ នៃក្រមរដ្ឋប្បវេណីកេបិច (បញ្ញើដោយមិនយកកម្រៃ ករណីដែលមិនបានរាយការណ៍អំពីវត្ថុដែលមានតម្លៃ)

**មាត្រា ៦៧៦**.- ការសម្រាលការទទួលខុសត្រូវក្នុងករណីដែលមិនបានរាយការណ៍អំពីវត្ថុដែលមានតម្លៃខ្ពស់

នៅក្នុងករណីដែលអ្នកផ្ញើបានផ្ញើប្រាក់ ឧបករណ៍អាចជួញដូរបាន និង វត្ថុដែលមានតម្លៃខ្ពស់ផ្សេងទៀត ប្រសិនបើអ្នកផ្ញើ មិនបានរាយការណ៍អំពីប្រភេទ និង តម្លៃនោះទៅឱ្យអ្នកទទួលបញ្ញើទេ តុលាការអាចបន្ថយការទទួលខុសត្រូវសងសំណងនៃការខូចខាតរបស់អ្នកទទួលបញ្ញើបាន ។

(កំណត់)

មាត្រានេះចែងពីការកាត់បន្ថយនូវការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើ ក្នុងករណីដែលអ្នកផ្ញើខកខានមិនបានរាយការណ៍ទៅអ្នកទទួលបញ្ញើថា វត្ថុផ្ញើជាវត្ថុមានតម្លៃ ។

មាត្រា ៥៩៥ នៃក្រមពាណិជ្ជកម្មជប៉ុនចែងថា ប្រសិនបើអ្នកផ្ញើមិនបានធ្វើប្រតិវេទន៍ជូនទៅអ្នកទទួលបញ្ញើទេ អ្នកទទួលបញ្ញើមិនទទួលខុសត្រូវឡើយ ។ ប៉ុន្តែ ប្រសិនបើអ្នកទទួលបញ្ញើមានកំហុសធ្ងន់ធ្ងរ វាមិនសមរម្យទេដែលអ្នកទទួលបញ្ញើមិនទទួលខុសត្រូវអ្វីសោះនោះ ហើយទោះបីជាកំហុសរបស់អ្នកទទួលបញ្ញើនោះតិចតួចក៏ដោយ ក៏វាមិនសមដែរក្នុងការបដិសេធចោលទាំងស្រុងនូវការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើដោយស្វ័យប្រវត្តិ ។ ហេតុដូច្នេះ មាត្រានេះ

កម្រិតអានុភាពនៃការខកខានរាយការណ៍អំពីវត្ថុមានតម្លៃត្រឹមការ "បន្ថយ" ការទទួលខុសត្រូវ ។ ប៉ុន្តែ មាត្រានេះមិនបដិសេធនូវការលើកលែងឱ្យរួចពីការទទួលខុសត្រូវទាំងស្រុងដែលអាចធ្វើទៅបានអាស្រ័យទៅតាមស្ថានភាពនោះទេ ។

ប្រសិនបើវត្ថុបញ្ញើជាវត្ថុដែលមានតម្លៃ អ្នកទទួលបញ្ញើនឹងធ្វើការរក្សាទុកដោយប្រុងប្រយ័ត្នពិសេស ដើម្បីកុំឱ្យមានការខូចខាត ។ ផ្ទុយទៅវិញ ប្រសិនបើអ្នកទទួលបញ្ញើមិនបានដឹងថា វត្ថុបញ្ញើនោះជាវត្ថុដែលមានតម្លៃទេ អ្នកទទួលបញ្ញើនឹងធ្វើការប្រុងប្រយ័ត្នធម្មតាតែប៉ុណ្ណោះ ។ ប៉ុន្តែ វាជារឿងអកុសលចំពោះទទួលបញ្ញើហើយនៅពេលដែលខ្លួនទទួលនូវការទាមទារសំណងការខូចខាតដែលមានទំហំធំ នៅក្រោយពេលដែលការខូចខាតបានកើតឡើងហើយនោះ ។

លើសពីនេះទៅទៀត ដោយសារតែការរក្សាទុកនូវវត្ថុដែលមានតម្លៃ ទាមទារឱ្យមានការចំណាយច្រើនសន្ធឹកសន្ធាប់ដែរនោះ អ្នកទទួលបញ្ញើទាមទារកម្រៃសម្រាប់ការរក្សាទុកនោះលើសពីធម្មតា ។ ប៉ុន្តែ ប្រសិនបើអ្នកទទួលបញ្ញើមិនបានដឹងថា វត្ថុនោះមានតម្លៃខ្ពស់ អ្នកទទួលបញ្ញើមិនអាចធ្វើដូច្នោះបានឡើយ ។ ដោយមូលហេតុនេះ គោលគំនិតនៃមាត្រានេះ គឺឱ្យអ្នកផ្ញើរាយការណ៍ប្រាប់អ្នកទទួលបញ្ញើថា វត្ថុនោះមានតម្លៃ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ២២៩០ នៃក្រមរដ្ឋប្បវេណីកបេិច, មាត្រា ៥៩៥ នៃក្រមពាណិជ្ជកម្មជប៉ុន

## មាត្រា ៦៧៧.- ករណីយកិច្ចនៃការរក្សាទុកដោយខ្លួនឯង

១-បើគ្មានការយល់ព្រមពីអ្នកផ្ញើទេ អ្នកទទួលបញ្ញើពុំអាចឱ្យតតិយជនរក្សាទុកវត្ថុបញ្ញើបានឡើយ ។

២-ក្នុងករណីដែលអ្នកទទួលបញ្ញើអាចឱ្យតតិយជនរក្សាទុកវត្ថុបញ្ញើបាន អ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវចំពោះការជ្រើសតាំង និង ត្រួតពិនិត្យអ្នកទទួលបញ្ញើដែលត្រូវបានឱ្យរក្សាទុកបន្ត ។

(កំណត់)

១. កថាខណ្ឌទី ១ នៃមាត្រានេះចែងអំពីករណីកិច្ចរបស់អ្នកទទួលបញ្ញើក្នុងការរក្សាទុកវត្ថុបញ្ញើដោយខ្លួនឯងផ្ទាល់ ។ ជាគោលការណ៍ អ្នកទទួលបញ្ញើពុំអាចឱ្យតតិយជនរក្សាទុកវត្ថុបញ្ញើបន្តបានឡើយ ។

ទោះបីជាអ្នកទទួលបញ្ញើគ្រាន់តែប្រតិបត្តិការរក្សាទុកនូវវត្ថុបញ្ញើប៉ុណ្ណោះក៏ដោយ ក៏អ្នកផ្ញើបានពិចារណាអំពីជំនាញ និង ល័ក្ខខ័ណ្ឌដទៃផ្សេងទៀតរបស់អ្នកទទួលបញ្ញើ នៅពេលសម្រេចផ្ញើវត្ថុនោះដែរ ហេតុដូច្នេះ វាមិនសមរម្យទេដែលអ្នកទទួលបញ្ញើនោះផ្ទុកផ្តាក់ផ្ញើបន្តនូវវត្ថុបញ្ញើទៅតតិយជនដោយសេរី ។ ប៉ុន្តែ ក្នុងករណីនៃបញ្ញើពាណិជ្ជកម្ម ជាញឹកញាប់ភាគីនៃកិច្ចសន្យាមានឆន្ទៈអនុញ្ញាតឱ្យមានបញ្ញើបន្ត ។ ក្នុងករណីនេះ ប្រការដែលអនុញ្ញាតឱ្យតតិយជនរក្សាទុកបន្តត្រូវតែសរសេរបញ្ចូលក្នុងកិច្ចសន្យាបញ្ញើ ។

២. កថាខណ្ឌទី ២ បញ្ជាក់ឱ្យបានច្បាស់លាស់ថា អ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវចំពោះការជ្រើសតាំង និង ត្រួតពិនិត្យអ្នកទទួលបញ្ញើបន្ត ។ ទោះបីជាកិច្ចសន្យាបញ្ញើអនុញ្ញាតឱ្យមានបញ្ញើបន្តក៏ដោយ ក៏អ្នកទទួលបញ្ញើត្រូវតែជ្រើសតាំងនូវអ្នកទទួលបញ្ញើបន្តដែលសមរម្យ នៅពេលដែលខ្លួនធ្វើបញ្ញើបន្តដែរ ។ ប្រសិនបើជ្រើសតាំងនូវអ្នកទទួលបញ្ញើបន្តមិនសមរម្យ ហើយវត្ថុបញ្ញើត្រូវបានខូចខាត ឬ បាត់បង់ដោយសារកំហុសរបស់អ្នកទទួលបញ្ញើបន្ត អ្នកទទួលបញ្ញើជាអ្នកត្រូវទទួលខុសត្រូវ ។ បន្ថែមពីលើនេះ ទោះបីជាអ្នកទទួលបញ្ញើបានជ្រើសតាំងអ្នកទទួលបញ្ញើបន្តដែលសមរម្យក៏ដោយ ក៏អ្នកទទួលបញ្ញើត្រូវតែទទួលខុសត្រូវចំពោះការត្រួតពិនិត្យមិនបានដិតដល់ដែរ ប្រសិនបើអ្នកទទួលបញ្ញើយល់ឃើញថា មធ្យោបាយថែរក្សាវត្ថុបញ្ញើរបស់អ្នកទទួលបញ្ញើបន្តនោះមិនត្រឹមត្រូវ ប៉ុន្តែ មិនបានអើពើចំពោះបញ្ហានេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៥៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៦៧៨.- បញ្ញើបន្ត

១-បញ្ញត្តិនៃជំពូកទី ១០ (បញ្ញើ) នេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះទំនាក់ទំនងរវាងអ្នកទទួលបញ្ញើ និង អ្នកទទួលបញ្ញើបន្ត ។

២-អ្នកទទួលបញ្ញើបន្ត មានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងអ្នកទទួលបញ្ញើដែរ ចំពោះអ្នកផ្ញើ ។

៣-ក្នុងករណីដែលបានសងវត្ថុបញ្ញើឱ្យទៅអ្នកផ្ញើហើយ អ្នកទទួលបញ្ញើបន្ត ត្រូវរួចផុតពីករណីយកិច្ចសង ចំពោះអ្នកទទួលបញ្ញើ ។

(កំណត់)

មាត្រានេះពាក់ព័ន្ធនឹងទំនាក់ទំនងគតិយុត្តនៅក្នុងករណីនៃបញ្ញើបន្ត ។

កថាខណ្ឌទី ១ បញ្ជាក់ថា បញ្ញត្តិដែលទាក់ទងនឹងបញ្ញើ ត្រូវយកមកអនុវត្តចំពោះទំនាក់ទំនងគតិយុត្តរវាងអ្នកទទួលបញ្ញើ និង អ្នកទទួលបញ្ញើបន្ត ។ ទោះបីជាការពិតគឺអញ្ចឹងមែនហើយក៏ដោយ យើងបញ្ចូលមាត្រានេះ ដើម្បីកុំឱ្យមានការសង្ស័យ ។

កថាខណ្ឌទី ២ បញ្ជាក់អំពីទំនាក់ទំនងរវាងអ្នកផ្ញើ និង អ្នកទទួលបញ្ញើបន្ត ។ ទោះបីជាមិនមានទំនាក់ទំនងកិច្ចសន្យារវាងអ្នកទាំងពីរក៏ដោយ ក៏វាមិនមានភាពសមរម្យដែរប្រសិនបើនិយាយថា ពួកគេគ្មានទំនាក់ទំនងគតិយុត្តនឹងគ្នានោះ ។ ឧទាហរណ៍ បន្ទាប់ពីផុតអំឡុងពេលសម្រាប់បញ្ញើហើយ អ្នកផ្ញើគួរតែអាចទាមទារដោយផ្ទាល់ទៅអ្នកទទួលបញ្ញើបន្ត ឱ្យសងវិញនូវវត្ថុបញ្ញើ ។ ប្រសិនបើអ្នកផ្ញើអាចទាមទារឱ្យសងវត្ថុវិញ តែពីអ្នកទទួលបញ្ញើប៉ុណ្ណោះ ការអនុវត្តបែបនេះនឹងមិនគ្រាន់តែប៉ះពាល់ដល់ផលប្រយោជន៍របស់អ្នកផ្ញើប៉ុណ្ណោះទេ ប៉ុន្តែ ជាវិធានការដែលប្រយោល

ពេកផងដែរ ។ លើសពីនេះទៅទៀត ប្រសិនបើអ្នកទទួលបញ្ញើបន្តមានសិទ្ធិទាមទារកម្រៃសម្រាប់ការផ្ញើ វាត្រឹមត្រូវហើយដែលអ្នកទទួលបញ្ញើបន្តអាចទាមទារនូវកម្រៃនេះពីអ្នកផ្ញើ ដោយសារតែទំនាក់ទំនងគតិយុត្តរវាងអ្នកផ្ញើ និង អ្នកទទួលបញ្ញើបន្តត្រូវបានទទួលស្គាល់ ។ ចំពោះចំនួននៃកម្រៃប៉ុន្មាន អាស្រ័យទៅលើល័ក្ខខ័ណ្ឌផ្សេងៗ ដូចជា តើអ្នកផ្ញើ និង អ្នកទទួលបញ្ញើមានធ្វើកិច្ចព្រមព្រៀងចំពោះកម្រៃដែរ ឬទេ និង តើអ្នកទទួលបញ្ញើ និង អ្នកទទួលបញ្ញើបន្ត មានធ្វើកិច្ចព្រមព្រៀងដែលពាក់ព័ន្ធជាមួយនឹងកម្រៃដែរ ឬទេ ជាអាទិ៍ ។ ការពិចារណាជាមូលដ្ឋានមានដូចតទៅ : អ្នកទទួលបញ្ញើបន្តអាចទាមទារកម្រៃពីអ្នកផ្ញើរហូតដល់ចំនួនអតិបរមា នៃចំនួនដែលបានព្រមព្រៀងគ្នារវាងអ្នកទទួលបញ្ញើ និង អ្នកទទួលបញ្ញើបន្ត (ឧបមាថា ១០០) និង ក្នុងទំហំនៃចំនួនកម្រៃដែលអ្នកផ្ញើ និង អ្នកទទួលបញ្ញើបានព្រមព្រៀង (ឧបមាថា ៨០) (ក្នុងករណីនេះ អ្នកទទួលបញ្ញើបន្តអាចទាមទារបាន ៨០) ។

កថាខណ្ឌទី ៣ បញ្ជាក់ជាពិសេសអំពីករណីយកិច្ចសងវត្ថុបញ្ញើ ។ អ្នកទទួលបញ្ញើបន្តមានករណីយកិច្ចសងវត្ថុទៅឱ្យអ្នកទទួលបញ្ញើវិញតាមកិច្ចសន្យាបញ្ញើបន្តដែលបានចុះជាមួយអ្នកទទួលបញ្ញើ ។ ប៉ុន្តែ ម្យ៉ាងវិញទៀត អ្នកទទួលបញ្ញើបន្ត មានករណីយកិច្ចសងវត្ថុឱ្យអ្នកផ្ញើវិញ ដោយយោងតាមកថាខណ្ឌទី ២ នៃមាត្រានេះ ។ ទំនាក់ទំនងរវាងករណីយកិច្ចទាំងពីរនេះគឺជាបញ្ហា ។ កថាខណ្ឌទី ៣ បានបញ្ជាក់យ៉ាងច្បាស់ថា ប្រសិនបើអ្នកទទួលបញ្ញើបន្តសងវត្ថុបញ្ញើទៅអ្នកផ្ញើវិញ អ្នកទទួលបញ្ញើបន្តមិនអាចអនុវត្តករណីយកិច្ចតាមកិច្ចសន្យាបញ្ញើបន្តជាមួយអ្នកទទួលបញ្ញើបានទៀត ប៉ុន្តែ អ្នកទទួលបញ្ញើបន្តនឹងមិនទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចទេ ។ មាត្រានេះមិនបានបញ្ញត្តអំពីករណីយកិច្ចសងដែលអ្នកទទួលបញ្ញើបន្តមានចំពោះអ្នកផ្ញើ ក្នុងករណីដែលអ្នកទទួលបញ្ញើបន្តបានសងវត្ថុបញ្ញើទៅអ្នកទទួលបញ្ញើទេ ប៉ុន្តែ ប្រសិនបើអ្នកទូលបញ្ញើបន្តនោះបានសងវត្ថុបញ្ញើ ទៅអ្នកទទួលបញ្ញើរួចហើយ អ្នកផ្ញើលែងអាចទាមទារឱ្យអ្នកទទួលបញ្ញើបន្តសងវត្ថុបញ្ញើមកខ្លួនវិញទៀតហើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១០៥ និង កថាខណ្ឌទី ២ មាត្រា ១០៧ នៃក្រមរដ្ឋប្បវេណីជប៉ុន ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ ដោយយោងតាម កថាខណ្ឌទី ២ មាត្រា ៦៥៨ នៃក្រមដដែលនោះ

## មាត្រា ៦៧៩.- ករណីយកិច្ចជូនដំណឹងរបស់អ្នកទទួលបញ្ញើ

ប្រសិនបើតតិយជនដែលអះអាងអំពីសិទ្ធិចំពោះវត្ថុបញ្ញើ បានដាក់ពាក្យបណ្តឹងចំពោះអ្នកទទួលបញ្ញើ ឬ វត្ថុបញ្ញើ ត្រូវបានរឹបអូស អ្នកទទួលបញ្ញើត្រូវជូនដំណឹងអំពីហេតុនោះ ទៅឱ្យអ្នកផ្ញើ ដោយគ្មានការយឺតយ៉ាវ ។

(កំណត់)

មាត្រានេះផ្តល់ឱ្យអ្នកផ្ញើនូវឱកាសការពារសិទ្ធិរបស់ខ្លួន តាមរយៈការជូនដំណឹងទៅអ្នកផ្ញើនោះ ក្នុងករណីដែល

តតិយជនអនុវត្តសិទ្ធិ ដោយអះអាងថា ខ្លួនមានកម្មសិទ្ធិលើវត្ថុបញ្ញើនោះ ។ ប្រសិនបើអ្នកផ្ញើទទួលដំណឹងថា តតិយជនបានអនុវត្តសិទ្ធិ អ្នកផ្ញើអាចប្រមូលភស្តុតាងដែលបញ្ជាក់ថា កម្មសិទ្ធិរបស់អ្នកផ្ញើមានសុពលភាព ហើយផ្តល់ភស្តុតាងនោះទៅអ្នកទទួលបញ្ញើ ដើម្បីឱ្យអ្នកទទួលបញ្ញើអាចធ្វើសកម្មភាពបណ្តឹង ជាអាទិ៍ ដើម្បីផលប្រយោជន៍ដល់អ្នកទទួលបញ្ញើ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៦០ និង មាត្រា ៦១៥ (ករណីយកិច្ចជូនដំណឹងចំពោះករណីភតិសន្យា) នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៦៨០.- ការទាមទារឱ្យសង ពីអ្នកផ្ញើ

ទោះបីជាភាគីបានកំណត់អំឡុងពេលនៃការសងវត្ថុបញ្ញើក៏ដោយ អ្នកផ្ញើអាចទាមទារឱ្យសងវត្ថុបញ្ញើនោះ នៅពេលណាក៏បាន ។

(កំណត់)

មាត្រានេះបញ្ជាក់ពីពេលវេលាដែលអ្នកផ្ញើអាចទាមទារឱ្យសងវិញនូវវត្ថុបញ្ញើ ។ ដោយសារបញ្ញើត្រូវបានធ្វើឡើងដើម្បីផលប្រយោជន៍របស់អ្នកផ្ញើ អ្នកទទួលបញ្ញើមិនមានផលប្រយោជន៍ផ្ទាល់ខ្លួនអ្វីក្នុងការបន្តបញ្ញើទេ លើកលែងតែកម្រៃ ។ ហេតុដូច្នេះ ទោះបីជាកិច្ចសន្យាបញ្ញើមានកំណត់អំឡុងពេលក៏ដោយ ក៏អ្នកផ្ញើអាចទាមទារឱ្យសងវិញ នៅពេលណាក៏បាន ។ គំនិតនេះត្រូវបានទទួលស្គាល់នៅក្នុងច្បាប់នៃប្រទេសផ្សេងៗជាច្រើន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៦២ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ១៩៤៤ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៦៨១.- ការសងពីអ្នកទទួលបញ្ញើ

១-ប្រសិនបើភាគីពុំបានកំណត់អំឡុងពេលនៃការសងវត្ថុបញ្ញើទេ អ្នកទទួលបញ្ញើអាចសងវត្ថុបញ្ញើនោះ នៅពេលណាក៏បាន ។

២-ប្រសិនបើមានកំណត់អំឡុងពេលដែលត្រូវសង បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកទទួលបញ្ញើមិនអាចសងវត្ថុបញ្ញើ នៅមុនពេលកំណត់បានឡើយ ។

(កំណត់)

មាត្រានេះចែងអំពីវិធាននានា ដែលទាក់ទងនឹងការសងនូវវត្ថុបញ្ញើដោយអ្នកទទួលបញ្ញើ ។

នៅក្នុងកិច្ចសន្យាបញ្ញើ ជាទូទៅ ពេលកំណត់ត្រូវសងត្រូវបានកំណត់ដើម្បីប្រយោជន៍របស់អ្នកផ្ញើ ។ មានន័យថា អ្នកផ្ញើរំពឹងថា អ្នកទទួលបញ្ញើនឹងរក្សាទុកវត្ថុរហូតដល់ពេលត្រូវសង ។ ដើម្បីការពារនូវការរំពឹងទុកនោះ កថាខណ្ឌទី ២

ចែងថា នៅពេលមានការកំណត់អំពីពេលត្រូវសងវត្ថុវិញ ជាគោលការណ៍ អ្នកទទួលបញ្ញើមិនអាចសងវត្ថុបញ្ញើ នៅមុនពេលកំណត់បានទេ ។ ប៉ុន្តែ អ្នកទទួលបញ្ញើអាចសងវត្ថុបញ្ញើមុនពេលកំណត់បាន ប្រសិនបើមានមូលហេតុដែលមិនអាចជៀសវាងបាន ដូចជាការរក្សាទុក មិនអាចធ្វើទៅបាន ដោយសារការខូចខាតសម្ភារៈសម្រាប់ស្តុកនៅកន្លែងផ្ញើ ជាដើម ។

ប្រសិនបើពេលសម្រាប់សងមិនត្រូវបានកំណត់ទេ វាមិនច្បាស់ទេថា អ្នកផ្ញើចង់ឱ្យអ្នកទទួលបញ្ញើរក្សាទុកវត្ថុបញ្ញើរហូតដល់ពេលណានោះទេ ។ ដូច្នេះ ផលប្រយោជន៍របស់អ្នកផ្ញើនឹងមិនត្រូវបានធ្វើឱ្យខូចខាតច្រើនទេ ប្រសិនអ្នកទទួលបញ្ញើអាចសងវត្ថុនៅពេលណាក៏បាន (កថាខណ្ឌទី ១) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៦៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៦៨២.- អត្ថន័យនៃករណីយកិច្ចសង

១-អ្នកទទួលបញ្ញើ មានករណីយកិច្ចសងវត្ថុដដែល ដែលបានទទួលនៅពេលផ្ញើ ។

២-នៅក្នុងករណីដែលអ្នកទទួលបញ្ញើ ពុំទទួលខុសត្រូវចំពោះការធ្វើឱ្យបាត់បង់ ឬ បែកបាក់វត្ថុបញ្ញើទេ ប្រសិនបើអ្នកទទួលបញ្ញើបានទទួលប្រាក់ធានារ៉ាប់រង ឬ វត្ថុផ្សេងទៀត ជំនួសវត្ថុបញ្ញើដែលត្រូវបានធ្វើឱ្យបាត់បង់ ឬ បែកបាក់នោះ អ្នកទទួលបញ្ញើមានករណីយកិច្ចត្រូវសងវត្ថុដែលបានធ្វើឧបាទេសកម្មនោះ ឱ្យទៅអ្នកផ្ញើវិញ ។

(កំណត់)

មាត្រានេះចែងអំពីអ្វីដែលអ្នកទទួលបញ្ញើត្រូវសងនៅពេលដែលអ្នកទទួលបញ្ញើនោះសងវត្ថុផ្ញើទៅវិញ ។

ក្នុងកិច្ចសន្យាបញ្ញើធម្មតា អ្នកទទួលបញ្ញើត្រូវសងនូវវត្ថុដដែល ដូចដែលបានទទួលនៅពេលទទួលបញ្ញើ លើកលែងតែក្នុងករណីនៃបញ្ញើបរិភោគ ដែលអ្នកទទួលបញ្ញើអាចបរិភោគវត្ថុនោះបាន (មាត្រា ៦៩០) ។

កថាខណ្ឌទី ២ បញ្ញត្តអំពីករណីដែលវត្ថុបញ្ញើត្រូវបានធ្វើឱ្យបាត់បង់ ឬ បែកបាក់ ។ ប្រសិនបើវត្ថុនោះត្រូវបានធ្វើឱ្យបាត់បង់ ឬ បែកបាក់ បណ្តាលមកពីកំហុសរបស់អ្នកទទួលបញ្ញើ អ្នកទទួលបញ្ញើនោះ ត្រូវទទួលខុសត្រូវក្នុងការសងនូវសំណងនៃការខូចខាតទៅឱ្យអ្នកផ្ញើ ។ ដោយសារបញ្ហានេះអាចត្រូវបានចេញពីគោលការណ៍ទូទៅទាក់ទងទៅនឹងការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច មាត្រានេះមិនបានចែងអំពីចំណុចនេះឡើយ ។

ប្រសិនបើអ្នកទទួលបញ្ញើគ្មានកំហុសចំពោះការបាត់បង់ ឬ ការបែកបាក់វត្ថុបញ្ញើទេ អ្នកទទួលបញ្ញើអាចសងទៅវិញនូវវត្ថុតាមភាពជាក់ស្តែង (ប្រសិនបើវត្ថុត្រូវបានធ្វើឱ្យខូចខាត អ្នកទទួលបញ្ញើអាចសងវត្ថុដែលខូចខាតនោះ) ។ ប៉ុន្តែ ប្រសិនបើអ្នកទទួលបញ្ញើបានទទួលនូវវត្ថុជំនួសវត្ថុដែលបាត់បង់ ឬ បែកបាក់ អ្នកទទួលបញ្ញើត្រូវតែប្រគល់នូវវត្ថុជំនួសនោះទៅឱ្យអ្នកផ្ញើ ។ ឧទាហរណ៍ ប្រសិនបើអ្នកទទួលបញ្ញើបានទទួលប្រាក់ធានារ៉ាប់រង អ្នកទទួលបញ្ញើត្រូវប្រគល់

ប្រាក់ធានារ៉ាប់រងនោះឱ្យទៅអ្នកផ្ញើ ។ បើនិយាយឱ្យតឹងរ៉ឹងទៅ ប្រសិនបើអ្នកទទួលបញ្ញើមានការធានារ៉ាប់រងលើការទទួលខុសត្រូវ ក្នុងករណីដែលអ្នកទទួលបញ្ញើមិនត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាត ប្រាក់ធានារ៉ាប់រងមិនត្រូវបានបង់ទៅអ្នកទទួលបញ្ញើទេ ។ ក្នុងករណីនៃការធានារ៉ាប់រងចំពោះការខូចខាត ដោយសារកម្មសិទ្ធិករគួរតែបង្កើតកិច្ចសន្យាធានារ៉ាប់រង ជាទូទៅ គ្មានប្រាក់ធានារ៉ាប់រងណាមួយនឹងត្រូវបានបង់ទៅឱ្យអ្នកទទួលបញ្ញើទេ ។ ប៉ុន្តែដោយសារអាចមានករណីដែលអ្នកទទួលបញ្ញើដែលមិនមានកម្មសិទ្ធិ បង្កើតកិច្ចសន្យាធានារ៉ាប់រងយ៉ាងទូលំទូលាយលើហានិភ័យទូទៅ ប្រសិនបើអ្នកទទួលបញ្ញើបានបង្កើតកិច្ចសន្យាបែបនេះ អ្នកទទួលបញ្ញើអាចទទួលប្រាក់ធានារ៉ាប់រង តាមខ្លឹមសារនៃកិច្ចសន្យាធានារ៉ាប់រងនោះបាន ។ ក្នុងករណីនេះ អ្នកទទួលបញ្ញើត្រូវប្រគល់ប្រាក់ធានារ៉ាប់រងនោះទៅអ្នកផ្ញើ ។ ប្រសិនបើវត្ថុបញ្ញើត្រូវបានធ្វើឱ្យខូចខាតបណ្តាលមកពីអំពើអនីត្យានុកូលរបស់តតិយជន សិទ្ធិទាមទារសំណងការខូចខាតគឺមិនមែនជារបស់អ្នកទទួលបញ្ញើទេ ប៉ុន្តែ ជារបស់ម្ចាស់វត្ថុបញ្ញើ ។ ដូច្នេះ អ្នកទទួលបញ្ញើមិនត្រូវទទួលសំណងការខូចខាតឡើយ ។ ប៉ុន្តែ មានករណីខ្លះដែលតតិយជននោះមិនដឹងថា កម្មសិទ្ធិករនៅឯណា ហើយសងសំណងការខូចខាតនេះទៅអ្នកទទួលបញ្ញើបាន ដើម្បីឱ្យអ្នកទទួលបញ្ញើប្រគល់សំណងការខូចខាតនោះទៅអ្នកផ្ញើ ។ ក្នុងករណីនេះ អ្នកទទួលបញ្ញើត្រូវប្រគល់នូវសំណងការខូចខាតដែលខ្លួនបានទទួលនោះទៅអ្នកផ្ញើ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៩៣២ (ករណីយកិច្ចសងនូវវត្ថុដដែល វិធានពិសេសក្នុងករណីជាប្រាក់), មាត្រា ១៩៣៣ (ការសងវិញនូវវត្ថុ តាមស្ថានភាពជាក់ស្តែងនៅពេលដែលត្រូវសង) និង មាត្រា ១៩៣៤ (ការសងវត្ថុដែលត្រូវបានឧបាទេសកម្ម) នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៦៨៣.- ការចាត់ចែងផល ជាអាទិ៍

ក្នុងករណីដែលបានទទួលផល ឬ ចំណូលដែលកើតឡើងពីវត្ថុបញ្ញើ អ្នកទទួលបញ្ញើ ត្រូវប្រគល់ផល ឬ ចំណូលនោះ ឱ្យទៅអ្នកផ្ញើ ។

(កំណត់)

មាត្រានេះកំណត់អំពីរបៀបចាត់ចែងផលដែលកើតឡើងពីវត្ថុបញ្ញើ ។

ឧទាហរណ៍មួយចំនួននៃផលដូចជា កូនសត្វដែលកើតមកពីសត្វដែលត្រូវបានផ្ញើ និង ផលចំណេញដែលបានមកពីអចលនវត្ថុដែលត្រូវបានផ្ញើ (ដូចជាផលចំណេញបានមកពីកន្លែងចតរថយន្តដែលបានដាក់ជាបញ្ញើ) ។ ប៉ុន្តែ ដោយសារសត្វត្រូវការថែទាំ វាមានការលំបាកក្នុងការយកសត្វមកធ្វើជាកម្មវត្ថុនៃកិច្ចសន្យាបញ្ញើដែលគ្រាន់តែដើម្បី "រក្សាទុក" វត្ថុ ។ តាមការជាក់ស្តែង កិច្ចសន្យាអាណត្តិនឹងត្រូវបានប្រើប្រាស់សម្រាប់ការរក្សាទុកសត្វ ។ ករណីដែលផលកើតពីអចលនវត្ថុក៏មិនខុសគ្នាដែរ គឺកិច្ចសន្យាអាណត្តិដែលចែងអំពីការគ្រប់គ្រងជាវិជ្ជមាន ត្រូវបានប្រើញឹកញាប់ជាងកិច្ចសន្យាបញ្ញើដែល

មានគោលបំណងត្រឹមតែដើម្បីរក្សាទុកវត្ថុប៉ុណ្ណោះ ។

បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធនឹងពេលសងវត្ថុបញ្ញើ ត្រូវយកមកអនុវត្តចំពោះពេលដែលត្រូវប្រគល់ផល ឬ ផលចំណេញដែរ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៦៤៦ (ករណីយកិច្ចប្រគល់វត្ថុដែលបានទទួល) នៃក្រមរដ្ឋប្បវេណីជប៉ុន ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ ដោយយោងតាមមាត្រា ៦៦៥ នៃក្រមដដែល និង មាត្រា ១៩៣៦ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៦៨៤.- បញ្ញើជាប្រាក់

១-ប្រសិនបើបានទទួលការផ្ញើជាប្រាក់ អ្នកទទួលបញ្ញើ ត្រូវរក្សាទុក តាមរបៀបដែលបានកំណត់ក្នុងកិច្ចសន្យា ។ នៅក្នុងករណីនេះ បើគ្មានការសន្យាជាពិសេសទេ អ្នកទទួលបញ្ញើ ពុំមានករណីយកិច្ចបង់ការប្រាក់ឡើយ ។

២-ក្នុងករណីដែលអ្នកទទួលបញ្ញើ អាចរក្សាទុកប្រាក់ ដោយដាក់ជាប្រាក់បញ្ញើក្នុងធនាគារ បញ្ញត្តិនៃមាត្រា ៦៨៣ (ការចាត់ចែងផល ជាអាទិ៍) ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះការប្រាក់នោះ ។

( កំណត់)

មាត្រានេះចែងអំពីបញ្ញើជាប្រាក់ដែលមិនមែនជាបញ្ញើបរិភោគ ។ ដោយសារបញ្ញើនេះមិនមែនជាបញ្ញើបរិភោគទេ អ្នកទទួលបញ្ញើមិនអាចប្រើប្រាស់ប្រាក់នោះទេ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកទទួលបញ្ញើរក្សាទុកប្រាក់ ដោយដាក់ជាប្រាក់បញ្ញើក្នុងធនាគារ ធនាគារអាចប្រើប្រាក់នោះបាន ។

របៀបរក្សាទុកប្រាក់ មានដូចជាការរក្សាទុកដោយខ្លួនផ្ទាល់ដោយដាក់ប្រាក់នោះក្នុងស្រោមសំបុត្រ ឬ ការរក្សាទុកដោយដាក់ជាប្រាក់បញ្ញើក្នុងធនាគារ ជាអាទិ៍ ។ ប្រសិនបើអ្នកទទួលបញ្ញើរក្សាទុកប្រាក់ដោយខ្លួនផ្ទាល់ ដោយដាក់ប្រាក់នោះនៅក្នុងស្រោមសំបុត្រ ប្រាក់នោះមិនបង្កើតការប្រាក់ទេ ហេតុដូច្នេះ អ្នកទទួលបញ្ញើមិនចាំបាច់បង់ការប្រាក់ទៅអ្នកផ្ញើទេ ។ ប៉ុន្តែ ប្រសិនបើអ្នកទទួលបញ្ញើរក្សាទុកប្រាក់ដោយការដាក់ជាប្រាក់បញ្ញើនៅក្នុងធនាគារ ប្រាក់នោះនឹងបង្កើតការប្រាក់សម្រាប់ប្រាក់បញ្ញើនៅធានាគារ ហើយការប្រាក់នេះត្រូវបែរទៅជាការប្រាក់របស់អ្នកផ្ញើ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ១៩៣៦ នៃក្រមរដ្ឋប្បវេណីបារាំង ( បញ្ញើជាប្រាក់គ្មានការប្រាក់)

## មាត្រា ៦៨៥.- សោហ៊ុយនៃការសងវត្ថុបញ្ញើ

នៅក្នុងបញ្ញើដោយមិនយកកម្រៃ សោហ៊ុយចាំបាច់នៃការសងវត្ថុបញ្ញើ ត្រូវជាបន្ទុករបស់អ្នកផ្ញើ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកទទួលបញ្ញើ បានផ្លាស់ប្តូរកន្លែងផ្ញើ សោហ៊ុយនៃការសងវត្ថុបញ្ញើ ដែលកើនឡើងដោយសារការផ្លាស់ប្តូរកន្លែងនោះ ត្រូវជាបន្ទុករបស់អ្នកទទួលបញ្ញើ ។

(កំណត់)

មាត្រានេះចែងបញ្ជាក់ថា តើអ្នកណាត្រូវទទួលបន្ទុកលើសោហ៊ុយដែលត្រូវចំណាយសម្រាប់ការសងវិញនូវវត្ថុបញ្ញើ ។ ជាគោលការណ៍ សោហ៊ុយសម្រាប់ការសង គឺជាបន្ទុករបស់កូនបំណុល (មាត្រា ៤៤៦) ។ ប៉ុន្តែ ក្នុងករណីនៃបញ្ញើដោយមិនយកកម្រៃ វាមិនសមរម្យទេ ប្រសិនបើអ្នកទទួលបញ្ញើ ដែលជាកូនបំណុលចំពោះកាតព្វកិច្ចសងវិញនូវវត្ថុបញ្ញើ ត្រូវទទួលបន្ទុកលើសោហ៊ុយ ។ ហេតុដូច្នេះ មាត្រានេះកំណត់អំពីបញ្ញត្តិពិសេសចំពោះមាត្រា ៤៤៦ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១៩៤២ នៃក្រមរដ្ឋប្បវេណីបារាំង (ការសងនៅកន្លែងដែលបានកំណត់ក្នុងកិច្ចសន្យា សោហ៊ុយគួរជាបន្ទុករបស់អ្នកផ្ញើ)

**មាត្រា ៦៨៦**.- ករណីយកិច្ចសងសោហ៊ុយវិញ របស់អ្នកផ្ញើ

១-អ្នកផ្ញើ ចាំបាច់ត្រូវបង់សោហ៊ុយដែលចាំបាច់ ក្នុងការរក្សាទុកវត្ថុបញ្ញើ ។

២-អ្នកទទួលបញ្ញើ អាចទាមទារសំណងនៃការខូចខាត ដែលបណ្តាលមកពីវត្ថុបញ្ញើ ដោយមិនមែនជាកំហុសរបស់ខ្លួន ពីអ្នកផ្ញើបាន ។

(កំណត់)

មាត្រានេះចែងអំពីសោហ៊ុយសម្រាប់ការរក្សាទុកវត្ថុបញ្ញើ និង បន្ទុកនៃការខូចខាតដែលបណ្តាលមកពីបញ្ញើ ។

សូម្បីតែក្នុងករណីនៃបញ្ញើដោយមិនយកកម្រៃ សោហ៊ុយសម្រាប់ការរក្សាទុកវត្ថុបញ្ញើ ក៏ត្រូវតែជាបន្ទុករបស់អ្នកផ្ញើដែរ ។ ពីព្រោះ "មិនយកកម្រៃ" មានន័យថា មិនបង់នូវលាភសក្ការៈទៅអ្នកទទួលបញ្ញើ ដូច្នេះ កម្រៃមិនពាក់ព័ន្ធជាមួយសោហ៊ុយចំណាយជាក់ស្តែងសម្រាប់ការរក្សាទុកទេ ។ ប្រសិនបើអ្នកទទួលបញ្ញើរក្សាទុកវត្ថុដោយការក្លាសេនោះ អ្នកទទួលបញ្ញើ អាចទាមទារថ្លៃអគ្គិសនី ជាអាទិ៍ ពីអ្នកផ្ញើបាន សូម្បីតែក្នុងករណីជាបញ្ញើដោយមិនយកកម្រៃក៏ដោយ ។

ប្រសិនបើអ្នកទទួលបញ្ញើទទួលការខូចខាតដោយសារវត្ថុបញ្ញើ ដោយមិនមែនមកពីកំហុសរបស់អ្នកទទួលបញ្ញើ វាជាការសមស្របនឹងសមភាពដែលអ្នកផ្ញើត្រូវសងសំណងការខូចខាតនោះទៅអ្នកទទួលបញ្ញើ ។ ឧទាហរណ៍ ប្រសិនបើផ្ទះរបស់អ្នកទទួលបញ្ញើត្រូវបានបំផ្លិចបំផ្លាញដោយសារតែការផ្ទុះវត្ថុបញ្ញើ អ្នកផ្ញើត្រូវទទួលបន្ទុកនូវការខូចខាតនោះ ។

អ្នកផ្ញើត្រូវបង់សោហ៊ុយ ឬ សងសំណងនៃការខូចខាត នៅពេលដែលសោហ៊ុយ ឬ ការខូចខាតនោះកើតឡើង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៤៩, កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃមាត្រា ៦៥០ នៃក្រមរដ្ឋប្បវេណីជប៉ុន ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ ដោយយោងតាមមាត្រា ៦៦៥ នៃក្រមដដែល

## មាត្រា ៦៨៧.- កន្លែងសង

ប្រសិនបើមិនបានកំណត់ក្នុងកិច្ចសន្យា ការសងវត្ថុបញ្ញើ ចាំបាច់ត្រូវធ្វើនៅកន្លែងដែលត្រូវរក្សាទុកវត្ថុបញ្ញើនោះ ។ ប៉ុន្តែ ប្រសិនបើអ្នកទទួលបញ្ញើបានផ្លាស់ប្តូរកន្លែងរក្សាទុកវត្ថុនោះ ដោយមានមូលហេតុត្រឹមត្រូវ ការសងអាចធ្វើនៅកន្លែងរក្សាទុកជាក់ស្តែងនាពេលសងបាន ។

(កំណត់)

មាត្រានេះចែងអំពីទីកន្លែងសងវត្ថុបញ្ញើ ។ ចំពោះទីកន្លែងដែលត្រូវសង មាត្រា ៤៤៥ ចែងថា ចំពោះវត្ថុដែលបានកំណត់ជាក់លាក់ កូនបំណុលត្រូវប្រគល់វត្ថុនោះ នៅទីកន្លែងដែលវត្ថុនោះបានស្ថិតនៅ នាពេលដែលសិទ្ធិលើបំណុលបានកើតឡើង ចំណែកឯចំពោះកាតព្វកិច្ចផ្សេងទៀតវិញ កូនបំណុលត្រូវសងនៅលំនៅឋានបច្ចុប្បន្នរបស់ម្ចាស់បំណុល ។ ប៉ុន្តែចំពោះករណីនៃបញ្ញើវិញ វាជាការសមរម្យក្នុងការសងវត្ថុបញ្ញើ នៅកន្លែងដែលវត្ថុនោះត្រូវបានរក្សាទុក ក្នុងករណីនៃបញ្ញើវត្ថុជាក់លាក់ក៏ដោយ ឬ មិនជាក់លាក់ក៏ដោយ ។ មូលហេតុគឺដោយសារតែបញ្ញើគឺជាកិច្ចសន្យាដែលមានខ្លឹមសារគ្រាន់តែរក្សាទុកប៉ុណ្ណោះ ។ ប្រសិនបើអ្នកទទួលបញ្ញើត្រូវសងវត្ថុបញ្ញើ នៅកន្លែងផ្សេងពីកន្លែងដែលវត្ថុនោះត្រូវបានរក្សាទុក ហានិភ័យថ្មីនឹងកើតឡើង នៅពេលអ្នកទទួលបញ្ញើសងវត្ថុ (ឧទាហរណ៍ ការបាត់បង់ក្នុងពេលដឹកជញ្ជូន) ជាមួយនឹងលទ្ធផលនេះ បន្ទុករបស់អ្នកទទួលបញ្ញើតាមកិច្ចសន្យាបញ្ញើ នឹងកើនឡើង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៦៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៩៤៣ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៦៨៨.- សិទ្ធិឃាត់ទុករបស់អ្នកទទួលបញ្ញើ

អ្នកទទួលបញ្ញើ អាចឃាត់ទុកវត្ថុបញ្ញើ រហូតដល់ពេលដែលអ្នកផ្ញើបានបង់សោហ៊ុយ និង សំណងនៃការខូចខាត ដែលបញ្ញត្តនៅក្នុងកថាខណ្ឌទី ១ និង ទី ២ នៃមាត្រា ៦៨៦ (ករណីយកិច្ចសងសោហ៊ុយវិញរបស់អ្នកផ្ញើ) នៃក្រមនេះ បាន ។

(កំណត់)

មាត្រានេះចែងអំពីសិទ្ធិឃាត់ទុករបស់អ្នកទទួលបញ្ញើ ។ តាមនិយមន័យនៃសិទ្ធិឃាត់ទុកនៅក្នុងមាត្រា ៧៧៤ មានភាពច្បាស់លាស់ហើយថា សិទ្ធិឃាត់ទុកកើតឡើងចំពោះសិទ្ធិទាមទារឱ្យសងសោហ៊ុយ និង សិទ្ធិទាមទារសំណង ការខូចខាតរបស់អ្នកទទួលបញ្ញើ ប៉ុន្តែ មាត្រានេះត្រូវបានដាក់បញ្ចូលនៅទីនេះ ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ថែមទៀត ។ ក្នុងករណីនៃបញ្ញើ សិទ្ធិឃាត់ទុកតែងតែកើតឡើងជាទម្លាប់ ដោយសារលក្ខណៈនៃកិច្ចសន្យា ហេតុដូច្នេះ មាត្រានេះ ត្រូវបានដាក់បញ្ចូលនៅទីនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ២២៩៣ នៃក្រមរដ្ឋប្បវេណីកេបិច

## ផ្នែកទី ២ បញ្ញើដោយរួមបញ្ចូលគ្នា

### មាត្រា ៦៨៩.- បញ្ញើដោយរួមបញ្ចូលគ្នា

ប្រសិនបើអ្នកទទួលបញ្ញើ ទទួលបញ្ញើ នូវវត្ថុដែលមានប្រភេទដូចគ្នា ពីអ្នកផ្ញើច្រើននាក់ ហើយអាចរក្សាទុករួមបញ្ចូលគ្នា ដោយមិនបាច់បែងចែកវត្ថុបញ្ញើនោះ តាមកិច្ចសន្យា អ្នកផ្ញើនីមួយៗ មានសិទ្ធិទៅតាមសមាមាត្រនៃចំនួនវត្ថុផ្ញើរបស់ខ្លួន ចំពោះវត្ថុទាំងមូល ដែលត្រូវបានរក្សាទុកដោយរួមបញ្ចូលគ្នា ។

(កំណត់)

មាត្រានេះចែងអំពីបញ្ញើដោយរួមបញ្ចូលគ្នា ។ បញ្ញើដោយរួមបញ្ចូលគ្នា នឹងកើតឡើង ឧទាហរណ៍ ក្នុងករណីដែលម្ចាស់ឃ្លាំងត្រូវបានកសិករជាច្រើនផ្ទុកផ្តាក់ឱ្យរក្សាទុកស្រូវរបស់ពួកគេម្នាក់ៗ ១ តោន ជាអាទិ៍ ។ ប្រសិនបើស្រូវនោះមានប្រភេទ និង គុណភាពដូចគ្នា ការរក្សាទុកដោយរួមគ្នាគឺមានលក្ខណៈសន្សំសំចៃ និង ងាយគ្រប់គ្រង ។ ប្រសិនបើស្រូវរបស់កសិករច្រើននាក់ត្រូវបានរក្សាទុករួមគ្នា ស្រូវនោះត្រូវលាយចូលគ្នា ហេតុដូច្នេះ ស្រូវដែលម្ចាស់ឃ្លាំងនឹងសង គឺជាស្រូវដែលត្រូវបានលាយចូលគ្នានោះ ពោលគឺមិនមែនជាស្រូវដើមដែលបានដាក់ជាបញ្ញើនោះទេ បើនិយាយឱ្យតឹងរ៉ឹង ។ ដូច្នេះ ករណីនេះមិនស្ថិតនៅក្រោមអត្ថន័យនៃបញ្ញើដែលថា ត្រូវសង "វត្ថុដដែល" (មាត្រា ៦៦៩) នោះទេ ។ ដូច្នេះ ការអនុញ្ញាតឱ្យមានបញ្ញើដោយរួមបញ្ចូលគ្នា តម្រូវឱ្យមានការបង្កើតនូវបញ្ញត្តិពិសេស ។

បញ្ញើដោយរួមបញ្ចូលគ្នា ខុសពីបញ្ញើបរិភោគ ។ ប្រសិនបើបញ្ញើបរិភោគមានកម្មវត្ថុជាស្រូវ អ្នកទទួលបញ្ញើអាចបរិភោគស្រូវនោះបាន ។ ក្នុងករណីនេះ នៅពេលត្រូវសងទៅវិញ អ្នកទទួលបញ្ញើត្រូវយកស្រូវប្រភេទដដែល មកប្រគល់ទៅឱ្យអ្នកផ្ញើ ។ ប៉ុន្តែ ក្នុងករណីនៃបញ្ញើដោយរួមបញ្ចូលគ្នា អ្នកទទួលបញ្ញើអាចមិនបរិភោគស្រូវបានទេ ។ អ្នកទទួលបញ្ញើ អាចគ្រាន់តែរក្សាស្រូវដោយរួមបញ្ចូលគ្នាជាមួយស្រូវរបស់អ្នកផ្ញើដទៃផ្សេងទៀតប៉ុណ្ណោះ ។

ទោះបីជាបញ្ញើដោយរួមបញ្ចូលគ្នាស្រដៀងគ្នាទៅនឹងការលាយច្របល់គ្នាក៏ដោយ ក៏បញ្ញត្តិនៃមាត្រា ១៩៨ មិនត្រូវយកកអនុវត្តចំពោះបញ្ញើដោយរួមបញ្ចូលគ្នាឡើយ ។ យោងតាមមាត្រា ១៩៨ ប្រសិនបើចលនវត្ថុដែលលាយច្របល់គ្នាមានទាំងវត្ថុចម្បង និង វត្ថុចំណុះ ម្ចាស់វត្ថុចម្បងទទួលបាននូវកម្មសិទ្ធិលើចលនវត្ថុទាំងអស់ ចំណែកឯម្ចាស់វត្ថុចំណុះទទួលបានតែសំណងប៉ុណ្ណោះ ។ គោលបំណងនៃមាត្រា ១៩៨ គឺដើម្បីកំណត់កម្មសិទ្ធិករតែមួយតាមដែលអាចធ្វើទៅបាន ។ ប៉ុន្តែ បញ្ញើដោយរួមបញ្ចូលគ្នា មិនមានគោលបំណងដូចគ្នាទេ គឺជាប្រព័ន្ធដែលសម្រួលដល់ការរក្សាទុក ។ ហេតុដូច្នេះមាត្រានេះដកចេញនូវការអនុវត្តមាត្រា ១៩៨ ហើយបង្កើតនូវទំនាក់ទំនងគតិយុត្តពិសេសក្នុងករណីនៃបញ្ញើដោយរួមបញ្ចូលគ្នា ។ ទោះបីជាចំណុចបន្តបន្ទាប់មិនត្រូវបានចែងឱ្យច្បាស់នៅក្នុងមាត្រានេះក៏ដោយ ក៏វាគួរតែត្រូវបានគិតថាអ្នកផ្ញើម្នាក់ៗមានកម្មសិទ្ធិអវិភាគលើវត្ថុរួមបញ្ចូលគ្នាទាំងស្រុង ទៅតាមសមាមាត្រនៃចំនួនវត្ថុដែលខ្លួនបានផ្ញើដែរ ។ ហើយវត្ថុដែលត្រូវបានបំបែកចេញពីវត្ថុរួមបញ្ចូលគ្នា អាចក្លាយជាកម្មវត្ថុនៃកម្មសិទ្ធិដាច់ដោយឡែករបស់អ្នកផ្ញើនីមួយៗ ។ នេះគឺជាប្រភេទមួយនៃការបែងចែកវត្ថុកម្មសិទ្ធិអវិភាគ ។

ឧទាហរណ៍ដែលបញ្ញើដោយរួមបញ្ចូលគ្នាត្រូវបានប្រើប្រាស់ មានដូចជាករណីដូចបានរៀបរាប់ខាងលើ ដែលកសិករច្រើននាក់ផ្ញើប្រភេទគ្រាប់ធញ្ញជាតិប្រភេទដូចគ្នា ទៅឃ្លាំងកសិកម្ម ហើយក្រៅពីនេះ មានប្រព័ន្ធរក្សាគ្រប់គ្រង និង ផ្ទេរឧបករណ៍ដែលអាចជួញដូរបាន (Central Certificate Depository and Transfer System) ដែលប្រមូលមករក្សាទុកនូវឧបករណ៍ដែលអាចជួញដូរបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧ នៃច្បាប់ស្តីពីការគ្រប់គ្រងឃ្លាំងកសិកម្ម (Agricultural Warehouse Law) និង ប្រការ ២ នៃប្រកាសស្តីពីការចុះបញ្ជីជាកញ្ចប់នូវប័ណ្ណបំណុលរដ្ឋ (Ministerial Ordinance concerning Shelf-registration of Government Bonds) របស់ជប៉ុន

## ផ្នែកទី ៣ បញ្ញើបរិភោគ

**មាត្រា ៦៩០**.- បញ្ញើបរិភោគ

នៅក្នុងកិច្ចសន្យាបញ្ញើ បើបានព្រមព្រៀងឱ្យអ្នកទទួលបញ្ញើ អាចបរិភោគវត្ថុបញ្ញើបាន អ្នកទទួលបញ្ញើ មានករណីយកិច្ចសងវត្ថុដែលមានប្រភេទ និង ចំនួនដូចគ្នានឹងវត្ថុបញ្ញើនោះ ។

(កំណត់)

មាត្រានេះចែងអំពីបញ្ញើបរិភោគ ។ ក្នុងករណីបញ្ញើធម្មតា អ្នកទទួលបញ្ញើរក្សាទុកវត្ថុដែលខ្លួនបានទទួលពីអ្នកផ្ញើ ហើយសងវិញនូវវត្ថុដដែល នៅពេលកំណត់សង រីឯក្នុងករណីនៃបញ្ញើបរិភោគ អ្នកទទួលបញ្ញើអាចបរិភោគវត្ថុដែលត្រូវ

បានផ្ញើដោយអ្នកផ្ញើនោះ ហើយនៅពេលកំណត់សង អ្នកទទួលបញ្ញើអាចយកវត្ថុដែលមានប្រភេទដូចគ្នាមកសងវិញបាន ។ ក្នុងករណីនៃបញ្ញើបរិភោគ វាត្រូវបានគិតថា កម្មសិទ្ធិនៃវត្ថុបញ្ញើត្រូវបានផ្ទេរទៅឱ្យអ្នកទទួលបញ្ញើ ។

បញ្ញើបរិភោគអាចអនុវត្តបានចំពោះប្រាក់ ផលិតផលកសិកម្ម និង គ្រឿងស្រវឹង ។ បញ្ញើនៅធនាគារត្រូវបានគិតថាជាបញ្ញើបរិភោគ ។ ហេតុអ្វីបានជាបញ្ញើនៅធនាគារមិនមែនជាការខ្ចីបរិភោគ ប៉ុន្តែ ជាបញ្ញើបរិភោគទៅវិញ ? ដោយសារតែបញ្ញើបរិភោគ គឺជាប្រភេទនៃបញ្ញើ វត្ថុបញ្ញើនេះត្រូវបានផ្ញើដើម្បីផលប្រយោជន៍របស់អ្នកផ្ញើ ។ ប្រសិនបើអ្នកផ្ញើនោះធ្វើការរក្សាទុកប្រាក់ដោយខ្លួនឯង គេនឹងប្រថុយប្រថានជាមួយចោរកម្ម ហើយបើគ្មានចំណេះដឹងអំពីវិនិយោគទុនទេ អ្នកនោះក៏មិនអាចធ្វើវិនិយោគបានផង ។ ដើម្បីជៀសវាងហានិភ័យនេះ ហើយដើម្បីទទួលផលប្រយោជន៍ផង អ្នកផ្ញើនឹងផ្ញើប្រាក់នៅធនាគារ ។ ហេតុដូច្នេះ នេះជាការសមរម្យក្នុងការយល់ឃើញថា បញ្ញើនៅធនាគារគឺជាបញ្ញើបរិភោគ ។ ផ្ទុយទៅវិញ ការខ្ចីបរិភោគត្រូវបានបង្កើតឡើងដើម្បីផលប្រយោជន៍របស់អ្នកខ្ចី ។ ការខ្ចីប្រាក់សម្រាប់ធ្វើជំនួញ ឬ សម្រាប់ការចំណាយក្នុងជីវភាពរស់នៅ ត្រូវបានធ្វើឡើងដើម្បីផលប្រយោជន៍របស់អ្នកខ្ចី ។ ក្នុងន័យនេះ ការខ្ចីបរិភោគ គឺខុសគ្នាពីបញ្ញើបរិភោគ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧០០ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ និង មាត្រា ១៩៣២ នៃក្រមរដ្ឋប្បវេណីបារាំង (ក្នុងករណីបញ្ញើជាប្រាក់ អ្នកទទួលបញ្ញើអាចសងប្រាក់នូវប្រភេទ និង ចំនួនដូចគ្នា)

**មាត្រា ៦៩១.-** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីការខ្ចីបរិភោគ

បញ្ញត្តិស្តីពីការខ្ចីបរិភោគ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបញ្ញើបរិភោគដែលបានកំណត់នៅក្នុងមាត្រា ៦៩០ (បញ្ញើបរិភោគ) ខាងលើនេះ ។ ប៉ុន្តែ ក្នុងករណីនេះ ប្រសិនបើគ្មានកំណត់អំឡុងពេលសងនៅក្នុងកិច្ចសន្យាទេ អ្នកផ្ញើអាចទាមទារឱ្យសង នៅពេលណាក៏បាន ។

(កំណត់)

មាត្រានេះបញ្ជាក់អំពីទំនាក់ទំនងនៃសិទ្ធិ និង ករណីយកិច្ច រវាងអ្នកផ្ញើ និង អ្នកទទួលបញ្ញើ នៅក្នុងករណីបញ្ញើបរិភោគ ។

មាត្រានេះចែងថា បញ្ញត្តិស្តីពីការខ្ចីបរិភោគ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបញ្ញើបរិភោគ លើកលែងតែពេលដែលត្រូវសងចេញ ។ ចំណុចសំខាន់មានដូចតទៅ :

ទីមួយ នៅក្នុងករណីបញ្ញើបរិភោគ ដោយសារតែកម្មសិទ្ធិលើវត្ថុបញ្ញើត្រូវបានផ្ទេរទៅឱ្យអ្នកទទួលបញ្ញើ អ្នកទទួលបញ្ញើ អាចបរិភោគវត្ថុនោះដោយសេរី ។

ទីពីរ រាល់ការចំណាយទាំងអស់សម្រាប់វត្ថុបញ្ញើ និង ការខូចខាតទាំងឡាយដែលបណ្តាលមកពីវត្ថុបញ្ញើនោះ ត្រូវជាបន្ទុករបស់អ្នកទទួលបញ្ញើ ហើយផលដែលកើតចេញពីវត្ថុបញ្ញើនោះ ត្រូវក្លាយទៅជាកម្មសិទ្ធិរបស់អ្នកទទួលបញ្ញើ ។

ប៉ុន្តែ ចំពោះពេលសង ជាគោលការណ៍ អ្នកផ្ញើអាចទាមទារឱ្យសងនៅពេលណាក៏បាន តាមវិធានស្តីពីបញ្ញើ ជំនួសឱ្យវិធានស្តីពីការខ្ចីបរិភោគ ។ ដោយសារបញ្ញើបរិភោគ គឺជាប្រភេទមួយនៃបញ្ញើ ដែលត្រូវបានធ្វើឡើងដើម្បី ផលប្រយោជន៍របស់អ្នកផ្ញើ ប្រសិនបើអ្នកផ្ញើមានបំណងទាមទារឱ្យសង ផលប្រយោជន៍របស់អ្នកផ្ញើនោះ ត្រូវបានការពារ ។ ផ្ទុយទៅវិញ ដោយសារការខ្ចីបរិភោគគឺជារបបមួយដែលផ្តល់ផលប្រយោជន៍ដល់អ្នកខ្ចី វាមិនសមរម្យទេ បើយកវិធានស្តីពីបញ្ញើដែលមានខ្លឹមសារថា អ្នកខ្ចីត្រូវសងប្រាក់នៅពេលណាដែលអ្នកឱ្យខ្ចីទាមទារឱ្យសង មកអនុវត្ត ចំពោះការខ្ចីបរិភោគ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៦៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ផ្នែកទី ៤ វិសុណ្ឋាប័ន

**មាត្រា ៦៩២.-** និយមន័យនៃវិសុណ្ឋាប័ន

វិសុណ្ឋាប័ន សំដៅទៅលើកិច្ចសន្យាមួយ ដែលបុគ្គលច្រើននាក់ មានវិវាទលើ សិទ្ធិកាន់កាប់ ឬ កម្មសិទ្ធិនៃវត្ថុ យកវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ ផ្ញើទុកនៅតតិយជន ដែលហៅថា វិសុណ្ឋាបនិក រហូតដល់ពេលអ្នកដែលមានសិទ្ធិនោះ ត្រូវបានកំណត់ជា ស្ថាពរ ។

(កំណត់)

មាត្រានេះចែងអំពីនិយមន័យនៃវិសុណ្ឋាប័ន ។ វិសុណ្ឋាប័នមានតួនាទីស្រដៀងគ្នាទៅនឹងការតម្កល់ ប៉ុន្តែ វិសុណ្ឋាប័ន មានភាពខុសគ្នាពីការតម្កល់ត្រង់ចំណុចដូចតទៅ : ទីមួយ គឺ ចំពោះការតម្កល់ គឺការិយាល័យតម្កល់ទទួលរក្សាទុកនូវវត្ថុ ដែលជាកម្មវត្ថុនៃវិវាទ ក្នុងនាមជាស្ថាប័នសាធារណៈ រីឯចំពោះវិសុណ្ឋាប័នវិញ អ្នកដែលរក្សាទុកវត្ថុនោះ មិនចាំបាច់ជា ស្ថាប័នសាធារណៈឡើយ ។ ទីពីរ គឺ ជាធម្មតា ការតម្កល់គ្របដណ្តប់តែលើប្រាក់ និង ឧបករណ៍ដែលអាចដូរបាន ប៉ុណ្ណោះ (ទោះបីជាវាផ្អែកទៅលើច្បាប់ស្តីពីការតម្កល់បញ្ញត្តថាយ៉ាងណាក៏ដោយ) ចំណែកឯវិសុណ្ឋាប័នវិញ គ្របដណ្តប់ លើចលនវត្ថុ និង អចលនវត្ថុ ។

ទោះបីជាប្រព័ន្ធវិសុណ្ឋាប័ន មិនមានក្នុងប្រទេសមួយចំនួន (ដូចជាប្រទេសជប៉ុន និង អាល្លឺម៉ង់ ជាដើម) ក៏ដោយ ក៏វាមាននៅក្នុងប្រទេសមួយចំនួនដែលប្រើប្រព័ន្ធច្បាប់បារាំង ហើយក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ក៏មានបញ្ញត្តិដែល

ទាក់ទងនឹងប្រព័ន្ធវិសុណ្ឋាប័នផងដែរ ។

ដោយសារវិសុណ្ឋាប័នជាប្រភេទមួយនៃបញ្ញើ បញ្ញត្តិស្តីពីបញ្ញើធម្មតាត្រូវយកមកអនុវត្ត ចំពោះចំណុចដែលមិនបាន ចែងនៅក្នុងផ្នែកទី ៤ នេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៥៨ នៃក្រមរដ្ឋប្បវេណីកម្ពុជាចាស់, មាត្រា ១៩៥៥ និង មាត្រាបន្តបន្ទាប់នៃក្រមរដ្ឋប្បវេណីបារាំង (វិសុណ្ឋាប័នដោយការព្រមព្រៀង និង វិសុណ្ឋាប័នដោយការបង្គាប់របស់តុលាការ), មាត្រា ២៣០៥ ដល់មាត្រា ២៣១១ នៃក្រមរដ្ឋប្បវេណីកេបិច និង មាត្រា ២២២ នៃគន្ថីស្តីពីលទ្ធកម្មទ្រព្យសម្បត្តិ នៃក្រមរដ្ឋប្បវេណីជប៉ុនចាស់ (ការរក្សាទុក)

## មាត្រា ៦៩៣.- ភាគីនៃវិសុណ្ឋាប័ន

១-ក្នុងករណីដែលបុគ្គលច្រើននាក់ អះអាងអំពីសិទ្ធិរបស់ខ្លួន ចំពោះវត្ថុដែលកាន់កាប់ដោយបុគ្គលដទៃ បុគ្គលដែលមានវិវាទច្រើននាក់នេះ អាចធ្វើកិច្ចសន្យាឱ្យតតិយជនរក្សាទុកវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយទទួលការយល់ព្រមពីអ្នកកាន់កាប់ ។ ក្នុងករណីនេះ កិច្ចសន្យាវិសុណ្ឋាប័ននេះ ត្រូវមានអានុភាព នៅពេលដែលអ្នកកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទ បានប្រគល់វត្ថុនោះទៅឱ្យតតិយជន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បុគ្គលដែលមានវិវាទច្រើននាក់ ក៏អាចធ្វើកិច្ចសន្យាបញ្ញើ ដោយយកអ្នកកាន់កាប់ ធ្វើជាវិសុណ្ឋាបនិកនោះបាន ។

(កំណត់)

មាត្រានេះចែងអំពីអ្នកណាខ្លះជាភាគីនៃវិសុណ្ឋាប័ន ។

អ្នកផ្ញើមានច្រើននាក់ដែលមានវិវាទគ្នាទៅវិញទៅមកលើវត្ថុណាមួយ ដោយអះអាងអំពីសិទ្ធិលើវត្ថុនោះ ។ ប៉ុន្តែការគិតរបៀបនេះ នាំឱ្យពិបាកពន្យល់នូវករណីជាឧទាហរណ៍ដូចតទៅ : នៅពេលដែល A នៅតែកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការលក់ដោយ A មាន B និង C ម្នាក់ៗអះអាងថា ខ្លួនជាអ្នកទិញ និង ទាមទារឱ្យ A ប្រគល់វត្ថុនោះ A ផ្ញើវត្ថុនោះទៅតតិយជន ដើម្បីជៀសវាងការពាក់ព័ន្ធក្នុងវិវាទរវាង B និង C ។ ប៉ុន្តែ ក្នុងករណីនេះផងដែរ វាសមរម្យបើគិតថា B និង C ដែលជាភាគីវិវាទ គឺជាអ្នកផ្ញើ ហើយដោយសារតែវត្ថុស្ថិតនៅក្រោមការកាន់កាប់របស់ A វិសុណ្ឋាប័ននឹងមានអានុភាព លុះត្រាតែ A ប្រគល់វត្ថុទៅតតិយជន ដោយមានការយល់ព្រម ។

ក្នុងករណីនេះ ប្រសិនបើថ្លៃលក់ទិញមិនត្រូវបានបង់ទេ A អាចភ្ជាប់នូវល័ក្ខខ័ណ្ឌសម្រាប់ការប្រគល់វត្ថុដូចតទៅ : A នឹងប្រគល់វត្ថុទៅឱ្យអ្នកមានសិទ្ធិ ជាថ្នូរនឹងថ្លៃលក់ទិញ ។

ក្នុងឧទាហរណ៍ដដែលនេះ A ដែលជាអ្នកកាន់កាប់វត្ថុនោះ អាចក្លាយជាវិសុណ្ឋាបនិកបាន (កថាខណ្ឌទី ២) ។ ក្នុងករណីនេះ ដោយសារតែវត្ថុនេះស្ថិតនៅក្រោមការកាន់កាប់របស់វិសុណ្ឋាបនិកស្រាប់ហើយ វាមិនចាំបាច់ត្រូវធ្វើការប្រគល់វត្ថុអ្វីទៀតទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៦០ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## មាត្រា ៦៩៤.- ល័ក្ខខ័ណ្ឌនៃសុពលភាព

បើគ្មានការយល់ព្រមពីបុគ្គលដែលអះអាងអំពីសិទ្ធិទាំងអស់គ្នាទេ បញ្ញើនៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ពុំមានសុពលភាពឡើយ ។

(កំណត់)

មាត្រានេះចែងពីល័ក្ខខ័ណ្ឌនៃសុពលភាព ។ ដោយសារភាគីនៃវិវាទត្រូវក្លាយទៅជាអ្នកផ្ញើ វាជាការសន្និដ្ឋានជាធម្មតាក្នុងការចែងថា វិសុណ្ឋាប័នទាមទារឱ្យមានការយល់ព្រមពីភាគីទាំងអស់ ។

មាត្រា ៦៩៨ ដែលចែងអំពីវិសុណ្ឋាប័នដោយការបង្គាប់របស់តុលាការ គឺជាករណីលើកលែងចំពោះមាត្រានេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៦០ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

## មាត្រា ៦៩៥.- គោលការណ៍យកកម្រៃ

នៅក្នុងវិសុណ្ឋាប័ន អ្នកផ្ញើមានករណីយកិច្ចត្រូវបង់កម្រៃឱ្យទៅវិសុណ្ឋាបនិក ។ ក្នុងករណីដែលភាគីមិនបានកំណត់អំពីចំនួនទឹកប្រាក់នៃកម្រៃទេ វិសុណ្ឋាបនិកអាចទាមទារចំនួនទឹកប្រាក់ ជាកម្រៃដែលសមរម្យ ពីអ្នកផ្ញើបាន ។

(កំណត់)

មាត្រានេះចែងថា ជាគោលការណ៍ វិសុណ្ឋាប័នយកកម្រៃ ។

វិសុណ្ឋាបនិកអនុវត្តនូវតួនាទីពិសេសដើម្បីរក្សាទុកវត្ថុដើម្បីដោះស្រាយវិវាទ ជាជាងរក្សាទុកវត្ថុនោះដោយសារតែសន្ដានចិត្ត ។ ដូច្នេះ វិសុណ្ឋាបនិកត្រូវយកចិត្តទុកដាក់ ដោយប្រុងប្រយ័ត្ន ក្នុងការរក្សាទុក និង ប្រគល់វត្ថុបញ្ញើនោះ ហើយវាមិនសមរម្យទេ បើយកការធ្វើដោយមិនយកកម្រៃមកធ្វើជាគោលការណ៍ ។ បន្ថែមលើនេះទៀត ប្រសិនបើ

វិសុណ្ឋាប័នមិនយកកម្រៃទេ គ្មាននរណាព្រមទទួលនូវបញ្ញើនេះទេ ។ ការកើតឡើងនូវវិវាទ មិនអាចព្យាករបានទេ ហើយដើម្បីអាចធ្វើវិសុណ្ឋាប័នឱ្យបានទាន់ពេលវេលា នៅពេលដែលវិវាទកើតឡើង ចាំបាច់មានបុគ្គលដែលអាចទទួលតួនាទីជាវិសុណ្ឋាបនិក ជាទៀងទាត់ ។ ប្រសិនបើវិសុណ្ឋាប័ន ជាវិសុណ្ឋាប័នដែលមិនយកកម្រៃ វិសុណ្ឋាបនិកនឹងមិនកើនចំនួនទេ ។ នេះគឺជាហេតុផលដែលយកវិសុណ្ឋាប័ន ដែលយកកម្រៃមកធ្វើជាគោលការណ៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៦១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ១៩៥៧ និង មាត្រា ១៩៥៨ នៃក្រមរដ្ឋប្បវេណីបារាំង

## មាត្រា ៦៩៦.- ការសងវត្ថុដែលជាកម្មវត្ថុនៃវិវាទ

វិសុណ្ឋាបនិកមានករណីយកិច្ចត្រូវសងវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ ចំពោះបុគ្គលដែលត្រូវបានទទួលស្គាល់ថា មានសិទ្ធិ នៅក្រោយពេលដែលវិវាទបានបញ្ចប់ ។

(កំណត់)

មាត្រានេះគឺជាបញ្ញត្តិពាក់ព័ន្ធនឹងការសង និង ការប្រគល់វត្ថុដែលជាកម្មវត្ថុនៃវិវាទដែលវិសុណ្ឋាបនិកបានរក្សាទុកតាមកិច្ចសន្យាវិសុណ្ឋាប័ន ។ មាត្រានេះមានខ្លឹមសារធម្មតា ។ ក្នុងករណីនៃបញ្ញើធម្មតា វត្ថុញ្ញើនឹងត្រូវបានសងទៅអ្នកផ្ញើ ប៉ុន្តែ ក្នុងវិសុណ្ឋាប័នវិញ អ្នកទទួលបញ្ញើត្រូវសងឱ្យទៅបុគ្គលដែលត្រូវបានកំណត់ជាស្ថាពរថាជាអ្នកដែលមានសិទ្ធិក្នុងចំណោមអ្នកផ្ញើទាំងឡាយនៃវិសុណ្ឋាប័ន ។ ដូច្នេះ មាត្រានេះគឺជាបញ្ញត្តិពិសេសចំពោះបញ្ញត្តិស្ដីពីបញ្ញើធម្មតា ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៦៣ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ២៣០៥ នៃក្រមរដ្ឋប្បវេណីកេបិច

## មាត្រា ៦៩៧.- ការរំលាយកិច្ចសន្យាវិសុណ្ឋាប័ន

វិសុណ្ឋាបនិកពុំអាចសងវត្ថុនោះ ទៅឱ្យអ្នកផ្ញើ នៅមុនពេលវិវាទនោះត្រូវបានដោះស្រាយឡើយ លើកលែងតែករណីមានការយល់ព្រមពីអ្នកផ្ញើទាំងអស់ ។

(កំណត់)

មាត្រានេះគឺជាបញ្ញត្តិពាក់ព័ន្ធនឹងការរំលាយកិច្ចសន្យាវិសុណ្ឋាប័ន ។ មាត្រានេះមានន័យថា នៅពេលអ្នកផ្ញើខ្លះក្នុងចំណោមអ្នកផ្ញើវត្ថុដែលជាកម្មវត្ថុនៃវិវាទ ទាមទារឱ្យសងវត្ថុ វិសុណ្ឋាបនិកមិនអាចសងទៅឱ្យអ្នកផ្ញើនោះបានឡើយ ។ មាត្រានេះមិនកំណត់ថា ពេលណាទើបអ្នកផ្ញើអាចទាមទារឱ្យសងវត្ថុទេ ។ ប៉ុន្តែ ដោយសារវិសុណ្ឋាប័នជាប្រភេទមួយនៃបញ្ញើ ជាគោលការណ៍ វិសុណ្ឋាប័នក៏ត្រូវបានធ្វើឡើងដើម្បីផលប្រយោជន៍អ្នកផ្ញើដែរ ។ ដូច្នេះ នៅពេលណាក៏ដោយឱ្យតែអ្នកផ្ញើទាមទារឱ្យសងវត្ថុ អ្នកទទួលបញ្ញើត្រូវសងវត្ថុនោះ ។ ប៉ុន្តែ នៅក្នុងករណីនៃវិសុណ្ឋាប័ន ដោយសារមាន

វិវាទថា អ្នកណាជាអ្នកមានសិទ្ធិចំពោះវត្ថុនោះ វិសុណ្ឋាប័នមិនអាចសងវត្ថុទេ លើកលែងតែអ្នកផ្ញើទាំងអស់យល់ព្រម ។
(មាត្រាពាក់ព័ន្ធ)
មាត្រា ២៣០៩ នៃក្រមរដ្ឋប្បវេណី

**មាត្រា ៦៩៨**.- វិសុណ្ឋាប័ន ដោយការបង្គាប់របស់តុលាការ

ក្នុងករណីដែលសិទ្ធិកាន់កាប់វត្ថុ ឬ កម្មសិទ្ធិនៃវត្ថុ ត្រូវបានយកជាកម្មវត្ថុនៃវិវាទនៅក្នុងតុលាការ ទោះបីជាគ្មានការព្រមព្រៀងរវាងភាគីក៏ដោយ តុលាការអាចឱ្យតតិយជនរក្សាទុកវត្ថុដែលជាកម្មវត្ថុនៃវិវាទបាន ។

(កំណត់)
ក្នុងដំណើរការនៃបណ្តឹង តុលាការអាចគិតថា វាសមរម្យក្នុងការផ្ទុកផ្តាក់ឱ្យតតិយជនរក្សាទុកវត្ថុដែលជាកម្មវត្ថុនៃវិវាទ ។ ឧទាហរណ៍ តុលាការអាចគិតដូច្នេះ ក្នុងករណីដែលអ្នកលក់កាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ប៉ុន្តែ ដោយសារភាគីទាំងពីរនៃវិវាទដោយអះអាងម្នាក់ៗថា ខ្លួនជាអ្នកទិញពិតប្រាកដ មិនយល់ព្រមចំពោះវិសុណ្ឋានប័ន អ្នកលក់មិនអាចធ្វើវិសុណ្ឋាប័នដោយការព្រមព្រៀងបានឡើយ ។ ប្រសិនបើច្បាប់ស្តីពីការតម្កល់គ្របដណ្តប់លើករណីបែបនេះ បញ្ហានេះអាចត្រូវបានដោះស្រាយបាន តាមការតម្កល់ ។ ប៉ុន្តែ ប្រសិនបើច្បាប់ស្តីពីការតម្កល់មិនអនុញ្ញាតឱ្យតម្កល់នូវចលនវត្ថុ និងអចលនវត្ថុទេ បញ្ហានេះមិនអាចត្រូវបានដោះស្រាយដោយការតម្កល់បានឡើយ ។ ក្នុងករណីនេះ វាជាការងាយស្រួលប្រសិនបើវិសុណ្ឋាប័ន អាចត្រូវបានធ្វើដោយការបង្គាប់របស់តុលាការបាន ។
(មាត្រាពាក់ព័ន្ធ)
មាត្រា ១២៦៤ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, ២៣១១ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ជំពូកទី ១១ កិច្ចសន្យាក្រុមហ៊ុន

**មាត្រា ៦៩៩**.- និយមន័យនៃកិច្ចសន្យាក្រុមហ៊ុន

កិច្ចសន្យាក្រុមហ៊ុន សំដៅទៅលើកិច្ចសន្យាបង្កើតជាក្រុម ដែលគ្មានការរៀបចំលក្ខណៈជានីតិបុគ្គល ដើម្បីប្រកបកិច្ចការ ដោយសហការគ្នា ដោយភាគីនីមួយៗធ្វើការវិនិយោគទ្រព្យធនរៀងៗខ្លួន ។

(កំណត់)
មាត្រានេះចែងថា អាចបង្កើតក្រុមហ៊ុនដោយកិច្ចសន្យាក្រុមហ៊ុន ព្រមទាំងបានឱ្យនិយមន័យនៃកិច្ចសន្យាក្រុមហ៊ុន ។

នៅក្នុងកិច្ចសន្យាក្រុមហ៊ុន ចាំបាច់ត្រូវមានវិនិយោគទ្រព្យធនរៀង១ខ្លួន និង កិច្ចព្រមព្រៀងអំពីកិច្ចការដែលត្រូវបានធ្វើដោយសហការគ្នា ។ មាត្រានេះបានចែងច្បាស់លាស់ថា លក្ខណៈពិសេសរបស់ក្រុមហ៊ុនគឺជាក្រុមដែលពុំមានលក្ខណៈជានីតិបុគ្គល ។ ក្រុមដែលមានខ្លឹមសារជាសារធាតុដូចក្រុមហ៊ុនដែរ គឺ នីតិបុគ្គលសាជីវកម្មដែលមានការទទួលខុសត្រូវគ្មានកម្រិត ក៏ប៉ុន្តែ ក្រុមនេះអាចមានលក្ខណៈជានីតិបុគ្គល ។ សូមមើល កថាខណ្ឌទី ៣ នៃមាត្រា ៤៦ និង បញ្ញត្តិចាប់ពីមាត្រា ១០១ ដល់ មាត្រា ១០៩ នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៨៧ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា. មាត្រា ៦៦៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧០៥ និង មាត្រា ៧០៦ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៨៣២ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៥៣០ នៃច្បាប់ស្តីពីកាតព្វកិច្ចរបស់ស្វីស

**មាត្រា ៧០០.-** ការបង្កើតកិច្ចសន្យាក្រុមហ៊ុន

១-ក្រុមហ៊ុន គឺជាក្រុមដែលបានបង្កើតដោយការសន្យា ដែលភាគីនីមួយៗ វិនិយោគទ្រព្យធនរៀងៗខ្លួន ហើយប្រកបកិច្ចការដោយសហការគ្នា ។

២-ទ្រព្យធនដែលភាគីនីមួយៗត្រូវវិនិយោគ នៅក្នុងកិច្ចសន្យាក្រុមហ៊ុន ក្រៅពីសិទ្ធិលើទ្រព្យសម្បត្តិ អាចយកពលកម្ម មកធ្វើជាកម្មវត្ថុបាន ។

៣-ក្នុងករណីដែលភាគីបានយកប្រាក់ធ្វើជាកម្មវត្ថុនៃការវិនិយោគទ្រព្យធន បើមានការយឺតយ៉ាវក្នុងការបង់ប្រាក់នោះ ក្រៅពីត្រូវបង់ការប្រាក់នៃការយឺតយ៉ាវ ក៏ត្រូវបង់ទៅលើការខូចខាតដែលកើតឡើងដោយសារការយឺតយ៉ាវនោះ ចំពោះក្រុមហ៊ុនផងដែរ ។

៤-ក្នុងករណីដែលសកម្មភាពនៃការបង្កើតក្រុមហ៊ុនរបស់ភាគីណាមួយ ក្នុងចំណោមភាគីដែលបានព្រមព្រៀងបង្កើតក្រុមហ៊ុន ក្លាយទៅជាមោឃៈ ឬ ត្រូវបានលុបចោល ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ២ (វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា) ជំពូកទី ២ នៃគន្ថីទី ៤ ត្រូវចាត់ទុកថា ក្រុមហ៊ុននោះ ត្រូវបានបង្កើត ដោយភាគីដទៃទៀត ។ ប៉ុន្តែ ក្នុងករណីដែលក្រុមហ៊ុនពុំអាចសម្រេចគោលបំណងបាន ដោយសារកង្វះភាគីនោះត្រូវចាត់ទុកថាក្រុមហ៊ុននោះ ពុំត្រូវបានបង្កើតឡើយ ។

(កំណត់)

(1) កថាខណ្ឌទី ១ នៃមាត្រានេះ កំណត់និយមន័យនៃក្រុមដែលហៅថាជាក្រុមហ៊ុន ។ម្យ៉ាងទៀត កិច្ចសន្យាក្រុមហ៊ុន

គឺជាកិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយការព្រមព្រៀង ក៏ប៉ុន្តែ ចំណុចដែលត្រូវប្រយ័ត្ន គឺ បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣៣៦ ត្រូវយកមកអនុវត្ត ចំពោះករណីដែលយកកម្មសិទ្ធិលើអចលនវត្ថុ មកធ្វើជាកម្មវត្ថុនៃការវិនិយោគទ្រព្យធន ។

(2) កថាខណ្ឌទី ២ ចែងអំពីខ្លឹមសារនៃការវិនិយោគទ្រព្យធន ។ ក្រៅពីសិទ្ធិលើទ្រព្យសម្បត្តិ ពលកម្មក៏អាចក្លាយទៅជាកម្មវត្ថុនៃការវិនិយោគទ្រព្យធនដែរ ។

(3) កថាខណ្ឌទី ៣ ជាបញ្ញត្តិស្ដីពីគឺការទទួលខុសត្រូវចំពោះការយឺតយ៉ាវក្នុងការបង់ប្រាក់តាមពេលកំណត់ ក្នុងករណីដែលកម្មវត្ថុនៃការវិនិយោគទ្រព្យធនជាប្រាក់ ។

(4) កថាខណ្ឌទី ៤ ចែងអំពីលទ្ធផលចំពោះក្រុមហ៊ុន ក្នុងករណីដែលសកម្មភាពនៃការបង្កើតរបស់អ្នកវិនិយោគខ្លះ ក្លាយទៅជាមោឃៈ ឬ ត្រូវបានលុបចោល ។ ដោយពិនិត្យមើលទៅតាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ព្រមទាំងការគោរពនូវឆន្ទៈភាគី គួរតែទទួលស្គាល់នូវអត្ថិភាពនៃក្រុមហ៊ុន តាមការដែលអាចធ្វើទៅបាន ហេតុនេះហើយបានជាបញ្ញត្តិនេះទទួលស្គាល់នូវការបង្កើតក្រុមហ៊ុនដោយបុគ្គលដែលជាភាគីដទៃ ទោះបីជាសកម្មភាពនៃការបង្កើតរបស់បុគ្គលណាម្នាក់ ក្លាយទៅជាមោឃៈ ឬ ត្រូវបានលុបចោលក៏ដោយ ។ ប៉ុន្តែ ប្រសិនបើគោលបំណងនៃក្រុមហ៊ុនមិនអាចសម្រេចបានដោយសារកង្វះបុគ្គលនោះ ការទទួលស្គាល់នូវអត្ថិភាពនៃក្រុមហ៊ុននោះនឹងបាត់បង់នូវអត្ថន័យ ហេតុនេះហើយ ក្នុងករណីនេះ ត្រូវចាត់ទុកថា ក្រុមហ៊ុននោះមិនត្រូវបានបង្កើតឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៦៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៨៤៦ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៧០១**.- កម្មសិទ្ធិអវិភាគនៃទ្រព្យសម្បត្តិក្រុមហ៊ុន

១-ទ្រព្យធនវិនិយោគរបស់សមាជិកក្រុមហ៊ុននីមួយៗ និង ទ្រព្យសម្បត្តិក្រុមហ៊ុនផ្សេងៗទៀត ត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សមាជិកក្រុមហ៊ុនទាំងអស់ ។

២-សមាជិកក្រុមហ៊ុន ពុំអាចទាមទារឱ្យបែងចែកទ្រព្យសម្បត្តិក្រុមហ៊ុន នៅមុនពេលធ្វើការជម្រះបញ្ជីរបស់ក្រុមហ៊ុន បានឡើយ ។ ប៉ុន្តែ ក្នុងករណីដែលសមាជិកទាំងអស់របស់ក្រុមហ៊ុន មានការព្រមព្រៀង ទោះបីជានៅមុនពេលធ្វើការជម្រះបញ្ជីក៏ដោយ ក៏អាចទាមទារឱ្យបែងចែកបានដែរ ។

៣-ការបែងចែកដែលបានកំណត់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ ខាងលើនេះ ពុំអាចយកមកតតាំងចំពោះតតិយជន ដែលបានធ្វើជំនួញជាមួយនឹងក្រុមហ៊ុន នៅមុនពេលធ្វើការបែងចែកនោះបានឡើយ ។

៤-សមាជិកក្រុមហ៊ុន ពុំអាចចាត់ចែងភាគដែលខ្លួនមាន ចំពោះទ្រព្យសម្បត្តិក្រុមហ៊ុននោះ បានឡើយ ។

(កំណត់)

(1) តាមធម្មតា ក្រុមហ៊ុនមានទ្រព្យសម្បត្តិផ្សេងៗ ដើម្បីសម្រេចនូវគោលដៅនៃកិច្ចការរបស់ខ្លួន ។ ទ្រព្យសម្បត្តិនេះត្រូវបានប្រើប្រាស់ និង គ្រប់គ្រង ដើម្បីសម្រេចនូវគោលបំណងនៃក្រុមហ៊ុន ហើយជាគ្រឹះនៃទំនុកចិត្តរបស់ក្រុមហ៊ុនដែលជាអង្គភាព (ដូចជាភាគី) នៃការជួញដូរ ។ ដូច្នេះហើយ ទោះបីជាក្រុមហ៊ុនមិនមែនជានីតិបុគ្គលក៏ដោយ ក៏ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន គួរតែគិតផ្សេងដោយឡែកពីទ្រព្យសម្បត្តិរបស់សមាជិកម្នាក់ៗនៃក្រុមហ៊ុននោះ ។ មាត្រានេះចែងច្បាស់លាស់អំពីបញ្ហានេះ ។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក្រុមហ៊ុនមិនមែនជានីតិបុគ្គលទេ ដូច្នេះហើយ ក្រុមហ៊ុនមិនអាចចុះបញ្ជីជាកម្មសិទ្ធិករអចលនវត្ថុក្នុងនាមខ្លួនបានឡើយ ។ ការចុះបញ្ជីអចលនវត្ថុរបស់ក្រុមហ៊ុនជាគោលការណ៍ ត្រូវធ្វើឡើងក្នុងរូបភាពជាកម្មសិទ្ធិអវិភាគរបស់សមាជិកទាំងអស់ ។ ប៉ុន្តែ បើធ្វើដូច្នេះ នឹងមានភាពស្មុគស្មាញចំពោះនីតិវិធី ។ មានករណីខ្លះដែលសមាជិកដែលអនុវត្តកិច្ចការម្នាក់ ក្នុងចំណោមសមាជិកក្រុមហ៊ុនឈរឈ្មោះចុះបញ្ជី ក្នុងនាមឯកជន ប៉ុន្តែ ភាគច្រើនអាចក្លាយទៅជាវិវាទ ។

(2) មាត្រានេះ កម្រិតអំពីការទាមទារឱ្យបែងចែកមុនការជម្រះបញ្ជី និង អំពីការចាត់ចែងភាគដែលខ្លួនមាន ហើយបញ្ជាក់អំពីខ្លឹមសារនៃការកម្រិតនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៦៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧១៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, កថាខណ្ឌទី ១ មាត្រា ៥៤៤ នៃច្បាប់ស្តីពីកាតព្វកិច្ចរបស់ស្វិស

## **មាត្រា ៧០២**.- វិធីអនុវត្តកិច្ចការ

១-ក្នុងករណីដែលពុំបានកំណត់សមាជិកក្រុមហ៊ុន ឬ តតិយជនទទួលអាណត្តិអនុវត្តកិច្ចការ នៅក្នុងកិច្ចសន្យាក្រុមហ៊ុនទេ សមាជិកនីមួយៗនៃក្រុមហ៊ុន មានសិទ្ធិអំណាចអនុវត្តកិច្ចការរបស់ក្រុមហ៊ុននោះ ។ ប៉ុន្តែ ការអនុវត្តកិច្ចការក្រុមហ៊ុន ត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកនោះ ។

២-ប្រសិនបើបានកំណត់ថាសមាជិកក្រុមហ៊ុន ឬ តតិយជនដែលទទួលអាណត្តិអនុវត្តកិច្ចការ នៅក្នុងកិច្ចសន្យាក្រុមហ៊ុន ត្រូវមានច្រើននាក់ ការអនុវត្តកិច្ចការក្រុមហ៊ុនត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកនោះ ។

៣-ទោះបីមានបញ្ញត្តិនៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះក៏ដោយ សមាជិកក្រុមហ៊ុននីមួយៗ ឬ អ្នកអនុវត្តកិច្ចការម្នាក់ៗ អាចអនុវត្តកិច្ចការប្រក្រតីរបស់ក្រុមហ៊ុនដោយឯកតោភាគីបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើសមាជិកនៃក្រុមហ៊ុន ឬ អ្នកអនុវត្តកិច្ចការផ្សេងទៀត បានបញ្ចេញមតិតវ៉ា នៅមុនពេលបញ្ចប់កិច្ចការនោះ ។

(កំណត់)

(1) ជាទូទៅ ក្រុមហ៊ុនភាគច្រើនដែលមានសមាជិកតិច មិនបានកំណត់អ្នកអនុវត្តកិច្ចការរបស់ក្រុមហ៊ុនទេ ។ ហេតុដូច្នេះ ក្នុងករណីដែលពុំមានការកំណត់នេះទេ ត្រូវចាត់ទុកថា សមាជិកម្នាក់ៗមានសិទ្ធិអនុវត្តកិច្ចការ (វាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ) ហើយការអនុវត្តកិច្ចការជាក់ស្តែងត្រូវធ្វើតាមសម្លេងលើសពាក់កណ្តាល (វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១) ។ ម្យ៉ាងទៀត ចំណុចដែលត្រូវប្រយ័ត្ន គឺ បញ្ហានៃសិទ្ធិអនុវត្តកិច្ចការជាបញ្ហាផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ រីឯបញ្ហាទំនាក់ទំនងខាងក្រៅស្តីពីសិទ្ធិតំណាងវិញ ត្រូវដោះស្រាយតាមបញ្ញត្តិស្តីពីការតំណាង (ការតំណាងក្រុមហ៊ុន) ទៅវិញ ។

(2) ម្យ៉ាងទៀត ចំពោះកិច្ចការស្រាលៗដែលក្រុមហ៊ុនត្រូវអនុវត្តដដែលៗរៀងរាល់ថ្ងៃវិញ មានន័យថាជាកិច្ចការប្រក្រតី ប្រសិនបើសមាជិកក្រុមហ៊ុនម្នាក់ៗអាចបំពេញរៀងៗខ្លួន នេះជាការល្អសម្រាប់ក្រុមហ៊ុន ហើយពុំមានអ្វីជាឧបសគ្គដល់ក្រុមហ៊ុនផង ។ ដូច្នេះហើយ កថាខណ្ឌទី ៣ បានចែងច្បាស់លាស់អំពីចំណុចនេះ ។ ក៏ប៉ុន្តែ ទោះបីជាកិច្ចការប្រក្រតីក៏ដោយ ក្នុងករណីដែលកិច្ចការនោះត្រូវបានអនុវត្តរៀងៗខ្លួន អាចមានឧបសគ្គដោយសារការវិនិច្ឆ័យរបស់សមាជិករៀងៗខ្លួននោះ ដូច្នេះហើយ ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ៣ ទទួលស្គាល់អំពីការតវ៉ាពីសមាជិកផ្សេងទៀត មុនពេលបញ្ចប់កិច្ចការនោះ ។ ទោះបីជាមានការតវ៉ាពីសមាជិកផ្សេងទៀតក៏ដោយ ប្រសិនបើសមាជិកនោះនៅតែបន្តការអនុវត្តកិច្ចការដូចគ្នាដដែល នោះសកម្មភាពរបស់សមាជិកដែលបានអនុវត្តកិច្ចការនេះក្លាយជាអំពើខុសច្បាប់ ហើយសមាជិកនេះត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាតចំពោះមុខសមាជិកផ្សេងទៀតរបស់ក្រុមហ៊ុន ។

(3) ក្រុមហ៊ុនពុំអាចយកឈ្មោះក្រុមហ៊ុនធ្វើជាដើមចោទបានឡើយ ដូច្នេះត្រូវជ្រើសរើសសមាជិកដែលអនុវត្តកិច្ចការរបស់ក្រុមហ៊ុន ជាដើម ជាភាគីដែលត្រូវបានជ្រើសរើស ឬ សមាជិកទាំងអស់ត្រូវដាក់ពាក្យបណ្តឹងក្នុងនាមជាសហដើមចោទ ។ ម្យ៉ាងទៀត ក្រុមហ៊ុនមិនអាចត្រូវបានប្តឹងជាចុងចម្លើយបានឡើយ ដូច្នេះហើយ បុគ្គលដែលមានបំណងប្តឹងក្រុមហ៊ុនត្រូវប្តឹងសមាជិកទាំងអស់ ក្នុងនាមជាសហចុងចម្លើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៧០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧០៩ និង មាត្រា ៧១០ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៨៥៩ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៥៣៥ នៃច្បាប់ស្តីពីកាតព្វកិច្ចរបស់ស្វីស

**មាត្រា ៧០៣.-** ការយកបញ្ញត្តិនៃអាណត្តិមកអនុវត្តដូចគ្នា

បញ្ញត្តិចាប់ពីមាត្រា ៦៤០ (ករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក) រហូតដល់មាត្រា ៦៤៦ (សិទ្ធិទាមទារឱ្យសងមកវិញ ជាអាទិ៍ នូវសោហ៊ុយរបស់អាណត្តិគាហក) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការរបស់ក្រុមហ៊ុន ។

(កំណត់)

ទំនាក់ទំនងគតិយុត្តរវាងអ្នកអនុវត្តកិច្ចការ និង ក្រុមហ៊ុន គឺជាកិច្ចសន្យាអាណត្តិ ឬ ប្រហាក់ប្រហែលនឹងកិច្ចសន្យាអាណត្តិដែរ ហេតុនេះហើយបញ្ញត្តិស្តីពីអាណត្តិ (ចាប់ពីមាត្រា ៦៤០ ដល់មាត្រា ៦៤៦) ត្រូវយកមកអនុវត្ត ដូចគ្នាផងដែរ ចំពោះទំនាក់ទំនងគតិយុត្តនោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៧១ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧០៨ និង មាត្រា ៧១៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៥៣៨ នៃច្បាប់ស្តីពីកាតព្វកិច្ចរបស់ស្វីស

**មាត្រា ៧០៤.-** ការលាឈប់ និង ការបញ្ឈប់សមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការ

១-ប្រសិនបើគ្មានមូលហេតុត្រឹមត្រូវទេ សមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការ ពុំអាចលាឈប់ ឬ ត្រូវបញ្ឈប់បានឡើយ ។

២-ដើម្បីបញ្ឈប់សមាជិកដែលអនុវត្តកិច្ចការរបស់ក្រុមហ៊ុន ដោយមានមូលហេតុត្រឹមត្រូវ ត្រូវមានសម្លេងយល់ព្រម លើសពីពាក់កណ្តាលនៃចំនួនសមាជិកផ្សេងទៀតរបស់ក្រុមហ៊ុន ។

(កំណត់)

(1) ក្នុងករណីដែលអ្នកអនុវត្តកិច្ចការដែលមិនមែនជាសមាជិកក្រុមហ៊ុន ត្រូវបានជ្រើសតាំងដោយកិច្ចសន្យាអាណត្តិ អ្នកអនុវត្តកិច្ចការនេះ អាចត្រូវបានបញ្ឈប់ នៅពេលណាក៏បានដែរ ក្រោមកិច្ចសន្យាអាណត្តិ (កថាខណ្ឌទី ១ នៃមាត្រា ៦៤៧) ។ ក៏ប៉ុន្តែ ក្នុងករណីដែលអ្នកអនុវត្តកិច្ចការត្រូវបានជ្រើសរើសក្នុងចំណោមសមាជិកក្រុមហ៊ុន តាមកិច្ចសន្យាក្រុមហ៊ុន ប្រសិនបើយើងអនុញ្ញាតឱ្យបញ្ឈប់អ្នកអនុវត្តកិច្ចការនោះដូចកិច្ចសន្យាអាណត្តិនេះទៅ នឹងធ្វើឱ្យឋានៈរបស់សមាជិកអនុវត្តកិច្ចការនោះពុំមានស្ថិរភាព ហើយអាចមានឥទ្ធិពលខ្លាំងទៅលើលទ្ធផលនៃការអនុវត្តកិច្ចការ ។ ផ្ទុយទៅវិញ ប្រសិនបើមិនទទួលស្គាល់ការលាលែងទេ នឹងធ្វើឱ្យមានការកម្រិតយ៉ាងខ្លាំងចំពោះសេរីភាពរបស់អ្នកអនុវត្ត

កិច្ចការ ដូច្នេះហើយ វាជាការមួយដែលមិនសមរម្យទេ ។ ដោយពិនិត្យដល់បញ្ហាទាំងនេះទៅ កថាខណ្ឌទី ១ នៃមាត្រានេះ បានចែងទទួលស្គាល់នូវការលាលែង និង ការបញ្ឈប់របស់អ្នកអនុវត្តកិច្ចការ ប្រសិនបើមានមូលហេតុត្រឹមត្រូវ ។ ម្យ៉ាងទៀត ដើម្បីបញ្ឈប់អ្នកអនុវត្តកិច្ចការដោយមានមូលហេតុត្រឹមត្រូវ ចាំបាច់ត្រូវមានសម្លេងយល់ព្រមរបស់សមាជិកផ្សេង លើសពាក់កណ្ដាល ។

(2) ក្នុងករណីដែលសមាជិកក្រុមហ៊ុនទាំងអស់អនុវត្តកិច្ចការក្រុមហ៊ុនវិញ បញ្ញត្តិនៃមាត្រានេះ មិនត្រូវយកមកអនុវត្តទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៧២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧១២ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៨៥៦ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៥៣២ នៃច្បាប់ស្ដីពីកាតព្វកិច្ចរបស់ស្វីស

## មាត្រា ៧០៥.- សិទ្ធិធ្វើការស្រាវជ្រាវលើកិច្ចការ និង ស្ថានភាពទ្រព្យសម្បត្តិ

ទោះបីជាគ្មានសិទ្ធិអំណាចក្នុងការអនុវត្តកិច្ចការរបស់ក្រុមហ៊ុនក៏ដោយ ក៏សមាជិកនីមួយៗរបស់ក្រុមហ៊ុន អាចធ្វើការស្រាវជ្រាវលើកិច្ចការ និង ស្ថានភាពទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននោះបានដែរ ។

(កំណត់)

(1) អាជីវកម្មរបស់ក្រុមហ៊ុន គឺជាអាជីវកម្មរួមរបស់សមាជិកទាំងអស់នៃក្រុមហ៊ុន ហើយទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន គឺជាកម្មសិទ្ធិអវិភាគរបស់សមាជិកក្រុមហ៊ុនទាំងអស់ ហេតុនេះហើយ សមាជិកដែលពុំមានសិទ្ធិអនុវត្តកិច្ចការ ចាំបាច់ត្រូវមានសិទ្ធិដឹងអំពីស្ថានភាពនៃការអនុវត្តកិច្ចការ ឬ ស្ថានភាពនៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ។ ដូច្នេះហើយ មាត្រានេះទទួលស្គាល់សិទ្ធិស្រាវជ្រាវអំពីកិច្ចការ និង អំពីទ្រព្យសម្បត្តិ ដើម្បីធានាសិទ្ធិដឹងនេះ ។

(2) សិទ្ធិស្រាវជ្រាវនេះ គឺជាសិទ្ធិមូលដ្ឋានរបស់សមាជិកក្រុមហ៊ុន ហេតុនេះហើយ មិនអាចបដិសេធសិទ្ធិនេះដោយការសន្យាពិសេសឡើយ ។ ក៏ប៉ុន្តែ ក្នុងករណីដែលសិទ្ធិស្រាវជ្រាវនោះត្រូវបានប្រើប្រាស់ ក្នុងគោលបំណងរារាំងកិច្ចការរបស់ក្រុមហ៊ុន ការប្រើប្រាស់សិទ្ធិអាចបដិសេធបាន ដើម្បីការពារកុំឱ្យមានការប្រើសិទ្ធិនេះដោយបំពាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៧៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧៧៦ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៥៤១ នៃច្បាប់ស្ដីពីកាតព្វកិច្ចរបស់ស្វីស

## មាត្រា ៧០៦.- សិទ្ធិទាមទារចែកចំណេញ ភាគនៃការបែងចែកការចំណេញ ខាត

១-សមាជិកក្រុមហ៊ុន ត្រូវគណនាការចំណេញ ខាត នៅក្នុងអំឡុងពេលទៀងទាត់ ហើយក្នុងករណីដែលមានចំណេញ អាចទាមទារឱ្យបែងចែកផលចំណេញនោះបាន ។

២-ប្រសិនបើសមាជិកក្រុមហ៊ុន មិនបានកំណត់ភាគនៃការបែងចែកការចំណេញ ខាតទេ ត្រូវកំណត់ទៅតាមសមាមាត្រនៃចំនួនតម្លៃវិនិយោគទ្រព្យធនរបស់សមាជិកនីមួយៗ នៃក្រុមហ៊ុននោះ ។

៣-ប្រសិនបើបានកំណត់តែភាគនៃការបែងចែកចំពោះការចំណេញ ខាតណាមួយ ត្រូវសន្មតថាភាគនោះ ដូចគ្នាទៅនឹងការខាតបង់ និង ការចំណេញ ។

(កំណត់)

ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន មិនមែនមានត្រឹមតែផលចំណេញដែលបានមកពីសកម្មភាពអាជីវកម្មរួមរបស់ក្រុមហ៊ុន ប៉ុណ្ណោះទេ គឺមានទាំងការខាតបង់ផងដែរ ហើយដែលជារបស់សមាជិកក្រុមហ៊ុនទាំងអស់ ។ ក៏ប៉ុន្តែ តាមស្ថានភាពផ្ទៃក្នុងរបស់ក្រុមហ៊ុន ជាទូទៅ គេធ្វើការបែងចែក ឬ ឱ្យសមាជិកម្នាក់ៗទទួលបន្ទុករៀងៗខ្លួន ។ ដោយឈរលើមូលដ្ឋាននេះ មាត្រានេះបានចែងអំពីសិទ្ធិទាមទារឱ្យធ្វើការបែងចែកផលចំណេញ (កថាខណ្ឌទី ១) ព្រមទាំងបានចែងកំណត់អំពីភាគនៃការបែងចែកចំណេញ និង ភាគនៃការទទួលបន្ទុកនូវការខាតបង់ផងដែរ (កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣) ។ ម្យ៉ាងទៀត ប្រសិនបើមានការព្រមព្រៀងរបស់សមាជិកទាំងអស់របស់ក្រុមហ៊ុន អំពីភាគនៃការបែងចែកចំណេញ ឬ ភាគនៃការទទួលបន្ទុកនូវការខាតបង់ ត្រូវអនុលោមតាមការព្រមព្រៀងនោះ ដោយមិនអនុវត្តមាត្រានេះ ។ លើសពីនេះ ការព្រមព្រៀងឱ្យសមាជិកណាម្នាក់មិនទទួលបន្ទុកនូវការខាតបង់សោះ មានសុពលភាព ក៏ប៉ុន្តែ ការព្រមព្រៀងដែលមិនបែងចែកចំណែកនៃផលចំណេញឱ្យសមាជិកណាម្នាក់ គួរតែត្រូវបានបកស្រាយថាជាការព្រមព្រៀងមោឃៈ ដោយសារយោងតាមគោលដៅនៃក្រុមហ៊ុនដែលត្រូវបានបង្កើតឡើងដើម្បីរកផលចំណេញនោះ ក្នុងករណីនេះ តាមផ្លូវរដ្ឋប្បវេណី មិនអាចហៅថាជាក្រុមហ៊ុនប្រកបកិច្ចការដោយសហការគ្នាបានទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១២៨៧ និង មាត្រា ១២៩២ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ៦៧៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧២២ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៨៤៤-១ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៥៣៣ នៃច្បាប់ស្តីពីកាតព្វកិច្ចរបស់ស្វីស

**មាត្រា ៧០៧**.- ភាគដែលត្រូវទទួលបន្ទុកនៃការខាតបង់របស់សមាជិកក្រុមហ៊ុន ចំពោះម្ចាស់បំណុល

១-កាតព្វកិច្ចដែលកើតឡើងដោយកិច្ចការរបស់ក្រុមហ៊ុន ជាកាតព្វកិច្ចដោយសាមគ្គីភាព ។ ប៉ុន្តែ កាតព្វកិច្ចនោះ ត្រូវសងដោយទ្រព្យសម្បត្តិក្រុមហ៊ុនសិន ហើយប្រសិនបើមិនអាចសងកាតព្វកិច្ចទាំងអស់ ដោយទ្រព្យសម្បត្តិក្រុមហ៊ុន ទើបសងដោយទ្រព្យដោយឡែករបស់សមាជិកនីមួយៗ ។

២-បន្ទុករបស់សមាជិកនីមួយៗ ត្រូវអនុលោមតាមសមាមាត្រនៃភាគវិនិយោគ លើកលែងតែមានការសន្យាពិសេស ។

(កំណត់)

(1) កាតព្វកិច្ចដែលកើតឡើងដោយសារកិច្ចការរបស់ក្រុមហ៊ុន អាចបែងចែកឱ្យសមាជិកក្រុមហ៊ុនម្នាក់ៗទទួលបន្ទុកបានដែរ ក៏ប៉ុន្តែ ការបែងចែកនេះនឹងធ្វើឱ្យខូចផលប្រយោជន៍ដល់ម្ចាស់បំណុលរបស់ក្រុមហ៊ុន ។ ដូច្នេះហើយ វាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ បានចែងថា កាតព្វកិច្ចរបស់ក្រុមហ៊ុន ជាកាតព្វកិច្ចដោយសាមគ្គីភាពរបស់សមាជិកម្នាក់ៗ ។ ក៏ប៉ុន្តែ ដើម្បីសងកាតព្វកិច្ច (យកមកធ្វើជា "ទ្រព្យសម្បត្តិទទួលខុសត្រូវ"[៥]) ជាបឋម ត្រូវប្រើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនជាមុន ហើយក្នុងករណីដែលមិនអាចសងកាតព្វកិច្ចឱ្យបានអស់ទេ ទ្រព្យសម្បត្តិដោយឡែករបស់សមាជិករៀងៗខ្លួន នឹងក្លាយទៅជាទ្រព្យសម្បត្តិទទួលខុសត្រូវ ។ ចំណុចនេះមានចែងច្បាស់លាស់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ។

(2) សមាជិកក្រុមហ៊ុនម្នាក់ៗ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ចរបស់ក្រុមហ៊ុន ក៏ប៉ុន្តែ តើសមាជិកម្នាក់ៗ ត្រូវទទួលបន្ទុកប៉ុន្មានភាគនោះ គឺជាបញ្ហាផ្ទៃក្នុងមួយ ។ ប្រសិនបើមានការសន្យាពិសេស ត្រូវអនុលោមតាមការសន្យាពិសេសនោះ ។ ក៏ប៉ុន្តែ សម្រាប់ករណីដែលពុំមានការសន្យាពិសេសទេ ចាំបាច់ត្រូវមានវិធានគោលមួយ ។ មានទស្សនៈខ្លះយល់ឃើញថា គួរតែឱ្យទទួលបន្ទុកស្មើភាពគ្នា ក៏ប៉ុន្តែ បើគិតទៅតាមសមាមាត្រនៃភាគវិនិយោគវិញ គឺជាការសមរម្យ ទៅតាមឆន្ទៈរបស់សមាជិកម្នាក់ៗ ហើយមានសមភាពផង ។ កថាខណ្ឌទី ២ ចែងបញ្ជាក់អំពីចំណុចនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៧៥ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៨៥៧ និង មាត្រា ១៨៥៨ នៃក្រមរដ្ឋប្បវេណីបារាំង, កថាខណ្ឌទី ៣ មាត្រា ៥៤៤ នៃច្បាប់ស្តីពីកាតព្វកិច្ចរបស់ស្វីស

## មាត្រា ៧០៨.- ការហាមឃាត់មិនឱ្យទូទាត់កាតព្វកិច្ចក្រុមហ៊ុន

[៥] ចំពោះពាក្យ "ទ្រព្យសម្បត្តិទទួលខុសត្រូវ" សូមមើលកថាភាគទី ១ ផ្នែកទី ៣ ជំពូកទី ២ នៃ "សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ២ : ការអនុវត្តដោយបង្ខំ និង ការចាត់ចែងរក្សាការពារ" (ក្រសួងយុត្តិធម៌ ២០០៩) ។

កូនបំណុលរបស់ក្រុមហ៊ុន ពុំអាចទូទាត់កាតព្វកិច្ចនោះ ជាមួយនឹងសិទ្ធិលើបំណុល ចំពោះសមាជិកនីមួយៗនៃក្រុមហ៊ុន បានឡើយ ។

(កំណត់)

ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន មិនមែនត្រូវបែងចែកទៅឱ្យសមាជិកម្នាក់ៗទេ គឺជាកម្មសិទ្ធិអវិភាគរបស់សមាជិកក្រុមហ៊ុនទាំងអស់ ។ បើមិនធ្វើដូចនេះទេ នឹងមានការពិបាកក្នុងការអនុវត្តកិច្ចការរបស់ក្រុមហ៊ុន ។ ដូច្នេះ ប្រសិនបើយកគំនិតនេះ មកធ្វើជាមូលដ្ឋាន មិនត្រូវទទួលស្គាល់ឱ្យកូនបំណុលនៃក្រុមហ៊ុនយកសិទ្ធិលើបំណុលដែលខ្លួនមានចំពោះសមាជិកម្នាក់ មកធ្វើការទូទាត់កាតព្វកិច្ចរបស់ខ្លួនដែលមានចំពោះក្រុមហ៊ុននោះឡើយ (មិនត្រូវទទួលស្គាល់ឱ្យកូនបំណុលនៃក្រុមហ៊ុនយកសិទ្ធិលើបំណុលដែលខ្លួនមានចំពោះសមាជិកម្នាក់ មកធ្វើជាសិទ្ធិលើបំណុលដែលផ្ដើមការទូទាត់ឡើយ) ។ មាត្រានេះបានចែងអំពីចំណុចនេះ ។ ម្យ៉ាងទៀត មាត្រានេះមានគោលគំនិតដូចគ្នានឹងមាត្រា ៧០១ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៧៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, កថាខណ្ឌទី ២ មាត្រា ៧១៩ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៧០៩.**- ការដកខ្លួនដោយស្ម័គ្រចិត្ត

១-ប្រសិនបើពុំបានកំណត់អំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុននៅក្នុងកិច្ចសន្យាក្រុមហ៊ុនទេ ឬ បើបានកំណត់អត្ថិភាពដែលក្រុមហ៊ុនត្រូវមាន ក្នុងរយៈពេលមួយជីវិតរបស់សមាជិកណាម្នាក់ សមាជិកនីមួយៗ អាចដកខ្លួនចេញ នៅពេលណាក៏បាន ។ ប៉ុន្តែការដកខ្លួននេះ ពុំអាចធ្វើបានឡើយ បើបណ្ដាលឱ្យខូចផលប្រយោជន៍ដល់ក្រុមហ៊ុន លើកលែងតែក្នុងករណីដែលពុំអាចជៀសវាងបាន ។

២-ទោះបីជាបានកំណត់អំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុនក៏ដោយ នៅក្នុងករណីដែលពុំអាចជៀសវាងបាន សមាជិកនីមួយៗ អាចដកខ្លួនបាន ។

៣-ការដកខ្លួនអាចធ្វើទៅបាន ដោយការបង្ហាញឆន្ទៈ ចំពោះសមាជិកផ្សេងទៀតទាំងអស់របស់ក្រុមហ៊ុន ។

(កំណត់)

មាត្រានេះបានចែងថា សមាជិកម្នាក់ៗអាចសុំដកខ្លួនពីក្រុមហ៊ុនបានដោយស្ម័គ្រចិត្តបាន ហើយបានចែងអំពីល័ក្ខខ័ណ្ឌ និង វិធីដកខ្លួនចេញផងដែរ ។ ការដកខ្លួនដោយស្ម័គ្រចិត្តនេះអាចធ្វើបាន ដោយការបង្ហាញឆន្ទៈរបស់ខ្លួន ចំពោះសមាជិកផ្សេងៗ (កថាខណ្ឌទី ៣) ហើយចំពោះល័ក្ខខ័ណ្ឌវិញ ក្នុងករណីដែលមានកំណត់អំពីអំឡុងពេលដែលក្រុមហ៊ុនមាន

អត្ថិភាព ក្រៅពីអំឡុងពេលមួយជីវិតរបស់សមាជិកណាម្នាក់ សមាជិកអាចដកខ្លួនបានក្នុងករណីដែលមានហេតុដែល "ពុំអាចជៀសវាងបាន" ហើយក្រៅពីករណីនេះ សមាជិកអាចដកខ្លួនបាន នៅពេលដែលការដកខ្លួននោះ "បណ្តាលឱ្យខូចផលប្រយោជន៍ដល់ក្រុមហ៊ុន" ឬ ទោះជាចំពេលដែលធ្វើឱ្យខូចផលប្រយោជន៍ក្រុមហ៊ុនក៏ដោយ តែប្រសិនបើមានហេតុដែល "មិនអាចជៀសវាងបាន" ក៏អាចដកខ្លួនបានដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៧៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧២៣, មាត្រា ៧២៤ និង មាត្រា ៧៣៦ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៧១០.- ការដកខ្លួនតាមច្បាប់

ក្រៅពីបញ្ញត្តិដែលបានកំណត់នៅក្នុងមាត្រា ៧០៩ (ការដកខ្លួនដោយស្ម័គ្រចិត្ត) ខាងលើ សមាជិកក្រុមហ៊ុន ត្រូវដកខ្លួន ដោយមូលហេតុណាមួយ ដូចខាងក្រោមនេះ :

ក-មរណភាព ។

ខ-ធនក្ស័យ ។

គ-បានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ។

ឃ-ការលុបឈ្មោះ ។

(កំណត់)

(1) មាត្រានេះចែងអំពីការដកខ្លួនរបស់សមាជិកក្រុមហ៊ុនតាមច្បាប់ ។

(2) ទោះបីជាសមាជិកក្រុមហ៊ុនបានទទួលមរណភាព ហើយសមាជិកនោះលែងមានអត្ថិភាពក៏ដោយ ក៏មាត្រានេះចែងថា មរណភាពនេះជាមូលហេតុនៃការដកខ្លួន ។ មានន័យថា សន្តតិជនរបស់សមាជិកក្រុមហ៊ុននោះមិនត្រូវទទួលបន្តដោយស្វ័យប្រវត្តិ នូវឋានៈជាសមាជិកក្រុមហ៊ុននោះទេ ។ តាមធម្មតា ទំនុកចិត្តរវាងសមាជិក និង សមាជិក មានសារៈសំខាន់ណាស់សម្រាប់ក្រុមហ៊ុន ដូច្នេះហើយ ប្រសិនបើឱ្យសន្តតិជនរបស់សមាជិកដែលទទួលមរណភាព ស្នងបន្តដោយស្វ័យប្រវត្តិនូវឋានៈជាសមាជិកទៅ នឹងអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់អត្ថិភាពនៃក្រុមហ៊ុន ។ ហេតុនេះហើយ មាត្រានេះបានចែងថា មរណភាព គឺជាមូលហេតុនៃការដកខ្លួនចេញពីក្រុមហ៊ុន ។ ម្យ៉ាងទៀត ប្រសិនបើមានកំណត់ជាមុននៅក្នុងកិច្ចសន្យាក្រុមហ៊ុនថា ឱ្យសន្តតិជនរបស់សមាជិកស្នងបន្តនូវឋានៈជាសមាជិក នោះការស្នងបន្តនោះត្រូវបានទទួលស្គាល់ ។ នេះគឺដោយសារតែការយកមរណភាពជាមូលហេតុនៃការដកខ្លួននេះ គឺដើម្បីការពារផលប្រយោជន៍របស់សមាជិកផ្សេងទៀត ហើយប្រសិនបើបានកំណត់ជាមុននូវការស្នងបន្តនេះដោយកិច្ចសន្យាក្រុមហ៊ុន មិនធ្វើឱ្យបាត់បង់នូវផលប្រយោជន៍របស់សមាជិកផ្សេងទេ ។

(3) ចំពោះធនក្ស័យវិញ ចំណែករបស់សមាជិកធនក្ស័យនោះ ចាំបាច់ត្រូវទុកសម្រាប់សងកាតព្វកិច្ច ដើម្បីការពារម្ចាស់បំណុលធនក្ស័យ (ម្ចាស់បំណុលរបស់សមាជិកធនក្ស័យ) នោះ ហេតុដូច្នេះ មិនអាចបង្កើតការសន្យាពិសេសដែលអនុញ្ញាតឱ្យជនធនក្ស័យ នៅជាសមាជិក នៅក្នុងកិច្ចសន្យាក្រុមហ៊ុនបានទេ ។

(4) មាត្រានេះចែងថា ការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ គឺជាមូលហេតុនៃការដកខ្លួនពីក្រុមហ៊ុន ដើម្បីការពារផលប្រយោជន៍របស់សមាជិកផ្សេងទៀត ។ ហេតុដូច្នេះ ប្រសិនបើមានការសន្យាពិសេសក្នុងកិច្ចសន្យាក្រុមហ៊ុន ការប្រកាសចាប់ផ្តើមអាណាព្យាបាលនេះ អាចត្រូវបានចេញពីមូលហេតុនៃការដកខ្លួនបាន ។

(5) ចំពោះការលុបឈ្មោះវិញ សូមមើលមាត្រា ៧១១ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៧៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧២៣, មាត្រា ៧២៧, មាត្រា ៧២៨, មាត្រា ៧៣៦ និង មាត្រា ៧៣៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៥៤៥ នៃច្បាប់ស្តីពីកាតព្វកិច្ចរបស់ស្វីស

## **មាត្រា ៧១១**.- ការលុបឈ្មោះ

ការលុបឈ្មោះសមាជិកក្រុមហ៊ុន អាចអនុវត្តបាន ដោយមតិយល់ព្រមជាឯកច្ឆន្ទពីសមាជិកផ្សេងទៀតទាំងអស់របស់ក្រុមហ៊ុន តែក្នុងករណីដែលមានមូលហេតុត្រឹមត្រូវប៉ុណ្ណោះ ។ ប៉ុន្តែ បើមិនបានជូនដំណឹងពីការលុបឈ្មោះ ដល់សមាជិកក្រុមហ៊ុនដែលត្រូវបានលុបឈ្មោះទេ ពុំអាចយកទៅតតាំងជាមួយនឹងសមាជិកក្រុមហ៊ុនដែលត្រូវបានលុបឈ្មោះនោះ បានឡើយ ។

(កំណត់)

(1) ការលុបឈ្មោះ ដែលជាការដកលក្ខណសម្បត្តិរបស់សមាជិកក្រុមហ៊ុនដោយបង្ខំ ដោយសមាជិកក្រុមហ៊ុនផ្សេងទៀត គឺជាវិធីមួយដែលធ្វើឱ្យខូចផលប្រយោជន៍របស់សមាជិកដែលត្រូវលុបឈ្មោះនោះ ។ ផ្ទុយទៅវិញ ចំពោះក្រុមហ៊ុនដែលយកទំនុកចិត្តរវាងសមាជិកទាំងអស់មកធ្វើជាមូលដ្ឋានវិញ ប្រសិនបើទុកឋានៈសមាជិកដែលបាត់បង់នូវទំនុកចិត្ត ឱ្យនៅដដែលនៅក្នុងក្រុមហ៊ុននោះទៅ មិនមែនជាការល្អចំពោះដំណើរការនៃកិច្ចការរួមរបស់ក្រុមហ៊ុននោះទេ ។ ដូច្នេះហើយ មាត្រានេះចែងអំពីល័ក្ខខ័ណ្ឌនៃការលុបឈ្មោះ ដើម្បីសម្របសម្រួលផលប្រយោជន៍ទាំងពីរនេះ ។

(2) មាត្រានេះ បានចែងថា ក្នុងករណីដែលមាន "មូលហេតុត្រឹមត្រូវ" ការលុបឈ្មោះអាចធ្វើបាន "ដោយមតិយល់ព្រមជាឯកច្ឆន្ទ ពីសមាជិកផ្សេងទៀតទាំងអស់" ហើយអានុភាពនៃការលុបឈ្មោះនេះ មិនអាចតតាំងនឹងសមាជិកដែលត្រូវបានលុបឈ្មោះបានទេ ប្រសិនបើមិនបានជូនដំណឹងទៅឱ្យសមាជិកនោះ ។ ម្យ៉ាងទៀត ចំពោះការលុបឈ្មោះ មានមតិខ្លះថា គួរតែទាមទារឱ្យមានសាលក្រម ឬ សាលដីការបស់តុលាការ ក៏ប៉ុន្តែ ប្រសិនបើបានធ្វើការជូនដំណឹងអំពីការលុបឈ្មោះ

ក្នុងករណីដែលសមាជិកដែលត្រូវបានលុបឈ្មោះនោះមិនពេញចិត្ត សមាជិកនោះអាចដាក់ពាក្យបណ្ដឹងទៅតុលាការបាន ហើយអាចទទួលលទ្ធផលដូចគ្នាបានដែរ ហេតុដូច្នេះ នៅក្នុងមាត្រានេះ មិនបានយកសាលក្រម ឬ សាលដីការបស់តុលាការ មកធ្វើជាល័ក្ខខ័ណ្ឌនៃការលុបឈ្មោះទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៨០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៣៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៧១២**.- ការសងវិញ នូវចំណែករបស់សមាជិកក្រុមហ៊ុន ដែលដកខ្លួន

១-ការគណនារវាងសមាជិកក្រុមហ៊ុនដែលបានដកខ្លួន និង សមាជិកផ្សេងទៀតរបស់ក្រុមហ៊ុន ចាំបាច់ត្រូវអនុវត្ត ដោយផ្អែកតាមស្ថានភាពនៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននៅពេលដែលដកខ្លួននោះ ។

២-ចំណែកដែលសមាជិកក្រុមហ៊ុនដែលបានដកខ្លួននោះមាន អាចសងវិញជាប្រាក់បាន ដោយពុំគិតពីប្រភេទនៃទ្រព្យធនដែលវិនិយោគនោះឡើយ ។

៣-ចំពោះចំណុចដែលពុំទាន់បានបញ្ចប់ នៅពេលដកខ្លួន អាចគណនាបាន នៅក្រោយពេលធ្វើការបញ្ចប់នោះ ។

៤-ការសងចំណែកដែលមាន ទៅសមាជិកក្រុមហ៊ុនដែលត្រូវបានលុបឈ្មោះ ត្រូវភ្ជាប់ការប្រាក់ តាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ចំពោះអំឡុងពេលគិតចាប់ពីពេលដែលបានជូនដំណឹងអំពីការលុបឈ្មោះ រហូតដល់ពេលដែលបានសងវិញ ។

(កំណត់)

(1) អតីតសមាជិកក្រុមហ៊ុនដែលបានបាត់បង់នូវលក្ខណសម្បត្តិជាសមាជិក ត្រូវបាត់បង់នូវសិទ្ធិ ព្រមទាំងកាតព្វកិច្ចវិនិយោគរបស់សមាជិកក្រុមហ៊ុន ។ ហេតុនេះហើយ ចាំបាច់ត្រូវគណនាទ្រព្យសម្បត្តិរវាងសមាជិកនេះ និង ក្រុមហ៊ុន ។ នេះគឺជាការសងវិញនូវចំណែករបស់សមាជិក ។

(2) មាត្រានេះចែងអំពីការសងនូវចំណែករបស់សមាជិក ។ ការសងនូវចំណែករបស់សមាជិកត្រូវធ្វើទៅតាមស្ថានភាពនៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនពេលដកខ្លួនចេញនោះ ហើយអាចសងជាសាច់ប្រាក់បាន ។ ម្យ៉ាងទៀត ពេលដែលសមាជិកបានដកខ្លួនចេញ ប្រសិនបើមានការពិបាកក្នុងការគណនាដោយសារកិច្ចការរបស់ក្រុនហ៊ុនមិនទាន់បានបញ្ចប់ទេ អាចធ្វើការគណនាក្រោយពេលកិច្ចការនោះបញ្ចប់បាន ។

(3) ម្យ៉ាងទៀត ចំពោះការសងវិញនូវចំណែករបស់សមាជិកដែលត្រូវបានលុបឈ្មោះ ត្រូវបូកបន្ថែមនូវការប្រាក់ ដោយគិតពីថ្ងៃដែលបានជូនដំណឹងអំពីការលុបឈ្មោះនោះ ដល់ថ្ងៃដែលបានសងចំណែកនោះ ។ ក្នុងករណីនៃការលុបឈ្មោះ

អាចនឹងមានវិវាទច្រើនពាក់ព័ន្ធនឹងការលុបឈ្មោះនេះ ហើយត្រូវការពេលវេលាយូរដើម្បីដោះស្រាយ ដូច្នេះហើយ ដើម្បីជៀសវាងនូវការបាតបង់ផលប្រយោជន៍របស់សមាជិកដែលត្រូវគេលុបឈ្មោះចោលនោះ ទើបមានការចែងដូចកថាខណ្ឌទី ៤ នៃមាត្រានេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៨១ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧៣៨ និង កថាខណ្ឌទី ២ មាត្រា ៧៤០ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៧១៣**.- ការរំលាយក្រុមហ៊ុន

១-ក្រុមហ៊ុន ត្រូវរំលាយតាមករណីណាមួយ ដូចកំណត់ខាងក្រោមនេះ :

ក-ការបញ្ចប់កិច្ចការដែលជាកម្មវត្ថុរបស់ក្រុមហ៊ុន ឬ អលទ្ធភាពក្នុងការបំពេញកិច្ចការនោះ ។

ខ-បើមានការព្រមព្រៀងពីសមាជិកទាំងអស់របស់ក្រុមហ៊ុន ។

គ-បើនៅសល់សមាជិកក្រុមហ៊ុន តែម្នាក់ ។

ឃ-បើអំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុន ដែលកំណត់នៅក្នុងកិច្ចសន្យាក្រុមហ៊ុន ត្រូវបានបញ្ចប់ ។

២-ក្នុងករណីដែលមានមូលហេតុមិនអាចជៀសវាងបាន សមាជិកនីមួយៗរបស់ក្រុមហ៊ុន អាចទាមទារឱ្យរំលាយក្រុមហ៊ុនបាន ។

៣-ការទាមទារនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើដោយការបង្ហាញឆន្ទៈ ចំពោះសមាជិកផ្សេងទៀតទាំងអស់ របស់ក្រុមហ៊ុន ។

(កំណត់)

(1) ការរំលាយក្រុមហ៊ុន រំសាយចំណងរបស់សមាជិក បញ្ចប់ និង រំលាយទំនាក់ទំនងគតិយុត្តដែលត្រូវបានកសាងឡើង ហើយតម្រូវឱ្យត្រៀមចាប់ផ្ដើមជម្រះបញ្ជី ។ មាត្រានេះចែងអំពីមូលហេតុ និង វិធីរំលាយក្រុមហ៊ុន ។

(2) ចំណុច ក នៃកថាខណ្ឌទី ១ ចែងអំពីករណីបញ្ចប់កិច្ចការដែលជាគោលបំណងនៃក្រុមហ៊ុន ឬ កិច្ចការនោះមិនអាចសម្រេចបាន ។ ពេលបានបញ្ចប់កិច្ចការ គោលបំណងរបស់ក្រុមហ៊ុននោះត្រូវបានសម្រេច ដូច្នេះហើយមិនចាំបាច់ឱ្យមានអត្ថិភាពបន្តទៀតទេ ហើយក្នុងករណីនៃអលទ្ធភាពក្នុងការបំពេញកិច្ចការនោះ ក៏គ្មានអត្ថន័យអ្វីឱ្យមានអត្ថិភាពបន្តទៀតដែរ ។

(3) ចំណុច ខ នៃកថាខណ្ឌទី ១ ចែងអំពីករណីដែលមានការព្រមព្រៀងពីសមាជិកទាំងអស់ ។ ប្រសិនបើមានការព្រមព្រៀងពីសមាជិកទាំងអស់គ្នា លែងមានអត្ថន័យអ្វីនឹងទុកឱ្យមានអត្ថិភាពបន្តទៀតទេ ។ ម្យ៉ាងទៀត ការព្រមព្រៀង

នេះមិនចាំបាច់ធ្វើជាលាយល័ក្ខណ៍អក្សរទេ ។ ក្រោយពីបានរំលាយ នៅរង់ចាំតែធ្វើការជម្រះបញ្ជីដើម្បីរំលត់ខ្លួនប៉ុណ្ណោះ ដូច្នេះហើយមិនចាំបាច់ទាមទារឱ្យធ្វើជាលាយល័ក្ខណ៍អក្សរឡើយ ។

(4) ចំណុច គ នៃកថាខណ្ឌទី ១ ចែងអំពីករណីដែលសមាជិកក្រុមហ៊ុនបែរជានៅតែម្នាក់ ហើយបានបាត់បង់នូវលក្ខណៈសារធាតុជាក្រុម ។ យើងអាចទទួលស្គាល់ក្រុមហ៊ុនដែលមានសមាជិកតែម្នាក់ក៏បានដែរ ក៏ប៉ុន្តែ ពុំមានផលប្រយោជន៍ក្នុងការទទួលស្គាល់ក្រុមហ៊ុនដែលមានសមាជិកតែម្នាក់ឡើយ ។ ម្យ៉ាងទៀត ពេលដែលភាគីនៃកិច្ចសន្យាក្រុមហ៊ុនមានតែម្នាក់ កិច្ចសន្យានោះអាចចាត់ទុកថាបានរលត់ក៏បានដែរ ប៉ុន្តែ មាត្រានេះបានចាត់ទុកករណីនេះថាជាទម្រង់មួយនៃការរំលាយដែរ ។

(5) ចំណុច ឃ នៃកថាខណ្ឌទី ១ ចែងអំពីករណីដែលអំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុន ដែលកំណត់នៅក្នុងកិច្ចសន្យាក្រុមហ៊ុន ត្រូវបានបញ្ចប់ ។ ដោយសារតែបានធ្វើការកំណត់នូវអំឡុងពេលដែលមានអត្ថិភាពក្នុងកិច្ចសន្យាក្រុមហ៊ុន គ្មានបញ្ហាអ្វីដែរក្នុងការចែងថា ក្រុមហ៊ុននោះនឹងចូលដល់ដំណាក់កាលត្រៀមរំលត់ខ្លួន នៅពេលបញ្ចប់អំឡុងពេលនោះ តាមកិច្ចសន្យាក្រុមហ៊ុននោះទេ ។

(6) កថាខណ្ឌទី ២ ចែងអំពីការទាមទារឱ្យរំលាយពីសមាជិក ។ ក្នុងនេះ មានចែងថា សមាជិកអាចទាមទារឱ្យរំលាយក្រុនហ៊ុនបានដោយការបង្ហាញឆន្ទៈរបស់ខ្លួនចំពោះសមាជិកផ្សេងទៀត ដោយយកអត្ថិភាពនៃមូលហេតុមិនអាចជៀសវាងបាន មកធ្វើជាល័ក្ខខ័ណ្ឌ ។ មូលហេតុដែលមិនអាចជៀសវាងបាន មានដូចជា ករណីដែលមានការលំបាកខ្លាំងក្នុងការបន្តធ្វើកិច្ចការរបស់ក្រុមហ៊ុន ដោយសារការមិនចុះសំរុងគ្នារវាងសមាជិក ការផ្លាស់ប្តូរនៃស្ថានភាពសេដ្ឋកិច្ច ឬ ការផ្លាស់ប្តូរនៃស្ថានភាពទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ជាអាទិ៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៨២ និង មាត្រា ៦៨៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៧២៦ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៧១៤.- ភាពគ្មានប្រតិសកម្មនៃការរំលាយ

ការរំលាយក្រុមហ៊ុន ពុំមានអានុភាពប្រតិសកម្មឡើយ ។

(កំណត់)

ការអនុវត្តប្រតិសកម្មនូវអានុភាពនៃការរំលាយក្រុមហ៊ុន នឹងធ្វើឱ្យទំនាក់ទំនងគតិយុត្តកាន់តែស្មុគស្មាញទៅ ហេតុនេះហើយ គ្រាន់តែឱ្យមានអានុភាពឆ្ពោះទៅអនាគតតែប៉ុណ្ណោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៨៤ នៃក្រមរដ្ឋប្បវេណីជប៉ុន

## មាត្រា ៧១៥.- អ្នកជម្រះបញ្ជី

១-ប្រសិនបើក្រុមហ៊ុនត្រូវបានរំលាយ ការជម្រះបញ្ជីត្រូវធ្វើ ដោយសហការគ្នារវាងសមាជិកទាំងអស់របស់ក្រុមហ៊ុន ឬ ដោយអ្នកជម្រះបញ្ជី ដែលត្រូវបានជ្រើសតាំងដោយសមាជិកក្រុមហ៊ុន ។

២-ការជ្រើសតាំងអ្នកជម្រះបញ្ជីនៃកថាខណ្ឌទី ១ ខាងលើនេះ ក្នុងករណីដែលគ្មានកំណត់ពិសេសនៅក្នុងកិច្ចសន្យាក្រុមហ៊ុនទេ ត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមហ៊ុននោះ ។

(កំណត់)

ដូចដែលបានពន្យល់រួចមកហើយ ការរំលាយមានន័យថា ការចាប់ផ្តើមធ្វើសកម្មភាពដើម្បីរំលត់ក្រុមហ៊ុន ។ ដើម្បីរំលត់ក្រុមហ៊ុននាអនាគត ចាំបាច់ត្រូវជម្រះបញ្ជីទ្រព្យសម្បត្តិ ហើយដើម្បីធ្វើការងារនេះ ត្រូវតែកំណត់អ្នកជម្រះបញ្ជី ។ នេះគឺជាគោលគំនិតដូចអ្នកអនុវត្តកិច្ចការដែរ ។ ដូច្នេះហើយ សមាជិកម្នាក់ៗ ត្រូវធ្វើការងារជម្រះបញ្ជី ដោយសហការគ្នា ឬ ជ្រើសតាំងអ្នកជម្រះបញ្ជី ដើម្បីឱ្យធ្វើការងារជម្រះបញ្ជី ។ ម្យ៉ាងទៀត កថាខណ្ឌទី ២ ចែងអំពីនីតិវិធីជ្រើសតាំងអ្នកជម្រះបញ្ជី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៨៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧១៦**.- ការអនុវត្តកិច្ចការរបស់អ្នកជម្រះបញ្ជី

បញ្ញត្តិនៃមាត្រា ៧០២ (វិធីអនុវត្តកិច្ចការ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលអ្នកជម្រះបញ្ជី មានចំនួនច្រើននាក់ ។

(កំណត់)

ដូចដែលបានពន្យល់ក្នុងមាត្រា ៧១៥ ដែរ អ្នកជម្រះបញ្ជីមានសិទ្ធិអំណាចត្រឹមតែធ្វើសកម្មភាពដើម្បីជម្រះបញ្ជីប៉ុណ្ណោះ ក៏ប៉ុន្តែ ឋានៈរបស់អ្នកនោះប្រហាក់ប្រហែលគ្នានឹងឋានៈរបស់អ្នកអនុវត្តកិច្ចការដែរ ។ ហេតុនេះហើយ ក្នុងករណីដែលមានអ្នកជម្រះបញ្ជីច្រើនរូប បញ្ញត្តិនៃមាត្រា ៧០២ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៨៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧១៧**.- ការលាឈប់ និង ការបញ្ឈប់អ្នកជម្រះបញ្ជី

បញ្ញត្តិនៃមាត្រា ៧០៤ (ការលាឈប់ និង ការបញ្ឈប់សមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលសមាជិកទាំងអស់របស់ក្រុមហ៊ុន បានព្រមព្រៀងជ្រើសតាំងអ្នកជម្រះបញ្ជី ពីក្នុងចំណោមសមាជិកក្រុមហ៊ុននោះ ។

(កំណត់)

ស្តីពីឋានៈរបស់អ្នកជម្រះបញ្ជី មានពន្យល់នៅក្នុងមាត្រា ៧១៥ និង មាត្រា ៧១៦ ហើយ ។ ហេតុនេះហើយ ចំពោះការលាឈប់ និង ការបញ្ឈប់អ្នកជម្រះបញ្ជី ដែលត្រូវបានជ្រើសតាំងដោយការព្រមព្រៀងរបស់សមាជិកក្រុមហ៊ុន មាត្រា ៧០៤ ស្តីពីអ្នកអនុវត្តកិច្ចការដែលត្រូវបានជ្រើសតាំងដោយកិច្ចសន្យាក្រុមហ៊ុន ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៨៧ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧១៨**.- មុខងារ និង សិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជី វិធីបែងចែកទ្រព្យសម្បត្តិដែលនៅសេសសល់

១-បញ្ញត្តិនៃមាត្រា ៧១ (មុខងារ និង សិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជី) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមុខនាទី និង សិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជី ។

២-ទ្រព្យសម្បត្តិដែលនៅសេសសល់ ត្រូវបែងចែកដោយសមាមាត្រតាមតម្លៃនៃទ្រព្យធនដែលសមាជិកនីមួយៗរបស់ក្រុមហ៊ុន បានវិនិយោគ ។

(កំណត់)

ចំពោះមុខងារ និង សិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជីក្រុមហ៊ុន បញ្ញត្តិស្តីពីអ្នកជម្រះបញ្ជីនីតិបុគ្គល ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយសារតែការងាររបស់អ្នកទាំងពីរនេះមានលក្ខណៈដូចគ្នា ។

ម្យ៉ាងទៀត ពេលជម្រះបញ្ជីហើយ ហើយទ្រព្យសម្បត្តិនៅសល់ ត្រូវបែងចែកទៅឱ្យសមាជិកទៅតាមចំនួនទឹកប្រាក់នៃការវិនិយោគរបស់សមាជិកម្នាក់ៗ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៨៨ នៃក្រមរដ្ឋប្បវេណីជប៉ុន

## ជំពូកទី ១២ កិច្ចសន្យាធនលាភសោធនមួយជីវិត

**មាត្រា ៧៦៩.-** និយមន័យនៃកិច្ចសន្យាធនលាភសាមយិកមួយជីវិត

១-កិច្ចសន្យាធនលាភសាមយិកមួយជីវិត សំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងជាកូនបំណុលនៃធនលាភ សន្យាថា មានករណីយកិច្ចត្រូវផ្តល់តាវកាលិកជាប្រាក់តាមពេលកំណត់ទៀងទាត់ ទៅឱ្យភាគីម្ខាងទៀតដែលជាម្ចាស់បំណុល ឬ តតិយជននៃធនលាភ រហូតដល់ពេលដែលខ្លួនផ្ទាល់ ភាគីម្ខាងទៀត ឬ តតិយជនបានទទួលមរណភាព ហើយភាគីម្ខាងទៀត សន្យាថាមានករណីយកិច្ចទទួលបន្ទុកផ្តល់តាវកាលិកនូវប្រាក់ដើមដែលជាតម្លៃថ្នូរនោះ ។

២-កិច្ចសន្យាធនលាភសាមយិកមួយជីវិត ប្រសិនបើពុំបានធ្វើជាលាយល័ក្ខណ៍អក្សរទេ ពុំមានអានុភាពឡើយ ។

៣-ម្ចាស់បំណុលនៃធនលាភ ត្រូវទទួលបាននូវឯកសិទ្ធិលើចលនវត្ថុ និង អចលនវត្ថុ ក្នុងចំណោមប្រាក់ដើមដែលខ្លួនបានផ្តល់តាវកាលិកឱ្យទៅភាគីម្ខាងទៀតដើម្បីសិទ្ធិលើបំណុលនៃធនលាភនោះ ។ ឯកសិទ្ធិដែលម្ចាស់បំណុលនៃធនលាភត្រូវទទួល ត្រូវបានចាត់ទុកថាជាឯកសិទ្ធិដែលបានកំណត់នៅក្នុងមាត្រា ៧៩៧ (ឯកសិទ្ធិចំពោះការលក់ចលនវត្ថុ) ឬ មាត្រា ៨០២ (ឯកសិទ្ធិចំពោះការលក់អចលនវត្ថុ) តាមប្រភេទនៃវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិនោះ ។

(កំណត់)

(1) កិច្ចសន្យាធនលាភសាមយិកមួយជីវិត គឺជាកិច្ចសន្យាមួយដែលតម្រូវឱ្យកូនបំណុលនៃធនលាភ បំពេញករណីយកិច្ចផ្តល់តាវកាលិកជាប្រាក់ឱ្យម្ចាស់បំណុលនៃធនលាភ តាមពេលកំណត់ទៀងទាត់ រហូតដល់ម្ចាស់បំណុលនៃធនលាភនោះទទួលមរណភាព ហើយភាគច្រើន គេប្រើកិច្ចសន្យានេះសម្រាប់ធានាជីវភាពម្ចាស់បំណុលនៃធនលាភនៅពេលចាស់ ។ កថាខណ្ឌទី ១ កំណត់អំពីនិយមន័យនៃកិច្ចសន្យាធនលាភសាមយិកមួយជីវិត ។ កិច្ចសន្យាផ្តល់តាវកាលិកជាប្រាក់ដោយទៀងទាត់ មួយជីវិតដោយមិនយកតម្លៃថ្នូរ ក៏មានដែរ ក៏ប៉ុន្តែ បញ្ញត្តិស្តីពីប្រទានកម្ម ឬ បញ្ញត្តិស្តីពីអាហារកាតព្វកិច្ចអាចយកមកអនុវត្តបាន ចំពោះកិច្ចសន្យាបែបនេះ ។ ដូច្នេះហើយ កថាខណ្ឌទី ១ កំណត់ថា កិច្ចសន្យាធនលាភសាមយិកមួយជីវិត គឺជាកិច្ចសន្យាដែលយកតម្លៃថ្នូរ ។

ម្យ៉ាងទៀត កិច្ចសន្យាធនលាភសាមយិកមួយជីវិតនេះ អាចធ្វើឡើងតាមទម្រង់នៃ "កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន" បានដែរ ហេតុនេះហើយបានជាបញ្ញត្តដូចក្នុងកថាខណ្ឌទី ១ នេះ ។

(2) កិច្ចសន្យាធនលាភសាមយិកមួយជីវិតនេះ គឺជាកិច្ចសន្យាផ្តល់តាវកាលិកជាប្រាក់ទៀងទាត់រយៈពេលវែង រហូតដល់

មរណភាពរបស់បុគ្គលជាក់លាក់ណាម្នាក់ដែលជាមូលហេតុនៃការបញ្ចប់កិច្ចសន្យា ដោយផ្អែកលើទ្រព្យសម្បត្តិដែលម្ចាស់បំណុលនៃធនលាភបានធ្វើវិភាគទាន ហើយគឺជាកិច្ចសន្យាដែលមានលក្ខណៈមិនទៀង (contrat aléatoire) ហេតុនេះហើយបានជាមានករណីច្រើនណាស់ដែលវិវាទកើតឡើង ។ ដូច្នេះហើយ ដើម្បីឱ្យដឹងច្បាស់លាស់នូវទីកន្លែង ព្រមទាំងខ្លឹមសារនៃកិច្ចសន្យានោះ ត្រូវធ្វើកិច្ចសន្យានោះជាលាយល័ក្ខណ៍អក្សរ ហើយចំណុចនេះ បានចែងក្នុងកថាខណ្ឌទី ២ ។ ម្យ៉ាងទៀត ការទាមទារឱ្យមានកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរ មានគោលបំណងទាមទារឱ្យមានការសម្រេចចិត្តដោយប្រយ័ត្នរបស់ភាគីផងដែរ ។

(3) ក្នុងកិច្ចសន្យាធនលាភសាមយិកមួយជីវិត ទំនាក់ទំនងរវាងសិទ្ធិលើបំណុល និង កាតព្វកិច្ច មានអត្ថិភាពរយៈពេលវែង ដូច្នេះ ចាំបាច់ត្រូវការពារឋានៈរបស់ម្ចាស់បំណុលធនលាភដែលបានអនុវត្តការធ្វើវិភាគទានទ្រព្យរបស់ខ្លួនមុន ។ កថាខណ្ឌទី ៣ មានគោលបំណងការពារម្ចាស់បំណុលនៃធនលាភ ដោយចែងទទួលស្គាល់នូវឯកសិទ្ធិរបស់ម្ចាស់បំណុលនៃធនលាភ លើទ្រព្យដែលបានធ្វើវិភាគទាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៨៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៩៦៨ ដល់មាត្រា ១៩៧៦ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៥១៧ និង មាត្រា ៥១៨ នៃច្បាប់ស្តីពីកាតព្វកិច្ចរបស់ស្វីស

## មាត្រា ៧២០.- ការគណនានៃធនលាភសាមយិកមួយជីវិត

ធនលាភសាមយិកមួយជីវិត ត្រូវគណនាដោយគិតតាមចំនួនថ្ងៃ ។

(កំណត់)

(1) ចំពោះកិច្ចសន្យាធនលាភសាមយិកមួយជីវិត ធនលាភសាមយិកដែលត្រូវបង់នោះ មិនមែនជាការប្រាក់ដោយយកទ្រព្យដែលបានមកពីវិភាគទាននៃម្ចាស់បំណុលធនលាភសាមយិកជាប្រាក់ដើមទេ ។ ដូច្នេះហើយ តាមទ្រឹស្តី មិនមានភាពចាំបាច់ក្នុងការយករូបមន្តនៃការគណនាការប្រាក់ ឬ រូបមន្តនៃការគណនាផលស៊ីវិលដែលជាតម្លៃថ្នូរនៃការប្រើប្រាស់ប្រាក់ដើមនោះមកប្រើទេ ។ ក៏ប៉ុន្តែ លក្ខណៈនៃធនលាភសាមយិក (ឬ ការវាយតម្លៃជាក់ស្តែងរបស់សង្គមចំពោះធនលាភសាមយិកនេះ) មានប្រហាក់ប្រហែលនឹងផលស៊ីវិលដែរ ហេតុនេះហើយបានជានៅក្នុងនេះបានចែងតម្រូវឱ្យគណនាដោយគិតតាមចំនួនថ្ងៃ ។

(2) មាត្រានេះ គឺជាបញ្ញត្តិមួយត្រៀមសម្រាប់ករណីដែលសិទ្ធិលើបំណុលធនលាភសាមយិកមួយជីវិត ត្រូវបានរលត់នៅពាក់កណ្តាលនៃកំណត់ពេលត្រូវបង់ ។ ឧទាហរណ៍ ក្នុងករណីដែលសិទ្ធិលើបំណុលនៃធនលាភសាមយិកមួយជីវិត ត្រូវបានបង់ ជាទឹកប្រាក់ចំនួន ៣០ ម៉ឺនរៀលរៀងរាល់ខែ ប្រសិនបើបុគ្គលណាម្នាក់បានទទួលមរណភាព នៅថ្ងៃទី ១០ ខែមេសា ហើយមរណភាពនេះជាមូលហេតុនៃការរំលត់សិទ្ធិលើបំណុលធនលាភ នោះសិទ្ធិលើបំណុលធនលាភត្រូវរលត់ហើយទឹក ប្រាក់ចំនួន ១០ ម៉ឺនរៀល ដោយគណនាតាមចំនួនថ្ងៃ ។

(3) ក្នុងករណីដែលប្រាក់ធនលាភសាមយិកត្រូវបានទទួលជាមុន ហើយសិទ្ធិលើបំណុលនៃធនលាភសាមយិកនេះ បាន រលត់ពាក់កណ្ដាលកាល ប្រសិនបើមូលហេតុនៃការរំលត់នោះមិនមែនកើតនៅដើមកាលទេ មានច្បាប់ខ្លះបានចែងឱ្យម្ចាស់បំណុលនៃធនលាភសាមយិកធ្វើលទ្ធកម្មនូវទឹកប្រាក់ទាំងមូលនេះបាន ក៏ប៉ុន្តែ មាត្រានេះមិនបានចែងដូចនេះទេ គឺតម្រូវឱ្យម្ចាស់បំណុលធនលាភសាមយិកនេះ សងដោយគណនាតាមចំនួនថ្ងៃវិញ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៩០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៩៨០ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៧២១.-** ការមិនអនុវត្តកាតព្វកិច្ចធនលាភសាមយិក

១-ប្រសិនបើកូនបំណុលនៃធនលាភ បានធ្វេសប្រហែសពុំបានផ្ដល់តាវកាលិកនៃធនលាភសាមយិក តាមពេលកំណត់ទៀងទាត់ ឬ បើពុំបានអនុវត្តករណីយកិច្ចផ្សេងទៀតទេ ភាគីម្ខាងទៀតអាចរំលាយកិច្ចសន្យា ហើយអាចទាមទារឱ្យធ្វើបដិទាននូវប្រាក់ដើមដែលបានធ្វើការផ្ដល់តាវកាលិកនោះបាន ។ ប៉ុន្តែ ក្នុងករណីនេះ ភាគីម្ខាងទៀតត្រូវសងនូវចំនួនទាំងអស់នៃធនលាភដែលខ្លួនបានទទួលរហូតដល់ការរំលាយ ដោយដកការប្រាក់នៃប្រាក់ដើមនោះរហូតដល់ការរំលាយ ឱ្យទៅកូនបំណុលនៃធនលាភវិញ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងលើការទាមទារសំណងនៃការខូចខាតឡើយ ។

(កំណត់)

(1) ដោយសារតែកិច្ចសន្យាធនលាភសាមយិកមួយជីវិត ជាកិច្ចសន្យាដែលមានលក្ខណៈមិនទៀង (contrat aléatoire) មានទស្សនៈខ្លះថា ទោះបីជាកូនបំណុលនៃធនលាភមិនបានអនុវត្តកាតព្វកិច្ចក៏ដោយ ក៏មិនគួរទទួលស្គាល់នូវសិទ្ធិរំលាយកិច្ចសន្យារបស់ម្ចាស់បំណុលនៃកិច្ចសន្យាធនលាភសាមយិកដែរ ក៏ប៉ុន្តែ ប្រសិនបើទទួលស្គាល់តែសិទ្ធិទាមទារឱ្យបង់នូវធនលាភសាមយិកដែលយឺតយ៉ាវ និង សំណងនៃការខូចខាតប៉ុណ្ណោះ នោះវានឹងបង្រួញនូវវិសាលភាពនៃការសង្គ្រោះម្ចាស់បំណុលនៃធនលាភសាមយិកទៅវិញ ហើយជាការមួយខ្វះសមភាព ដូច្នេះហើយ មាត្រានេះទទួលស្គាល់នូវសិទ្ធិរំលាយកិច្ចសន្យា ហើយដាក់ករណីយកិច្ចឱ្យកូនបំណុលនៃធនលាភសាមយិកដែលមិនបានអនុវត្តតព្វកិច្ចនោះ ធ្វើបដិទានស្ថានភាពដើមឡើងវិញ ។ ក៏ប៉ុន្តែ ដើម្បីឱ្យមានសមភាព ចំណែកនៃកាតព្វកិច្ចដែលបានអនុវត្តហើយ ចាំបាច់ត្រូវទូទាត់ ដូច្នេះហើយបានជាគោលគំនិតនេះត្រូវបានបញ្ចូលក្នុងវាក្យខណ្ឌទី ២ ។

(2) ដោយយោងតាមបញ្ញត្តិនៃមាត្រា ៣៩០ ប្រសិនបើមានការខូចខាតដែលកើតមានឡើងដោយសារការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុលនៃធនលាភសាមយិក ព្រមជាមួយគ្នានឹងការកើតឡើងនៃសិទ្ធិរំលាយកិច្ចសន្យា សិទ្ធិទាមទារ

ឱ្យសងនូវសំណងនៃការខូចខាតក៏កើតឡើងដែរ ។ កថាខណ្ឌទី ២ បញ្ជាក់អំពីចំណុចនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៩១ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៩៧៧ និង មាត្រា ១៩៧៨ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៧២២.-** មរណភាព ដែលជាមូលហេតុនៃការទទួលខុសត្រូវរបស់កូនបំណុលនៃធនលាភសាមយិក

ប្រសិនបើមរណភាពរបស់បុគ្គលដែលធ្វើជាមូលដ្ឋាននៃកំណត់ពេលចប់នៃកិច្ចសន្យាធនលាភសាមយិក បានកើតឡើង ដោយសារមូលហេតុដែលជាការទទួលខុសត្រូវរបស់កូនបំណុលនៃធនលាភសាមយិក តុលាការអាចប្រកាសថា សិទ្ធិលើបំណុលបន្តមានអត្ថិភាព ក្នុងអំឡុងពេលសមរម្យ តាមការទាមទាររបស់ម្ចាស់បំណុលនៃធនលាភសាមយិក ឬ សន្តតិជន របស់បុគ្គលនោះបាន ។

(កំណត់)

(1) ដោយសារតែមរណភាពនៃបុគ្គលជាក់លាក់ណាម្នាក់ ជាមូលហេតុនៃការរំលត់កិច្ចសន្យាធនលាភសាមយិកមួយជីវិតចំពោះកូនបំណុលនៃធនលាភសាមយិក ប្រសិនបើបុគ្គលជាក់លាក់នោះទទួលមរណភាពកាន់តែឆាប់ បន្ទុកកូនបំណុលកាន់តែស្រាល ។ ក្នុងករណីដែលមរណភាពរបស់បុគ្គលជាក់លាក់នោះ បានកើតឡើង ដោយសារមូលហេតុដែលជាការទទួលខុសត្រូវរបស់កូនបំណុលនៃធនលាភសាមយិក ប្រសិនបើទទួលស្គាល់នូវការសម្រាលនូវបន្ទុករបស់កូនបំណុលនោះទៅនឹងធ្វើឱ្យបាត់បង់នូវសមភាព ។ បញ្ហានេះមានវិធីសាស្ត្រមួយដើម្បីដោះស្រាយដែរ គឺ ការទទួលស្គាល់នូវសិទ្ធិរំលាយកិច្ចសន្យាធនលាភសាមយិកមួយជីវិត ក៏ប៉ុន្តែ វិធីសាស្ត្រនេះមិនមែនជាដំណោះស្រាយទន់ភ្លន់ទេ ។ ដូច្នេះហើយបានជាក្នុងមាត្រានេះ វិធីសាស្ត្រផ្សេងត្រូវបានជ្រើសរើស គឺ ពេលបញ្ចប់កិច្ចសន្យាធនលាភ សាមយិកមួយជីវិតនោះ អាចពន្យារពេលសមរម្យបាន ដោយការវិនិច្ឆ័យរបស់តុលាការ ដើម្បីរក្សានូវសមភាព ។

(2) ក្នុងករណីដែលតុលាការទទួលស្គាល់នូវ "អំឡុងពេលសមរម្យ" នេះ "អំឡុងពេលសមរម្យ" នេះ មានន័យថាជាអំឡុងពេលមួយសមស្របទៅតាមពេលដែលបុគ្គលនោះអាចមានជីវិត ដោយព្យាករទៅតាមស្ថានភាពនៃសុខភាព ឬ អាយុ ជាអាទិ៍ របស់បុគ្គលជាក់លាក់នោះ ។

(3) តើតុលាការប្រកាសបន្តនូវអត្ថិភាពកិច្ចសន្យានៅក្នុង "អំឡុងពេលសមរម្យ" ឬ មិនប្រកាសនោះ គឺជាការប្រគល់ឱ្យតុលាការធ្វើការវិនិច្ឆ័យឱ្យបានសមស្រប ដោយគិតពិចារណានូវភាពជាក់ស្តែងនៃមូលហេតុដែលជាការទទួលខុសត្រូវរបស់កូនបំណុលនៃធនលាភសាមយិក ។ ដូច្នេះហើយ មាត្រានេះចែងថា ជាចំណុចសម្រេចដោយឆន្ទានុសិទ្ធិរបស់ តុលាការ ។

(4) មាត្រានេះពុំរារាំងនូវការអនុវត្តតាមមាត្រា ៧២១ ទេ ហេតុដូច្នេះ ម្ចាស់បំណុលនៃធនលាភសាមយិក ឬ សន្តតិជនរបស់អ្នកនោះ អាចជ្រើសរើសយកការទាមទារដោយយោងតាមមាត្រានេះ ឬ អាចទាមទារដោយយោងតាមមាត្រា ៧២១ ក៏បានដែរ ។ មានន័យថា ម្ចាស់បំណុលនៃធនលាភសាមយិក ឬ សន្តតិជនរបស់អ្នកនោះ អាចជ្រើសរើសយកវិធីណាមួយចំណេញជាងបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៩៣ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧២៣.-** ធនលាភសាមយិកមួយជីវិត ដោយអច្ច័យទាន

បញ្ញត្តិនៃជំពូកទី ១២ (កិច្ចសន្យាធនលាភសាមយិកមួយជីវិត) នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអច្ច័យទានដែលភ្ជាប់បន្ទុកនៃធនលាភសាមយិកមួយជីវិត ។

(កំណត់)

ធនលាភសាមយិកអាចធ្វើដោយកិច្ចសន្យា ឬ ដោយអច្ច័យទានដែលភ្ជាប់នឹងបន្ទុក ។ គ្មានមូលហេតុណាមួយឱ្យចាត់ចែងធនលាភសាមយិកមួយជីវិតដោយអច្ច័យទាន ផ្សេងពីធនលាភសាមយិកមួយជីវិតដោយកិច្ចសន្យាទេ ហេតុដូច្នេះ មាត្រានេះចែងច្បាស់លាស់ឱ្យអនុវត្តដូចគ្នាតាមបញ្ញត្តិនៃជំពូកនេះ ចំពោះធនលាភសាមយិកមួយជីវិតដោយអច្ច័យទានដែលភ្ជាប់នឹងបន្ទុកផងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៩៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៩៦៩ នៃក្រមរដ្ឋប្បវេណីបារាំង

## ជំពូកទី ១៣ ការសះជា

**មាត្រា ៧២៤.-** និយមន័យ

ការសះជា សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីបានព្រមព្រៀងបញ្ចប់វិវាទដែលមានរវាងគ្នានឹងគ្នា ដោយធ្វើសម្បទានទៅវិញទៅមក ។

(កំណត់)

មាត្រានេះចែងអំពីនិយមន័យនៃការសះជា ។

ការសះជា គឺជាកិច្ចសន្យាបញ្ចប់នូវវិវាទរវាងភាគីដែលមានវិវាទនោះ ។ ឧទាហរណ៍ដូចជា អំពីគ្រោះថ្នាក់ចរាចរណ៍ រវាងចារី និង អ្នករងគ្រោះ មានវិវាទអំពីទឹកប្រាក់នៃសំណងនៃការខូចខាត ហើយភាគីទាំងនេះបានព្រមព្រៀងគ្នាស្តីពីទឹកប្រាក់នៃសំណងនេះ តាមរយៈការចរចារដើម្បីដោះស្រាយវិវាទនេះ ។ ចំពោះការសះជាតាមផ្លូវតុលាការ មាន

អានុភាពបញ្ចប់រឿងក្ដីតាមនីតិវិធីរដ្ឋប្បវេណី ហើយមានខ្លឹមសារមួយទៀត គឺ ការបង្កើតកិច្ចសន្យាសះជាដើម្បីបញ្ចប់វិវាទរវាងភាគីតាមផ្លូវច្បាប់នីតិឯកជន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៩៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧២៥**.- វត្ថុដែលជាកម្មវត្ថុនៃការសះជា

១-ដើម្បីធ្វើការសះជា ភាគីត្រូវមានសិទ្ធិអំណាចចាត់ចែងវត្ថុដែលជាកម្មវត្ថុ មាននៅក្នុងការសះជានោះ ។

២-ការសះជា ដើម្បីធ្វើឱ្យទំនាក់ទំនងគតិយុត្តដែលមោឃៈ ដោយសារភាពផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ ឬ ទំនៀមទម្លាប់ល្អ ឬ បញ្ញត្តិដែលអនុវត្តដោយបង្ខំ ឱ្យមានអានុភាពឡើងនោះ ត្រូវទុកជាមោឃៈ ។

(កំណត់)

មាត្រានេះចែងស្ដីពីវត្ថុដែលជាកម្មវត្ថុនៃការសះជា ។

កថាខណ្ឌទី ១ ចែងអំពីល័ក្ខខ័ណ្ឌនៃការសះជាថា ភាគីនៃការសះជាត្រូវមានសិទ្ធិអំណាចចាត់ចែងវត្ថុដែលជាកម្មវត្ថុដែលមាននៅក្នុងការសះជានោះ ។ ឧទាហរណ៍ ភតិកៈនៃដីធ្លីម្នាក់ មិនអាចសះជាគ្នាចំពោះវិវាទអំពីព្រំដី ជាមួយនឹងម្ចាស់កម្មសិទ្ធិដីធ្លីនៅជាប់ដីនោះបានទេ ។ ទោះបីជាបានធ្វើកិច្ចសន្យាសះជា ក៏កិច្ចសន្យានោះក្លាយជាមោឃៈដែរ ហើយម្ចាស់កម្មសិទ្ធិដីធ្លីជាប់គ្នានោះ ពុំអាចអះអាងអំពីខ្លឹមសារនៃកិច្ចសន្យាសះជានោះ ចំពោះម្ចាស់កម្មសិទ្ធិដីធ្លីដែលបានជួលទេ ។

កថាខណ្ឌទី ២ ចែងថា ឧទាហរណ៍ ស្ដីពីប្រាក់ឈ្នះល្បែងស៊ីសង ឬ ប្រាក់លក់ទិញគ្រឿងញៀន ការបង្វែរប្រាក់នេះទៅជាប្រាក់កម្ចី ដើម្បីធ្វើឱ្យសិទ្ធិលើបំណុលមានសុពលភាពនោះ ត្រូវទុកជាមោឃៈ ។ មានន័យថា មិនអនុញ្ញាតឱ្យបង្វែរអ្វីមួយទៅជាទំនាក់ទំនងគតិយុត្តមួយផ្សេង ដើម្បីសំអាតប្រាក់បានឡើយ ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ២០៥៤ នៃក្រមរដ្ឋប្បវេណីបារាំង ។

**មាត្រា ៧២៦**.- ខសន្យាអំពីប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា

ក្នុងកិច្ចសន្យាសះជា អាចបន្ថែមខសន្យាអំពីប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ចំពោះបុគ្គលដែលមិនអនុវត្តកិច្ចសន្យានោះបាន ។

(កំណត់)

មាត្រានេះចែងឡើងដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ថា អាចបន្ថែមនូវខសន្យាស្តីពីប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា នៅក្នុងកិច្ចសន្យាសះជាបាន ។

ក្នុងកិច្ចសន្យាសះជា ដើម្បីដោះស្រាយវិវាទ ហើយទាមទារឱ្យភាគីម្ខាងទៀតនៃកិច្ចសន្យា អនុវត្តតាមការសន្យានោះដោយស្ម័គ្រចិត្ត តាមធម្មតា ភាគីច្រើនតែបន្ថយនូវទឹកប្រាក់ដែលបានទាមទារពីមុន ឬ ទទួលស្គាល់នូវការសងបណ្តាក់ជាដើម ។ ក៏ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាងទៀតមិនបានអនុវត្តតាមការព្រមព្រៀងនៃការសះជានោះទេ មូលដ្ឋាននៃការសះជានឹងត្រូវបែកបាក់ ហេតុនេះហើយ អាចដាក់បន្ទុកឱ្យបង់ប្រាក់ធានាសំណងពេលបំពានកិច្ចសន្យានោះបាន ។ម្យ៉ាងទៀត ក្នុងករណីសះជាដែលមិនត្រូវធ្វើសកម្មភាពណាមួយ ដូចជាពុំត្រូវបញ្ចេញសម្លេងអឺងកង ជាអាទិ៍ មានករណីខ្លះភាគីកំណត់ជាមុននូវការពិន័យពេលដែលបំពានការព្រមព្រៀងនេះ ដើម្បីធ្វើឱ្យអ្នកមានករណីយកិច្ចអនុវត្តតាមការសន្យារបស់ខ្លួន ។ មាត្រានេះ អនុញ្ញាតឱ្យមានកិច្ចសន្យាសះជាដែលភ្ជាប់ជាមួយនឹងខសន្យានៃប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ។ ប៉ុន្តែ ក្នុងករណីដែលបានកំណត់នូវប្រាក់សំណងក្នុងករណីបំពានកិច្ចសន្យាដែលមានទឹកប្រាក់សំណងច្រើនហួសហេតុ កិច្ចសន្យាអាចក្លាយទៅជាមោឃៈ ដោយសារផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ហេតុនេះហើយ ត្រូវកំណត់នូវខសន្យាដែលមានសំណងធានាក្នុងករណីបំពានកិច្ចសន្យា ដោយមានទឹកប្រាក់សមរម្យមួយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ២០៤៧ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៧២៧**.- អានុភាពនៃការសះជា

ក្នុងករណីដែលទទួលស្គាល់ថាភាគីម្ខាងមានសិទ្ធិ ឬ បានទទួលស្គាល់ថាភាគីម្ខាងទៀតគ្មានសិទ្ធិលើកម្មវត្ថុនៃវិវាទ ដោយការសះជា ហើយបើបានរកឃើញភស្តុតាងដែលសន្និដ្ឋានបានថា ភាគីនោះគ្មានសិទ្ធិនោះតាំងពីដើមមក ឬ បើបានរកឃើញភស្តុតាងដែលសន្និដ្ឋានបានថា ភាគីម្ខាងទៀតមានសិទ្ធិនោះ ត្រូវចាត់ទុកថា សិទ្ធិនោះ ត្រូវបានផ្ទេរទៅឱ្យភាគីនោះ ដោយការសះជា ឬ ត្រូវចាត់ទុកថា សិទ្ធិរបស់ភាគីម្ខាងទៀត ត្រូវបានរលត់ ។

(កំណត់)

មាត្រានេះចែងថា តើទំនាក់ទំនងគតិយុត្តដែលមានពីមុនមក នឹងក្លាយទៅជាយ៉ាងណាដែរ ក្នុងករណីដែលមានកិច្ចសន្យាសះជា ។

ឧទាហរណ៍ A បានអះអាងថា បានធ្វើលទ្ធកម្មនូវដីធ្លីមួយកន្លែងរបស់កម្មសិទ្ធិករ B ដោយសារអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ ហើយរឿងវិវាទពាក់ព័ន្ធនឹងកម្មសិទ្ធិលើដីធ្លីនេះរវាង A និង B បានកើតឡើង ។ បន្ទាប់មក A និង B បានធ្វើកិច្ចសន្យា សះជាមួយដែលមានខ្លឹមសារថា ដីពាក់កណ្តាលដែលនៅភាគខាងកើត គឺជារបស់ A ដែលបានធ្វើលទ្ធកម្មដោយ

អាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ រីឯដីពាក់កណ្តាលទៀតដែលនៅភាគខាងលិច គឺជារបស់ B ដដែល ។ ក្នុងករណីនេះ ប្រសិនបើក្រោយពីនោះមក គេរកឃើញភស្តុតាងច្បាស់លាស់ថា តាមការពិត A ពុំបានកាន់កាប់ដីនោះទេ នោះ A ក៏ពុំបានធ្វើលទ្ធកម្មនូវដីពាក់កណ្តាលភាគខាងកើតនោះដោយអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិដែរ ។ ទោះបីជាមានករណីដូចនេះក៏ដោយ ក៏កម្មសិទ្ធិនៃដីពាក់កណ្តាលភាគខាងកើត ត្រូវផ្ទេរទៅឱ្យ A តាមកិច្ចសន្យាសះជា ដោយអានុភាពនៃកិច្ចសន្យាសះជាដែរ ។ ម្យ៉ាងទៀត ប្រសិនបើពេលក្រោយមក គេរកឃើញភស្តុតាងច្បាស់លាស់ថា A បានកាន់កាប់ដីនោះទាំងអស់ក្នុងគោលបំណងធ្វើជាកម្មសិទ្ធិករនៃដីទាំងមូលនោះ ពិតមែន A អាចធ្វើលទ្ធកម្មនូវដីពាក់កណ្តាលភាគខាងលិចដែរ ដោយអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ ។ ក្នុងករណីនេះក៏ដោយ ក៏កម្មសិទ្ធិនៃដីពាក់កណ្តាលភាគខាងលិចនៅតែជារបស់ B ដដែល ដោយសារកិច្ចសន្យាសះជានោះ មានន័យថា អានុភាពនៃលទ្ធកម្មដោយអាជ្ញាយុកាលរបស់ A ត្រូវបានបាត់បង់ ។ នេះគឺជាអានុភាពនៃការសះជា ។ ចំពោះរឿងវិវាទអំពីប្រាក់ ក៏ដូចគ្នាដែរ ឧទាហរណ៍ ក្នុងរឿងសំណងនៃការខូចខាតដោយសារគ្រោះថ្នាក់ចរាចរណ៍ ជនរងគ្រោះ A បានទាមទារសំណងនៃការខូចខាតជាទឹកប្រាក់ ២០០ ដុល្លារ រីឯចារីវិញបានអះអាងថា ការខូចខាតមានតែ ១០០ ដុល្លារប៉ុណ្ណោះទេ ហើយគេទាំងពីរបានសះជាដោយកំណត់ជាទឹកប្រាក់សំណងនៃការខូចខាត ១៥០ ដុល្លារ ។ តែក្រោយមក ពេលគេរកឃើញភស្តុតាងថា ការខូចខាតមាន ១៧០ ដុល្លារ ដូច្នេះសិទ្ធិទាមទារនូវសំណងនៃការខូចខាត ២០ ដុល្លាររបស់ A ត្រូវរលត់ ។ ផ្ទុយទៅវិញ ប្រសិនបើការខូចខាតពិតមានតែ ១២០ ដុល្លារប៉ុណ្ណោះ ទេ មានន័យថា ៣០ ដុល្លារដែលលើស ក៏ត្រូវបានផ្ទេរពី B ទៅ A ដោយសារអានុភាពនៃកិច្ចសន្យាសះជានេះដែរ ។ ដូច្នេះហើយបានជាមាត្រានេះចែងថា អានុភាពនៃការរលត់ ឬ ការផ្ទេរសិទ្ធិនឹងកើតឡើងដោយសារកិច្ចសន្យាសះជា ដើម្បីកុំឱ្យមានបញ្ហាទាមទារសំណងនៃសេចក្តីចម្រើនដោយឥតហេតុកើតឡើងពេលក្រោយទៀត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៩៦ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ៧២៨**.- ការភាន់ច្រឡំដែលទាក់ទងទៅនឹងសិទ្ធិដែលជាកម្មវត្ថុនៃវិវាទ ជាអាទិ៍

ទោះបីជាក្នុងករណីដែលបានសះជា ដោយភាគីម្ខាងភាន់ច្រឡំអំពីម្ចាស់សិទ្ធិ ឬ អង្គហេតុដែលជាមូលដ្ឋាននៃការគណនាតម្លៃនៃកម្មវត្ថុក៏ដោយ ប្រសិនបើការសះជានោះបានធ្វើដោយសម្បទានគ្នាទៅវិញទៅមកអំពីម្ចាស់សិទ្ធិ ឬ អត្ថិភាព នត្ថិភាពនៃអង្គហេតុ ឬ ការវាយតម្លៃ ជាអាទិ៍ ភាគីពុំអាចយកមូលហេតុនៃការភាន់ច្រឡំពីម្ចាស់សិទ្ធិ ឬ អត្ថិភាព នត្ថិភាពនៃអង្គហេតុ ឬ ការវាយតម្លៃ ជាអាទិ៍ មកលុបចោលការសះជាបានឡើយ ។

(កំណត់)

មាត្រានេះជាបញ្ញត្តិធ្វើការកម្រិតចំពោះការលុបចោលកិច្ចសន្យាសះជាដោយសារការភាន់ច្រឡំ តាមលក្ខណៈពិសេស

នៃកិច្ចសន្យាសះជា ។

ភាគីអាចមានការភាន់ច្រឡំ អំពីអង្គហេតុ ជាអាទិ៍ ក្នុងការធ្វើកិច្ចសន្យាសះជា ។ ក្នុងចំណោមនោះ អាចមានករណីដែលភាគីពុំមានគំនិតសះជាទេ តែបានចុះហត្ថលេខាលើលិខិតសះជាក្រៅតុលាការដោយការភាន់ច្រឡំ ឬ មានគំនិតសះជាក្នុងទឹកប្រាក់ចំនួន ១០០០ ដុល្លារ តែបានច្រឡំសរសេរតែ ១០០ ដុល្លារប៉ុណ្ណោះ នៅលើលិខិតសះជា ។ ក្នុងករណីដូចនេះ ភាគីដែលបានភាន់ច្រឡំ អាចលុបចោលកិច្ចសន្យាសះជានោះបាន ដោយការភាន់ច្រឡំ ដោយផ្អែកលើល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងមាត្រា ៣៤៦ នៃក្រមនេះ ។ បន្ទាប់មក អាចមានករណីដែលភាគីធ្វើកិច្ចសន្យាសះជាដោយមានការភាន់ច្រឡំអំពីម្ចាស់សិទ្ធិ ឬ អង្គហេតុដែលជាមូលដ្ឋាននៃការគណនាតម្លៃនៃកម្មវត្ថុ ។ ឧទាហរណ៍ A បានអះអាងថា ខ្លួនបានធ្វើលទ្ធកម្មដីធ្លីដែលជាកម្មសិទ្ធិរបស់ B ដោយអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ រីឯ B វិញ ដោយគិតឃើញថា A បានកាន់កាប់ដីនោះ ជាប់លាប់អស់រយៈពេល ១០ ឆ្នាំហើយ ក៏សុខចិត្តយល់ព្រមសះជាជាមួយ A ដោយផ្ទេរកម្មសិទ្ធិដីនោះទៅឱ្យ A ហើយទទួលប្រាក់តាមការសះជាតែបន្តិចបន្តួចវិញ ។ ក៏ប៉ុន្តែ ក្រោយមក គេរកឃើញថា ក្នុងអំឡុងពេល ១០ ឆ្នាំនោះ មានពេល ២ ឆ្នាំ ដែល A មិនបានកាន់កាប់ដីនោះ ដូច្នេះហើយ អាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិនោះ មិនទាន់បានសម្រេចនៅឡើយទេ ។ ក្នុងករណីនេះ ប្រសិនបើរវាង A និង B ពេលចរចារដើម្បីធ្វើកិច្ចសន្យាសះជា មានការជជែកអំពីការកាន់កាប់ដោយ A តែ B បានយល់ព្រមធ្វើកិច្ចសន្យាសះជា ដោយសារខ្លួនយល់ឃើញថា ការអះអាងរបស់ A មានភាពសមរម្យខ្លាំង នោះ B មិនអាចលុបចោលកិច្ចសន្យាសះជានោះ ដោយយកមូលហេតុថា មានការភាន់ច្រឡំអំពីការមិនបានកាន់កាប់ដីនោះ រយៈពេល ២ ឆ្នាំ នៅក្នុងអំឡុងពេល ១០ ឆ្នាំនោះ ដោយ A (ការភាន់ច្រឡំអំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុ) បានទេ ។ មានករណីផ្សេងទៀត ដូចជាករណីទាមទារសំណងនៃការខូចខាតដោយគ្រោះថ្នាក់ចរាចរណ៍វិញ ជនរងគ្រោះបានអះអាងថា មានការខូចខាតចំនួន ២០០ ដុល្លារ រីឯចារីវិញ បានអះអាងថា ការខូចខាតមានតែ ១០០ ដុល្លារទេ ហើយភាគីសងខាងបានសះជាគ្នាថា ការខូចខាតមានចំនួន ១៥០ ដុល្លារ ។ ក្នុងករណីនេះ ប្រសិនបើភាគីទាំងសងខាងបានជជែកគ្នាអំពីការវាយតម្លៃនៃការខូចខាតនោះ ហើយបានធ្វើកិច្ចសន្យាសះជាដូចនោះ ភាគីមិនអាចលុបចោលកិច្ចសន្យាសះជា ក្រោយពេលនោះ ដោយយកមូលហេតុថា មានការភាន់ច្រឡំអំពីការវាយតម្លៃនៃការខូចខាតបានឡើយ ។ ការដាក់កម្រិតក្នុងការលុបចោលនូវកិច្ចសន្យាសះជា ដោយការភាន់ច្រឡំនេះ គឺដើម្បីជៀសវាងនូវវិវាទជាថ្មីទៀតកើតឡើង ដោយសារមានមូលហេតុភាន់ច្រឡំ ។ម្យ៉ាងទៀត ការកម្រិតនេះទទួលស្គាល់តែចំពោះករណីដែល "ការសះជានោះ បានធ្វើដោយសម្បទានទៅវិញទៅមកអំពីម្ចាស់សិទ្ធិ ឬ អត្ថិភាព នត្ថិភាពនៃអង្គហេតុ ឬ ការវាយតម្លៃជាអាទិ៍" ប៉ុណ្ណោះទេ ដូច្នេះហើយ យើងសន្និដ្ឋានថា ភាគីនោះបានសះជា ដោយមានការទទួលស្គាល់ថា ខ្លួនអាចមានការភាន់ច្រឡំ ហើយទោះបីជាមានការកម្រិតដូចនេះក៏ដោយ ក៏មិនមែនជាការមួយតឹងរ៉ឹងធ្ងន់ធ្ងរសម្រាប់ភាគីដែលបានភាន់ច្រឡំទេ ។

(មាត្រាពាក់ព័ន្ធ)

វាក្យខណ្ឌទី ២ មាត្រា ២០៥៤ និង មាត្រា ២០៥៥ នៃក្រមរដ្ឋប្បវេណីបារាំង

# ជំពូកទី ១៤ ការគ្រប់គ្រងដោយឈឺឆ្អាល

**មាត្រា ៧២៩.-** ករណីយកិច្ចគ្រប់គ្រងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

១-ទោះបីជាគ្មានសិទ្ធិអំណាចក៏ដោយ ការចាប់ផ្តើមគ្រប់គ្រងកិច្ចការដើម្បីបុគ្គលដទៃ ហៅថា ការគ្រប់គ្រងដោយឈឺឆ្អាល ។ បុគ្គលដែលធ្វើការគ្រប់គ្រងដោយឈឺឆ្អាល ហៅថា អ្នកគ្រប់គ្រងដោយឈឺឆ្អាល ។

២-អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវគ្រប់គ្រងដោយព្យាយាមប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត តាមវិធីដែលសមរម្យជាងគេ ដើម្បីផលប្រយោជន៍របស់សាមីខ្លួន ផ្អែកតាមលក្ខណៈនៃកិច្ចការនោះ ។

៣-ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានដឹងអំពីឆន្ទៈរបស់សាមីខ្លួន ឬ ប្រសិនបើអាចដឹងអំពីឆន្ទៈនោះបាន ត្រូវធ្វើការគ្រប់គ្រងដោយផ្អែកតាមឆន្ទៈនោះ ។

(កំណត់)

(1) ក្នុងជីវភាពប្រចាំថ្ងៃ មនុស្សយើងជានិច្ចកាលយកចិត្តទុកដាក់ចំពោះកិច្ចការរបស់អ្នកដទៃ ទោះបីជាគ្មានសិទ្ធិអំណាច ឬ ករណីយកិច្ចតាមផ្លូវច្បាប់ដើម្បីធ្វើបែបនោះក៏ដោយ ។ ដូចដែលយើងដឹងស្រាប់ហើយថា ការជួយគ្នាទៅវិញទៅមករវាងអ្នកជិតខាង សាមគ្គីភាពសង្គម និង កិច្ចសហប្រតិបត្តិការទៅវិញទៅមក មានសារៈសំខាន់ណាស់នៅក្នុងជីវិតរបស់មនុស្សយើង ។ ប៉ុន្តែ វាច្បាស់ណាស់ទៅហើយដែលថា ការជួយគ្នាទៅវិញទៅមកនេះ គឺជា "ការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរបស់អ្នកដទៃ" ។ ប្រសិនបើយើងអនុវត្តគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនឱ្យជាក់លាក់ទៅ ការជួយគ្នាទៅវិញទៅមកបែបនេះ ត្រូវបានវាយតម្លៃថា ខុសច្បាប់ ។ ដោយសារតែហេតុផលនេះហើយ ជាករណីលើកលែងចំពោះគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ជំពូកនេះដាក់បញ្ចូលនូវបញ្ញត្តិដែលធ្វើឱ្យ "ការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរបស់អ្នកដទៃ" មិនខុសច្បាប់ ប្រសិនបើការជ្រៀតជ្រែកនោះបានបំពេញនូវល័ក្ខខ័ណ្ឌមួយចំនួន និង បញ្ញត្តិដទៃផ្សេងទៀតដែលពាក់ព័ន្ធជាមួយនឹងទំនាក់ទំនងសិទ្ធិ និង ករណីយកិច្ចរវាងអ្នកគ្រប់គ្រងដោយឈឺឆ្អាល និង សាមីខ្លួន ។ ដោយសារទំនាក់ទំនងនេះកើតឡើងដោយច្បាប់ តែមិនមែនដោយឆន្ទៈរបស់ភាគី ទំនាក់ទំនងនេះត្រូវបានហៅថាជា "ទំនាក់ទំនងនៃកាតព្វកិច្ចដែលកំណត់ដោយច្បាប់" ។

(2) កថាខណ្ឌទី ១ នៃមាត្រានេះកំណត់និយមន័យថា "ការជ្រៀតជ្រែកចូលក្នុងកិច្ចការអ្នកដទៃ" តាមរយៈការជួយគ្នាទៅវិញទៅមក គឺជា "ការគ្រប់គ្រងដោយឈឺឆ្អាល" ហើយឱ្យនិយមន័យថា បុគ្គលដែលប្រតិបត្តិការគ្រប់គ្រង គឺជាអ្នកគ្រប់គ្រងដោយឈឺឆ្អាល ។

ដើម្បីឱ្យសកម្មភាពមួយអាចត្រូវបានចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាល អ្នកគ្រប់គ្រងចាំបាច់ត្រូវមានឆន្ទៈ

គ្រប់គ្រងកិច្ចការ "ដើម្បីបុគ្គលដទៃ" ។ ឆន្ទៈនេះគឺហៅថា "ឆន្ទៈគ្រប់គ្រង" ។ ប្រសិនបើអ្នកគ្រប់គ្រងគ្មានឆន្ទៈគ្រប់គ្រងទេ សកម្មភាពគ្រប់គ្រងនោះមិនត្រូវបានចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាលទេ ហើយអ្នកគ្រប់គ្រងមិនអាចទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានចំណាយសម្រាប់ការគ្រប់គ្រងនោះ ជាអាទិ៍ ទេ ។ ប៉ុន្តែ សកម្មភាពមួយក៏អាចត្រូវបានចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាលផងដែរ ប្រសិនបើអ្នកគ្រប់គ្រងមានទាំងឆន្ទៈគ្រប់គ្រង "ដើម្បីបុគ្គលដទៃ" និង "ដើម្បីសាមីខ្លួន" ។ ឧទាហរណ៍ ដូចជា ប្រសិនបើច្រាំងទន្លេទំនងជាត្រូវបាក់ដោយសារការកើនឡើងនៃទឹកទន្លេ ហើយមានអ្នករស់នៅក្បែរដងទន្លេណាម្នាក់ ចាត់វិធានការជាបន្ទាន់ ដើម្បីទប់កុំឱ្យច្រាំងបាក់ ដើម្បីការពារមិនមែនតែផ្ទះខ្លួនឯងប៉ុណ្ណោះទេ គឺដើម្បីការពារផ្ទះអ្នកជិតខាងដែរ សកម្មភាពបែបនោះនឹងត្រូវចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាល ។

ពាក្យថា "ការគ្រប់គ្រង" ដែលប្រើនៅក្នុងការគ្រប់គ្រងដោយឈឺឆ្អាល គឺខុសគ្នាពីគោលគំនិតនៃ "ការគ្រប់គ្រង" ដែលត្រូវបានប្រើនៅក្នុងផ្នែកដទៃទៀតនៃក្រមរដ្ឋប្បវេណី ត្រង់ចំណុចថា ពាក្យ "គ្រប់គ្រង" ដែលត្រូវបានប្រើក្នុងការគ្រប់គ្រងដោយឈឺឆ្អាលនោះ រាប់បញ្ចូលទាំងសកម្មភាពចាត់ចែងផងដែរ ។ ប៉ុន្តែ ការចាត់ចែងនេះត្រូវតែធ្វើឡើងតាមមធ្យោបាយសមស្របបំផុតដើម្បីផលប្រយោជន៍របស់សាមីខ្លួន ។

(3) កថាខណ្ឌទី ២ ចែងអំពីករណីយកិច្ចជាមូលដ្ឋានរបស់អ្នកគ្រប់គ្រងថា អ្នកគ្រប់គ្រងដោយឈឺឆ្អាល មានករណីយកិច្ចគ្រប់គ្រងដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ដើម្បីគ្រប់គ្រងកិច្ចការតាមវិធីដែលសមរម្យជាងគេដើម្បីផលប្រយោជន៍របស់សាមីខ្លួន ។ ប្រសិនបើអ្នកគ្រប់គ្រងមិនបានបំពេញករណីយកិច្ចគ្រប់គ្រងដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិតទេ សកម្មភាពគ្រប់គ្រងនោះត្រូវចាត់ទុកថា ខុសច្បាប់ ហើយអ្នកគ្រប់គ្រងត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាតដែលកើតឡើងពីការខកខាននោះ ។

ករណីយកិច្ចគ្រប់គ្រងដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត មានន័យថា ជាការគ្រប់គ្រងកិច្ចការដោយមានការយកចិត្តទុកដាក់ខ្ពស់ ដែលអ្នកប្រកបដោយវិចារណញ្ញាណនឹងធ្វើ ក្នុងស្ថានភាពជាក់លាក់ណាមួយ ។

(4) ចំពោះបញ្ហាថា តើសកម្មភាពរបស់អ្នកគ្រប់គ្រងបម្រើ ឬ មិនបម្រើឱ្យផលប្រយោជន៍របស់សាមីខ្លួន ជាគោលការណ៍ត្រូវវិនិច្ឆ័យដោយសាមីខ្លួនផ្ទាល់ ។ ហេតុដូច្នេះ ក្នុងករណីដែលអ្នកគ្រប់គ្រងបានដឹង ឬ អាចដឹងបាននូវឆន្ទៈរបស់សាមីខ្លួន អ្នកគ្រប់គ្រងត្រូវគ្រប់គ្រងកិច្ចការដោយយោងតាមឆន្ទៈរបស់សាមីខ្លួននោះ ។ កថាខណ្ឌទី ៣ បញ្ជាក់អំពីចំណុចនេះ ។ ក្នុងករណីដែលអ្នកគ្រប់គ្រងមិនអាចដឹងឆន្ទៈរបស់សាមីខ្លួនទេ ឆន្ទៈរបស់សាមីខ្លួននោះ ត្រូវបានវិនិច្ឆ័យដោយយោងតាមទស្សនៈទូទៅក្នុងសង្គម ដោយគិតពិចារណានូវលក្ខណៈនៃកិច្ចការ កាលៈទេសៈជាក់ស្តែងជុំវិញសកម្មភាពគ្រប់គ្រង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៩៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៧៧ មាត្រា ៦៧៩ និង មាត្រា ៦៨៧៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៤១៩ នៃច្បាប់ស្តីពីកាតព្វកិច្ចនៃប្រទេសស្វីស, មាត្រា ៨២៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ៧៣០.- ការគ្រប់គ្រងដោយឈឺឆ្អាលក្នុងភាពបន្ទាន់**

ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានធ្វើការគ្រប់គ្រងដោយឈឺឆ្អាល ដើម្បីជៀសវាងគ្រោះថ្នាក់ នៅក្នុងសភាពបន្ទាន់ ចំពោះរូបកាយសាមីខ្លួន កិត្តិយស ឬ ទ្រព្យសម្បត្តិ លុះត្រាតែគ្មានគំនិតទុច្ចរិត ឬ កំហុសធ្ងន់ធ្ងរ តែប៉ុណ្ណោះទេ ទើបអ្នកគ្រប់គ្រងដោយឈឺឆ្អាល ពុំមានការទទួលខុសត្រូវលើសំណងនៃការខូចខាត ដែលកើតឡើងដោយសារការគ្រប់គ្រងនោះ ។

(កំណត់)

ប្រសិនបើផលប្រយោជន៍តាមផ្លូវច្បាប់របស់អ្នកដទៃ ដែលមានដូចជា ជីវិត ឬ ទ្រព្យសម្បត្តិ ជាដើម ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ សកម្មភាពដើម្បីសង្គ្រោះផលប្រយោជន៍ស្របច្បាប់ទាំងអស់នោះ មិនមែនគ្រាន់តែគួរតែទទួលស្គាល់ថា ស្របច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែ គួរតែត្រូវបានគាំទ្រយ៉ាងសកម្មផងដែរ ពីទស្សនៈនៃការជួយគ្នាទៅវិញទៅមក ។ ហេតុដូច្នេះ ចំពោះសកម្មភាពគ្រប់គ្រងក្នុងករណីដែលមានស្ថានភាពបន្ទាន់ មាត្រានេះបន្ថយនូវករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកគ្រប់គ្រងតិចជាងការគ្រប់គ្រងដោយឈឺឆ្អាលក្នុងករណីធម្មតា ហើយចែងថា អ្នកគ្រប់គ្រងមិនមានការទទួលខុសត្រូវក្នុងការសងសំណងការខូចខាតទៅសាមីខ្លួនឡើយ ចំពោះរាល់ការខូចខាតទាំងឡាយណាដែលបង្កឡើងដោយសកម្មភាពគ្រប់គ្រងដោយឈឺឆ្អាលក្នុងភាពបន្ទាន់ លើកលែងតែអ្នកគ្រប់គ្រងនោះមានគំនិតទុច្ចរិត ឬ កំហុសធ្ងន់ធ្ងរ ។ ម្យ៉ាងទៀត ស្ថានភាពបន្ទាន់ក៏ត្រូវគិតពិចារណាដាក់ចូលជាកត្តាសម្រាប់កាត់បន្ថយនូវករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកគ្រប់គ្រងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៩៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៨០ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៣៧៤ នៃក្រមរដ្ឋប្បវេណីបារាំង, កថាខណ្ឌទី ២ មាត្រា ៤២០ នៃច្បាប់ស្តីពីកាតព្វកិច្ចនៃប្រទេសស្វីស

**មាត្រា ៧៣១.-** ករណីយកិច្ចជូនដំណឹងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវជូនដំណឹងអំពីការបានចាប់ផ្តើមការគ្រប់គ្រងដោយឈឺឆ្អាលទៅឱ្យសាមីខ្លួន ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ ក្នុងករណីដែលសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងនោះហើយ ការជូនដំណឹងនេះពុំចាំបាច់ឡើយ ។

(កំណត់)

(1) ជាទូទៅ នៅពេលណាដែលការគ្រប់គ្រងដោយឈឺឆ្អាលចាប់ផ្តើម សាមីខ្លួនច្រើនតែមិនដឹងអំពីការគ្រប់គ្រងដោយឈឺឆ្អាលនោះទេ ។ ទោះបីជាការគ្រប់គ្រងដោយឈឺឆ្អាលនេះ គឺជាការជួយគ្នាទៅវិញទៅមករវាងអ្នកជិតខាងក៏ដោយ

ក៏វានៅតែជាការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរបស់អ្នកដទៃដែរ ហេតុដូច្នេះ តាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន គួរតែសាមីខ្លួនចូលរួមនៅក្នុងការគ្រប់គ្រងដោយឃើញ្ឆាលនោះឱ្យបានឆាប់តាំងពីដំបូងតាមដែលអាចធ្វើទៅបាន ។ ដោយសារមូលហេតុនេះ មាត្រានេះកំណត់អំពីករណីយកិច្ចរបស់អ្នកគ្រប់គ្រង ក្នុងការជូនដំណឹងអំពីការចាប់ផ្តើមការគ្រប់គ្រងនោះ ទៅសាមីខ្លួន ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ ប្រសិនបើមិនស្គាល់សាមីខ្លួនទេ អ្នកគ្រប់គ្រងមិនចាំបាច់ធ្វើការជូនដំណឹងទេ ដោយសារតែអ្នកគ្រប់គ្រងមិនអាចធ្វើការជូនដំណឹងទៅសាមីខ្លួនបានឡើយ ។

(2) ភាពយឺតយ៉ាវ ឬ មិនយឺតយ៉ាវនៃការជូនដំណឹង ត្រូវវិនិច្ឆ័យទៅតាមលក្ខណៈនៃការគ្រប់គ្រងកិច្ចការនោះ ។ ប្រសិនបើកិច្ចការដែលត្រូវបានគ្រប់គ្រងនោះ គឺជាកិច្ចការតែមួយដង អ្នកគ្រប់គ្រងហាក់ដូចជាមិនចាំបាច់ធ្វើការជូនដំណឹងទេ ។ ប៉ុន្តែ ដោយសារបញ្ញត្តិស្តីពីអាណត្តិត្រូវយកមកអនុវត្តដូចគ្នាផងដែរ អ្នកគ្រប់គ្រងមានករណីយកិច្ចរាយការណ៍នៅចុងបញ្ចប់ អ្នកគ្រប់គ្រងត្រូវតែជូនដំណឹង (រាយការណ៍) ទៅសាមីខ្លួន ទោះបីជាកិច្ចការគ្រប់គ្រងជាកិច្ចការតែមួយដងក៏ដោយ ។

(3) ដោយសារការជូនដំណឹងដែលបានចែងនៅក្នុងមាត្រានេះ មានគោលបំណងបញ្ជាក់ថា តើសាមីខ្លួនយល់ព្រម ឬ មិនយល់ព្រមចំពោះ ការគ្រប់គ្រងកិច្ចការ អ្នកគ្រប់គ្រងត្រូវរង់ចាំការចង្អុលបង្ហាញពីសាមីខ្លួន លើកលែងតែក្នុងស្ថានភាពពិសេស ដែលការរង់ចាំនឹងបង្កនូវការខូចខាតដល់ផលប្រយោជន៍របស់សាមីខ្លួន ។ ប៉ុន្តែ រហូតទាល់តែមានការចង្អុលបង្ហាញពីសាមីខ្លួនទៅចំពោះអ្នកគ្រប់គ្រង អ្នកគ្រប់គ្រងនៅតែបន្តការគ្រប់គ្រងដែលស្របទៅនឹងឆន្ទៈដែលអាចយល់បានរបស់សាមីខ្លួន ឬ ប្រសិនបើមិនអាចប្រមាណយល់បានអំពីឆន្ទៈរបស់សាមីខ្លួនទេ អ្នកគ្រប់គ្រងត្រូវបន្តការគ្រប់គ្រងឱ្យបានស្របនឹងផលប្រយោជន៍របស់សាមីខ្លួន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៩៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៨១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៧៣២.-** ករណីយកិច្ចបន្តការគ្រប់គ្រងរបស់អ្នកគ្រប់គ្រងដោយឃើញ្ឆាល

អ្នកគ្រប់គ្រងដោយឃើញ្ឆាល ត្រូវបន្តការគ្រប់គ្រងនោះ រហូតដល់ពេលដែលសាមីខ្លួន សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់ របស់សាមីខ្លួននោះ អាចធ្វើការគ្រប់គ្រងបាន ។ ប៉ុន្តែ ប្រសិនបើការបន្តការគ្រប់គ្រងនោះ ផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួន ឬ ប្រសិនបើច្បាស់ថានឹងធ្វើឱ្យខូចផលប្រយោជន៍សាមីខ្លួន ត្រូវបញ្ឈប់ការគ្រប់គ្រងនោះ ។

(កំណត់)

(1) មាត្រានេះកំណត់ថា អ្នកគ្រប់គ្រងដែលបានចាប់ផ្តើមការគ្រប់គ្រង ត្រូវបន្តការគ្រប់គ្រងនោះរហូតដល់ពេលណាមួយ ។ ប្រសិនបើកិច្ចការដែលត្រូវបានគ្រប់គ្រងនោះ ជាកិច្ចការដែលត្រូវធ្វើតែមួយដង នោះនឹងមិនមានបញ្ហាអ្វីកើតឡើងទេ

ដោយសារការគ្រប់គ្រងនោះ ត្រូវចប់នៅពេលដែលអ្នកគ្រប់គ្រងបំពេញកិច្ចការគ្រប់គ្រងចប់សព្វគ្រប់ ។ ប៉ុន្តែ ប្រសិនបើកិច្ចការទាមទារឱ្យមានការគ្រប់គ្រងជាបន្ត ហើយអំឡុងពេលដែលត្រូវធ្វើការគ្រប់គ្រងនោះ មិនបានកំណត់ជាក់លាក់ទេនោះ បញ្ហានឹងកើតឡើងថា តើអ្នកគ្រប់គ្រងត្រូវបន្តគ្រប់គ្រងរហូតដល់ពេលណា ។ ដើម្បីដោះស្រាយបញ្ហានេះ មាត្រានេះចែងថា អ្នកគ្រប់គ្រងត្រូវបន្តការគ្រប់គ្រងរហូតដល់មានហេតុជាក់លាក់ណាមួយកើតឡើង ។

(2) អ្នកគ្រប់គ្រងមានករណីយកិច្ចបន្តធ្វើការគ្រប់គ្រងរហូតដល់ពេលដែលសាមីខ្លួន សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់ អាចប្រុងប្រៀបដើម្បីធ្វើការគ្រប់គ្រងដោយខ្លួនឯងបាន ។ ប្រសិនបើអ្នកគ្រប់គ្រងចាប់ផ្ដើមធ្វើការគ្រប់គ្រងដោយឈឺឆ្អាល ហើយបោះបង់ចោលពាក់កណ្ដាលទី អំពើរបៀបនេះនឹងបង្កឱ្យមានការខូចខាតមិនត្រឹមត្រូវដល់សាមីខ្លួនជាញឹកញាប់ ។ ដោយសារតែហេតុផលនេះហើយ ជាគោលការណ៍ អ្នកគ្រប់គ្រងមិនត្រូវបានអនុញ្ញាតឱ្យបញ្ឈប់ការគ្រប់គ្រងដោយការសម្រេចចិត្តរបស់ខ្លួនឯងតែម្ខាងនោះទេ ។ ប៉ុន្តែ ប្រសិនបើមានភាពច្បាស់លាស់ថា ការគ្រប់គ្រងដោយឈឺឆ្អាលនោះ ផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួន ឬ ធ្វើឱ្យខូចផលប្រយោជន៍របស់សាមីខ្លួន ការបន្តការគ្រប់គ្រងមិនត្រូវបានអនុញ្ញាត ដោយយោងតាមស្មារតីនៃគោលគំនិតដើមនៃការគ្រប់គ្រងដោយឈឺឆ្អាលដូចមានចែងក្នុង កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ នៃមាត្រា ៧២៩ ហេតុដូច្នេះ អ្នកគ្រប់គ្រងត្រូវបញ្ឈប់ការគ្រប់គ្រង ទោះបីជាសាមីខ្លួន ជាអាទិ៍ មិនទាន់បានប្រុងប្រៀបដើម្បីធ្វើការគ្រប់គ្រងក៏ដោយ ។ វាក្យខណ្ឌទី ២ នៃមាត្រានេះ ធ្វើការបញ្ជាក់ឱ្យច្បាស់ឡើងវិញនូវគោលគំនិតនេះ ។

(3) មាត្រានេះមិនមានបញ្ញត្តិចែងថា តើការគ្រប់គ្រងដោយឈឺឆ្អាលត្រូវបញ្ចប់ដែរ ឬ យ៉ាងណានោះទេ នៅពេលដែលអ្នកគ្រប់គ្រងទទួលមរណភាព ។ ទោះបីជាមានលទ្ធភាពក្នុងការបកស្រាយថា សន្តតិជនរបស់អ្នកគ្រប់គ្រង ត្រូវទទួលសន្តតិកម្មនូវករណីយកិច្ចបន្តគ្រប់គ្រងកិច្ចការក៏ដោយ ក៏សន្តតិជននោះអាចនឹងមិនមានសមត្ថភាពគ្រប់គ្រងបានត្រឹមត្រូវដែរ ឧទាហរណ៍ដូចជាករណីដែលសន្តតិជនរស់នៅឆ្ងាយ ជាដើម ។ ដោយសារតែសុឆន្ទៈរបស់អ្នកគ្រប់គ្រង មានសារៈសំខាន់ ចំពោះការគ្រប់គ្រងដោយឈឺឆ្អាល ហើយដោយសារតែមរណភាពរបស់អាណត្តិគាហក ក៏ជាមូលហេតុមួយនៃការបញ្ចប់អាណត្តិ (មាត្រា ៦៤៩) វាប្រហែលជាសមរម្យក្នុងការបកស្រាយថា ការគ្រប់គ្រងដោយឈឺឆ្អាលត្រូវបញ្ចប់នៅពេលដែលអ្នកគ្រប់គ្រងទទួលមរណភាព ។ ប៉ុន្តែ បញ្ហានេះទុកឱ្យតុលាការសម្រេចថា តើត្រូវប្រកាន់យកការបកស្រាយមួយណានោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨២៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ៧០០ នៃក្រមរដ្ឋប្បវេណីជប៉ុន, កថាខណ្ឌទី ២ មាត្រា ១៣៧២ នៃ ក្រមរដ្ឋប្បវេណីបារាំង

## **មាត្រា ៧៣៣.-** ការយកបញ្ញត្តិនៃអាណត្តិមកអនុវត្តដូចគ្នា

បញ្ញត្តិចាប់ពីមាត្រា ៦៤១ (ករណីយកិច្ចរាយការណ៍ របស់អាណត្តិគាហក) រហូតដល់មាត្រា ៦៤៣ (ករណីយកិច្ចសងសំណងនៃការខូចខាតរបស់អាណត្តិគាហកដែលបានប្រើប្រាក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ នៅក្នុងការគ្រប់គ្រងដោយឈឺឆ្នាល ។

(កំណត់)

ទោះបីជាការគ្រប់គ្រងដោយឈឺឆ្នាលមិនត្រូវបានធ្វើឡើងដោយផ្អែកលើឆន្ទៈរបស់សាមីខ្លួនក៏ដោយ ក៏វាស្រដៀងគ្នានឹងកិច្ចសន្យាអាណត្តិដែរ ត្រង់ចំណុចថា តាមរយៈកិច្ចសន្យាអាណត្តិ អាណត្តិគាហកធ្វើការចាត់ចែងកិច្ចការរបស់អាណត្តិទាយក ឯតាមការគ្រប់គ្រងដោយឈឺឆ្នាល អ្នកគ្រប់គ្រងធ្វើការចាត់ចែងកិច្ចការដោយឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីផលប្រយោជន៍របស់សាមីខ្លួន ។ ដូច្នេះ វាទំនងជាសមរម្យដែលអ្នកគ្រប់គ្រងត្រូវទទួលបន្ទុកនូវករណីយកិច្ច ដូចគ្នានឹងករណីយកិច្ចដែលអាណត្តិគាហកត្រូវទទួលបន្ទុក ។ ហេតុដូច្នេះ មាត្រានេះចែងថា បញ្ញត្តិចាប់ពីមាត្រា ៦៤១ (ករណីយកិច្ចរាយការណ៍របស់អាណត្តិគាហក) ដល់មាត្រា ៦៤៣ (ករណីយកិច្ចសងសំណងនៃការខូចខាតរបស់អាណត្តិគាហកដែលបានប្រើប្រាក់) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការគ្រប់គ្រងដោយឈឺឆ្នាល ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧០១ នៃក្រមរដ្ឋប្បវេណីជប៉ុន, កថាខណ្ឌទី ២ មាត្រា ១៣៧២ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៦៨១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៧៣៤.-** សិទ្ធិទាមទារសងសោហ៊ុយវិញរបស់អ្នកគ្រប់គ្រងដោយឈឺឆ្នាល

១-ប្រសិនបើបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ឬចំណាយបង្កើនតម្លៃ ដើម្បីសាមីខ្លួន អ្នកគ្រប់គ្រងដោយឈឺឆ្នាលអាចទាមទារ ចំពោះសាមីខ្លួនឱ្យសងវិញបាន ។

២-បញ្ញត្តិកថាខណ្ឌទី ២ នៃមាត្រា ៦៤៦ (សិទ្ធិទាមទារឱ្យសងមកវិញ ជាអាទិ៍ នូវសោហ៊ុយរបស់អាណត្តិគាហក) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្នាល បានទទួលបន្ទុកកាតព្វកិច្ចដែលជាសោហ៊ុយដែលបានបង្កើនតម្លៃ ដើម្បីសាមីខ្លួន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្ត ត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលសាមីខ្លួនបានទទួលជាក់ស្តែង ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានធ្វើការគ្រប់គ្រងផ្ទុយពីឆន្ទៈរបស់សាមីខ្លួន ។

(កំណត់)

(1) អត្ថប្រយោជន៍ក្នុងការទទួលស្គាល់ការបង្កើតសកម្មភាពគ្រប់គ្រងដោយឈឺឆ្អាល មាននៅត្រង់ចំណុចថា ប្រសិនបើសកម្មភាពគ្រប់គ្រងមួយរបស់អ្នកគ្រប់គ្រងត្រូវបានចាត់ទុកថាជាស្របច្បាប់ ករណីយកិច្ចមួយចំនួននឹងកើតឡើងចំពោះសាមីខ្លួន ដោយសារតែសកម្មភាពស្របច្បាប់របស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល ។ ក្នុងចំណោមករណីយកិច្ចដែលកើតឡើងចំពោះសាមីខ្លួន ករណីយកិច្ចមួយដែលទទួលស្គាល់បានដោយមិនមានមន្ទិល គឺករណីយកិច្ចសងនូវសោហ៊ុយដែលបានចំណាយសម្រាប់ការគ្រប់គ្រង ។ បើនិយាយពីទស្សនៈនៃអ្នកគ្រប់គ្រងវិញ វាគឺជាសិទ្ធិទាមទារឱ្យសងនូវសោហ៊ុយ ។

ដោយសារតែការគ្រប់គ្រងដោយឈឺឆ្អាលបម្រើឱ្យផលប្រយោជន៍របស់សាមីខ្លួន យ៉ាងហោចណាស់ សាមីខ្លួនត្រូវទទួលបន្ទុកនូវសោហ៊ុយដែលបានចំណាយសម្រាប់ការគ្រប់គ្រងដែរ ។ វាសមហេតុសមផលដែលយើងគិតបែបដូច្នេះថា "ទីណាមានផលប្រយោជន៍ ទីនោះមានបន្ទុកនូវសោហ៊ុយ" ។ កថាខណ្ឌទី ១ កំណត់ច្បាស់លាស់អំពីបញ្ហានេះ ។

(2) ប្រសិនបើអ្នកគ្រប់គ្រងទទួលបន្ទុកនូវកាតព្វកិច្ច ក្នុងការប្រតិបត្តិនូវការគ្រប់គ្រងដោយឈឺឆ្អាល វាមានលក្ខណៈងាយស្រួលដែលអ្នកគ្រប់គ្រងអាចមិនត្រឹមតែអនុវត្តកាតព្វកិច្ច និង ទាមទារឱ្យសាមីខ្លួនសងសោហ៊ុយមកវិញ ដោយយោងតាមកថាខណ្ឌទី ១ ប៉ុន្តែ អាចទាមទារឱ្យសាមីខ្លួនអនុវត្តកាតព្វកិច្ចជំនួសអ្នកគ្រប់គ្រងដោយឈឺឆ្អាលដែរនោះ ។ ការអនុវត្តរបៀបនេះនឹងកាត់បន្ថយនូវហានិភ័យរបស់អ្នកគ្រប់គ្រងផងដែរ ។ ដោយគិតដល់បញ្ហានេះហើយ ទើបយើងបង្កើតឱ្យមានកថាខណ្ឌទី ២ ឡើង ។

(3) វាទាមទារឱ្យមានការគិតពិចារណាបន្ថែមដើម្បីកំណត់ថា ការខូចខាតដែលអ្នកគ្រប់គ្រងទទួលរង នៅពេលប្រតិបត្តិការគ្រប់គ្រងដោយឈឺឆ្អាល គួរត្រូវបានដាក់បញ្ចូលនៅក្នុងសោហ៊ុយដែលបានចំណាយសម្រាប់ការគ្រប់គ្រងដែរ ឬទេ ។ ដូចកថាខណ្ឌទី ៣ នៃមាត្រា ៦៤៦ ដែលពាក់ព័ន្ធនឹងអាណត្តិដែរ វាអាចត្រូវបានបកស្រាយថា អ្នកគ្រប់គ្រងអាចទាមទារនូវសំណងការខូចខាតពីសាមីខ្លួន ចំពោះការខូចខាតទាំងឡាយណាដែលអ្នកគ្រប់គ្រងទទួលរងដោយគ្មានកំហុស ។ ប៉ុន្តែ យើងក៏អាចគិតបានដែរថា អ្នកគ្រប់គ្រងដោយឈឺឆ្អាលមិនមានសិទ្ធិទាមទារសំណងការខូចខាតពីសាមីខ្លួនទេ ពីព្រោះអ្នកគ្រប់គ្រងដោយឈឺឆ្អាល ដែលធ្វើកិច្ចការ មិនមែនដោយផ្អែកលើឆន្ទៈរបស់សាមីខ្លួន មិនគួរត្រូវបានចាត់ចែងដូចគ្នានឹងអាណត្តិគាហកដែលធ្វើកិច្ចការ ដោយផ្អែកលើកិច្ចសន្យាអាណត្តិដែលធ្វើជាមួយសាមីខ្លួន (អាណត្តិទាយក) នោះទេ ។

ជាទូទៅ ដោយសារតែមានករណីច្រើនប្រភេទដែលអ្នកគ្រប់គ្រងដោយឈឺឆ្អាលទទួលរងនូវការខូចខាត នៅពេលអនុវត្តការគ្រប់គ្រងដោយឈឺឆ្អាល វាហាក់ដូចជាមានភាពសមរម្យដែលថា ការសម្រេចថា តើការខូចខាតត្រូវដាក់បញ្ចូល

ទៅក្នុងសោហ៊ុយដែលបានចំណាយសម្រាប់ការគ្រប់គ្រងដែរ ឬយ៉ាងណានោះ ត្រូវទុកឱ្យតុលាការវិនិច្ឆ័យ ដោយផ្អែកទៅតាមស្ថានភាពជាក់លាក់នីមួយៗ ។ ប្រសិនបើបុគ្គលណាម្នាក់បានជួយអ្នកដែលលង់ទឹក ហើយសម្លៀកបំពាក់របស់ខ្លួនប្រឡាក់កខ្វក់ ការខូចខាតនោះត្រូវបានបង្កឡើងជាធម្មតា នៅក្នុងអំឡុងពេលនៃការគ្រប់គ្រងដោយឈឺឆ្អាល ហេតុដូច្នេះ ការខូចខាតនោះត្រូវរាប់បញ្ចូលទៅក្នុងសោហ៊ុយ ។ ប៉ុន្តែ ប្រសិនបើបុគ្គលនោះ ទៅប៉ះទង្គិចជាមួយនឹងឈើអណ្តែតទឹក ហើយមានរបួស ការខូចខាតនោះបានកើតឡើងដោយគ្រោះថ្នាក់ចៃដន្យនាអំឡុងពេលជួយសង្គ្រោះ ហេតុដូច្នេះ វានៅមានការជជែកដេញដោលគ្នាថា តើរបួសស្នាមដោយគ្រោះថ្នាក់ចៃដន្យនាអំឡុងពេលជួយសង្គ្រោះនោះ គួរដាក់បញ្ចូលក្នុងសោហ៊ុយដែរ ឬទេ ។ យើងអាចនិយាយបានថា បញ្ហាទាំងនេះនឹងកើតឡើងផងដែរនៅក្នុងករណីនៃអាណត្តិ ពីព្រោះថា ការពិនិត្យមើលស្រដៀងគ្នានេះនឹងត្រូវធ្វើឡើងនៅពេលធ្វើការវិនិច្ឆ័យថា តើអាណត្តិគាហកទទួលរងនូវការខូចខាត "ដើម្បីចាត់ចែងកិច្ចការអាណត្តិ" ឬទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨២៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ៧០២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៨៣ និង មាត្រា ៦៨៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៣៧៥ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៧៣៥**.- សិទ្ធិទាមទារកម្រៃរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

ក្នុងករណីដែលការគ្រប់គ្រងដោយឈឺឆ្អាលនោះរួមបញ្ចូលនៅក្នុងវិជ្ជាជីវៈ ឬ អាជីវកម្មរបស់អ្នកគ្រប់គ្រង ចំពោះកិច្ចការដែលនៅតែធ្វើបន្ត ក្រោយពេលដែលសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងដោយឈឺឆ្អាលនោះរួចហើយ អ្នកគ្រប់គ្រងដោយឈឺឆ្អាល អាចទាមទារកម្រៃដែលត្រូវបង់ជាទូទៅ ចំពោះការគ្រប់គ្រងដោយឈឺឆ្អាលនោះបាន ។

(កំណត់)

(1) ចំពោះបញ្ហាថា តើត្រូវផ្តល់កម្រៃដល់ការគ្រប់គ្រងដោយឈឺឆ្អាល ឬយ៉ាងណា អាចមានមតិផ្សេងៗគ្នាបានដែរ ។ ប៉ុន្តែ ការគ្រប់គ្រងដោយឈឺឆ្អាល ត្រូវបានធ្វើឡើង តាមសុឆន្ទៈរបស់អ្នកគ្រប់គ្រង ដូចជា សាមគ្គីភាពរវាងគ្នា ការជួយគ្នាទៅវិញទៅមករវាងអ្នកជិតខាង ជាអាទិ៍ ហើយក៏ត្រូវបានធ្វើឡើងដោយមិនផ្អែកលើឆន្ទៈរបស់សាមីខ្លួនទេ ហេតុដូច្នេះ ការគ្រប់គ្រងនោះ គួរតែត្រូវបានចាត់ទុកថាជាសកម្មភាពដោយឥតយកកម្រៃ ហើយសិទ្ធិទាមទារកម្រៃរបស់អ្នកគ្រប់គ្រង ជាគោលការណ៍ គួរតែត្រូវបានបដិសេធ ។

(2) ប៉ុន្តែ បើយោងទៅតាមយុត្តិសាស្ត្រ និង ទស្សនៈរួមរបស់ប្រទេសបារាំង និង ទស្សនៈរួមរបស់ប្រទេសអាល្លឺម៉ង់ និង ប្រទេសជប៉ុន ប្រសិនបើសកម្មភាពគ្រប់គ្រងដោយឈឺឆ្អាលរបស់អ្នកគ្រប់គ្រង ត្រូវបានដាក់បញ្ចូលក្នុងវិជ្ជាជីវៈ ឬ អាជីវកម្មរបស់អ្នកគ្រប់គ្រង អ្នកគ្រប់គ្រងដោយឈឺឆ្អាល អាចទាមទារនូវកម្រៃដែលនឹងត្រូវបានបង់ចំពោះវិជ្ជាជីវៈ ឬ

អាជីវកម្មរបស់ខ្លួន ។ ដោយយោងទៅលើទស្សនៈនេះ មាត្រានេះចែងថា សាមីខ្លួនមានករណីយកិច្ចបង់កម្រៃដែលត្រូវបង់ជាទូទៅ ចំពោះការគ្រប់គ្រងដោយឈឺឆ្អាល ដែលប្រតិបត្តិដោយអ្នកគ្រប់គ្រង នៅក្រោយពេលដែលសាមីខ្លួនបានដឹងថា ការគ្រប់គ្រងដោយឈឺឆ្អាលត្រូវធ្វើឡើងដោយអ្នកគ្រប់គ្រងដែលប្រកបវិជ្ជាជីវៈ ឬ អាជីវកម្មគ្រប់គ្រង ។ នៅក្រោយពេលដែលសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងនេះ វាមិនមានបញ្ហាអ្វីកើតឡើងទេ ក្នុងការតម្រូវឱ្យសាមីខ្លួនមានករណីយកិច្ចបង់កម្រៃ ពីព្រោះសកម្មភាពគ្រប់គ្រង អាចត្រូវបានចាត់ទុកថា ត្រូវបានធ្វើឡើងដោយផ្អែកលើឆន្ទៈរបស់សាមីខ្លួន ។ ចំពោះបញ្ហាថា តើសាមីខ្លួនមានករណីយកិច្ចបង់កម្រៃ នៅមុនពេលខ្លួនបានដឹងអំពីការគ្រប់គ្រងដោយឈឺឆ្អាលប្រភេទនោះដែរ ឬយ៉ាងណា គួររង់ចាំឱ្យមានយុត្តិសាស្ត្រនាអនាគត ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨២៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ៧០២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៨៣ និង មាត្រា ៦៨៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៣៧៥ នៃក្រមរដ្ឋប្បវេណីបារាំង

## ជំពូកទី ១៥ សេចក្តីចម្រើនដោយឥតហេតុ

**មាត្រា ៧៣៦**.- លក្ខខណ្ឌ និង អានុភាពនៃសេចក្តីចម្រើនដោយឥតហេតុ

១-ទោះបីជាគ្មានមូលហេតុលើផ្លូវច្បាប់ក៏ដោយ បុគ្គលដែលបានទទួលផលប្រយោជន៍ដោយសារទ្រព្យសម្បត្តិ ឬ ពលកម្មរបស់អ្នកដទៃ ហើយធ្វើឱ្យកើតមានការបាត់បង់ផលប្រយោជន៍ដល់អ្នកដទៃ ដោយសារការទទួលនោះ មានករណីយកិច្ចត្រូវសងផលប្រយោជន៍នោះ ត្រឹមកម្រិតដែលផលប្រយោជន៍នោះមាន ។

២-នៅក្នុងករណីដែលបានទទួលការផ្តល់តាវកាលិកពីអ្នកដទៃ ដោយយោលតាមកិច្ចសន្យា ប្រសិនបើកិច្ចសន្យានោះពុំមានអានុភាព ឬ ត្រូវបានបាត់បង់អានុភាព បុគ្គលដែលបានទទួលការផ្តល់តាវកាលិកនោះ មានករណីយកិច្ចត្រូវសងផលប្រយោជន៍ ដែលខ្លួនទទួលបានដោយសារការផ្តល់តាវកាលិកនោះ ឱ្យទៅអ្នកដទៃដែលបានផ្តល់តាវកាលិកនោះវិញ ដូចគ្នានឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះដែរ ។

(កំណត់)

(1) ការពិភាក្សាដំសកម្មស្តីពីសេចក្តីចម្រើនដោយឥតហេតុ កំពុងតែបន្តធ្វើឡើងនៅបណ្តាប្រទេសនីមួយៗ ។ ជាពិសេសមានប្រទេសជាច្រើន កំពុងតែចាប់ផ្តើមទទួលស្គាល់ថា វាពិតជាមានសារៈសំខាន់ក្នុងការធ្វើការចាត់ប្រភេទសេចក្តីចម្រើនដោយឥតហេតុ និង ធ្វើការពិចារណាដោយយោងទៅតាមការបែងចែកនោះ ។ នៅពេលប្រទេសណាមួយបង្កើតនូវវិធាន

នានាស្តីពីសេចក្តីចម្រើនដោយឥតហេតុ ប្រទេសនោះនឹងប្រឈមមុខជាមួយនឹងបញ្ហាស្តីពីរបៀបដែលត្រូវប្រកាន់យក គឺបញ្ហាថា ត្រូវអនុម័តនូវវិធានសម្រាប់ប្រភេទនៃសេចក្តីចម្រើនដោយឥតហេតុនីមួយៗ ឬ ត្រូវអនុម័តនូវវិធានទូទៅហើយដោយផ្អែកលើវិធានទូទៅនេះ បង្កើតនូវវិធានជាក់លាក់តាមយុត្តិសាស្ត្រ ។ យើងបានសម្រេចយកវិធីទីពីរនេះសម្រាប់ក្រមរដ្ឋប្បវេណីកម្ពុជា ពីព្រោះទោះបីជាគេនិយាយថា វាចាំបាច់ដើម្បីធ្វើការបែងចែកប្រភេទសេចក្តីចម្រើនដោយឥតហេតុក៏ដោយ ក៏ទស្សនៈស្តីពីប្រភេទដែលត្រូវបង្កើតនោះខុសគ្នាពីប្រទេសមួយទៅប្រទេសមួយដែរ ។ ហេតុផលមួយទៀតដែលយើងស្នាក់ស្ទើរក្នុងការសម្រេចយកវិធីទីមួយ គឺដោយសារតែក្រមរដ្ឋប្បវេណីនេះ មិនទទួលយកនូវរបបឯករាជ្យភាពនៃសកម្មភាពទាក់ទងនឹងសិទ្ធិប្រត្យក្ស និង ភាពគ្មានទំនាក់ទំនងគ្នារវាងមូលហេតុ និង លទ្ធផលនៃសកម្មភាពទាក់ទងនឹងសិទ្ធិប្រត្យក្សទេ ។

(2) ពីទស្សនៈនៃសមភាព កថាខណ្ឌទី ១ ចែងថា ប្រសិនបើបុគ្គលណាមួយទទួលបានផលប្រយោជន៍ ដោយគ្មានមូលហេតុគតិយុត្ត ក្នុងខណៈពេលដែលបុគ្គលម្ខាងទៀតទទួលរងនូវការបាត់បង់ផលប្រយោជន៍ដែលជាមូលហេតុនៃការទទួលប្រយោជន៍ដោយបុគ្គលម្ខាងទៀតនោះ អ្នកទទួលរងនូវការបាត់បង់ផលប្រយោជន៍នោះ មានសិទ្ធិទាមទារឱ្យសងមកវិញនូវផលប្រយោជន៍ពីអ្នកទទួលនោះ ។ បញ្ហាថា តើ "ផលប្រយោជន៍" បានកើតឡើងដែរ ឬយ៉ាងណា តើ "ការបាត់បង់ផលប្រយោជន៍" ត្រូវបានទទួលរងដែរ ឬយ៉ាងណា និង ថា តើមានទំនាក់ទំនងហេតុផលរវាង "ផលប្រយោជន៍" និង "ការបាត់បង់ផលប្រយោជន៍" ដែរ ឬយ៉ាងណា នឹងត្រូវបានវិនិច្ឆ័យដោយយោងទៅតាមស្ថានភាពជាក់លាក់នីមួយៗ ។

(3) ទំហំនៃ "ផលប្រយោជន៍" ដែលត្រូវសងទៅវិញដោយបុគ្គលដែលបានទទួលផលប្រយោជន៍នោះ ត្រូវបានកម្រិតនៅក្នុងទំហំនៃ "ការបាត់បង់ផលប្រយោជន៍" ។ ជាញឹកញាប់ បុគ្គលដែលបានទទួលផលប្រយោជន៍ តែងតែបរិភោគផលប្រយោជន៍នោះ ។ ប្រសិនបើបុគ្គលដែលបានទទួលផលប្រយោជន៍ ត្រូវបានបង្គាប់ឱ្យសងផលប្រយោជន៍ក្រោយពេលបរិភោគ បុគ្គលដែលបានទទួលផលប្រយោជន៍អាចទទួលរងនូវការខូចខាតដោយមិនបានព្យាករទុកជាមុន ។ ហេតុដូច្នេះអ្វីដែលត្រូវសងទៅវិញនោះ ត្រូវបានកម្រិតត្រឹម "ផលប្រយោជន៍ដែលមាន" ។ ប៉ុន្តែ ដោយសារតែមិនសូវមានភាពចាំបាច់ច្រើនក្នុងការការពារបុគ្គលដែលបានទទួលផលប្រយោជន៍ដោយទុច្ចរិត ដូចបានចែងក្នុងមាត្រា ៧៣៧ មាត្រានេះត្រូវយកមកអនុវត្តតែចំពោះបុគ្គលណាដែលបានទទួលផលប្រយោជន៍ដោយសុចរិតប៉ុណ្ណោះ ។

(4) ចំពោះបញ្ហាថា តើផលប្រយោជន៍ "មាន" ឬ "គ្មាន" គឺអាស្រ័យទៅលើការវិនិច្ឆ័យរបស់តុលាការ ។ ប៉ុន្តែ ប្រសិនបើ "ផលប្រយោជន៍" ជាប្រាក់វិញ ការវិនិច្ឆ័យដែលសម្រេចថា "មាន" នឹងមានភាពទូលំទូលាយ ដោយសារលក្ខណៈនៃសិទ្ធិដែលមានតម្លៃ ឬ ភាពអរូបីនៃប្រាក់ ។ ឧទាហរណ៍ ប្រសិនបើបុគ្គលដែលបានទទួលប្រាក់ជាផលប្រយោជន៍ បានប្រើប្រាស់ប្រាក់នោះ សម្រាប់ចំណាយក្នុងជីវភាពរស់នៅ បុគ្គលនោះសន្សំប្រាក់ពីប្រាក់ដែលត្រូវចំណាយសម្រាប់ការផ្គត់ផ្គង់គ្រួសារ ហេតុដូច្នេះ "ផលប្រយោជន៍" នៅតែមានជាប្រាក់ដែលបានសន្សំទុក ។

(5) កថាខណ្ឌទី ២ ចែងថា វិធានស្តីពីសេចក្តីចម្រើនដោយឥតហេតុ ត្រូវយកមកអនុវត្ត ចំពោះករណីដែលកិច្ចសន្យាក្លាយជាមោឃៈ ឬ បាត់បង់អានុភាពដោយសារការលុបចោល ឬ ការរំលាយ ។ ប៉ុន្តែ ក្នុងករណីនេះ ប្រសិនបើ

មានវិធានពិសេសចំពោះកិច្ចសន្យាគួរអនុវត្ត ការអនុវត្តវិធានពិសេសនោះត្រូវចាត់ទុកថា ស្របទៅតាមឆន្ទៈរបស់ភាគី និង នាំមកនូវលទ្ធផលដែលប្រកបដោយភាពត្រឹមត្រូវ ។ បញ្ហាថា តើករណីនីមួយៗស្ថិតក្នុងករណីបែបនេះ ឬ យ៉ាងណានោះ ត្រូវបានទុកឱ្យតុលាការធ្វើការវិនិច្ឆ័យ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨២១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ៧០៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៧៦ និង មាត្រា ១៣៧៧ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៨១២ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៧៣៧.-** ករណីយកិច្ចសងរបស់អ្នកទទួលផលប្រយោជន៍ដោយគំនិតទុច្ចរិត

១-បុគ្គលដែលបានទទួលផលប្រយោជន៍ ដូចបានកំណត់នៅក្នុងមាត្រា ៧៣៦ (ល័ក្ខខ័ណ្ឌ និង អានុភាពនៃសេចក្ដីចម្រើនដោយឥតហេតុ) ខាងលើនេះ ក្នុងករណីដែលបានដឹងថាគ្មានមូលហេតុលើផ្លូវច្បាប់ ឬ ដឹងថាកិច្ចសន្យានោះពុំមានអានុភាព បុគ្គលដែលបានទទួលផលប្រយោជន៍ មានករណីយកិច្ចត្រូវសងផលប្រយោជន៍ដែលមាននៅពេលដែលបានដឹង និង ការប្រាក់ គិតចាប់ពីពេលដែលបានដឹង រហូតដល់ពេលសង ។

២-បើបុគ្គលដែលបានទទួលផលប្រយោជន៍ មានចេតនា ឬ កំហុស ចំពោះអានុភាពនៃកិច្ចសន្យាដែលត្រូវបានបាត់បង់ បុគ្គលដែលបានទទួលផលប្រយោជន៍នោះ មានករណីយកិច្ចត្រូវសងផលប្រយោជន៍នោះ ដោយភ្ជាប់ជាមួយនឹងការប្រាក់ ដូចគ្នានឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះដែរ ។

៣-បើបុគ្គលដែលត្រូវបានបាត់បង់ផលប្រយោជន៍ ទទួលការខូចខាត ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ បុគ្គលដែលបានទទួលផលប្រយោជន៍ត្រូវទទួលខុសត្រូវលើសំណងនៃការខូចខាតនោះ ។

(កំណត់)

(1) ប្រសិនបើបុគ្គលដែលបានទទួលផលប្រយោជន៍បានដឹងថា ផលប្រយោជន៍នោះគ្មានមូលហេតុគតិយុត្តទេ បុគ្គលនោះអាចត្រូវបាននិយាយបានថា បានដឹងថាផលប្រយោជន៍នោះជារបស់បុគ្គលដទៃ ។ ហេតុដូច្នេះ កថាខណ្ឌទី ១ ចែងថា នៅក្នុងករណីបែបនេះ បុគ្គលដែលបានទទួលផលប្រយោជន៍ ត្រូវសងផលប្រយោជន៍ដែលមាននៅពេលដែលខ្លួនបានដឹងពីការណ៍នោះ ជាមួយគ្នានឹងការប្រាក់ដែលបានមកពីផលប្រយោជន៍នោះ ។ ភាពត្រឹមត្រូវនៃការអនុវត្តបែបនេះ គឺច្បាស់លាស់ដូចបានពន្យល់អំពីមាត្រា ៧៤៧ ហើយ ។ ចូរកត់សម្គាល់ថា ទោះបីជាបុគ្គលដែលបានទទួលផលប្រយោជន៍នោះ

មិនបានដឹងអំពីការណ៍នោះពីដំបូង (សុចរិត) ក៏ដោយ ប្រសិនបើបុគ្គលនោះក្លាយទៅជាទុច្ចរិតវិញនៅពេលក្រោយ ក៏មាត្រានេះត្រូវយកមកអនុវត្តដែរ ។ ចំណុចនេះ ខុសគ្នាពីការអនុវត្តតាមក្រមរដ្ឋប្បវេណីជប៉ុន ។

(2) ប្រសិនបើកិច្ចសន្យាត្រូវបានលុបចោលដោយសារការឆបោក គេអាចនិយាយបានថា ជនឆបោកនោះ បានដឹងថា ផលប្រយោជន៍ដែលខ្លួនទទួលបាន នឹងគ្មានមូលហេតុគតិយុត្ត ដោយសារការលុបចោលនាអនាគត ។ ក្នុងករណីនេះ ជនឆបោកអាចត្រូវបានចាត់ទុកថា បានដឹងថា ខ្លួនគ្មានមូលហេតុគតិយុត្តក្នុងការទទួលប្រយោជន៍ទេ ។ កថាខណ្ឌទី ២ បញ្ជាក់ច្បាស់លាស់អំពីបញ្ហានេះ ។ ការចាត់ចែងបែបនេះគួរធ្វើឡើង មិនគ្រាន់តែក្នុងករណីដែលបុគ្គលដែលបានទទួលផលប្រយោជន៍ មានចេតនាប៉ុណ្ណោះទេ ព្រមទាំងករណីដែលបុគ្គលនោះមានកំហុសដែរ ហេតុដូច្នេះ កថាខណ្ឌទី ២ ត្រូវយកមកអនុវត្ត មិនមែនតែចំពោះករណីដែលបុគ្គលបានទទួលប្រយោជន៍ដោយចេតនាប៉ុណ្ណោះទេ ព្រមទាំងចំពោះករណីដែលបុគ្គលបានទទួលផលប្រយោជន៍ដោយមានកំហុសផងដែរ ។

(3) កថាខណ្ឌទី ៣ ចែងថា ប្រសិនបើបុគ្គលដែលបង្កឱ្យមានការបាត់បង់ផលប្រយោជន៍ ក៏ទទួលរងនូវការខូចខាតដែរ បុគ្គលដែលបានទទួលផលប្រយោជន៍ដែលបានដឹង ឬ គួរអាចដឹងបានថា ផលប្រយោជន៍នោះគ្មានមូលហេតុគតិយុត្ត ត្រូវសងការខូចខាតនោះ ។ កថាខណ្ឌទី ៣ ទទួលស្គាល់នូវការទទួលខុសត្រូវរបស់អ្នកទទួលផលប្រយោជន៍ ចំពោះសំណងនៃការខូចខាត ក្រោមគោលការណ៍នៃការទទួលខុសត្រូវដោយកំហុស ។

ចំពោះការទទួលខុសត្រូវក្នុងការសំណងនៃការខូចខាតនេះ វានៅតែមានការជជែកដេញដោលគ្នាថា តើត្រូវទទួលស្គាល់ជាពិសេសតាមបញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ ដើម្បីធានាឱ្យបាននូវភាពយុត្តិធម៌ ឬ គួរត្រូវទទួលស្គាល់តាមបញ្ញត្តិស្តីពីអំពើអនីត្យានុកូល (ការកំណត់ក្នុងមាត្រានេះដើម្បីជាការបញ្ជាក់បន្ថែមចំពោះករណីនេះ) ។ ដោយសារតែបញ្ហានេះត្រូវដោះស្រាយទៅតាមការវិវត្តនៃវិធានស្តីពីការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល និង ការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច យើងមិនព្យាយាមស្វែងរកចម្លើយទេ ដោយទុកឱ្យតុលាការ និង ទ្រឹស្តីនីតិសាស្ត្រនាពេលអនាគតធ្វើការបកស្រាយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨២៣ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ៧០៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៧៨ នៃក្រមរដ្ឋប្បវេណីបារាំង, កថាខណ្ឌទី ១ មាត្រា ៨១៩ និង កថាខណ្ឌទី ៤ មាត្រា ៨១៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៧៣៨.- ការសងដោយគ្មានកាតព្វកិច្ច

បុគ្គលដែលបានសងកាតព្វកិច្ចដែលខ្លួនគ្មាន អាចទាមទារឱ្យសងតាវកាលិកនៃការសងនោះ មកវិញបាន ។ ប៉ុន្តែ ក្នុងករណីដែលដឹងថា គ្មានកាតព្វកិច្ចនៅពេលសងនោះទេ បុគ្គលដែលបានសង មិនអាចទាមទារឱ្យសងតាវកាលិកនៃការសងនោះ មកវិញបានឡើយ ។

(កំណត់)

ប្រសិនបើបុគ្គលណាម្នាក់ដែលគ្មានកាតព្វកិច្ច បានសងកាតព្វកិច្ចនោះ បុគ្គលនោះអាចត្រូវបានចាត់ទុកថា បានរងនូវការបាត់បង់ផលប្រយោជន៍ ។ ផ្ទុយទៅវិញ ប្រសិនបើបុគ្គលណាម្នាក់ដែលគ្មានសិទ្ធិលើបំណុល បានទទួលការសងចំពោះសិទ្ធិលើបំណុលនោះ បុគ្គលនោះអាចត្រូវបានចាត់ទុកថា បានទទួលផលប្រយោជន៍ ដោយគ្មានមូលហេតុគតិយុត្ត ។ ហេតុដូច្នេះ វាក្យខណ្ឌទី ១ នៃមាត្រានេះចែងថា ជាគោលការណ៍ ករណីបែបនេះបង្កើតឱ្យមាននូវសេចក្ដីចម្រើនដោយឥតហេតុ ហើយបុគ្គលដែលបានទទួលរងនូវការបាត់បង់ផលប្រយោជន៍ អាចទាមទារឱ្យសងវិញនូវតាវកាលិកដែលត្រូវបានផ្ដល់ជាការសង ។ ប៉ុន្តែ ប្រសិនបើបុគ្គលម្នាក់សងកាតព្វកិច្ចដោយដឹងអំពីនត្ថិភាពនៃកាតព្វកិច្ចនោះ សកម្មភាពរបស់បុគ្គលនោះ គឺជាសកម្មភាពមិនសមហេតុផល ក្នុងន័យសេដ្ឋកិច្ចទីផ្សារ ហើយមិនចាំបាច់ត្រូវបានការពារដោយច្បាប់ទេ ។ វាក្យខណ្ឌទី ២ នៃមាត្រានេះ បញ្ជាក់អំពីចំណុចនេះ ហើយចែងថា តុលាការនឹងមិនគាំទ្រការទាមទារឱ្យសងដោយបុគ្គលដែលបានសង ដោយដឹងថា ខ្លួនមិនមានកាតព្វកិច្ច ។

ម្យ៉ាងទៀត មាត្រានេះមិនត្រូវយកមកអនុវត្តទេ ចំពោះករណីដែលការសងដោយតតិយជន (ដែលតតិយជនដែលគ្មានកាតព្វកិច្ច សងកាតព្វកិច្ចរបស់កូនបំណុល) ត្រូវបានធ្វើដោយមានសុពលភាព ។ ក្នុងករណីនេះ ម្ចាស់បំណុលមានសិទ្ធិលើបំណុល ដូច្នេះ ការទទួលការសងពីតតិយជនដោយម្ចាស់បំណុល មិនអាចចាត់ទុកថា ម្ចាស់បំណុលបានទទួលផលប្រយោជន៍ដោយគ្មានមូលហេតុគតិយុត្តនោះទេ ។

លើសពីនេះទៅទៀត មាត្រា ៧៤០ (ការសងកាតព្វកិច្ចរបស់អ្នកដទៃ) ត្រូវយកមកអនុវត្ត ចំពោះករណីដែលបុគ្គលដែលមិនមែនជាកូនបំណុល បានសងកាតព្វកិច្ច ដោយគិតថា កាតព្វកិច្ចនោះជាកាតព្វកិច្ចរបស់ខ្លួន ។ ដូច្នេះ គួរយកចិត្តទុកដាក់លើការកម្រិតចំពោះការបង្កើតសេចក្ដីចម្រើនដោយឥតហេតុ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៩ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ៧០៥ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១២៣៥ មាត្រា ១៣៧៦ និង មាត្រា ១៣៧៧ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៨១៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## **មាត្រា ៧៣៩**.- ការសងនៅមុនកំណត់ពេល

ក្នុងករណីដែលបានផ្ដល់តាវកាលិកនៃការសង ចំពោះកាតព្វកិច្ចដែលមិនទាន់ដល់កំណត់ពេលសងនៅឡើយ កូនបំណុលពុំអាចទាមទារឱ្យសងតាវកាលិកដែលត្រូវបានផ្ដល់នោះ មកវិញបានឡើយ ។ ប៉ុន្តែ ក្នុងករណីដែលកូនបំណុលបានសង ដោយពុំបានដឹងអំពីកំណត់ពេលសងដែលមិនទាន់មកដល់នៅឡើយ ម្ចាស់បំណុលមានករណីយកិច្ចត្រូវសងផលប្រយោជន៍ ដែលបានទទួលដោយសារការសងនៅមុនកំណត់ពេលនោះ ។

(កំណត់)

(1) ទោះបីជាកូនបំណុលមិនចាំបាច់សងកាតព្វកិច្ចរហូតដល់ពេលកំណត់ត្រូវសងក៏ដោយ ក៏កូនបំណុលអាចសងកាតព្វកិច្ច ដោយបោះបង់ផលប្រយោជន៍នៃការកំណត់ពេលបានដែរ ។ ហេតុដូច្នេះ ជាគោលការណ៍ បើទោះបីជាកូនបំណុលសងកាតព្វកិច្ចមុនពេលកំណត់ក៏ដោយ ក៏កូនបំណុលមិនត្រូវបានអនុញ្ញាតឱ្យទាមទារការសងតាវកាលិកឡើយ ។ វាក្យខណ្ឌទី ១ នៃមាត្រានេះបញ្ជាក់អំពីចំណុចនេះ ។ ប៉ុន្តែ ក្នុងករណីដែលកូនបំណុលសងកាតព្វកិច្ច ដោយមិនបានដឹងថា ពេលកំណត់មិនទាន់មកដល់នៅឡើយ នោះកូនបំណុលបានបោះបង់ចោលផលប្រយោជន៍នៃការកំណត់ពេលដោយមិនដឹងខ្លួន ហើយម្ចាស់បំណុលទទួលផលប្រយោជន៍ទៅតាមការបោះបង់ផលប្រយោជន៍នៃការកំណត់ពេលនោះ ។ ហេតុដូច្នេះ វាក្យខណ្ឌទី ២ នៃមាត្រានេះ ចែងថា ក្នុងករណីដែលកូនបំណុលបានសងកាតព្វកិច្ច ដោយមិនបានដឹងថា កាតព្វកិច្ចមិនទាន់ដល់ពេលកំណត់សងនៅឡើយ កូនបំណុលអាចទាមទារឱ្យសងផលប្រយោជន៍ដែលម្ចាស់បំណុលអាចប្រើប្រាស់តាវកាលិកដែលខ្លួនបានទទួលមុនពេលកំណត់សង រហូតដល់ពេលកំណត់សង (ផលប្រយោជន៍ក្នុងចន្លោះពេល) ពីម្ចាស់បំណុលបាន ។

(2) ការចាត់ចែងចំពោះការប្រាក់ដែលបង្ការ រហូតដល់ពេលកំណត់ត្រូវសង ក្នុងករណីនៃការសងនាំមុនពេលកំណត់ គឺជាបញ្ហាដែលពាក់ព័ន្ធនឹងមាត្រានេះ ។ សូមមើលសេចក្ដីកំណត់ដែលទាក់ទងទៅនឹងការបោះបង់ប្រយោជន៍នៃការកំណត់ពេល ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧០៦ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១១៨៥ និង មាត្រា ១១៨៦ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៨១៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ៧៤០.- ការសងកាតព្វកិច្ចរបស់អ្នកដទៃ

១-ក្នុងករណីដែលបុគ្គលក្រៅពីកូនបំណុល បានផ្ដល់តាវកាលិកនៃការសង ដោយភាន់ច្រឡំអំពីកាតព្វកិច្ចរបស់អ្នកដទៃថាជាកាតព្វកិច្ចរបស់ខ្លួន អាចទាមទារឱ្យសងតាវកាលិកនោះ មកវិញបាន ។ ប៉ុន្តែ ក្នុងករណីដែលម្ចាស់បំណុលពុំបានដឹងថា ការផ្ដល់តាវកាលិកនោះ បណ្ដាលមកពីការភាន់ច្រឡំរបស់បុគ្គលដែលបានផ្ដល់តាវកាលិកនៃការសងនោះទេ ហើយបានបំផ្លាញលិខិតលាយល័ក្ខណ៍អក្សរដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើបំណុល ឬបានបោះបង់ប្រាតិភោគចោល ដោយបានជឿជាក់ថាជាការសងដែលមានសុពលភាព បុគ្គលដែលបានផ្ដល់តាវកាលិកនោះ មិនអាចទាមទារឱ្យសងតាវកាលិកនោះ មកវិញបានឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងការអនុវត្តសិទ្ធិទាមទារសំណង របស់បុគ្គលដែលបានផ្តល់តាវកាលិកនៃការសង ចំពោះកូនបំណុលឡើយ ។

(កំណត់)

(1) ឋានៈរបស់បុគ្គលដែលសងកាតព្វកិច្ចរបស់អ្នកដទៃ ដោយភាន់ច្រឡំថាជាកាតព្វកិច្ចរបស់ខ្លួន មានភាពស្រដៀងគ្នានឹងឋានៈរបស់បុគ្គលដែលគ្មានកាតព្វកិច្ច តែសងកាតព្វកិច្ចដោយភាន់ច្រឡំថា ខ្លួនមានកាតព្វកិច្ច ដូចបានចែងក្នុងវាក្យខណ្ឌទី ១ នៃមាត្រា ៧៣៨ ដែរ ។ ហេតុដូច្នេះ វាក្យខណ្ឌទី ១ កថាខណ្ឌទី ១ នៃមាត្រានេះចែងដូចនឹងវាក្យខណ្ឌទី ១ នៃមាត្រា ៧៣៨ ថា បុគ្គលដែលបានសងកាតព្វកិច្ចអាចទាមទារឱ្យសងនូវតាវកាលិកដែលបានផ្តល់ជាការសង ។ ប៉ុន្តែ ប្រសិនបើម្ចាស់បំណុលដែលទទួលនូវការសងមិនបានដឹងថា ការផ្តល់តាវកាលិកនោះធ្វើឡើងដោយការភាន់ច្រឡំរបស់អ្នកសង ជាញឹកញាប់ណាស់ ម្ចាស់បំណុលដែលជឿជាក់ថា ខ្លួនបានទទួលការសងដែលមានសុពលភាព ហើយបំផ្លាញចោលនូវលិខិតដែលបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិលើបំណុល ដូចជាប័ណ្ណបំណុល ជាអាទិ៍ ឬ បោះបង់ប្រាតិភោគចោល ។ ក្នុងករណីនេះ ប្រសិនបើការទាមទារឱ្យសងវិញនូវកាតព្វកិច្ចរបស់អ្នកសងត្រូវបានអនុញ្ញាត នោះម្ចាស់បំណុលនឹងត្រូវទទួលលទ្ធផលដែលមិនសមហេតុផល ដូចជាមានការលំបាកក្នុងការទាមទារឱ្យអនុវត្តកាតព្វកិច្ច ដោយសារមានការលំបាកក្នុងការបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើបំណុល ឬ សិទ្ធិលើបំណុលមិនអាចត្រូវបានរក្សាការពារដោយប្រាតិភោគបានជាអាទិ៍ ។ ហេតុដូច្នេះ វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ចែងថា បុគ្គលណាដែលសងកាតព្វកិច្ចបណ្តាលមកពីការភាន់ច្រឡំមិនអាចទាមទារឱ្យសងនូវតាវកាលិកនៃការសងនោះ ក្នុងករណីបំពេញល័ក្ខខ័ណ្ឌដូចតទៅ : (ក) ម្ចាស់បំណុលមិនបានដឹងថា ការសងត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ និង (ខ) ករណីដែលម្ចាស់បំណុលបំផ្លាញលិខិតលាយល័ក្ខណ៍អក្សរដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើបំណុល ឬ បោះបង់ប្រាតិភោគចោល ។ម្យ៉ាងទៀត វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ក៏គួរអនុញ្ញាតឱ្យយកមកអនុវត្តផងដែរ ចំពោះករណីដែលម្ចាស់បំណុលដែលបានជឿជាក់ថា ការសងដោយការភាន់ច្រឡំគឺជាការសងដែលមានសុពលភាព ទុកឱ្យសិទ្ធិលើបំណុលរលត់ដោយអាជ្ញាយុកាល ។

(2) ក្នុងករណីដែលបុគ្គលដែលបានសងដោយភាន់ច្រឡំ មិនអាចទាមទារឱ្យសងនូវតាវកាលិកនៃការសងនោះពីម្ចាស់បំណុលបានទេ ម្ចាស់បំណុលអាចក្តាប់ទុកនូវតាវកាលិកនោះបាន ហើយករណីនេះត្រូវបានចាត់ចែងដូចគ្នានឹងករណីដែលមានការសងដោយមានសុពលភាព ។ មានន័យថា ករណីនេះត្រូវបានចាត់ចែងដូចគ្នានឹងករណីដែលបុគ្គលបានសងកាតព្វកិច្ចរបស់អ្នកដទៃ ក្នុងនាមជាតតិយជន (កថាខណ្ឌទី ១ មាត្រា ៤៣៤ នៃក្រមនេះ) ។ ហេតុដូច្នេះ វាជាការពិតណាស់ហើយដែលអ្នកសងអាចអនុវត្តសិទ្ធិទាមទារសំណងចំពោះកូនបំណុលដែលបានរួចផុតពីកាតព្វកិច្ចនោះ ។ កថាខណ្ឌទី ២ ចែងដើម្បីបញ្ជាក់អំពីបញ្ហានេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧០៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, កថាខណ្ឌទី ២ មាត្រា ១៣៧៧ នៃក្រមរដ្ឋប្បវេណីបារាំង និង មាត្រា ៨១៦ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៧៤១**.- ការផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់

នៅក្នុងជំពូកទី ១៥ (សេចក្តីចម្រើនដោយឥតហេតុ) នេះ ក្នុងករណីដែលការទាមទាររបស់បុគ្គលដែលត្រូវបានខូចខាតផលប្រយោជន៍ ចំពោះបុគ្គលដែលបានទទួលផលប្រយោជន៍នោះ ផ្ទុយនឹងរបៀបរៀបរយសាធារណៈ ឬ ទំនៀមទម្លាប់ល្អ ឬ ច្បាប់ដែលទាក់ទងទៅនឹងសណ្តាប់ធ្នាប់សាធារណៈ ការទាមទារឱ្យសងនោះ ពុំត្រូវបានអនុញ្ញាតឡើយ ។

(កំណត់)

សេចក្តីចម្រើនដោយឥតហេតុតែងកើតឡើងជាញឹកញាប់នៅពេលកិច្ចសន្យាក្លាយជាមោឃៈ ។ នៅពេលតាវកាលិកត្រូវបានផ្តល់ដោយសារតែការសន្និដ្ឋានថា កិច្ចសន្យាមានសុពលភាព ប្រសិនបើកិច្ចសន្យាក្លាយជាមោឃៈ តាវកាលិកនោះក្លាយទៅជាផលប្រយោជន៍ដែលគ្មានមូលហេតុគតិយុត្ត ហើយអាចសន្និដ្ឋានថា ផលប្រយោជន៍នោះបណ្តាលមកពីការបាត់បង់ផលប្រយោជន៍របស់បុគ្គលដែលបានផ្តល់តាវកាលិក ។ ហេតុដូច្នេះ ជាគោលការណ៍ បញ្ញត្តិនេះអនុញ្ញាតឱ្យទាមទារឱ្យសងសេចក្តីចម្រើនដោយឥតហេតុ ចំពោះតាវកាលិកដែលត្រូវបានផ្តល់តាមរយៈកិច្ចសន្យាមោឃៈ ។

ប៉ុន្តែ វាមិនមែនជាករណីដែលកម្រទេ ដែលកិច្ចសន្យាក្លាយជាមោឃៈ ដោយសារមានភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ឬ ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ ។ ប្រសិនបើការទាមទារឱ្យសងនូវតាវកាលិកដែលត្រូវបានផ្តល់ក្នុងគោលបំណងណាមួយដែលប្រឆាំងនឹងសង្គម អាចត្រូវបានធ្វើឡើង តាមគោលការណ៍នេះ អ្នកដែលបានធ្វើសកម្មភាពផ្តល់តាវកាលិក នឹងមានលទ្ធភាពប្រមូលសោហ៊ុយចំណាយបាន ។ ការអនុវត្តបែបនេះ នឹងកាត់បន្ថយយ៉ាងសម្បើមនូវអានុភាពនៃការព្យាយាមទប់ស្កាត់នូវសកម្មភាពប្រឆាំងសង្គម ដោយការធ្វើឱ្យសកម្មភាពនោះទុកជាមោឃៈ ។ ហេតុដូច្នេះ មានភាពចាំបាច់ក្នុងការបដិសេធនូវការទាមទារឱ្យសងតាវកាលិកដែលបានផ្តល់ក្នុងគោលបំណងធ្វើសកម្មភាពប្រឆាំងនឹងសង្គម ។ ប៉ុន្តែ ទោះបីជាតាវកាលិកណាមួយដែលត្រូវបានផ្តល់ មានគោលបំណងធ្វើសកម្មភាពដែលប្រឆាំងនឹងសង្គមក៏ដោយ ក៏មានករណីខ្លះដែលអ្នកទទួលតាវកាលិកនោះ ប្រឆាំងនឹងសង្គមច្រើនជាងអ្នកទាមទារឱ្យសងតាវកាលិកនោះទៅទៀត ។ ក្នុងករណីនេះ ការបដិសេធនូវការទាមទារឱ្យសងតាវកាលិក នឹងជំរុញឱ្យមានសកម្មភាពប្រឆាំងនឹងសង្គមទៅវិញ ។ ហេតុដូច្នេះ មាត្រានេះទទួលស្គាល់ ឬ មិនទទួលស្គាល់នូវការទាមទារឱ្យសងមិនមែនអាស្រ័យលើបញ្ហាថា តើមូលហេតនៃសេចក្តីចម្រើនដោយឥតហេតុប្រឆាំងទៅនឹងសង្គមដែរ ឬ ក៏យ៉ាងណាទេ ប៉ុន្តែ អាស្រ័យទៅលើបញ្ហាថា តើការទាមទារឱ្យសងនោះប្រឆាំងនឹងសង្គមដែរ ឬទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧០៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៨១៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៦៦ នៃច្បាប់ស្តីពី

កាតព្វកិច្ចរបស់ប្រទេសស្វីស

# ជំពូកទី ១៦ អំពើអនីត្យានុកូល

(កំណត់)

ក្នុងករណីដែលមានអង្គហេតុមួយបានកើតឡើង រវាងភាគីដែលពុំមានទំនាក់ទំនងគតិយុត្តអ្វីមួយជាមុន ដូចជា ទំនាក់ទំនងនៃកិច្ចសន្យា ជាដើម ហើយភាគីម្ខាង (ចារី) បានប្រព្រឹត្តអំពើអ្វីមួយ (រួមទាំងអំពើអនីត្យានុកូល ដែលបានប្រព្រឹត្តឡើងដោយចារី) ហើយបានធ្វើឱ្យភាគីម្ខាងទៀត (ជនរងគ្រោះ) ទទួលការខូចខាត ជំពូកទី ១៦ នេះ បានចែងថា អ្នកណាត្រូវទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាតចំពោះជនរងគ្រោះ ត្រឹមកម្រិតណា និង ក្រោមល័ក្ខខ័ណ្ឌណាមួយ ។

ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ត្រូវបានទទួលស្គាល់ថាជាការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត រវាងភាគីដែលពុំមានទំនាក់ទំនងគតិយុត្តជាមុន ។ ចំពោះសំណងនៃការខូចខាតដោយការមិនអនុវត្តកិច្ចសន្យា រវាងភាគីនៃកិច្ចសន្យាវិញ មានបញ្ញត្តិផ្សេងពីអំពើអនីត្យានុកូលដែលចែងអំពីការទទួលខុសត្រូវក្នុងការបញ្ជាក់អំពីកំហុស អំឡុងពេលនៃអាជ្ញាយុកាល ជាដើម ដោយគិតដល់លក្ខណៈពិសេសនៃទំនាក់ទំនងនៃកិច្ចសន្យា ដូច្នេះហើយ តាមទស្សនៈធម្មតា បញ្ញត្តិស្តីពីអំពើអនីត្យានុកូល មិនត្រូវយកមកអនុវត្តចំពោះភាគីនៃកិច្ចសន្យាឡើយ (ទស្សនៈមិនអនុញ្ញាតឱ្យមានការប្រជែងនៃសិទ្ធិទាមទារ) ។ ប៉ុន្តែ នៅតែមានមតិមួយចំនួនទៀតយល់ឃើញថា ទោះបីជាមានទំនាក់ទំនងកិច្ចសន្យាក៏ដោយ ក៏បញ្ញត្តិស្តីពីអំពើអនីត្យានុកូលអាចយកមកអនុវត្តចំពោះភាគីនៃកិច្ចសន្យានោះ លុះត្រាតែគ្មានបញ្ហាក្នុងការអនុវត្តបញ្ញត្តិណាមួយតាមទម្រង់នៃបញ្ញត្តិនោះ (ទស្សនៈអនុញ្ញាតឱ្យមានការប្រជែងនៃសិទ្ធិទាមទារ) ។ ជាពិសេស ចំពោះករណីដែលកិច្ចសន្យាពុំបានកំណត់អំពីខ្លឹមសារស្តីពីសុវត្ថិភាពច្បាស់លាស់ជាមុន ដូចជា កិច្ចសន្យាការងារ និង ករណីយកិច្ចយកចិត្តទុកដាក់ដល់ការគិតដល់សុវត្ថិភាពនៃកន្លែងធ្វើការ ឬ កិច្ចសន្យាលក់ និង សុវត្ថិភាពនៃផលិតផល ជាដើម ការលើកយកការបំពានករណីយកិច្ចប្រុងប្រយ័ត្នដោយមានលក្ខណៈខ្ពស់ក្នុងករណីនៃអំពើអនីត្យានុកូល នឹងធ្វើឱ្យមានការងាយស្រួលក្នុងការជួយដល់ជនរងគ្រោះ ហេតុដូច្នេះ ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ត្រូវបានអះអាងចំពោះទំនាក់ទំនងកិច្ចសន្យា ។

សង្គមប្រជាពលរដ្ឋ (សង្គមសេដ្ឋកិច្ចទីផ្សារសេរី) ផ្អែកលើគោលការណ៍មូលដ្ឋានដែលមានខ្លឹមសារថា បុគ្គលឯកជនម្នាក់ៗ មានលក្ខណៈបុគ្គលឯករាជ្យតាមផ្លូវច្បាប់ ម្នាក់ៗនឹងធ្វើសកម្មភាពដោយយោងតាមឆន្ទៈសេរី ហើយមានការទទួលខុសត្រូវរៀងៗខ្លួន ចំពោះការសម្រេចតាមឆន្ទៈរបស់ខ្លួននោះ ។ ដោយផ្អែកលើគោលការណ៍មូលដ្ឋាននេះ គន្លឹះផ្សេងទៀតនៃក្រមរដ្ឋប្បវេណី ចែងអំពីគោលការណ៍នៃសេរីភាពនៃលក្ខណៈបុគ្គលតាមផ្លូវច្បាប់ គោលការណ៍នៃភាពដាច់ខាតនៃកម្មសិទ្ធិរបស់បុគ្គលឯកជន គោលការណ៍នៃសេរីភាពក្នុងការធ្វើកិច្ចសន្យា ជាអាទិ៍ ។ ហេតុដូច្នេះ ចំពោះករណីដែលបុគ្គលណាម្នាក់ត្រូវទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត ជាដើម ជាគោលការណ៍ បុគ្គលនោះត្រូវទទួលខុសត្រូវចំពោះសកម្មភាពដែលផ្អែកទៅលើសេចក្តីសម្រេចដោយឆន្ទៈសេរីរបស់ខ្លួន ហើយមិនត្រូវទទួលខុសត្រូវចំពោះអំពើរបស់

អ្នកដទៃដែលមិនពាក់ព័ន្ធនឹងឆន្ទៈរបស់ខ្លួន ឬ ចំពោះរឿងដែលកើតឡើងដោយចៃដន្យទេ ។ គោលការណ៍នេះ ហៅថា គោលការណ៍នៃការទទួលខុសត្រូវចំពោះកំហុស ។ សូមមើលមាត្រា ៧៤២ មាត្រា ៧៤៣ មាត្រា ៧៤៥ មាត្រា ៧៥៥ និង មាត្រា ៧៥៦ ។

ប៉ុន្តែ ដោយមើលតាមទស្សនៈនៃការការពារជនរងគ្រោះ ចាំបាច់ត្រូវមានបញ្ញត្តិពិសេសមួយចំនួនស្ដីពីការលើកលែងគោលការណ៍នៃការទទួលខុសត្រូវចំពោះកំហុសនេះ ។

ទីមួយ គឺជាការទទួលខុសត្រូវរបស់អ្នកត្រួតពិនិត្យ ឬ អ្នកគ្រប់គ្រង ។ ចំពោះការទទួលខុសត្រូវរបស់និយោជក ជាដើម អ្នកត្រួតពិនិត្យ និង អ្នកគ្រប់គ្រង (និយោជក) ទទួលផលប្រយោជន៍ពីសកម្មភាពអ្នកផ្សេង (និយោជិត) ដូច្នេះហើយ មានការពន្យល់ថា និយោជក ជាអាទិ៍ ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើងដោយសារអំពើអនីត្យានុកូលរបស់ជននោះ (ការទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើងក្នុងដំណើរការទទួលផលប្រយោជន៍) ។

អ្នកមានករណីយកិច្ចត្រួតពិនិត្យអសមត្ថជន ត្រូវទទួលខុសត្រូវនូវសំណងនៃការខូចខាតចំពោះអំពើដែលបង្កឱ្យមានការខូចខាតរបស់បុគ្គលដែលគ្មានសមត្ថភាពក្នុងការខ្លួនទទួលខុសត្រូវ ។ ម្យ៉ាងទៀត បុគ្គលដែលប្រើបុគ្គលដទៃ និង បុគ្គលដែលត្រួតពិនិត្យនិយោជិតជំនួសនិយោជក ត្រូវទទួលខុសត្រូវចំពោះអំពើដែលបង្កឱ្យមានការខូចខាតរបស់របស់និយោជិត ហើយនីតិបុគ្គលត្រូវទទួលខុសនូវសំណងនៃការខូចខាតចំពោះអំពើដែលបង្កឱ្យមានការខូចខាតរបស់អភិបាលនៃនីតិបុគ្គលនោះ រីឯរដ្ឋ ឬ ស្ថាប័នសាធារណៈ ត្រូវទទួលខុសត្រូវនូវសំណងនៃការខូចខាតចំពោះអំពើដែលបង្កឱ្យមានការខូចខាតរបស់មន្ត្រីរាជការ ។ សូមមើលមាត្រា ៧៤៦ មាត្រា ៧៤៧ មាត្រា ៧៤៨ និង មាត្រា ៧៤៩ ។

ទី ពីរ គឺជាករណីពិសេសទទួលស្គាល់នូវសំណងនៃការខូចខាតដែលបណ្ដាលមកពីវត្ថុគ្រោះថ្នាក់ ដោយពុំចាំបាច់មានល័ក្ខខ័ណ្ឌកំហុស ។

ក្នុងសង្គមបច្ចុប្បន្ន ហានិភ័យច្រើនបែបច្រើនយ៉ាងកើតឡើងដោយសារការជឿនលឿននៃបច្ចេកទេសវិទ្យាសាស្ត្រទំនើបៗ ។ តាមការជាក់ស្ដែង គ្រោះថ្នាក់នៃរោងចក្រផលិតអគ្គិសនីដោយប្រើកម្លាំងបរិមាណូ គ្រោះថ្នាក់ដោយសារថ្នាំពេទ្យ ការបង្ខូចបរិស្ថានដោយជាតិគីមី ជាដើម បានកើតឡើងរួចហើយ ។ ប្រសិនបើមានតែវិធីសង្គ្រោះជនរងគ្រោះនៃគ្រោះថ្នាក់បែបនេះ តាមការទទួលខុសត្រូវចំពោះកំហុសដែលមានពីមុនៗមកនោះទៅ មានករណីច្រើនដែលនឹងទុកចោលនូវជនរងគ្រោះជាច្រើននាក់ដែលបានទទួលការខូចខាតចំពោះរាងកាយ ឬ ទ្រព្យសម្បត្តិដោយគ្មានជួយសង្គ្រោះ ។ ក្នុងករណីទាំងអស់នេះ មានការពិបាកនឹងធ្វើការបញ្ជាក់បង្ហាញអំពីទំនាក់ទំនងនៃហេតុផលរវាងគ្រោះថ្នាក់ និង លទ្ធផលដែលកើតឡើង តាមផ្លូវបច្ចេកទេស ឬ វិជ្ជាពេទ្យ ហើយមានជនរងគ្រោះច្រើននាក់ និង សម្បូរបែប ព្រមទាំងទឹកប្រាក់នៃការខូចខាតមានចំនួនដ៏មហិមា ជាអាទិ៍ ដែលទុកនូវបញ្ហាជាច្រើនធំហួសហេតុ លើសពីការសង្គ្រោះជនរងគ្រោះតាមផ្លូវបណ្ដឹងរដ្ឋប្បវេណីធម្មតា ។ នៅបណ្ដាប្រទេសជឿនលឿនជាច្រើន គេបានជជែកគ្នាអំពីរបបសំណងចំពោះជនរងគ្រោះក្រោមការទទួលខុសត្រូវថ្មីចំពោះគ្រោះថ្នាក់ទាំងនេះ រួមទាំងការធ្វើកំណែទម្រង់ប្រព័ន្ធវិនិច្ឆ័យរឿងក្ដីរដ្ឋប្បវេណី ប៉ុន្តែនៅតែពុំទាន់រកដំណោះស្រាយបាននៅឡើយ ។ ដូច្នេះហើយ ក្នុងក្រមរដ្ឋប្បវេណីកម្ពុជានេះ បានចែងអំពីការទទួលខុស

ត្រូវរបស់អ្នកកាន់កាប់សត្វ ការទទួលខុសត្រូវចំពោះសំណង់ដែលជាប់នឹងលើដី អំពើអនីត្យានុកូលរួម ដែលត្រូវបានទទួលស្គាល់តាមទំនៀមទម្លាប់ ហើយក្រៅពីនេះ បានបញ្ចូលនូវបញ្ញត្តិអំពីការទទួលខុសត្រូវចំពោះផលិតផលរបស់អ្នកផលិតវត្ថុ និង ការទទួលខុសត្រូវចំពោះវត្ថុគ្រោះថ្នាក់ ដែលជាការទទួលខុសត្រូវថ្មីដោយពុំចាំបាច់មានល័ក្ខខ័ណ្ឌនៃកំហុស ។ សូមមើលមាត្រា ៧៥០ មាត្រា ៧៥៣ មាត្រា ៧៥៤ មាត្រា ៧៥១ និង មាត្រា ៧៥២ ។

សិទ្ធិ និង ផលប្រយោជន៍ ដែលត្រូវបានបំពានដោយអំពើអនីត្យានុកូល មានច្រើនប្រភេទដូចជាទ្រព្យសម្បត្តិ អាយុជីវិត រាងកាយ សិទ្ធិបុគ្គល ជាដើម ប៉ុន្តែ សិទ្ធិ និង ផលប្រយោជន៍ទាំងនេះត្រូវបានបែកបាក់ ឬ បាត់បង់ដោយសារអំពើបំពាន ហេតុនេះហើយ ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលនោះ ជាគោលការណ៍ ត្រូវសងជាប្រាក់ ។ សូមមើលមាត្រា ៧៥៧ ។

ប្រភេទនៃការខូចខាតដែលត្រូវសង មានមិនត្រឹមតែការខូចខាតទ្រព្យសម្បត្តិប៉ុណ្ណោះទេ គឺមានទាំងការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ ដូចជាការឈឺចាប់ខាងផ្លូវចិត្ត ឬ ការចុះថយនូវការវាយតម្លៃក្នុងសង្គម ជាដើម ផងដែរ ។ សូមមើលមាត្រា ៧៤៤ ។ ចំពោះការគណនាចំនួនទឹកប្រាក់នៃការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ សូមមើលកថាខណ្ឌទី ២ នៃមាត្រា ៧៥៨ ។

ចំពោះបញ្ហាថា តើអាចធ្វើការទាមទារដែលមានខ្លឹមសារអ្វីខ្លះ ពេលធ្វើការទាមទារសំណងនៃការខូចខាត បញ្ញត្តិចាប់ពីមាត្រា ៧៥៧ ដល់មាត្រា ៧៦២ ចែងអំពីបញ្ហានេះ ។ ម្យ៉ាងទៀត មាត្រា ៧៦៣ ជាបញ្ញត្តិកាត់បន្ថយនូវចំនួនទឹកប្រាក់នៃផលប្រយោជន៍ ក្នុងករណីដែលជនរងគ្រោះបានទទួលផលប្រយោជន៍ពីអំពើអនីត្យានុកូលបាន ។ រីឯមាត្រា ៧៦៤ ចែងថា ប្រសិនបើជនរងគ្រោះបានរួមចំណែកក្នុងការកើតឡើង ឬ រីករាលដាលនៃការខូចខាត តុលាការអាចគិតពិចារណាអំពីការណ៍នេះ នៅពេលគណនាចំនួនទឹកប្រាក់នៃសំណងនៃការខូចខាត ។

មាត្រា ៧៦៥ គឺជាបញ្ញត្តិចែងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ។

**មាត្រា ៧៤២**.- និយមន័យនៃកំហុសចេតនា និង អចេតនា

នៅក្នុងជំពូកទី ១៦ (អំពើអនីត្យានុកូល) នេះ អំពើដោយមានកំហុសចេតនា ឬ អចេតនា សំដៅទៅលើ អំពើដែលត្រូវនឹងចំណុចណាមួយខាងក្រោមនេះ :

ក-ធ្វើអំពើបំពានដោយព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផល ហើយដោយទទួលយកការកើតឡើងនៃលទ្ធផលនោះ ។

ខ-ធ្វើអំពើដែល បើតាមប្រក្រតី បុគ្គលដែលមានឋានៈនៃការងារ ឬ បទពិសោធន៍ស្មើគ្នានឹងអ្នកធ្វើអំពើនោះ អាចព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលក៏ដោយ ក៏អ្នកធ្វើអំពើនោះនៅតែពុំបានព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផល

នោះ ដោយសារការធ្វេសប្រហែសមិនប្រុងប្រយ័ត្ន ហើយទោះជាមានករណីយកិច្ចជៀសវាងនូវលទ្ធផលនោះក៏ដោយ ក៏នៅតែប្រព្រឹត្តផ្ទុយនឹងករណីយកិច្ចនោះ ។

(កំណត់)

ចំណុច ក គឺជានិយមន័យនៃកំហុសចេតនា ។ បញ្ញត្តិនេះទាមទារឱ្យមានការទទួលខុសត្រូវចំពោះឆន្ទៈដែលព្យាករនូវការកើតឡើងនៃលទ្ធផល និង យល់ព្រមឱ្យលទ្ធផលនោះកើតឡើង ។ ចំណុច ខ គឺជានិយមន័យនៃកំហុសអចេតនា ។ បញ្ញត្តិនេះមិនយកឆន្ទៈខាងផ្លូវចិត្តរបស់សាមីខ្លួនទេ ។ ផ្ទុយទៅវិញ ក្នុងករណីដែលបុគ្គលណាម្នាក់ដែលមានឋានៈក្នុងសង្គមដូចអ្នកប្រព្រឹត្តអំពើនោះ អាចព្យាករបានអំពីការកើតឡើងនៃលទ្ធផល តាមប្រក្រតី ហើយអ្នកប្រព្រឹត្តអំពើនោះមានករណីយកិច្ចជៀសវាងលទ្ធផលនោះ តែមិនបានជៀសវាងឱ្យផុតពីលទ្ធផលនោះទេ អ្នកប្រព្រឹត្តអំពើនោះត្រូវបានចាត់ទុកថា មានកំហុស ។ ចំពោះកំហុសនេះ មិនមែនយកឆន្ទៈខាងផ្លូវចិត្ត (ភាពអាចព្យាករបាន) របស់សាមីខ្លួនអ្នកប្រព្រឹត្តអំពើនោះមកប្រើទេ គឺបានយកទស្សនៈនៃឆន្ទៈប្រក្រតី ឧទាហរណ៍ដូចជាបុគ្គលដែលមានការងារដូចគ្នានឹងអ្នកប្រព្រឹត្តអំពើនោះ មកប្រើនេះ ដើម្បីជួយសង្គ្រោះជនរងគ្រោះដោយល័ក្ខខ័ណ្ឌជាក់ស្តែងតាមការដែលអាចធ្វើទៅបាន ដោយមិនយកល័ក្ខខ័ណ្ឌខាងផ្លូវចិត្តរបស់អ្នកប្រព្រឹត្តអំពើ ដែលមានការពិបាកក្នុងការបញ្ជាក់បង្ហាញមកប្រើទេ ។ ល័ក្ខខ័ណ្ឌនៃសំណងនៃការខូចខាតរដ្ឋប្បវេណី គឺ "កំហុសចេតនា ឬ កំហុសអចេតនា" ដែលបានកំណត់ក្នុងមាត្រា ៧៤៣ ហេតុនេះហើយ ដើមចោទ (= ជនរងគ្រោះ) ពុំចាំបាច់ធ្វើការបែងចែកថា តើឆន្ទៈរបស់អ្នកធ្វើអំពើនោះ ជាកំហុស ចេតនា ឬ ជាកំហុសអចេតនាទេ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨ A និង មាត្រា ២៨១ នៃ "ការបញ្ជាក់ឡើងវិញអំពីអំពើអនីត្យានុកូល (Restatement of Torts)" លើកទី ២ របស់សហរដ្ឋអាមេរិក

**មាត្រា ៧៤៣.-** ល័ក្ខខ័ណ្ឌ និង ការទទួលខុសត្រូវក្នុងការបញ្ជាក់បង្ហាញនៃអំពើអនីត្យានុកូលទូទៅ

១-បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬ ផលប្រយោជន៍របស់ជនដទៃ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការខូចខាតបានកើតឡើង ដោយសារមានករណីយកិច្ចធ្វើអំពើណាមួយ តែមិនបានធ្វើអំពើនោះ ។

៣-ចំពោះកំហុសចេតនា ឬ កំហុសអចេតនារបស់ចារីនេះ ទំនាក់ទំនងនៃហេតុផលរវាងអំពើរបស់អ្នកប្រព្រឹត្តអំពើបំពាន និង ការកើតឡើងនៃការខូចខាត និង ការខូចខាតដែលកើតមានឡើងលើជនរងគ្រោះ បុគ្គលដែលទាមទារសំណងការខូចខាតនោះ ត្រូវបញ្ជាក់បង្ហាញ លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេងទៀត ។

(កំណត់)

មាត្រានេះ ជាបញ្ញត្តិចែងស្តីពីគោលការណ៍នៃការទទួលខុសត្រូវចំពោះកំហុស ។ ស្តីពីគោលការណ៍នៃការទទួលខុសត្រូវចំពោះកំហុសនេះ សូមមើលកំណត់ដំបូងនៃជំពូកនេះ ។ កថាខណ្ឌទី ២ បានចែងអំពីករណីដែលការខូចខាតកើតឡើងដោយសារអ្នកដែលមានករណីយកិច្ចត្រូវធ្វើអំពើអ្វីមួយ មិនបានធ្វើអំពើនោះ ។ ឧទាហរណ៍ មានអ្នកជម្ងឺម្នាក់ដួលដេកនៅផ្លូវចូលទៅស្ថានីយរថភ្លើង ហើយប្រសិនបើអ្នកធ្វើដំណើរតាមផ្លូវនោះ មិនជួយសង្គ្រោះអ្នកជម្ងឺនោះទេ ទោះបីជាអ្នកធ្វើដំណើរនោះនឹងអាចទទួលនូវការទិតៀនពីសង្គមក៏ដោយ ក៏អ្នកនោះគមិនមានការទទួលខុសត្រូវ ក្នុងការសងសំណងនៃការខូចខាតទេ ដោយសារពុំមានករណីយកិច្ចជួយសង្គ្រោះតាមផ្លូវច្បាប់ទេ ។ ប៉ុន្តែ ប្រសិនបើអ្នកយាមស្ថានីយរថភ្លើងមិនជួយសង្គ្រោះអ្នកជម្ងឺទេ អ្នកយាមនោះនឹងត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលនេះ ។

កថាខណ្ឌទី ៣ បានចែងថា ដើមចោទដែលជាភាគីខាងជនរងគ្រោះនោះ ត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់ ក្នុងករណីដែលទាមទារនូវសំណងនៃការខូចខាត ។ នេះគឺខុសពីការទទួលខុសត្រូវតាមកិច្ចសន្យា ក្នុងករណីនៃការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ភាគច្រើនរវាងភាគី ពុំមានទំនាក់ទំនងអ្វីជាមួយគ្នាជាមុនទេ ហេតុនេះហើយ ភាគីដើមចោទត្រូវរៀបចំឯកសារទាំងអស់ដើម្បីដាក់ពាក្យបណ្តឹង បើមិនដូច្នេះទេ គឺដូចជាការវាយឆ្នក់ចុងចម្លើយទៅវិញ ដូច្នេះហើយជាគោលការណ៍ ភាគីដើមចោទត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់ទាំងស្រុង ។ ប៉ុន្តែ ក្នុងសង្គមសព្វថ្ងៃនេះ មានការវិវឌ្ឍន៍នៃបច្ចេកទេសវិទ្យាសាស្ត្រកាន់តែលឿន តែផ្ទុយទៅវិញ មានបាតុភូតដែលមិនច្បាស់លាស់តាមផ្លូវវិទ្យាសាស្ត្រកើនកាន់តែច្រើនឡើងៗ ហើយចំពោះទំនាក់ទំនងរវាងហេតុ និង ផលខាងវិជ្ជាពេទ្យ ឬ ការព្យាករអំពីលទ្ធផលដែលកើតឡើង ដោយសារដំណើរការនៃសហគ្រាស ជាដើម បើឱ្យភាគីខាងជនរងគ្រោះទទួលខុសត្រូវក្នុងការបញ្ជាក់នូវបញ្ហាទាំងនេះ ពុំមានសមធម៌ឡើយ ។ លើសពីនេះ ចំពោះករណីខ្លះ ប្រសិនបើមិនយកគោលការណ៍នៃការទទួលខុសត្រូវចំពោះកំហុសមកប្រើ គ្មានភាពត្រឹមត្រូវទេ ហេតុនេះហើយបានជាមានច្បាប់ពិសេសសម្រាប់ករណីនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧០៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៨២ និង មាត្រា ១៣៨៣ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៨២៣ និង មាត្រា ៨២៦ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៤១ នៃច្បាប់ស្តីពីកាតព្វកិច្ចស្វិស

## **មាត្រា ៧៤៤.-** សំណងនៃការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ

បុគ្គលដែលទទួលខុសត្រូវតាមបញ្ញត្តិនៃមាត្រា ៧៤៣ (ល័ក្ខខ័ណ្ឌ និង ការទទួលខុសត្រូវក្នុងការបញ្ជាក់បង្ហាញនៃអំពើអនីត្យានុកូលទូទៅ) ខាងលើនេះ ត្រូវសងការខូចខាតចំពោះអ្វីដែលមិនមែនជាទ្រព្យសម្បត្តិផងដែរ ។

(កំណត់)

ការខូចខាតក្រៅពីទ្រព្យសម្បត្តិ មានរួមទាំងការខូចខាតដោយសារការឈឺចាប់ខាងផ្លូវចិត្ត ការអាប់ឱនកិត្តិយសក្នុងសង្គម ជាអាទិ៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧១០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៨២ និង មាត្រា ១៣៨៣ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៨៤៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៤៧ និង មាត្រា ៤៩ នៃច្បាប់ស្តីពីកាតព្វកិច្ចស្វិស

**មាត្រា ៧៤៥**.- អសមត្ថភាពក្នុងការទទួលខុសត្រូវ

១-ជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលទេ ។

២-បុគ្គលដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង និង វិនិច្ឆ័យបានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន នៅពេលដែលខ្លួនបានប្រព្រឹត្តអំពើបំពាននោះ ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ឬ មូលហេតុផ្សេងទៀត មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលស្ថានភាពនោះបណ្តាលមក ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ។

(កំណត់)

នៅក្រោមគោលការណ៍នៃការទទួលខុសត្រូវចំពោះឆន្ទៈ បុគ្គលដែលមានការខ្វះខាតនូវសមត្ថភាពក្នុងការវិនិច្ឆ័យឆន្ទៈ ឬ មានសមត្ថភាពក្នុងការវិនិច្ឆ័យឆន្ទៈមិនគ្រប់គ្រាន់ ដោយសារអាយុ ឬ ដោយសារមានបញ្ហាខាងសតិអារម្មណ៍ ឬ មិនឱ្យមានការទទួលខុសត្រូវនូវសំណងនៃការខូចខាតឡើយ ។ ម្យ៉ាងទៀត ជនដែលមានសមត្ថភាពខាងឆន្ទៈ តែបានធ្លាក់ក្នុងស្ថានភាពនៃអសមត្ថភាពខាងឆន្ទៈដោយសារឆន្ទៈរបស់ខ្លួននោះ ហើយបានប្រព្រឹត្តអំពើអនីត្យានុកូល ជននោះត្រូវទទួលខុសត្រូវចំពោះករណីនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧១២ និង មាត្រា ៧១៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៨២៧ មាត្រា ៨២៨ និង មាត្រា ៨២៩

នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៩៣ និង មាត្រា ៩៤ នៃច្បាប់ស្ដីពីកាតព្វកិច្ចស្វិស

**មាត្រា ៧៤៦**.- ការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ

១-បុគ្គលដែលមានករណីយកិច្ចដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ឬ បុគ្គលដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង និង វិនិច្ឆ័យបានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ឬ មូលហេតុផ្សេងទៀត មានករណីយកិច្ចត្រូវសងការខូចខាតរបស់អ្នកដទៃ ដែលកើតឡើង ដោយអំពើបំពានរបស់បុគ្គលនៅក្រោមការត្រួតពិនិត្យរបស់ខ្លួននេះ ។

២-បុគ្គលដែលមានករណីយកិច្ចដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពជាមួយអនីតិជន ចំពោះការខូចខាតរបស់អ្នកដទៃដែលកើតឡើង ដោយអំពើអនីត្យានុកូលរបស់អនីតិជននោះ ។

៣-បុគ្គលដែលមានករណីយកិច្ចត្រួតពិនិត្យដែលទទួលខុសត្រូវក្នុងការសងការខូចខាត តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ អាចរួចខ្លួនពីការទទួលខុសត្រូវក្នុងការសងការខូចខាតបាន ដោយបញ្ជាក់បង្ហាញថា ខ្លួនបានបំពេញករណីយកិច្ចត្រួតពិនិត្យជាប្រក្រតី ។

(កំណត់)

អ្នកមានករណីយកិច្ចត្រួតពិនិត្យអ្នកអសមត្ថភាពក្នុងការទទួលខុសត្រូវ ត្រូវទទួលខុសត្រូវនូវសំណងនៃការខូចខាតជំនួសអ្នកអសមត្ថភាពដែលមិនទទួលខុសត្រូវដោយផ្អែកលើមាត្រា ៧៤៥ ។ ទោះបីជាអ្នកត្រួតពិនិត្យសាមីខ្លួនគ្មានកំហុសក៏ដោយ ក៏អ្នកនោះត្រូវទទួលខុសត្រូវដែរ ។ កថាខណ្ឌទី ៣ បានចែងថា ក្នុងករណីដែលអ្នកមានករណីយកិច្ចត្រួតពិនិត្យចំពោះអនីតិជនដែលមានអាយុពី ១៤ ឆ្នាំឡើងទៅ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពជាមួយនឹងអនីតិជន ដោយយោងតាមកថាខណ្ឌទី ២ អ្នកនោះអាចរួចផុតពីការទទួលខុសត្រូវនោះបាន ប្រសិនបើបានបញ្ជាក់បង្ហាញថា ខ្លួនបានបំពេញករណីយកិច្ចត្រួតពិនិត្យជាប្រក្រតី ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧១៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៨៤ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៨៣២ នៃក្រមរដ្ឋប្បវេណី

អាល្លឺម៉ង់, មាត្រា ៣៣៣ នៃក្រមរដ្ឋប្បវេណីស្វិស

**មាត្រា ៧៤៧**.- ការទទួលខុសត្រូវរបស់និយោជក

១-បុគ្គលដែលប្រើនិយោជិតដើម្បីអនុវត្តកិច្ចការ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលនិយោជិតបានបង្កដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា នៅក្នុងការអនុវត្តកិច្ចការនោះ ។

២-បុគ្គលដែលស្ថិតក្នុងឋានៈត្រូវត្រួតពិនិត្យនិយោជិតជំនួសនិយោជក ត្រូវទទួលខុសត្រូវដូចគ្នានឹងនិយោជកដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះបានត្រួតពិនិត្យដោយត្រឹមត្រូវ ។

៣-និយោជក ឬ អ្នកត្រួតពិនិត្យជំនួស អាចទាមទារសំណងពីនិយោជិតបាន ដោយយោងទៅតាមកម្រិតនៃកំហុសរបស់និយោជិតនោះ ។

(កំណត់)

មាត្រានេះចែងអំពីការទទួលខុសត្រូវរបស់និយោជក ។ និយោជក ជាអ្នកប្រើនិយោជិតឱ្យពង្រីកសកម្មភាព ដើម្បីរកផលចំណេញឱ្យខ្លួន ហេតុនេះហើយ ចំពោះអំពើអនីត្យានុកូលដែលបង្កឡើងដោយនិយោជិត "ក្នុងការអនុវត្តកិច្ចការ" និយោជកត្រូវទទួលខុសត្រូវជំនួសនិយោជិត ។ មាត្រានេះត្រូវបានបញ្ញត្តឡើងតាមក្រមរដ្ឋប្បវេណីបារាំង ដោយដាក់បន្ទុកឱ្យនិយោជកទទួលខុសត្រូវនូវអំពើអនីត្យានុកូលដែលបានធ្វើឡើងដោយនិយោជិត ប្រសិនបើអំពើនោះត្រូវបំពេញល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូល ទោះបីជានិយោជកនោះគ្មានកំហុសក៏ដោយ ។ ការទទួលខុសត្រូវនេះគឺជាការទទួលខុសត្រូវដោយឧបាទេសកម្ម ។ ផ្ទុយទៅវិញ តាមក្រមរដ្ឋប្បវេណីបារាំង ឬ ក្រមរដ្ឋប្បវេណីជប៉ុន ប្រសិនបើនិយោជកអាចបញ្ជាក់បង្ហាញថា ខ្លួនពុំមានកំហុសក្នុងការជ្រើសតាំង និង ត្រួតពិនិត្យនយោជិតទេ និយោជកនោះនឹងអាចរួចផុតពីការទទួលខុសត្រូវនោះបាន ។ ក៏ប៉ុន្តែ ដោយសារតែចាំបាច់ត្រូវសង្គ្រោះអ្នករងគ្រោះ ពុំសូវមានយុត្តិសាស្ត្រដែលបានអនុគ្រោះឱ្យនិយោជករួចផុតពីការទទួលខុសត្រូវទេ ។ ហើយមូលហេតុនៃការទទួលខុសត្រូវរបស់និយោជក ត្រូវបានពន្យល់ថាជាការទទួលខុសត្រូវចំពោះការទទួលផល (អ្នកដែលទទួលផលប្រយោជន៍ ត្រូវទទួលខុសត្រូវចំពោះការខូចខាតផងដែរ) ឬ ការទទួលខុសត្រូវចំពោះហានិភ័យ (ការទទួលខុសត្រូវចំពោះការនាំមកនូវហានិភ័យដល់សង្គម ក្នុងការធ្វើសកម្មភាពរបស់សហគ្រាស) ។

ចំពោះល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវរបស់និយោជក មានវិវាទត្រង់ចំណុចថា តើសកម្មភាពអ្វីខ្លះ ត្រូវនឹង "ការអនុវត្តកិច្ចការ" ។ នៅក្នុងយុត្តិសាស្ត្ររបស់ជប៉ុន ឧទាហរណ៍ ក្នុងករណីដែលអ្នកដែលតាមការពិតពុំមែនជាគណនេយ្យករទេ តែមើលភិនភាគពីក្រៅទៅ ដូចជាគណនេយ្យករ ហើយបានទទួលប្រាក់ ដោយពន្យល់ថា ទទួលប្រាក់នោះដើម្បីក្រុមហ៊ុន

ហើយបានយកប្រាក់នោះដាក់ហោប៉ៅខ្លួនឯងទៅវិញ ឬ ករណីដែលបានយកឡានរបស់ក្រុមហ៊ុនទៅប្រើដោយគ្មានការអនុញ្ញាត ហើយបានបង្កឱ្យមានគ្រោះថ្នាក់ តុលាការទទួលស្គាល់ថាជាការអនុវត្តកិច្ចការដោយមើលតាម "ភិនភាគខាងក្រៅ" ដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧១៥ នៃក្រមរដ្ឋប្បវេណីជប៉ុន, កថាខណ្ឌទី ៥ មាត្រា ១៣៨៤ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៨៣១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៥៥ នៃច្បាប់ស្តីពីកាតព្វកិច្ចស្វិស

## មាត្រា ៧៤៨.- អំពើអនីត្យានុកូលរបស់នីតិបុគ្គល

១-នីតិបុគ្គលត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលអភិបាល ឬ អ្នកតំណាងឯទៀត បានបង្កដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនាក្នុងការអនុវត្តភារកិច្ច ។[១០]

២-បើបានសងការខូចខាតតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ នីតិបុគ្គលអាចទាមទារសំណងពីអ្នកតំណាងដែលបានប្រព្រឹត្តអំពើបង្កការខូចខាតនោះ ។

(កំណត់)

មាត្រានេះចែងអំពីការទទួលខុសត្រូវរបស់នីតិបុគ្គល ដោយឧបាទេសកម្ម ចំពោះអភិបាល ឬ អ្នកតំណាងផ្សេងទៀតនៃនីតិបុគ្គល ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៨២ និង មាត្រា ១៣៨៤ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៣១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៥៥ នៃក្រមរដ្ឋប្បវេណីស្វិស

## មាត្រា ៧៤៩.- អំពើអនីត្យានុកូលរបស់មន្ត្រីរាជការ

១-បើមន្ត្រីរាជការដែលទទួលការអនុវត្តនូវអំណាចសាធារណៈរបស់រដ្ឋ ឬ ស្ថាប័នសាធារណៈ បានបង្កការខូចខាតដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួននោះ រដ្ឋ ឬ ស្ថាប័នសាធារណៈត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតនោះ ។

---

[១០] កថាខណ្ឌទី ១ នៃមាត្រា ៧៤៨ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើកម្រិតនៃការបំពានករណីយកិច្ចរបស់មន្ត្រីរាជការ ក្នុងការជៀសវាងនូវលទ្ធផល មានភាពធ្ងន់ធ្ងរ រដ្ឋ ឬ ស្ថាប័នសាធារណៈអាចទាមទារសំណងពីមន្ត្រីរាជការនោះបាន ។

(កំណត់)

មាត្រានេះចែងអំពីការទទួលខុសត្រូវរបស់រដ្ឋ ឬ ស្ថាប័នសាធារណៈ ដោយឧបាទេសកម្ម ចំពោះមន្ត្រីរាជការ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ១ នៃច្បាប់ស្តីពីសំណងនៃការខូចខាតដោយរដ្ឋរបស់ជប៉ុន, មាត្រា ៨៣៩ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៣៤ នៃច្បាប់មូលដ្ឋាន (Grundgesetz) របស់អាល្លឺម៉ង់

**មាត្រា ៧៥០**.- ការទទួលខុសត្រូវរបស់អ្នកកាន់កាប់សត្វ

បុគ្គលដែលកាន់កាប់សត្វ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដល់អ្នកដទៃ ដោយសត្វដែលខ្លួនកាន់កាប់ ។

(កំណត់)

មាត្រានេះចែងអំពីការទទួលខុសត្រូវដោយគ្មានកំហុសរបស់អ្នកកាន់កាប់សត្វ ។ នៅក្នុងនេះ ពុំមានការអនុគ្រោះឱ្យរួចផុតពីការទទួលខុសត្រូវទេ ដោយយោងតាមក្រមរដ្ឋប្បវេណីបារាំង ។ មាត្រានេះគឺជាឧទាហរណ៍នៃការទទួលខុសត្រូវចំពោះវត្ថុដែលមានគ្រោះថ្នាក់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧១៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៨៥ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៨៣៣ និង មាត្រា ៨៣៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៥៦ នៃច្បាប់ស្តីពីកាតព្វកិច្ចស្វីស

**មាត្រា ៧៥១**.- ការទទួលខុសត្រូវចំពោះផលិតផលរបស់អ្នកផលិតវត្ថុ

១-ក្នុងករណីដែលមានវិការៈនាំឱ្យមានគ្រោះថ្នាក់មិនសមហេតុផលក្នុងចលនវត្ថុដែលត្រូវបានផលិត ហើយបានបណ្តាល ឱ្យមានការខូចខាតដល់អ្នកដទៃដោយវិការៈនោះ ផលិតករនៃចលនវត្ថុនោះត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាតនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលមិនអាចប្រមាណនូវវិការៈនោះ តាមកម្រិតវិទ្យាសាស្ត្រ នៃបច្ចេកទេស ដែលមាននៅសម័យដែលផលិតនោះ ។

២-អ្នកដែលផលិតចលនវត្ថុដែលផ្សំដោយគ្រឿង ឬ វត្ថុធាតុដើមដែលមានវិការៈ ត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាត ក្នុងនាមជាផលិតករផងដែរ ។

៣-ក្នុងខ្លឹមសារនៃមាត្រានេះ ចំពោះចលនវត្ថុដែលនាំចូល អ្នកនាំចូលត្រូវចាត់ទុកថាជាផលិតករ ។

៤-ក្នុងខ្លឹមសារនៃមាត្រានេះ បុគ្គលដែលបានដាក់សញ្ញាណនៃនាមករណ៍របស់ខ្លួនជាផលិតករ ឬ អ្នកលក់ នៅលើចលនវត្ថុ ត្រូវចាត់ទុកថាជាផលិតករនៃចលនវត្ថុនោះ ។

(កំណត់)

ការទទួលខុសត្រូវចំពោះផលិតផលរបស់អ្នកផលិតវត្ថុ គឺជាទ្រឹស្តីច្បាប់នៃការទទួលខុសត្រូវតឹងរ៉ឹងមួយដែលត្រូវបានអភិវឌ្ឍ តាមរយៈយុត្តិសាស្ត្ររបស់អាមេរិក ពីទសវត្សរ៍ ១៩៦០ មក ។ ដោយសារផលិតផលរថយន្ត ជាដើម មានចំនួនច្រើន ហើយក្នុងដំណើរការនៃការផលិត ផលិតផលត្រូវបានផលិតមិនត្រឹមត្រូវប្រកបដោយគ្រោះថ្នាក់ និង ត្រូវបានជួញដូរនៅទីផ្សារ មានករណីដែលអតិថិជនជាច្រើនបានទទួលរងគ្រោះដល់ផ្លូវកាយ ហេតុនេះហើយបានជាច្បាប់ស្តីពីការទទួលខុសត្រូវចំពោះផលិតផលដោយអ្នកផលិតវត្ថុ ត្រូវបានបង្កើតឡើង ដើម្បីឱ្យមានការទទួលខុសត្រូវនូវសំណងនៃការខូចខាតដោយអ្នកផលិត ឬ ដោយអ្នកលក់ ដោយយកវិការៈនៃផលិតផលមកធ្វើជាល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវ ជំនួសការទទួលខុសត្រូវចំពោះកំហុសដែលមានពីមុនមក ។ ក្រោយមក ក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រីនៃសហគមន៍អឺរ៉ុប (EC សព្វថ្ងៃនេះ EU) ក៏បានចេញបញ្ជាឱ្យបង្កើតច្បាប់ស្តីពីការទទួលខុសត្រូវចំពោះផលិតផល ហើយបណ្តាប្រទេសអឺរ៉ុប ឬ ប្រទេសជប៉ុន ជាអាទិ៍ បានបង្កើតច្បាប់ពិសេសស្តីពីការទទួលខុសត្រូវចំពោះផលិតផលជាបន្តបន្ទាប់ ។

កម្មវត្ថុនៃការទទួលខុសត្រូវចំពោះផលិតផលដោយអ្នកផលិត គឺជាចលនវត្ថុដែលត្រូវបានផលិត ។ ហេតុដូច្នេះ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តចំពោះអចលនវត្ថុឡើយ ។ ចំពោះចលនវត្ថុដែលមិនបានកែច្នៃទេ ដូចជាត្រីដែលស្ទូចបាន ក៏មិនអនុវត្តតាមមាត្រានេះដែរ ។ ក្នុងមាត្រានេះ មានលើកឡើងនូវ "វិការៈដែលនាំឱ្យមានគ្រោះថ្នាក់មិនសមហេតុសមផល" ដែលជាល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវ ។ ចំពោះវិការៈវិញ ពុំមាននិយមន័យពិសេសក្នុងនេះទេ គឺទុកឱ្យធ្វើការបកស្រាយទៅវិញ ។ ប៉ុន្តែ សូមជូនជាគំនិតទៅវិញ គឺ មាត្រា ២ នៃច្បាប់ស្តីពីការទទួលខុសត្រូវចំពោះផលិតផលរបស់ជប៉ុន ឱ្យនិយមន័យថា "វិការៈ សំដៅទៅលើកង្វះនូវសុវត្ថិភាពដែលចាំបាច់ត្រូវមានជាធម្មតាសម្រាប់ផលិតផលដែលបានផលិតឡើង ដោយគិតពិចារណានូវលក្ខណៈពិសេសនៃផលិតផលនោះ វិធីប្រើផលិតផលនោះដែលអាចត្រូវបានព្យាករបាន ពេលវេលាដែលអ្នកផលិតវត្ថុនោះ ជាអាទិ៍ បានប្រគល់ផលិតផលនោះ និង ស្ថានភាពផ្សេងៗដែលពាក់ព័ន្ធនឹងផលិតផលនោះ" ។ ម្យ៉ាងទៀត ដោយមើលតាមច្បាប់របស់បណ្តាប្រទេសនានា មាត្រានេះក៏អនុគ្រោះឱ្យអ្នកផលិតរួចផុតពីការទទួលខុសត្រូវចំពោះផលិតផលដែរ ក្នុងករណីដែលមិនបានយល់ដឹងជាមុននូវវិការៈនៃវត្ថុនោះ

ដោយវិទ្យាសាស្ត្រដែលមាននាពេលផលិតវត្ថុនោះ (= សិទ្ធិតវ៉ាចំពោះគ្រោះថ្នាក់នៃការអភិវឌ្ឍន៍) ។ អ្នកដែលត្រូវទទួលខុសត្រូវចំពោះផលិតផល គឺជាអ្នកផលិត ។ មិនត្រឹមតែអ្នកផលិតវត្ថុចុងក្រោយទេ ដែលទទួលខុសត្រូវចំពោះវត្ថុនោះ គឺមានរួមទាំងអ្នកផលិតគ្រឿង ឬ សារធាតុដែលមានវិការៈផងដែរដែលត្រូវទទួលខុសត្រូវ (កថាខណ្ឌទី ២) ។ ជាគោលការណ៍ អ្នកលក់ពុំមានការទទួលខុសត្រូវចំពោះផលិតផលឡើយ ហើយចំណុចនេះខុសពីយុត្តិសាស្ត្ររបស់អាមេរិក ប៉ុន្តែ មានករណីលើកលែងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ និង កថាខណ្ឌទី ៤ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ២ មាត្រា ៣ និង មាត្រា ៤ នៃច្បាប់ស្តីពីការទទួលខុសត្រូវចំពោះផលិតផលរបស់ជប៉ុន, មាត្រា ១៣៨៦-១ ចំណុចទី ៤ កថាខណ្ឌទី ១ នៃមាត្រា ១៣៨៦-១១ និង មាត្រា ១៣៨៦-៦ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១ និង មាត្រា ៤ នៃច្បាប់ស្តីពីការទទួលខុសត្រូវចំពោះផលិតផលរបស់អាល្លឺម៉ង់, មាត្រា ១ មាត្រា ៥ មាត្រា ១៤ និង មាត្រា ២០ នៃច្បាប់ស្តីពីការទទួលខុសត្រូវ នៃ "ការបញ្ជាក់ឡើងវិញអំពីអំពើអនីត្យានុកូល (Restatement of Torts)" លើកទី ៣ របស់សហរដ្ឋអាមេរិក

## **មាត្រា ៧៥២**.- ការទទួលខុសត្រូវចំពោះវត្ថុគ្រោះថ្នាក់

បុគ្គលជាកម្មសិទ្ធិករ ឬ អ្នកគ្រប់គ្រងរថយន្ត គ្រឿងចក្រសម្រាប់ដឹកជញ្ជូនផ្សេងទៀត គ្រឿងផ្ទុះ វត្ថុធាតុវិទ្យុសកម្ម វត្ថុធាតុគីមីដែលមានជាតិពុល អតិសុខុមប្រាណឧត្បាត ឬ គ្រឿងដែលមានកម្រិតគ្រោះថ្នាក់ខ្ពស់ផ្សេងទៀត ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលបង្កដល់អ្នកដទៃ ដោយសារវត្ថុគ្រោះថ្នាក់ដែលខ្លួនមានកម្មសិទ្ធិ ឬ គ្រប់គ្រង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការខូចខាតនោះកើតមានឡើងបណ្តាលមកពីប្រធានសក្តិ ឬ ករណីដែលការគ្រប់គ្រងវត្ថុគ្រោះថ្នាក់គ្មានវិការៈ ហើយការខូចខាតបានកើតឡើង ដោយសារអំពើរបស់ជនរងគ្រោះ ឬ តតិយជន ។

(កំណត់)

មាត្រានេះចែងអំពីការទទួលខុសត្រូវចំពោះវត្ថុដែលមានគ្រោះថ្នាក់របស់បុគ្គលដែលជាកម្មសិទ្ធិករ ឬ អ្នកគ្រប់គ្រងរថយន្ត ឬ វត្ថុដែលមានគ្រោះថ្នាក់ផ្សេងទៀត ។ កម្មវត្ថុនៃមាត្រានេះ មានរួមទាំង វត្ថុ "ដែលមានកម្រិតគ្រោះថ្នាក់ខ្ពស់ផ្សេងទៀត" ហេតុនេះហើយ គឺមានភាពទូលំទូលាយណាស់ ។ ល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវ មិនតម្រូវឱ្យមានកំហុសទេ ប៉ុន្តែ (១) ក្នុងករណីដែលមានការខូចខាតដោយប្រធានសក្តិ ឬ (២) ក្នុងករណីដែលពុំមានវិការៈក្នុងការគ្រប់គ្រង ហើយការខូចខាតបានកើតឡើងដោយជនរងគ្រោះ ឬ ដោយតតិយជន ម្ចាស់វត្ថុ ឬ អ្នកគ្រប់គ្រងវត្ថុនោះ អាចរួចផុតពីការទទួលខុសត្រូវបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៣ នៃច្បាប់ស្តីពីការធានារ៉ាប់រងសំណងនៃការខូចខាតរថយន្តរបស់ជប៉ុន, មាត្រា ១០៩ នៃច្បាប់ស្តីពីរ៉ែជប៉ុន, មាត្រា ៣ នៃច្បាប់ស្តីពីសំណងនៃការខូចខាតដោយការប្រើថាមពលបរិមាណូរបស់ជប៉ុន, មាត្រា ២៥ នៃច្បាប់ស្តីពីការការពារការបំពុលអាកាសរបស់ជប៉ុន, មាត្រា ១៩ នៃច្បាប់ស្តីពីការការពារការបង្ខូចគុណភាពទឹករបស់ជប៉ុន

## មាត្រា ៧៥៣.- ការទទួលខុសត្រូវចំពោះសំណង់ដែលជាប់នឹងដី

១-ក្នុងករណីដែលការសាងសង់សំណង់ដែលជាប់នឹងដី ឬ ការគ្រប់គ្រងសំណង់នោះ មានវិការៈ ហើយបានបណ្តាលឱ្យមានការខូចខាតដល់អ្នកដទៃ អ្នកគ្រប់គ្រងសំណង់ និង កម្មសិទ្ធិករនៃសំណង់នោះត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ក្នុងការសងការខូចខាតនោះ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកគ្រប់គ្រងបានបញ្ជាក់ថា ខ្លួនបានគ្រប់គ្រងដោយត្រឹមត្រូវ អ្នកគ្រប់គ្រងនោះអាចរួចផុតពីការទទួលខុសត្រូវបាន ។

២-បន្ទុករបស់កម្មសិទ្ធិករនៃសំណង់ដែលជាប់នឹងដី និង អ្នកគ្រប់គ្រងសំណង់នោះ ត្រូវកំណត់ទៅតាមកម្រិតនៃការបង្កឱ្យមានវិការៈនៃការសាងសង់ ឬ ការគ្រប់គ្រង ។

(កំណត់)

ការទទួលខុសត្រូវដោយគ្មានកំហុសរបស់កម្មសិទ្ធិករ និង អ្នកគ្រប់គ្រងសំណង់ដែលជាប់នឹងដី ដែលមានវិការៈក្នុងការសាងសង់ ឬ ការគ្រប់គ្រង គឺជាការទទួលខុសត្រូវចំពោះវត្ថុដែលមានគ្រោះថ្នាក់មួយដែលមានពីយូរណាស់មកហើយ ។ ក្រមរដ្ឋប្បវេណីបារាំង និង ក្រមរដ្ឋប្បវេណីជប៉ុន ក៏ដូចមាត្រានេះដែរ មិនទទួលស្គាល់នូវមូលហេតុសម្រាប់ការរួចផុតពីការទទួលខុសត្រូវរបស់ម្ចាស់សំណង់ទេ ។ ប៉ុន្តែ ចំពោះអ្នកគ្រប់គ្រង (អ្នកកាន់កាប់) វិញ ប្រសិនបើអ្នកនោះអាចបញ្ជាក់នូវការគ្រប់គ្រងត្រឹមត្រូវបាន អ្នកនោះអាចរួចផុតពីការទទួលខុសត្រូវនេះបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧១៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, កថាខណ្ឌទី ១ នៃមាត្រា ១៣៨៤ និង មាត្រា ១៣៨៦ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៨៣៦ មាត្រា ៨៣៧ និង មាត្រា ៨៣៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៥៨ និង មាត្រា ៥៩ នៃច្បាប់ស្តីពីកាតព្វកិច្ចស្វិស

## មាត្រា ៧៥៤.- អំពើអនីត្យានុកូលរួម

១-បើការខូចខាតបានកើតឡើង ដោយសារអំពើរបស់បុគ្គលច្រើននាក់រួមគ្នា អ្នកប្រព្រឹត្តអំពើបំពានទីមួយៗត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអ្នកប្រព្រឹត្តអំពើបំពាននីមួយៗបានបញ្ជាក់អំពីភាគនៃអំពើដែលខ្លួនបានបង្កឱ្យមានការខូចខាត ជននោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត តាមសមាមាត្រនៃភាគដែលខ្លួនបានបង្ក ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលទទួលស្គាល់ថាមានការសមគំនិត ឬ មានទំនាក់ទំនងសហការយ៉ាងជិតស្និទ្ធក្នុងចំណោមអ្នកប្រព្រឹត្តអំពើបំពាន ។

៣-បើជនម្នាក់ក្នុងចំណោមអ្នកប្រព្រឹត្តអំពើអនីត្យានុកូលរួម បានសងការខូចខាតទាំងអស់ ដោយចេញចំណាយរបស់ខ្លួន ជននោះអាចទាមទារសំណងពីអ្នកផ្សេងទៀតដែលប្រព្រឹត្តអំពើអនីត្យានុកូលរួមនោះបាន តាមសមាមាត្រនៃភាគដែលជនម្នាក់ៗបានបង្ក ។

(កំណត់)

ជីវភាពក្នុងសង្គមកាន់តែមានការស្មុគស្មាញទៅៗ ហើយកាន់តែមានកម្រិតខ្ពស់ទៅៗ ហេតុនេះហើយ មានករណីជាច្រើនដែលការខូចខាតកើតឡើងដោយសារបុគ្គលច្រើននាក់ (ការខូចខាតដោយសារមូលហេតុចម្រុះ) ។ ករណីដែលប្រជាជនដែលរស់នៅជុំវិញ ខូចសុខភាពដោយសារការបំពុលធាតុអាកាស ដែលបង្កើតឡើងដោយប្រភពច្រើន ដូចជារោងចក្រ ជាអាទិ៍ គឺជាឧទាហរណ៍មួយដែរ ។ ក្នុងករណីនេះ មានការពិបាកនឹងកំណត់អ្នកដែលបង្កើតបញ្ហានោះណាស់ ។ ដូច្នេះហើយ មាត្រានេះមានគោលបំណងជួយសង្គ្រោះអ្នករងគ្រោះ ដោយបន្ថយនូវភាពពិបាកក្នុងការបញ្ជាក់របស់ជនរងគ្រោះ តាមរយៈការចាត់ទុក ឬ ការសន្និតនូវទំនាក់ទំនងហេតុ និង ផល រវាងអ្នកធ្វើអំពើរួមទាំងអស់ និង ការខូចខាតដែលបានកើតឡើងដោយយកភាពរួមគ្នា (ពាក់ព័ន្ធគ្នា) មកធ្វើជាល័ក្ខខ័ណ្ឌ ។

ក្នុងករណីដែលមានទំនាក់ទំនងរួមជិតស្និទ្ធ ដូចជាការសមគំនិតគ្នា ជាដើម រវាងអ្នកធ្វើអំពើអនីត្យានុកូលរួមច្រើននាក់ អ្នកប្រព្រឹត្តអំពើបំពាននីមួយៗត្រូវទទួលខុសត្រូវនូវសំណងនៃការខូចខាតទាំងអស់ដោយសាមគ្គីភាព ។ ប៉ុន្តែក្នុងករណីដែលទំនាក់ទំនងមិនសូវជិតស្និទ្ធដូចការសមគំនិតទេ ប្រសិនបើចារីម្នាក់ៗបានបញ្ជាក់អំពីភាគនៃអំពើដែលខ្លួនបានបង្កឱ្យមានការខូចខាត ចារីនោះអាចទទួលបន្ទុកតែចំនួនទឹកប្រាក់នៃសំណង តាមសមាមាត្រនៃភាគនោះប៉ុណ្ណោះបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧១៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៨៣០ និង មាត្រា ៨៤០ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៥០ និង មាត្រា ៥១ នៃច្បាប់ស្តីពីកាតព្វកិច្ចស្វីស

**មាត្រា ៧៥៥.-** និយមន័យនៃការការពារជាធម្មានុរូប និង ស្ថានភាពចាំបាច់

១-អំពើការពារជាធម្មានុរូប សំដៅទៅលើអំពើវិលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះអំពើបំពានមិនត្រឹមត្រូវ ហើយដែលស្ថិតក្នុងករណីដែលពេលវេលានៃអំពើបំពាន និង អំពើវិលោភនោះ ស្ថិតជិតគ្នា និង មានតុល្យភាពរវាងវិធីការពារនិងកម្រិតនៃអំពើបំពាននោះ ។

២-អំពើដោយសារស្ថានភាពចាំបាច់ សំដៅទៅលើអំពើវិលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬ អច្ចាសន្ន ហើយដែលស្ថិតក្នុងករណីមានតុល្យភាព រវាងវិធីការពារ និង កម្រិតគ្រោះថ្នាក់នោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧២០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២២៧ និង មាត្រា ២២៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៥២ នៃច្បាប់ស្តីពីកាតព្វកិច្ចស្វិស

**មាត្រា ៧៥៦**.- មូលហេតុនៃការរួចផុតពីភាពផ្ទុយច្បាប់

១-អ្នកប្រព្រឹត្តអំពើបំពានត្រូវរួចផុតពីការទទួលខុសត្រូវ ក្នុងករណីដែលមានការយល់ព្រម ឬ ការទទួលយកគ្រោះថ្នាក់ ពីសំណាក់អ្នករងគ្រោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការយល់ព្រម ឬ ការទទួលយកគ្រោះថ្នាក់នោះមិនត្រូវបានសង្គមទទួលស្គាល់ថាសមហេតុផល ។

២-ចំពោះការខូចខាតដែលកើតមានឡើងដោយសារអំពើការពារជាធម្មានុរូប ឬ អំពើដោយសារស្ថានភាពចាំបាច់ អ្នកដែលបានប្រព្រឹត្តអំពើការពារ ឬ អំពើដោយសារស្ថានភាពចាំបាច់ ពុំត្រូវទទួលខុសត្រូវឡើយ ។ ក្នុងករណីនេះ បុគ្គលដែលបានប្រព្រឹត្តអំពើផ្ទុយច្បាប់ដែលជាមូលហេតុនៃអំពើនោះ ត្រូវទទួលខុសត្រូវ ។

៣-ចំពោះការខូចខាតដោយសារអំពើដែលត្រូវសង្គមទទួលស្គាល់ថា សមហេតុផល អ្នកប្រព្រឹត្តអំពើបំពានមិនត្រូវទទួលខុសត្រូវឡើយ ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ២ សូមមើលមាត្រា ៧២០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២២៧ និង មាត្រា ២២៨

នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៥២ នៃច្បាប់ស្តីពីកាតព្វកិច្ចស្វិស

**មាត្រា ៧៥៧**.- គោលការណ៍សងការខូចខាតជាប្រាក់ និង ករណីលើកលែង

១-ជាគោលការណ៍ សំណងនៃការខូចខាតត្រូវសងជាប្រាក់ ។

២-ក្នុងករណីដែលមិនអាចទទួលការសង្គ្រោះត្រឹមត្រូវដោយសំណងជាប្រាក់ ជនរងគ្រោះអាចទាមទារឱ្យធ្វើបដិទាន ឬ អាចទាមទារឱ្យហាមឃាត់មិនឱ្យធ្វើអំពើណាមួយបាន ។

៣-ចំពោះការបរិហារកេរ្តិ៍ ក្រៅពីសំណងនៃការខូចខាត ជនរងគ្រោះអាចទាមទារវិធានការស្តារកិត្តិយសឡើងវិញ ដូចជាការផ្សព្វផ្សាយសេចក្តីសុំអភ័យទោសជាសាធារណៈបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧២២ និង មាត្រា ៧២៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៨២ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ២៤៩ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, កថាខណ្ឌទី ២ មាត្រា ៤៩ នៃច្បាប់ស្តីពីកាតព្វកិច្ចស្វិស

**មាត្រា ៧៥៨**.- ការគណនាចំនួនទឹកប្រាក់នៃការខូចខាត

១-ក្នុងការគណនាចំនួនទឹកប្រាក់នៃការខូចខាតលើទ្រព្យសម្បត្តិដោយសារអំពើអនីត្យានុកូល ភាពខុសគ្នារវាងស្ថានភាពនៃទ្រព្យសម្បត្តិដែលត្រូវបានសន្មតថា នឹងមានប្រសិនបើគ្មានអំពើអនីត្យានុកូល និង ស្ថានភាពនៃទ្រព្យសម្បត្តិជាក់ស្តែង ក្រោយពេលដែលអំពើអនីត្យានុកូលបានកើតឡើង ត្រូវបានវាយតម្លៃ ដោយប្រើប្រាស់នូវស្ថិតិ និង ឯកសារផ្សេងទៀត ។

២-ក្នុងការគណនាចំនួនទឹកប្រាក់នៃការខូចខាតសតិអារម្មណ៍ដោយសារអំពើអនីត្យានុកូល ចំនួនទឹកប្រាក់នៃជម្ងឺចិត្ត ត្រូវបានវាយតម្លៃ ដោយគិតពិចារណានូវស្ថានភាពផ្សេងៗ ដូចជាកម្រិតនៃកំហុសចេតនា ឬ អចេតនារបស់អ្នកប្រព្រឹត្តអំពើបំពាន ប្រភេទ និង កម្រិតនៃការរងគ្រោះ អំពើរបស់អ្នកប្រព្រឹត្តអំពើបំពាននៅក្រោយអំពើបង្កឱ្យមានការរងគ្រោះនោះ ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ២៤៩ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ។

**មាត្រា ៧៥៩.-** ការទាមទារសំណងនៃការខូចខាតដោយសារការបាក់បែកវត្ថុ

នៅពេលដែលវត្ថុបានបាក់បែក ដោយអំពើអនីត្យានុកូល អ្នករងគ្រោះអាចទាមទារសំណង ដូចជាតម្លៃនៃវត្ថុដែលបាក់បែក ឬ សោហ៊ុយជួសជុលវត្ថុនោះ ជាអាទិ៍ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន ពុំមានបញ្ញត្តិប្រភេទនេះទេ ។

**មាត្រា ៧៦០.-** ការទាមទារសំណងនៃការខូចខាតដោយការបំពានលើជីវិត

១-បើជនរងគ្រោះទទួលមរណភាព ដោយអំពើអនីត្យានុកូល អ្នករងគ្រោះអាចទទួលសិទ្ធិទាមទារសំណងចំពោះការខូចខាតលើទ្រព្យសម្បត្តិ និង ការខូចខាតសតិអារម្មណ៍ដែលបានកើតឡើងចំពោះខ្លួន រហូតដល់មរណភាព ។ ការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នេះ ត្រូវរួមបញ្ចូលទាំងសោហ៊ុយព្យាបាល និងសោហ៊ុយចំណាយផ្សេងទៀតដែលជនរងគ្រោះបានបង់ ឬ មានករណីយកិច្ចត្រូវបង់ ចាប់ពីក្រោយអំពើបង្កឱ្យមានការរងគ្រោះ រហូតដល់ពេលទទួលមរណភាព ប្រាក់ចំណូលដែលជនរងគ្រោះមិនបានទទួល ចាប់ពីក្រោយអំពើបង្កឱ្យមានការរងគ្រោះ រហូតដល់ពេលទទួលមរណភាព ជាអាទិ៍ ។

២-បើបុគ្គលដែលមានករណីយកិច្ចផ្តល់អាហារកាតព្វកិច្ច ដោយច្បាប់ ទំនៀមទំលាប់ ឬ ដោយកិច្ចសន្យា បានទទួលមរណភាព ដោយអំពើអនីត្យានុកូល បុគ្គលដែលទទួលជីវព្រឹត្តិ អាចទាមទារសំណងការខូចខាតលើទ្រព្យសម្បត្តិ ដែលបានកើតឡើងចំពោះខ្លួន ដោយសារមរណភាពរបស់ជនរងគ្រោះ ។ ការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នេះ ត្រូវរួមបញ្ចូលទាំងប្រាក់ជីវព្រឹត្តិដែលបុគ្គលដែលទទួលជីវព្រឹត្តិលែងបានទទួលដោយសារមរណភាពនៃជនរងគ្រោះ សោហ៊ុយដែលចេញជំនួសជនរងគ្រោះ សោហ៊ុយធ្វើបុណ្យសព ជាអាទិ៍ ។

៣-បើជនរងគ្រោះទទួលមរណភាព ដោយអំពើអនីត្យានុកូល សហព័ទ្ធ ញាតិនៅក្នុង ១ (មួយ) ថ្នាក់ និង ញាតិដែលរស់នៅជាមួយជនរងគ្រោះ អាចទាមទារសំណង

នៃការខូចខាតសតិអារម្មណ៍ដែលបានកើតឡើង ដោយសារមរណភាពរបស់ជនរងគ្រោះនោះបាន ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ៨៤៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ចំពោះកថាខណ្ឌទី ២ សូមមើលមាត្រា ៨៤៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ចំពោះកថាខណ្ឌទី ៣ សូមមើលមាត្រា ៧១១ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៨២ និង មាត្រា ១៣៨៣ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៤៧ នៃច្បាប់ស្តីពីកាតព្វកិច្ចស្វិស ។

**មាត្រា ៧៦១**.- ការទាមទារសំណងនៃការខូចខាតដោយការបំពានលើរូបរាងកាយ

បើមានការបំពានលើរូបរាងកាយ ដោយអំពើអនីត្យានុកូល ជនរងគ្រោះអាចទាមទារសំណងនៃការខូចខាតលើទ្រព្យសម្បត្តិ និង ការខូចខាតសតិអារម្មណ៍ដែលបានកើតឡើងចំពោះខ្លួន ។ ការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងមាត្រានេះ ត្រូវរួមបញ្ចូលទាំងសោហ៊ុយព្យាបាលដែលបានចំណាយហើយ ឬ សោហ៊ុយព្យាបាលដែលប្រមាណថានឹងត្រូវចំណាយនាពេលអនាគត ប្រាក់ចំណូលដែលមិនអាចទទួលបាននៅពេលកំពុងព្យាបាល និង ប្រាក់ចំណូលដែលមិនអាចទទួលបាននៅពេលអនាគតដោយសារផលវិបាកដែលបន្សល់ក្រោយពីការព្យាបាល ជាអាទិ៍ ។ ការខូចខាតដែលបានកំណត់នៅក្នុងមាត្រានេះ ត្រូវរួមបញ្ចូលទាំងការឈឺចាប់ផ្នែកសតិអារម្មណ៍នៅពេលព្យាបាល និង ពេលអនាគត ជាអាទិ៍ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧១០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៨២ និង មាត្រា ១៣៨៣ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៨៤២ មាត្រា ៨៤៣ និង មាត្រា ៨៤៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៤៧ នៃច្បាប់ស្តីពីកាតព្វកិច្ចស្វិស

**មាត្រា ៧៦២**.- ការទាមទារសំណងនៃការខូចខាតផ្នែកសតិអារម្មណ៍ដោយសារការបរិហារកេរ្តិ៍

បើមានការបរិហារកេរ្តិ៍ ដោយអំពើអនីត្យានុកូល ជនរងគ្រោះអាចទាមទារសំណងនៃការខូចខាតសតិអារម្មណ៍ ដោយសារការអាប់ឱនកេរ្តិ៍ឈ្មោះក្នុងសង្គម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧១០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ១៣៨២ និង មាត្រា ១៣៨៣ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៨៤៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៤៩ នៃច្បាប់ស្តីពីកាតព្វកិច្ចស្វិស

**មាត្រា ៧៦៣.-** ការទូទាត់ប្រាក់ចំណេញ និង ខាត

ប្រសិនបើជនរងគ្រោះបានទទួលផលចំណេញដោយសារអំពើអនីត្យានុកូល ចំនួនប្រាក់ចំណេញនោះត្រូវដកចេញ នៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃសំណងការខូចខាត ។[១១]

(មាត្រាពាក់ព័ន្ធ)

ពុំមានបញ្ញត្តិដូចគ្នាក្នុងក្រមរដ្ឋប្បវេណីជប៉ុនទេ

**មាត្រា ៧៦៤.-** ការទូទាត់នូវកំហុស

បើកំហុសរបស់ជនរងគ្រោះ ឬ កំហុសរបស់អ្នកដែលមានករណីយកិច្ចត្រូវត្រួតពិនិត្យជនរងគ្រោះ បានរួមចំណែកក្នុងការកើតឡើង ឬរីករាលដាលនៃការខូចខាត តុលាការអាចគិតពិចារណានូវកម្រិតនៃការរួមចំណែកនោះ នៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃសំណងការខូចខាត ។[១២]

(កំណត់)

ក្នុងការទូទាត់កំហុសនេះ កំហុសមានភាពខុសពីកំហុសនៃល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវ ។ ដោយសារកំហុសនៅក្នុងមាត្រានេះ ត្រូវបានគិតពិចារណាថាជាមូលហេតុដើម្បីបន្ថយនូវចំនួនទឹកប្រាក់សំណងនៃការខូចខាតដែលចារីត្រូវទទួលបន្ទុក កំហុសនេះមិនចាំបាច់ជាអំពើដែលបានកំណត់នៅក្នុងនិយមន័យនៃចំណុច ខ នៃមាត្រា ៧៤២ ក៏បានដែរ ។ ហេតុដូច្នេះ ស្ថានភាពដែលភាគីខាងជនរងគ្រោះមានការធ្វេសប្រហែស ឬ មានបញ្ហាមិនសមរម្យ ក៏អាចក្លាយទៅជាកំហុសដែលបានកំណត់នៅក្នុងមាត្រានេះបានដែរ ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ២ មាត្រា ៧២២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ២៥៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៧៦៥.-** អាជ្ញាយុកាលនៃការរំលត់

---

[១១] មាត្រា ៧៦៣ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

[១២] មាត្រា ៧៦៤ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

សិទ្ធិទាមទារសំណងនៃការខូចខាតដោយអំពើអនីត្យានុកូល ត្រូវរលត់ដោយអាជ្ញា-យុកាល បើអំឡុងពេល ៣ (បី) ឆ្នាំ បានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះ បានដឹងថា អាចទាមទារសំណងការខូចខាតចំពោះអ្នកប្រព្រឹត្តអំពើបំពាន ឬ បើអំឡុងពេល ១០ (ដប់) ឆ្នាំ បានកន្លងហួស បន្ទាប់ពីអំពើអនីត្យានុកូលនោះត្រូវបានប្រព្រឹត្តឡើង ។

(កំណត់)

ដើមកាលនៃការគណនាអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណងនៃការខូចខាតដោយអំពើអនីត្យានុកូល ដែលមានអំឡុងពេល ៣ ឆ្នាំនោះ គឺ "ពេលដែលជនរងគ្រោះ,,,,,,,,,បានដឹងថា អាចទាមទារសំណងនៃការខូចខាត" បាន ។ ទោះជាសិទ្ធិទាមទារសំណងនៃការខូចខាតបានកើតមានឡើងជាក់ស្តែងក៏ដោយ ប្រសិនបើជនរងគ្រោះមិនបានដឹងថា អាចទាមទារសំណងនៃការខូចខាតបានទេ ក៏ជនរងគ្រោះនោះមិនអាចទាមទារសំណងនៃការខូចខាតបានឡើយ ។ ប៉ុន្តែអំឡុងពេលអាជ្ញាយុកាលនៃការរំលត់ដែលមានតែ ៣ ឆ្នាំនេះ គឺជាអំឡុងពេលខ្លីមួយ ។ នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន អាជ្ញាយុកាលនេះក៏មានតែ ៣ ឆ្នាំដែរ ប៉ុន្តែ មានមតិមួយចំនួនថា អំឡុងពេលនេះមានការពិបាកខ្លាំងសម្រាប់ជនរងគ្រោះ ដើម្បីដាក់ពាក្យបណ្តឹងទាមទារសំណងនៃការខូចខាតដោយអំពើអនីត្យានុកូល នៅក្នុងសង្គមបច្ចុប្បន្នដែលមានភាពកាន់តែស្មុគស្មាញទៅៗនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧២៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៨៩២ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៦០ នៃច្បាប់ស្តីពីកាតព្វកិច្ចស្វិស